អំណាច និងកេជបស្ស័ក្តិនៃមហាក្សត្រខ្មែរសៃ

# អង្គឌួង នរោត្តម ស៊ីសុវត្ថិ




ឆាយ សុផល

www.elibraryofcambodia.org

ជំណោយពី លោក ឃៅ ឃុនសំរ៉ាំង ដល់កុមារ
ខ្មែរ ដើម្បីទុកដាក់ក្នុង elibrary of Cambodia

អំណាច និង រាជបល្ល័ង្កនៃមហាក្សត្រខ្មែរសៃ កក្កដា 2015

# អង្គឌួង នរោត្តម ស៊ីសុវត្ថិ



ឆាយ សុផល

www.elibraryofcambodia.org

## មាតិកា

សេចក្តីថ្លែងអំណរគុណ....................i
សេចក្តីផ្តើម....................vii

រាជវង្សខ្មែរសែ អង្គឌួង នរោត្តម និង ស៊ីសុវត្ថិ ....................១
ព្រះបាទ អង្គឌួង- ព្រឹត្តិការណ៍នៅក្នុងនិងមុនរជ្ជកាលរបស់ព្រះអង្គ......១០

មហាក្សត្រសែ នរោត្តម និង ស៊ីសុវត្ថិ (១៨៦០-១៩៥៥)...៥៧
ព្រះបាទ នរោត្តម....................៥៨
ព្រះបាទ ស៊ីសុវត្ថិ....................១០៧
ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស....................១៥២
ព្រះបាទសម្តេចព្រះនរោត្តម សីហនុ....................១៨៩

មហាក្សត្រ (៣ មីនា ១៩៥៥ - ១៨ មីនា ១៩៧៥)....................២៨២
ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត....................២៨៣
ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ....................៣០២

មហាក្សត្រ (ចាប់ពីថ្ងៃទី២៤ កញ្ញា ១៩៩៣)....................៣១៥
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី............៣១៦

ឯកសារពិគ្រោះ និងទីកន្លែង....................៣៧៩

www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ



ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ( ឆ្វេង ) និងខ្ញុំអ្នកចងក្រងសៀវភៅ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណជាអនេកនិងដោយសេចក្តីគោរពស្មោះសរចំពោះឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលឯកឧត្តមបានជួយថវិកាផ្ទាល់ខ្លួនចំនួន២.០០០ដុល្លារ ដើម្បីសម្រួលក្នុងការបោះពុម្ពសៀវភៅនេះឡើង។ ឯកឧត្តមតែងតែជួយខ្ញុំនៅក្នុងកិច្ចការនិពន្ធ និងបោះពុម្ពសៀវភៅដែលចំណុចនេះគឺជាសន្តានចិត្តដ៏ប្រសើរ និងកម្រមាននៅក្នុងចំណោមមន្ត្រីក្នុងការលើកទឹកចិត្តអ្នកនិពន្ធ និងចងក្រងសៀវភៅដូចជារូបខ្ញុំ។ ដោយសារឯកឧត្តមមានអាជីពជំនាញផ្នែកព័ត៌មាននិងជាអ្នកនិពន្ធសៀវភៅផងនោះ ឯកឧត្តមជានិច្ចកាលបានផ្តល់យោបល់ និងលើកទឹកចិត្តរាល់អ្នកនិពន្ធឯទៀតៗឲ្យខិតខំ



www.elibraryofcambodia.org

និពន្ធនិងចងក្រងសៀវភៅប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌ ដោយផ្អែកលើប្រភពឲ្យបានគ្រប់ជ្រុងជ្រោយ ដោយអ្នកនិពន្ធមិនត្រូវសំអាងតែលើឯកសារ ឬបកប្រែចេញតែពីសៀវភៅបរទេសនោះទេ។ តម្លៃរបស់អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រ ឬការសរសេរបែបវិជ្ជាជីវៈ (Professional Writing) ផ្សេងៗទៀត គឺអ្នកនិពន្ធ ឬអ្នកចងក្រងសៀវភៅត្រូវតែស្រាវជ្រាវដោយផ្អែកលើប្រភពដ៏សំខាន់បី៖ ប្រភពមនុស្ស ប្រភពឯកសារ និងប្រភពទីកន្លែង គឺខុសប្លែកពីការសរសេរតាមបែបបញ្ចេញបញ្ចូល (Creative Writing)។ ការខ្វះចន្លោះប្រភពណាមួយក្នុងចំណោមប្រភពទាំងបីខាងលើ នោះអ្នកនិពន្ធ ឬអ្នកចងក្រងសៀវភៅបែបវិជ្ជាជីវៈអាចបាត់បង់ដំណឹងជាក់ស្តែងផ្នែកណាមួយមិនខាន។



ពិតជាទឹកចិត្តដ៏ប្រពៃចំពោះលោក **ហៀង ស្រ៊ុន** មិត្តភក្តិចាស់របស់ខ្ញុំ ដែលលោកបានជួយឧបត្ថម្ភប្រាក់ចំនួន១.០០០ដុល្លារសម្រាប់ការងារស្រាវជ្រាវ ការរចនា និងការបោះពុម្ព ដែលជាការលើកទឹកចិត្តមួយដ៏ធំសម្រាប់ខ្ញុំ។ នេះមិនមែនជាលើកដំបូងទេ តែកន្លងមក **ហៀង ស្រ៊ុន** តែងតែលើកទឹកចិត្ត និងឧបត្ថម្ភខ្ញុំក្នុងការងារនិពន្ធសៀវភៅ សម្រាប់មិត្តអ្នកអាន ព្រោះលោកក៏ចូលចិត្តអានសៀវភៅ ដើម្បីបង្កើនពុទ្ធិបន្ថែមដែរ។



សូមអរគុណឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** អ្នកតំណាងរាស្ត្រ ដែលមានសណ្តានចិត្តជ្រះថ្លាជួយឧត្តម្ភការបោះពុម្ពចំនួន៥០០ដុល្លារ។ ការឧបត្ថម្ភនេះ



www.elibraryofcambodia.org

គឺជាការជួយសម្រួលមួយដ៏ធំក្នុងការបោះពុម្ពសៀវភៅដែលមានតម្លៃសរុបជាងមួយម៉ឺនដុល្លារ។

បន្ទាប់មក ទូលបង្គំខ្ញុំ ខ្ញុំបាទ ក៏សូមអរព្រះគុណ និងអរគុណៈ



សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះរាជបុត្រាព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** និងជាព្រះជេដ្ឋាព្រះមហាក្សត្រសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**



សម្តេចក្រុមឃុន **នរោត្តម សិរិវុឌ្ឍ** ព្រះរាជបុត្រាព្រះបាទ **នរោត្តម សុរាម្រិត** និងជាព្រះអនុជព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** និងជាមារបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**



ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** ជាក្មួយនិងជាអតីតជំនួយការព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** និងត្រូវជាបងជីដូនមួយរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**



លោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា



ម្ចាស់ក្សត្រិយ **នរោត្តម សោម៉ា** (**សិរី**) ជាចៅទួត ព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ**



ឯកឧត្តម **ចាប ញ៉ាលីវុឌ្ឍ** ប្អូនប្រុសសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** (បិតាទីទែ)



www.elibraryofcambodia.org

ព្រមទាំងជំនួយការរបស់ទ្រង់ និងលោកទាំងអស់ដែលបានផ្តល់ដំណឹង ឯកសារ និងព្រះឆាយាល័ក្ខណ៍/រូបថតមួយចំនួននៃសមាជិកញាតិវង្សឲ្យទូលបង្គំខ្ញុំនិងខ្ញុំដើម្បីធ្វើឲ្យសៀវភៅប្រវត្តិសាស្ត្រមួយក្បាលនេះកាន់តែមានតម្លៃ។

បន្ថែមពីលើនេះ ខ្ញុំសូមអរគុណលោកគ្រូ **សំបូរ មាណ្ណារ៉ា** សាស្ត្រាចារ្យប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យបញ្ញាសាស្ត្រដែលលោកគ្រូបានជួយប្រាប់ខ្ញុំបន្ថែមពីការប្តូរឈ្មោះអតីតស្រុក-ខេត្តខ្មែរមួយចំនួន។



ខ្ញុំពិតជាមិនអាចបំភ្លេចបានទេ ចំពោះអ្នកដែលបានខិតខំជួយផ្ទៀងផ្ទាត់កាលបរិច្ឆេទ និងកែសម្រួលអក្ខរាវិរុទ្ធ ព្រមទាំងខ្លឹមសារខ្លះដោយយកចិត្តទុកដាក់ ដោយអ្នកទាំងនោះរួមមាន៖



**ស៊ី ផង់** គ្រូបង្រៀនសាលា Home of English



**ខៀន សាឃាន** អ្នកយកព័ត៌មានកាសែតរស្មីកម្ពុជា





កញ្ញា **សរ ពិសី** និង **អូន ឆេងប៉ែរ** ដែលអ្នកទាំងពីរជានិស្សិតជំនាន់ទី១៣នៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (DMC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



www.elibraryofcambodia.org

ដូចមុនៗដែរ ខ្ញុំសូមអរគុណលោក **ផាង សុខឡា** មន្ត្រីមូលនិធិ ខុនរ៉ាដ អាដេណៅអ៊ែរ (Kondrad Adenauer Stiftung) ដែលបានរចនាគ្របសៀវភៅដោយយកចិត្តទុកដាក់ និងអរគុណលោក **ហេន មុនីរ័ត្ន**





បុគ្គលិកគេហទំព័រ CEN ចំពោះការជួយរចនាព្រះបរមរូបរបស់ព្រះមហាក្សត្រខ្មែរទាំង៨អង្គនៅទំព័រមុខនៃសៀវភៅនេះ។

ខ្ញុំក៏មានមោទនភាពចំពោះលោកស្រី **ខ្លូត ធបុលឡា** ប្រធានបណ្ណាល័យជាតិដែលបានផ្តល់រូបព្រះឆាយាល័ក្ខណ៍មួយចំនួនរបស់អតីតព្រះមហាក្សត្រខ្មែរ និងរូបឯកសារប្រវត្តិសាស្ត្រនាអតីតកាលជាច្រើនដល់ខ្ញុំ។ បន្ថែមពីលើនេះ ខ្ញុំក៏សូមអរគុណមន្ត្រីបម្រើការនៅបណ្ណាល័យជាតិ បណ្ណសារដ្ឋានជាតិកម្ពុជា បណ្ណាល័យព្រឹទ្ធសភា បណ្ណាល័យ មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងបណ្ណាល័យ DMC ដែលបានជួយសម្រួលឲ្យខ្ញុំបានស្វែងរកឯកសារនិងរូបថតទាក់ទិននឹងសៀវភៅ។ ប្រសិនបើមិនមានការជួយពីមន្ត្រីទាំងនោះទេ នោះខ្ញុំពិតជាមានការលំបាកក្នុងការប្រមូលឯកសារនិងរូបថតសម្រាប់សៀវភៅនេះ។

ព្រមពេលជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណអ្នកនិពន្ធសៀវភៅ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ ទីភ្នាក់ងារព័ត៌មាន វិទ្យុ ទូរទស្សន៍ និង



www.elibraryofcambodia.org

គេហទំព័រនានាដែលបន្សល់ទុកឯកសារពាក់ព័ន្ធសម្រាប់ខ្ញុំបានដកស្រង់ខ្លឹមសារ និងរូបភាពយកមកធ្វើជាឯកសារពិគ្រោះ (សូមអាននៅក្នុងបញ្ជីឯកសារពិគ្រោះនៅទំព័រខាងក្រោយ)។

ទូលបង្គំខ្ញុំ និងខ្ញុំសូមថ្វាយព្រះពរនិងជូនពរ ឯកឧត្តម ទ្រង់ លោក និងនាងកញ្ញា ដែលបានជួយធ្វើឲ្យខ្លឹមសារសៀវភៅនេះកាន់តែមានគុណភាពនិងមានតម្លៃសម្រាប់អនុជន ហើយសូមឲ្យទឹកចិត្តនិងទឹកព្រះទ័យដ៏ប្រពៃនេះក្លាយជាកុសលផលបុណ្យកើតមានដល់ឯកឧត្តម ទ្រង់ លោក និងនាងកញ្ញា ព្រមទាំងក្រុមគ្រួសារដោយទទួលបានការគោរពស្រឡាញ់ពីអ្នកផងទាំងពួង និងទទួលបានជោគជ័យលើអាជីពគ្រប់ពេលវេលា៕



www.elibraryofcambodia.org

# សេចក្តីផ្តើម

ជាដំបូង ខ្ញុំសូមបង្ហាញពីប្រភពសម្រាប់ចងក្រងសៀវភៅមួយក្បាលនេះ។ ជាការពិត ខ្ញុំបានចំណាយពេលវេលា និងហាមពលច្រើន



ណាស់ ដោយរួមទាំងថវិកាជាច្រើនផង ដើម្បីធ្វើការសិក្សា និងស្រាវជ្រាវ ដោយផ្អែកលើ ៖

**ប្រភពទីកន្លែង៖** ខ្ញុំបានធ្វើដំណើរទៅខេត្តសមុទ្រប្រាកាន ខេត្តប្រាជីនបូរី និងរាជធានីបាងកក ប្រទេសថៃ ទីក្រុងហូជីមិញ ប្រទេសវៀតណាម (អតីតក្រុងព្រៃនគរក្នុងដែនដីកម្ពុជាក្រោម) ទីក្រុងយ៉ាំងហ្គូន ប្រទេសភូមា ប្រទេសសិង្ហបុរី កំពូលភ្នំឧដុង្គក្នុងខេត្តកណ្តាល ស្រុកសាមគ្គីមានជ័យ និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្រុកកំពង់ត្រាច និងកំពូលភ្នំបូកគោខេត្តកំពតប្រាសាទព្រះវិហារ រាជដំណាក់ខេត្តសៀមរាប រាជដំណាក់នៅខេត្តបាត់ដំបង ទីកប់សុក ព្រះបាទនរោត្តម ក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ព្រះបរមរាជវាំង សារមន្ទីរជាតិ ការិយាល័យអង្គការយូនីស្កូប្រចាំកម្ពុជា បណ្ណាល័យជាតិ បណ្ណសារដ្ឋានជាតិកម្ពុជា បណ្ណាល័យព្រឹទ្ធសភា បណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យ DMC នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការិយាល័យក្លឹបអ្នកកាសែតកម្ពុជា ទីស្នាក់ការមូលនិធិ Kondrad Adenauer Stiftung នៃប្រទេសអាល្លឺម៉ង់ប្រចាំរាជធានីភ្នំពេញ និងក្រសួងព័ត៌មាន។



www.elibraryofcambodia.org

ឯកសារពិគ្រោះមានចំនួន៩២ប្រភេទដែលក្នុងនោះមាន៖

**ប្រភពសៀវភៅ៖** ៤៤ ក្បាល

**ប្រភពសារព័ត៌មាន៖** ផ្នែកបោះពុម្ពមានចំនួន៩ប្រភេទ

**គេហទំព័រ៖** ៤៣ ប្រភេទ

**ប្រភពមនុស្ស៖** ខ្ញុំបានទៅជួបសមាជិកញាតិវង្សានុវង្ស និងមន្ត្រីពាក់ព័ន្ធជាច្រើនអង្គ/រូប។

ជនរួមជាតិជាទីមេត្រី! បច្ចុប្បន្ននេះ ក្នុងកាលៈទេសៈដ៏ទំនើបហើយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកំពុងរីកចម្រើនដ៏សម្បូរបែប ប្រសិនបើយើងនិយាយពីប្រវត្តិសាស្ត្រខ្មែរនាអតីតកាល ពិសេសរឿងការបាត់បង់ទឹកដី និងវិបត្តិក្នុងរាជវង្សខ្មែរនោះ គឺមានមនុស្សភាគច្រើនតែងតែជ្រួញចិញ្ចើមដោយពោលថា ពួកគាត់មិនចង់ដឹង និងមិនចង់ឮនោះទេ ហើយក៏មិនចង់និយាយផងដែរ ព្រោះថា នោះជារឿងអតីតកាលដែលមិនត្រូវរម្លឹកវិញឡើយ។ បន្ថែមពីលើនេះ មានបុគ្គលខ្លះបានលើកឡើងថា វាជារឿងដ៏រសើប ព្រោះវាពាក់ព័ន្ធជាមួយប្រទេសជិតខាង ពិសេសជាមួយប្រទេសវៀតណាម និងប្រទេសថៃ ដែលអាចធ្វើឲ្យចំណងមិត្តភាពនិងការទូតមានបញ្ហា ដែលនាំឲ្យពួកគាត់មិនហ៊ាននិយាយនោះទេ។ ការយល់ឃើញបែបនេះគឺត្រូវមួយជ្រុងដែរ តែសម្រាប់ខ្ញុំ ខ្ញុំគិតថា យើងកុំបារម្ភពេក ឬក៏ថា កុំមានគំនិតទុទ្ទិដ្ឋិនិយមពេក និងកុំខ្លាចរអាពេក តែត្រូវមានគំនិតឲ្យទូលាយ។ យើងត្រូវចេះចែករំលែកពីអ្វីដែលកើតមានពីអតីតកាល ដើម្បីធ្វើឲ្យបច្ចុប្បន្នបានប្រសើរ ហើយអនាគតបានកាន់ត្រចះត្រចង់។ រឿងសំខាន់គឺយើងមិនត្រូវយករឿងអតីតកាលទាំងនោះ



www.elibraryofcambodia.org

ប្រែក្លាយជាកំហឹងដ៏ស្រួចស្រាល់ ចងគំនុំ គុំកួនសងសឹកនោះទេ ព្រោះថា អតីតកាលបានកន្លងផុតរួចទៅហើយ។ ខ្ញុំនៅចាំបានពីអ្វីដែលមិត្តភក្តិរបស់ខ្ញុំជាជនជាតិកូរ៉េខាងត្បូងបានលើកឡើងថា ជនជាតិកូរ៉េស្អប់ជនជាតិជប៉ុនបំផុតនាអតីតកាល ព្រោះថា ជប៉ុនបានចូលឈ្លានពានប្រទេសកូរ៉េនាសម័យសង្គ្រាមលោកលើកទី២ និងបានធ្វើបាបជនជាតិកូរ៉េបំផុត ហើយដោយផ្តើមចេញពីការឈឺចាប់និងការស្អប់នេះ ជនជាតិកូរ៉េបានប្តេជ្ញាប្រែក្លាយប្រទេសរបស់ខ្លួនឲ្យដូចប្រទេសជប៉ុន ឬក៏លើសពីនេះ។ ដោយហេតុនេះហើយ ទើបបច្ចុប្បន្ន សេដ្ឋកិច្ចនិងវិទ្យាសាស្ត្ររបស់កូរ៉េមិនចាញ់ប្រទេសជប៉ុនប៉ុន្មាននោះទេ ហើយប្រជាជនកូរ៉េភាគច្រើននាពេលបច្ចុប្បន្ន ក៏មិនមានគំនិតចងអាឃាតនឹងជប៉ុនដែរ បើទោះជាការរម្លឹកពីការឈឺចាប់នាអតីតកាលនៅតែមានក៏ដោយ[1]។ ចំណែកឯប្រជាជនកម្ពុជាមួយចំនួនវិញ ជាគំនិតបុគ្គលរបស់ខ្ញុំ ខ្ញុំសង្កេតឃើញថា វាខុសប្លែកពីជនជាតិកូរ៉េត្រង់ថា យួន [វៀតណាម] និងស្យាម ឬសៀម [ថៃ] ធ្លាប់បានចូលឈ្លានពាននិងគ្រប់គ្រងជិះជាន់សង្កត់សង្កិនខ្លួននាអតីតកាល ហើយទឹកដីខ្លះក៏បានបាត់បង់ទៅប្រទេសទាំងនោះ គឺខ្មែរខ្លះនៅតែចងកំហឹងជិតក្នុងអារម្មណ៍មិនចេះឈប់ ហើយប្រែក្លាយកំហឹងនេះទៅជាកំហឹងពូជសាសន៍ ឬក៏ជាតិសាសន៍ទៅវិញ ដោយមិនគិតពីមូលហេតុដែលនាំឲ្យគេខ្លាំងជាងខ្លួន និងធ្វើខ្លួនឲ្យដូចគេនិងប្រសើរជាងគេឡើយ។ ចំណុចខ្សោយមួយទៀតដែលមិនអាចប្រកែកបានគឺថា ខ្មែរមិនសូវស្តាប់គ្នា ពោលគឺមិនមានវប្បធម៌យកបញ្ហាដាក់លើតុដើម្បីជជែក

*[1] ជាទូទៅ មានអ្នកជាតិនិយម ដែលតែងតែឲ្យជប៉ុនធ្វើការសូមទោសជនជាតិកូរ៉េ ពេលរម្លឹកខួបម្តងៗ តែនេះជាបញ្ហាធម្មតានៅក្នុងសង្គមប្រជាធិបតេយ្យសេរី។*



www.elibraryofcambodia.org

វែកញែករកហេតុផលឡើយ ឲ្យតែខឹងដឹងតែពីបំបែកខ្លួន បង្កើតជាក្រុម ចងជាបក្ខជាពួក ហើយលាបពណ៌ឲ្យគ្នាថា "ខ្មែរស" "ខ្មែរក្រហម" ខ្មែរឥស្សរៈ" ខ្មែរសាធារណរដ្ឋ" និង "ខ្មែរវៀតមិញ" ជាដើមដែលនាំឲ្យប្រជាជនមានការច្របូកច្របល់ ជាឱកាសសម្រាប់បរទេសកេងចំណេញពីការបែបបាក់គ្នានេះ។

ក្នុងសម័យកាលដ៏ទំនើបនេះ យើងទាំងអស់គ្នាត្រូវបំភ្លេចនូវអ្វីដែលហៅថា "សត្រូវសួពូជ" និងពាក្យដែលថា "ខ្មែរជាពូជអ្នកចម្បាំង"។ អតីតកាលត្រូវតែគិត តែយើងត្រូវច្នៃវាឲ្យទៅជាបច្ចុប្បន្នភាពដ៏ប្រសើរ និងអនាគតដ៏រុងរឿង ដោយមិនត្រូវវិលវល់តែនៅក្នុងអតីតកាលមុជមិនជ្រៅទៅមិនឆ្ងាយនោះទេ ពោលគឺ ប្រវត្តិសាស្ត្រជាប្រវត្តិសាស្ត្រ តែអ្វីដែលសំខាន់ យើងត្រូវរួមគ្នាក្នុងទឹកចិត្តស្មោះត្រង់តម្រង់ទៅមុខ ដើម្បីអភិវឌ្ឍជាតិ ហើយត្រូវរក្សាអ្វីៗដែលមាននាពេលបច្ចុប្បន្នកុំឲ្យបាត់បង់ និងបែកបាក់បន្ថែមទៀត។ ចំណុចមួយដែលខ្ញុំកត់សម្គាល់ ហើយប្រវត្តិសាស្ត្រក៏បានកត់ត្រាផងដែរថា ខ្មែរពិតជាខ្លាំងនិងមានឥទ្ធិពលនៅពេលដែលពួកគេរួបរួមគ្នា។ ដោយសារតែភាពខ្លាំងនេះហើយ ទើបបរទេសជិតឆ្ងាយបានព្យាយាមបំបែកកម្លាំងខ្មែរជាដុំៗ ជាកង់ៗ និងជាបក្ខជាពួក ដើម្បីបំបែកកម្លាំងដ៏មានឥទ្ធិពលនេះ។ ដោយហេតុនេះហើយ ទើបមានពាក្យបុរាណខ្មែរលើកឡើងថា "ចង្កឹះមួយបាច់កាច់មិនបាក់" គឺវាប្រៀបនឹងកម្លាំងសាមគ្គីរបស់ជនរួមជាតិ ដែលជាហេតុនាំឲ្យបរទេសចេះតែព្យាយាមបំបែកបាច់ចង្កឹះនេះ ដើម្បីកាច់បំបាក់ម្តងមួយៗ។ ប្រសិនបើគិតថា ទឹកដីដែលបាត់បង់នាអតីតកាល ហើយទំនងជាអាចទាមទារយកមកវិញបាន នោះគឺត្រូវរួមគ្នាធ្វើទៅតាមផ្លូវច្បាប់អន្តរជាតិ គឺមិនត្រូវ



www.elibraryofcambodia.org

ប្រើយុទ្ធសាស្ត្រ "**ក្អែកហែកមេឃ**" នោះទេ នេះមានន័យថា បើទោះបីជាសត្វក្អែកមានស្លាបអាចហោះបោះពួយលើអាកាសវេហាក៏ដោយ ក៏ខ្លួនមិនអាចហោះហើរហែកពពកបំបុកមេឃដ៏ធំល្វឹងល្វើយបានឡើយ តែត្រូវប្រមាណកម្លាំងរបស់ខ្លួននិងសន្ទុះខ្យល់ បើមិនដូច្នោះទេ យើងនឹងអន្តរាយទាំងខ្លួន និងរលាយទាំងសម្បុក។

ដោយសារតែសង្គ្រាមរ៉ាំរ៉ៃកន្លងមក ខ្មែរបានលាបពណ៌ឲ្យគ្នា ហែកហួរនិងកាប់សម្លាប់គ្នា ដោយចោទគ្នាទៅវិញទៅមកថា ជាអាយ៉ងប្រទេសនេះ ឬខ្ញុំកញ្ជះប្រទេសនោះ ដែលធ្វើឲ្យខ្មែរស្អប់ខ្ពើមនិងសងសឹកគ្នាមិនចេះចប់។ ជាងនេះទៅទៀត ឲ្យតែនរណាមានកំហុសបន្តិចចាប់ទោសអួសដំណើរ ដោយមិនព្រមជួយអូសទាញ និងកែលម្អគ្នាឡើយ តែបែរជាខំជាន់ពន្លិច ខណៈដែលអ្នកប្រព្រឹត្តខុសខ្លះក៏រឹងក្បាលមិនព្រមទទួលយកកំហុស និងការកែលម្អពីអ្នកដទៃ ដែលនាំឲ្យមានការមិនចុះសម្រុងគ្នា ឈានដល់ការបែកបាក់បង្ករជម្លោះប្រដាប់អាវុធបង្ហូរឈាមគ្នា ជាឱកាសដ៏ល្អសម្រាប់បរទេសបានចំណេញទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ២០០០មក កម្ពុជាមិនមានសង្គ្រាមប្រដាប់អាវុធទៀតទេ គឺយើងមានសន្តិភាពពេញលេញ។ ឯរឿងជម្លោះនយោបាយនៅក្នុងពេលបោះឆ្នោតម្តងៗ គឺវាជារឿងធម្មតានៅក្នុងសង្គមប្រជាធិបតេយ្យ។ ដូច្នេះ យើងត្រូវចាប់ផ្តើមជាថ្មីក្នុងការចេះរស់នៅជាមហាគ្រួសារខ្មែរតែមួយ ចេះរៀនរស់នៅជាមួយប្រទេសជិតខាងនិងសហគមន៍ក្នុងតំបន់ឲ្យបានល្អ ដោយដោះស្រាយរាល់បញ្ហាតាមការទូត ហើយបើការទូតមិនបានសម្រេចទេ យើងអាចបន្តទៅអង្គការសហប្រជា



www.elibraryofcambodia.org

ជាតិ និងតុលាការអន្តរជាតិជាដើម។ មានតែកម្លាំងសរុបនិងសំឡេងតែមួយទេដែលអាចធ្វើឲ្យយើងទទួលបានជោគជ័យ ទោះតិចឬច្រើន។

កន្លងមក ប្រវត្តិសាស្ត្រខ្មែរបានបញ្ជាក់ច្បាស់ថា ជំនឿរបស់ប្រជាកសិករខ្មែរភាគច្រើនចំពោះរាជានិយមនិងមហាក្សត្រ បានដិតដាមក្នុងបេះដូងរបស់ពួកគេ។ បើទោះជានៅក្នុងរជ្ជកាលមុនៗ សមាជិករាជវង្សានុវង្សខ្លះបានឈ្លោះគ្នាដើម្បីអំណាចនិងរាជបល្ល័ង្ក ដោយកែនប្រជារាស្ត្រឲ្យធ្វើសឹកសង្គ្រាមឈាមហូរដាបពេញនគរក៏ដោយ ក៏ប្រជារាស្ត្រខ្មែរជាច្រើននៅតែជឿថា ប្រទេសពិតជាមិនអាចខ្វះរាជានិយម និងព្រះមហាក្សត្របានទេ។

ដោយសារតែអំណាច ព្រះរាជបល្ល័ង្ក និងរាជសម្បត្តិផ្តាច់មុខនេះហើយ ដោយរួមទាំងការជ្រៀតជ្រែកនិងការប៉ុនប៉ងដណ្តើមយកទឹកដីខ្មែរពីសំណាក់ពួកស្យាម [សៀម] និងអណ្ណាម [យួន] ផងនាអតីតកាល ប្រទេសកម្ពុជាបានកើតកលិយុគ ហើយព្រះញាតិវង្សានុវង្សខ្លះដែលជាគូបដិបក្ខនឹងគ្នាបានទៅពឹងស្តេចស្យាម និងស្តេចយួនឲ្យជួយរៀងៗខ្លួនវាយប្រហារគ្នាឥតឈប់ឈរ ហើយទីបំផុត ទឹកដីដ៏មហាសាលគ្របដណ្តប់ទ្វីបអាស៊ីត្រូវបានរួញតូច ឯប្រទេសនិងប្រជារាស្ត្របានធ្លាក់ខ្លួនតោកយ៉ាក និងត្រូវបានគេប្រមាថ។ នោះគឺជារឿងប្រវត្តិសាស្ត្រនាអតីតកាលដែលខ្ញុំ [អ្នកចងក្រងសៀវភៅ] មិនចាំបាច់ធ្វើអត្ថាធិប្បាយច្រើនពេកទេនៅទីនេះ ព្រោះនៅក្នុងសៀវភៅ ខ្ញុំក៏បានរំលេចចំណុចខ្លះៗទាក់ទិនចម្បាំងរាំងជល់និងការបាត់បង់ទឹកដីដែរ ដោយសារតែវិបត្តិរាជបល្ល័ង្ក។



www.elibraryofcambodia.org

ចាប់ផ្តើមពីថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៩០ ដោយសារតែប្រទេសជួបវិបត្តិសង្គ្រាមផ្ទៃក្នុង និងពួកអ្នកនយោបាយប្រឆាំងនឹងរាជានិយម ពិសេសអ្នកប្រឆាំងសីហនុនិយម ដែលមានការគាំទ្រពីប្រទេសវៀតណាម ប្រទេសចិន ប្រទេសរុស្ស៊ី និងសមាជិកខ្លះនៃសមាគមអាស៊ាន ដោយរួមទាំងសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តផងបានធ្វើឲ្យអំណាចនិងឥទ្ធិពលរាជានិយមនិងព្រះមហាក្សត្រខ្មែរស្ទើរតែរលត់រលាយ ហើយរាជានិយមនិងព្រះមហាក្សត្រត្រូវបានគេប្រមាថដោយចោទថា ជាពួកសក្តិភូមិ ឬឈ្លើងជញ្ជក់ឈាមប្រជានុរាស្ត្រ។ ជាងនេះទៅទៀតនៅក្នុងរបបខ្មែរក្រហមប្រល័យពូជសាសន៍របស់ពួក ប៉ុល ពត អៀង សារី ខៀវ សំផន នួន ជា សុន សេន និងតាម៉ុក នៅចន្លោះឆ្នាំ១៩៧៥-៧៩ សម្តេច នរោត្តម សីហនុ និងអគ្គមហេសី មុនិនាថ និងបុត្រា នរោត្តម សីហមុនី ត្រូវបានឃុំព្រះកាយនៅក្នុងវាំង ខណៈដែលសមាជិករាជវង្សានុវង្សជាច្រើនអង្គត្រូវបានធ្វើគុតដោយអយុត្តិធម៌ដែរ។ នៅចន្លោះរយៈពេលជាង១៥ឆ្នាំ (១៨ មីនា ១៩៧០ - ២៣ កញ្ញា ឆ្នាំ ១៩៩៣) ប្រទេសគ្មានមហាក្សត្រសោយរាជ្យឡើយ ហើយទាំងអតីតព្រះមហាក្សត្រ និងសមាជិករាជវង្សានុវង្សស្ទើរគ្រប់អង្គត្រូវបានគេប្រមាថថា ហើយព្រះបរមរាជវាំងត្រូវបានគេទុកជាសារមន្ទីរ។ នៅឆ្នាំ១៩៧៣ ដែលពេលនោះខ្ញុំមានអាយុប្រមាណ១០ឆ្នាំ មីងជីដូនមួយខាងឪពុកខ្ញុំគាត់ជាអ្នករាំរបាំ ហើយគាត់បានហាត់នៅលើប្រាសាទចន្ទឆាយាស្ទើរជារៀងរាល់ព្រឹក។ គាត់តែងតែនាំខ្ញុំទៅជាមួយគាត់ ដោយទុកឲ្យខ្ញុំអង្គុយមើល និងដើរនៅម្តុំប្រាសាទនោះ ខណៈដែលគាត់កំពុងហាត់នៅលើប្រាសាទចន្ទឆាយា។ នោះគឺជាលើកដំបូងហើយដែលខ្ញុំបានចូល



www.elibraryofcambodia.org

ក្នុងវាំង តែបាននៅមុំប្រាសាទចន្ទឆាយាប៉ុណ្ណោះ ហើយថ្វីបើខ្ញុំនៅតូច ក៏ខ្ញុំគិតថា នោះជាវិមាណដ៏ធំរបស់ស្តេច។ នៅឆ្នាំ១៩៨២ ព្រះបរមរាជវាំងក៏ត្រូវដាក់ជាសារមន្ទីរដែរ ដែលរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលវៀតណាមបានអនុញ្ញាតិឲ្យប្រជាជនចូលទស្សនាដោយលក់សំបុត្រក្នុងតម្លៃ២កាក់។ ខ្ញុំបានទៅទីនោះ ហើយដោយសារតែមនុស្សច្រើនណែនតាន់តាប់ឈរនៅខាងក្រៅរបងវាំងរង់ចាំប្រជ្រៀតចូលទៅខាងក្នុងដើម្បីដណ្តើមគ្នាទិញសំបុត្រ ខ្ញុំនិងមិត្តភក្តិពីរបីនាក់ទៀតបានបែកគំនិតឡើងផ្លោះរបងវាំង ទិញសំបុត្របានក្នុងម្នាក់ៗពី១០ទៅ២០សន្លឹក ហើយយកមកលក់នៅខាងក្រៅបានតម្លៃពី៣កាក់ទៅ៤កាក់។ បន្ទាប់មក ឲ្យតែថ្ងៃសៅរ៍និងថ្ងៃអាទិត្យខ្ញុំតែងតែមកវាំង ដើម្បីរកស៊ីលក់សំបុត្រវាំងគ្រាន់បានលុយចាយនិងទិញសៀវភៅ ក្រៅពីរត់កង់ឌុបនាពេលយប់។ នៅដើមទសវត្សរ៍១៩៩០ មានព្រឹត្តិការណ៍គួរឲ្យរន្ធត់នៅក្នុងបរិវេណខាងក្នុងវាំងផ្នែកខាងកើតនិងខាងជើង ដោយមានមនុស្សរាប់រយនាក់ផ្អើលរត់ជាន់គ្នា ធ្វើឲ្យបុរសម្នាក់ស្លាប់ជាមួយកូនពីរនាក់ទៀតនៅទីនោះគួរឲ្យអាណោចអាធម។ មូលហេតុដោយសារផ្ទុះសេភ្លើងចេញពីទីកន្លែងតាំងពិពរណ៌មួយនៅខាងក្នុងវាំងផ្នែកជ្រុងខាងកើត។

ចាប់តាំងពីថ្ងៃទី២៤ កញ្ញា ឆ្នាំ១៩៩៣ មក ប្រទេសកម្ពុជាបានក្លាយជាព្រះរាជាណាចក្រជាថ្មី និងប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ បន្ទាប់ពីអវត្តមានតាំងពីទី១៨ មីនា ឆ្នាំ១៩៧០។ នេះក៏អាស្រ័យលើអ្នកនយោបាយខ្មែរភាគច្រើនបានទទួលយកនូវគោលនយោបាយឯកភាពជាតិនិងផ្សះផ្សាជាតិ ដោយមានការជួយជ្រោមជ្រែងពី



www.elibraryofcambodia.org

អង្គការសហប្រជាជាតិផង។ ខ្ញុំពិតជាកោតសរសើរ និងគាំទ្រចំពោះការចាប់ផ្តើមជាថ្មីនៃការបង្កើនវប្បធម៌សន្ទនាគ្នា ដែលធ្វើឡើងរវាងសម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនិងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា ជាមួយឯឧត្តម សម រង្ស៊ី តំណាងសមាជិកភាគតិចនៅក្នុងរដ្ឋសភានិងជាប្រធានគណបក្សសង្គ្រោះជាតិ។ ដោយសារតែការសន្ទនានេះហើយ ទើបធ្វើឲ្យប្រទេសមានស្ថេរភាពនយោបាយនៅពាក់កណ្តាលឆ្នាំ២០១៤។ នៅព្រឹកថ្ងៃទី១៤ មេសា ឆ្នាំ២០១៥ នៅក្នុងពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៥ជាផ្លូវការនៅឯប្រាសាទបាយ័នដែលមានវត្តមានឯឧត្តម សម រង្ស៊ី និងលោកជំទាវដែរនោះ សម្តេចតេជោបានផ្តល់អនុសាសន៍ដល់យុវជនខ្មែរ ឲ្យចេះស្គាល់ប្រវត្តិសាស្ត្រនិងអ្វីដែលប្រទេសបានឆ្លងកាត់កន្លងមក ហើយខិតខំរួបរួមសាមគ្គីគ្នា ការពារទឹកដីដែលដូនតាបានបន្សល់ទុក ដោយចៀសវាងការលាបពណ៌ឲ្យគ្នា និងបង្ករអរិភាពនឹងគ្នា ទោះជាក្នុងរូបភាពណាក៏ដោយ ពេលគឺយុវជនត្រូវរួមគ្នារៀនគិត រៀនធ្វើ រៀនទទួលខុសត្រូវ ហើយហ៊ានទទួលយកការរិះគន់ និងចេះកែលម្អដើម្បីប្រយោជន៍រួម។ សម្តេចបានបញ្ជាក់ថា "គ្មានជោគជ័យណាមួយបានមកពីការមិនចូលរួមនោះទេ ហើយសូមឲ្យស្មារតីនៃការរួបរួមគ្នាមានជារៀងរហូត"។ ជាងនេះទៅទៀត សម្តេចបានអំពាវនាវឲ្យខ្មែររួមសាមគ្គីគ្នាឡើង ដើម្បីឲ្យខ្មែរខ្លាំង ដោយកុំឲ្យមានព្រឹត្តិការណ៍ដដែលៗកើតឡើង។ ជាការពិតណាស់ នៅពេលលង់លក់ក្នុងដំណេក មនុស្សម្នាទាំងឡាយតែងតែចង់បានសុបិនល្អ ហើយសូម្បីតែជូនពរគ្នានាពេលរាត្រី ក៏មនុស្សម្នាតែងតែជូនពរគ្នាថា "សូមឲ្យគេងលក់ស្រួល និងសុបិនល្អ"។ នេះមានន័យថា មនុស្សសូម្បីតែសម្រាកលង់



www.elibraryofcambodia.org

លក់ក៏ដោយ ក៏នៅតែចង់បានសុបិនល្អដែរ។ ចំណែកឯជីវិតរស់នៅរបស់មនុស្សគឺគ្រាន់តែជាសុបិនមួយដ៏វែងប៉ុណ្ណោះ ហេតុនេះ នៅពេលមានជីវិត មនុស្សត្រូវតែគោរពស្រឡាញ់គ្នា ចេះជួយនិងចែករំលែកគ្នាខំសាងអំពើល្អឲ្យមានសេចក្តីថ្លៃថ្នូក្នុងនាមមិនមែនជាសត្វ ដើម្បីឲ្យសុបិនដ៏យូរនេះបានល្អ។

ដោយសារមាត្រា១៤នៃរដ្ឋធម្មនុញ្ញចែងថា "ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបព្វាញាតិនៃព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ។....." ខ្ញុំក៏ចាប់យកតែព្រះរាជជីវប្រវត្តិនៃញាតិវង្សនៃមហាក្សត្រអង្គទាំងនោះមករៀបរាប់ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយក៏ខ្ញុំបានបញ្ចូលព្រឹត្តិការណ៍សំខាន់ៗខ្លះនៅមុនរជ្ជកាលព្រះបាទអង្គឌួងផងដែរ។

សរុបសេចក្តី សៀវភៅនេះ ខ្ញុំមានគោលបំណងឲ្យមិត្តអ្នកអានបានដឹងពីព្រះរាជជីវប្រវត្តិសង្ខេបទាក់ទិននឹងការចាប់ផ្តើម និងការបាត់បង់នៃព្រះមហាក្សត្រខ្មែរសែ អង្គឌួង នរោត្តម និង ស៊ីសុវត្ថិ ព្រមទាំងព្រឹត្តិការណ៍ខ្លះដែលកើតមាននៅក្នុងរជ្ជកាលនីមួយៗ។ ខ្ញុំគិតថា បើទោះជាសៀវភៅនេះមិនមានដំណឹងអស់សេចក្តីក៏ដោយ ក៏មានសៀវភៅជាច្រើនទៀតដែរ ហើយសៀវភៅរបស់ខ្ញុំអាចជាឯកសារជំនួយស្មារតីមួយដ៏សំខាន់សម្រាប់មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រទាក់ទិននឹងរាជវង្សានុវង្សសែព្រះបាទ អង្គឌួង ព្រះបាទ នរោត្តម និងព្រះបាទស៊ីសុវត្ថិ។ ខ្ញុំរំពឹងថា អ្នកនិពន្ធជំនាន់ក្រោយអាចធ្វើបច្ចុប្បន្ន



www.elibraryofcambodia.org

ភាពបន្ថែមទៀតទាក់ទិននឹងព្រះរាជជីវប្រវត្តិមហាក្សត្រខ្មែរ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានាដែលបានកើតមាននៅក្នុងប្រទេសកម្ពុជានៃយើង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរមិត្តអ្នកអានឲ្យមានសុខភាពល្អ ដើម្បីប្រកបការងារបានតាមសមត្ថភាពនិងប្រាជ្ញាវាងវៃរៀងៗខ្លួន ហើយសូមកុំសំឡឹងមើលអតីតកាលប្រកបដោយការចងកំហឹង តែត្រូវប្រែទឹកចិត្តឲ្យបានប្រពៃ ដើម្បីសាងអនាគតខ្លួននិងប្រទេសជាតិឲ្យបានរុងរឿងចាប់ពីពេលនេះទៅ ខណៈដែលប្រទេសកំពុងធ្វើសមាហរណកម្មក្នុងតំបន់និងសកលភាវូបនីយកម្មដ៏ទំនើប។

សូមមិត្តអ្នកអានរីករាយអានដោយក្ដីសោមនស្ស ហើយសូមមេត្តាអធ្យាស្រ័យចំពោះរាល់កំហុសឆ្គងនានារួមទាំងផ្នែករចនាប្លង់និងអក្ខរាវិរុទ្ធដោយអចេតនា៕

*សូមអរព្រះគុណនិងអរគុណ*

រាជធានីភ្នំពេញ ឆ្នាំ ២០១៥

**ឆាយ សុផល**

អ្នកនិពន្ធសៀវភៅនិងអ្នកសារព័ត៌មាន

**ទូរស័ព្ទ៖ ០១៧ ៥៣៥ ៥៣៥**

អ៊ីម៉ែល៖ chhaysophal@yahoo.com

Facebook៖ Sophal Chhay Journalist



www.elibraryofcambodia.org

# រាជវង្សខ្មែរសែ អង្គឌួង នរោត្តម និង ស៊ីសុវត្ថិ




1

www.elibraryofcambodia.org




www.elibraryofcambodia.org




ប្រភព៖ ឯកសារ Preah Khan Reach and The Genealogy of Khmer Kings



www.elibraryofcambodia.org

# ញាតិវង្សព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ និង នរោត្តម




www.elibraryofcambodia.org



**នរោត្តម សុរាម្រឹត**

(១៨៩៦ – ១៩៦០)

សោយរាជ្យ៖ ១៩៥៥ – ១៩៦០

ត្រូវជាបងប្អូនជីដូនមួយ
ហើយបានរៀបអភិសេកនឹងគ្នា



**នរោត្តម សីហនុ** (១៩២២ – ២០១២)

សោយរាជ្យ៖ ១៩៤១ – ១៩៥៥
១៩៩៣ – ២០០៤



+ **ស៊ីសុវត្ថិ កុសមៈ**

(១៩០៤ - ១៩៧៥)

សោយរាជ្យ៖ ១៩៦០ -

ស៊ីសុវត្ថិ ថារេត វង្សី នារីវង្ស

+ អ្នកម្នាង ប៉ុក វ៉ាន (Poc Vane ) មាន
បុត្រ៤អង្គ៖



១. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ រ៉េតណារ៉ា
(Rethnara) ប្រសូត៖១៩៣៥



២. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ រក្សមុនី
(Rakmoni) ប្រសូត៖ ១៦ មីនា ១៩៣៦ -
សុគត ១៩៧៥
៣. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ មុនីសុវត្ថិ
(Monisowath) ប្រសូត៖ ១ មករា ១៩៣៨
- សុគត ២៨ ឧសភា ១៩៤៩
៤. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សមុនី
(Pongmoni)



ស៊ីសុវត្ថិ មុនីរ៉េត
១៩០៩ - ១៩៧៥



ស៊ីសុវត្ថិ មុនីពង្ស
១៩១២ - ១៩៥៦

+ យុវនព្រះម្នាង បុប្ផានលក្ខណ៍ គាត

ព្រះអង្គម្ចាស់ Vongchivan
(១៩៣៣)



ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ
ជីវ័ន្តមុនីរក្ស
(១៩៣៦)

+ យុវនព្រះម្នាង
នារីកេសរត្រយង់យេម
បុត្រ៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ
មុនីជីវ័ន្ត
(១៩៣២)

+ យុវនព្រះម្នាង កេសរ
មាលីណាត
បុត្រ៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ
មុនីល័ក្ខណា
(១៩៣១)

ក្រៅពីនោះ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មាន
មេហសី និងបុត្រជាច្រើនអង្គ/នាក់ផ្សេង
ទៀត (នេះមិនទាន់គិតសំរួលផ្សេងៗនៅឡើយ
ទេ)។



www.elibraryofcambodia.org

**មហេសីទី១៖** អ្នកម្នាង Andrée Lambert មានបុត្រ៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សាមិល មុនីពង្ស (ប្រសូត៖ ១១ មេសា ១៩៤១)។ **មហេសីទី២៖** អ្នកម្នាង Phit Sopheak Samosan Chhomya មានបុត្រ៖ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សសុរិយា (Pongsorya) ២៣ កុម្ភៈ ១៩៤២ – ១៩៧៥។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ មុនីស៊ីសុវត្ថិ (២០ មករា ១៩៤៣ – ១៩៧៤) និងអ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ មុនីវង្សី (៦ កុម្ភៈ ១៩៤៤)។ **មហេសីទី៣៖** អ្នកម្នាង Mam Duong Monirak Ous មានបុត្រ៖ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ លីសា (Lysa) ប្រសូត៖ ២០ វិច្ឆិកា ១៩៤២ សុគត ១៩៧៥។ **មហេសីទី៤៖** អ្នកម្នាង សន់ ស៊ីននារី មានបុត្រ៖ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ សុវត្ថិវង្ស (Sovethvong) ប្រសូត៖ ១៧ កញ្ញា ១៩៤៥ សុគត ១៩៩៤។ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ពង្សនារី (Pongneary) ប្រសូត៖ ២៩ ឧសភា ១៩៤៧។ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ មុនីសោភា (Monisophea) ប្រសូត៖ ១ មិថុនា ១៩៤៩ សុគត ១៩៧៥ និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ដួង តារាវង្ស (Duong Daravong) (១០ សីហា ១៩៥០ – ១៩៧៤)។ **មហេសីទី៥៖** អ្នកម្នាង Chan Sorey មានបុត្រ៖ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ រ៉ៃមុនី (Reymoni) ប្រសូត៖ ២៣ មិថុនា ១៩៥២ សុគត ១៩៧៥)។ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ស៊ីម៉ែន (Siviman) ប្រសូត៖ ៨ ឧសភា ១៩៥៣ សុគត ១៩៧៥)។ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ផូងនារាស៊ីលវ៉ា (Phuong Nara Sylvia) ប្រសូត៖ ៩ វិច្ឆិកា ១៩៥៤ និងអ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ផុន្នីរ័ត្ន (Ponnirath) ប្រសូត៖ ២៥ កញ្ញា ១៩៥៦ សុគត ១៩៧៥

## ញាតិវង្សព្រះបាទសម្ដេចព្រះ នរោត្តម

រូបទាំងនេះមិនដាក់តាមលំដាប់រៀងទេ អង្គខ្លះមានសង្ខារ អង្គខ្លះសុគត។






នរោត្តម ចន្ទារង្សី
បងប្អូនជីដូនមួយ នរោត្តម សុរាម្រិត

ប្រភព៖ ព្រះអង្គម្ចាស់ នរោត្តម ដាវិល័ត



www.elibraryofcambodia.org


នរោត្តម ផានុវង្ស


Norodom Duong Chak


នរោត្តម Ronida


Norodom Chantraingsey


Norodom Veakchearavouth


Norodom Monisara


Norodom Daravadey


Norodom Savroth


Norodom Bophavadeiy


Norodom Monidara


Norodom Pekina





នរោត្តម Montana និងបុត្រា នរោត្តម វ៉ាត់វ៉ាននី ព្រមទាំងចៅស្រី Soma និង Seda



នរោត្តម Narithipong និងមហេសី នរោត្តម Ermine


នរោត្តម Amarithivong


នរោត្តម Ravichak


នរោត្តម Buddhapong


Ang Duong Salivong

គួរបញ្ជាក់ថា ខ្ញុំ [អ្នកចងក្រងសៀវភៅ] មិនអាចស្វែងរករូបញ្ញាតខ្យអស់ទេ ព្រោះមានរាប់រយអន្ត



www.elibraryofcambodia.org

# ញាតិវង្សព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ (រូបទាំងនេះមិនដាក់តាមលំដាប់រៀងទេ អង្គខ្លះមានសង្ខារ អង្គខ្លះសុគត)



ស៊ីសុវត្ថិ វង្វារី



ស៊ីសុវត្ថិ វ័ឆ្វាវង្ស



ស៊ីសុវត្ថិ សីង្ហារ៉



ស៊ីសុវត្ថិ MONICHIVAN
ព្រះបុត្រា ស៊ីសុវត្ថិ មុនីវង្ស



**Sisowath Youtevong**



**Sisowath Chittara**



ស៊ីសុវត្ថិ



**Sisowath Daramath**



**Sisowath Ritharapong**



ស៊ីសុវត្ថិ Doussadey និង
មហេសី នរោត្តម Botum Bopha



**Sisowath Sovethvong**



**Sisowath Essaro**



**Sisowath Rethnara**



ស៊ីសុវត្ថិ
Phuong Nara Sylvia



**Sisowath Samyl Monipong**



**Sisowath Raviraddhana Monipong**



**Sisowath Ubbolvadey Monipong**



**Sisowath Pongsiriya**



**Sisowath Monisowath**



ស៊ីសុវត្ថិ Hubertine



**Sisowath Pongneary**



**Sisowath Marie Josée**

*ប្រភព៖ ឯកសារ Preah Khan Reach and The Genealogy of Khmer Kings*



www.elibraryofcambodia.org



ស៊ីសុវត្ថិ ធម្មិកោ និងមហេសី ស៊ីសុវត្ថិ Simarch



ស៊ីសុវត្ថិ សេរីរ័ត្ន និងមហេសី ក្រោយស៊ីសុវត្ថិ Marina





ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស និង ស៊ីសុវត្ថិ Kanthireth Monique



ស៊ីសុវត្ថិ Pongneary Monipong



ស៊ីសុវត្ថិ Santa



ស៊ីសុវត្ថិ Rajavong Lichavi និង អ្នកម្នាង Brigitte



ស៊ីសុវត្ថិ Vic





ស៊ីសុវត្ថិ Nikko និង ស៊ីសុវត្ថិ Narita



ស៊ីសុវត្ថិ សិរីរិន



ស៊ីសុវត្ថិ Yubhiphan





ស៊ីសុវត្ថិ Amanda និង ស៊ីសុវត្ថិ Marilyn



ស៊ីសុវត្ថិ Ravivaddhana Monipong

ខ្ញុំបានទាក់ទងសមាជិករាជវង្សានុវង្សមួយចំនួន ប៉ុន្តែពួកទ្រង់មិនចង់បង្ហាញសញ្ញាណជាសាធារណៈទេ។ នោះជាសិទ្ធិរបស់ពួកទ្រង់ ឯរូបភាពដែលមាននេះគឺខ្ញុំបានមកពីឯកសារ និងពីសមាជិករាជវង្សមួយចំនួន។



ស៊ីសុវត្ថិ Chea Virakpong



www.elibraryofcambodia.org

# ព្រះបាទ អង្គឌួង

## ព្រឹត្តការណ៍ក្នុងនិងមុនរជ្ជកាលរបស់ព្រះអង្គ



ព្រះបរមរូប ព្រះបាទ អង្គឌួង នៅកែងផ្លូវជាតិលេខ៥ ខាងជើងស្ពានព្រែកក្ដាម (រូប ឆាយ សុផល)



www.elibraryofcambodia.org

**ព្រះបាទ អង្គឌួង** សោយរាជ្យក្នុងព្រះជន្ម៥២ព្រះវស្សា ហើយទ្រង់គ្រងរាជ្យបាន១៨ព្រះវស្សា៖ ១៨៤២ - ១៨៦០។ ព្រះអង្គបានបួសនិងរៀនធម៌នៅស្រុកសៀមតាំងពីរាជកុមាររហូតធំដឹងក្តី។ ដូចនេះ ព្រះអង្គស្និទ្ធស្នាលនឹងរាជវង្សសៀមជាខ្លាំង។

នៅពេលគ្រងរាជ្យ ព្រះអង្គទទួលបានព្រះបរមងារថា "ព្រះករុណា ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សាធិបតី ព្រះអង្គឌួង"។

ព្រះនាមក្នុងរាជ្យគឺ "*ព្រះករុណា ព្រះបាទសម្តេច ព្រះហរិរក្សរាមា មហាឥស្សាធិបតីស្រីសុរិយោបរមធ្មិស្សា វរបរមសុរិន្ទ្រាភូវណៃមហាចក្រពត្តិពិសេនាសាធិបាឥស្សរកម្ពុជរាជាណាចក្រ ឧភតោសុជាតិវង្ស៍ តម្រង់កម្ពុជា មហាប្រទេសសុរិយាណាចក្រភូមិន្ទរាជវិឡ្សែន៍ អធិរាជរាមមហាកាមារផ្ទធិបាតនរិន្ទ្រា រាជវិសុទ្ធបរមពោធិ ព្រះចៅក្រុងកម្ពុជាធិបតី*"។

ចំណុចខ្លាំងរបស់ ព្រះបាទ អង្គឌួង គឺទ្រង់បានព្យាយាមធ្វើឲ្យនគររួចចាកផុតពីការត្រួតត្រា អាណានិគម ឬនៅក្រោមឥទ្ធិពលរបស់ប្រទេសជិតខាង ពិសេសប្រទេសសៀម [ថៃ] និងយួន [វៀតណាម]។ ទ្រង់បានផ្តាំមហាមន្ត្រីនិងបុត្រាបុត្រីទាំងពួងឲ្យខិតខំធ្វើបែបនេះ បើទោះជាកិច្ចការមិនបានសម្រេចនៅក្នុងរជ្ជកាលរបស់ទ្រង់នោះ។ រាជផ្ទត់គំនិតនេះត្រូវបានអនុវត្តតៗគ្នារបស់ស្តេចអង្គក្រោយៗ រហូតដល់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ដែលអាចទទួលបានឯករាជ្យពីអាណានិគមបារាំងនាថ្ងៃទី៩ វិច្ឆិកា ឆ្នាំ១៩៥៣។ នៅឆ្នាំ១៨៥៩ ព្រះបាទអង្គឌួង បានខ្នះខ្នែងប្រានចោលនូវការរងឥទ្ធិពលរបស់សៀមមកលើអាណាចក្រកម្ពុជា ប៉ុន្តែព្រះអង្គបានបរាជ័យក្នុងគោលបំណងនេះ ហើយព្រះអង្គក៏ត្រូវបានគេនាំព្រះកាយយាងយកទៅរាជធានីបាងកកដោយធ្វើជា



www.elibraryofcambodia.org

អ្នកទោស។ ក្រោយមកដោយមានការជួយជ្រោមជ្រែងពីរដ្ឋមន្ត្រីបារាំងដែលគ្រប់គ្រងកម្ពុជានិងព្រះរាជបុត្រា នរោត្តម ប្រទេសសៀមក៏បានដោះលែងព្រះបាទអង្គឌួង ឲ្យយាងមកកម្ពុជាវិញ[1]។

**ប្រសូត៖** ១៧៩៦ (ថ្ងៃអាទិត្យ ៩ កើត ខែ អាសាឍ ឆ្នាំរោង)

**សោយព្រះទិវង្គត៖** ១៩ តុលា ១៨៦០ វេលាម៉ោង៤រសៀលនៅឯព្រះបរមរាជវាំង រាជធានីឧដុង្គមានជ័យ ដែលស្ថិតនៅក្បែរភ្នំឧដុង្គ (បច្ចុប្បន្ន៖ ភ្នំឧដុង្គ/ភ្នំព្រះរាជទ្រព្យ/ភ្នំអង្គរស្ស)។ ព្រះអង្គមានព្រះរោគឫសដូងបាតធ្ងន់ធ្ងរ ហើយពេទ្យប្រកបព្រះឱសថថ្វាយមិនត្រូវ។ ឯកសារមួយសរសេរថា មុនសោយព្រះទិវង្គត ព្រះអង្គបានមានព្រះរាជបណ្តាំដល់សម្តេចចៅហ្វាទឡ្ហៈ[2] មាស ថា បន្ទាប់ពីព្រះអង្គលាចាកលោកទៅត្រូវពន្លះមំសៈ [សាច់] របស់ទ្រង់ឲ្យសត្វស៊ីជាអាហារ ហើយរាជសម្បត្តិត្រូវថ្វាយជូនព្រះរាជបុត្រាច្បងគឺ នរោត្តម ហើយដោយធ្វើតាមព្រះរាជបណ្តាំ នោះរាជបុត្រា នរោត្តម សមាជិករាជវង្សានុវង្ស និងនាហ្មឺនសព្វមន្ត្រីក៏បានវះមំសៈរបស់ទ្រង់ដាក់លើភាជន៍ [ប្រដាប់ដាក់អាហារ] ប្រាក់ហើយហែរចេញទៅឲ្យសត្វទ្វេបាទ និងចតុបាទស៊ីជាអាហារ ឯទ្រង់ទ្រាយព្រះសពដែលនៅសេសសល់ត្រូវបានធ្វើរាជពិធីបុណ្យតាមប្រពៃណីខ្មែរពីបុរាណ[3]។ ព្រះអង្គទទួលបានព្រះបរមរណនាមថា "ព្រះបរមកោដ្ឋ"។ ទោះបីជាយ៉ាងនេះក្តី គ្មានឯកសារផ្សេងទៀតទេដែលសរសេរពី

---

[1] *សៀវភៅ៖ FINALE – The Cremation of Norodom and Norodom Sihanouk, Kings of Cambodia (ឆ្នាំ២០១២-២០១៣)by Jim Mizerski (ទំព័រ១៨២)*

[2] *សម្តេចចៅហ្វាទឡ្ហៈ = មានឋានន្តរស័ក្តិថ្នាក់ខ្ពស់បំផុតក្នុងមន្ត្រីកម្ពុជាផ្នែនាសម័យបុរាណ.....(វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត)*

[3] *ឯកសារមហាបុរសខ្មែរ (ទំព័រ២០)*



www.elibraryofcambodia.org

បណ្តាំនេះ ហើយឯកសារដែលសរសេរនោះក៏មិនបានបញ្ជាក់ពីមូលហេតុដែលនាំឲ្យព្រះអង្គសុខព្រះទ័យឲ្យគេពន្លះមំសៈរបស់ទ្រង់ឡើយ។ ចំណុចនេះ មនុស្សជំនាន់ក្រោយខ្លះបានបញ្ចេញទស្សនៈថា ទំនងជាព្រះអង្គចង់បង្ហាញថា កើតមកជាមនុស្សគឺរាង្គកាយសុទ្ធតែជារបស់ធម្មជាតិ ដូចនេះត្រូវប្រគល់ឲ្យធម្មជាតិវិញ នៅពេលរលត់សង្ខារ ហើយថានេះក៏ជាសារមួយប្រាប់ដល់អនុជនដែរ ពោលគឺ នៅពេលមានជីវិតមនុស្សមិនត្រូវលោភលន់នោះទេ តែត្រូវចេះជួយយកអាសាគ្នា។

**ព្រះបិតា៖** ព្រះបាទ អង្គអេង ដែលទ្រង់បានបួសនិងរៀនធម៌នៅស្រុកសៀម។ **ព្រះមាតា៖** អ្នកម្នាង រស់

អង្គឌួង គឺជាបុត្រាពៅ ហើយទ្រង់មានព្រះរៀម៤អង្គ៖ អង្គច័ន្ទ អង្គភឹម អង្គស្ងួន និង អង្គអឹម/អែម[4]។ ព្រះអង្គមានអ្នកម្នាង១៥អង្គ/នាក់ និងមានរាជបុត្រ២១អង្គ (រាជបុត្រា១០អង្គនិងរាជបុត្រី១១អង្គ) ។

ព្រះបាទ អង្គឌួង មានមហេសីបួនរូបនិងបុត្រ២០អង្គ[5]ដែលក្នុងនោះរួមមាន[6]៖

**មហេសីទី១៖** អ្នកម្នាង ប៉ែន (១៨១៣-២៧ មិថុនា ១៨៩៥) មានបុត្រ៣អង្គ៖

១. ព្រះបាទ នរោត្តម (កុម្ភៈ ១៨៣៤ - ២៤ មេសា ១៩០៤)

---

[4] *ឯកសារមួយសរសេរថា ព្រះបាទអង្គឌួងមានព្រះរៀមមួយអង្គទៀតព្រះនាម មាធុកឆា (Meatuccha)៖ http://freepages.genealogy.rootsweb.ancestry.com/~royalty/cambodia/i582.html#I583*

[5] *ឯកសារមហាបុរសខ្មែរ (ទំព័រ២០) សរសេរថា ទ្រង់មានបុត្រ១៧អង្គ (បុត្រា៨អង្គ និងបុត្រី៩អង្គ)*

[6] *http://freepages.genealogy.rootsweb.ancestry.com/~royalty/cambodia/i205.html*



www.elibraryofcambodia.org

២. ម្ចាស់ក្សត្រិយ៍ អង្គឌួង ចង់កុលណី (Changkolney) ១៨៣៩ -១៩០២

៣. ព្រះអង្គម្ចាស់ អង្គឌួង កេសនី (Kessaney) ១៨៤០ -?)

**មហេសីទី២៖** អ្នកម្នាង ពូ (Pou) មានបុត្រតែមួយអង្គគឺ៖ ព្រះបាទ ស៊ីសុវត្ថិ (៧ កញ្ញា ១៨៤០ - ៩ សីហា ១៩២៧)

**មហេសីទី៣៖** អ្នកម្នាង ខាម មានបុត្រា មួយអង្គគឺ ស៊ីវត្ថា

**មហេសីទី៤៖** មិនស្គាល់ឈ្មោះ ហើយមានបុត្រ១៦អង្គ៖

១. ព្រះអង្គម្ចាស់ អង្គឌួង មុំ (Mom) [១៨២១ - ទសវត្សរ៍ ១៨៨០]

២. ព្រះអង្គម្ចាស់ អង្គឌួង ត្រមុល (Tramol) [១៨២៨ - ១៨៧២]

៣. ព្រះអង្គម្ចាស់ អង្គឌួង អ៊ូ (Ou) [១៨៣០ - ១៨៦៦]

៤. ព្រះអង្គម្ចាស់ អង្គឌួង ស៊ីវត្ថា [១៨៤១ - ៣១ ធ្នូ ១៨៩១]

៥. ព្រះអង្គម្ចាស់ អង្គឌួង សិរីវង្ស (Serivong) [១៨៤២ - កក្កដា ១៨៨៣]

៦. ព្រះអង្គម្ចាស់ អង្គឌួង ដារ៉ាកា (Daracar) [១៨៤៣ - ១៨៦៨]

៧. ព្រះអង្គម្ចាស់ អង្គឌួង អ៊ឹង (Ing) [១៨៤៤ - ? ]

៨. ព្រះអង្គម្ចាស់ អង្គឌួង អ៊ូបុណ្យ Oubon [១៨៤៩ - មុន ១៩០៩]

៩. ព្រះអង្គម្ចាស់ អង្គឌួង ចន្ទវង្ស (Chantavong) [១៨៥២ - ១៨៩៣]

១០.ព្រះអង្គម្ចាស់ អង្គឌួង ស្រអ៊ុក (Sra Ouk) [១៨៥២ - ? ]

១១. ព្រះអង្គម្ចាស់ អង្គឌួង នុផារ័ត្ន (Nupparot) [១៨៥៣ - ១៨៩១]

១២. ព្រះអង្គម្ចាស់ អង្គឌួង Monthea Ti [១៨៥៤ - ? ]



www.elibraryofcambodia.org

១៣. ព្រះអង្គម្ចាស់ អង្គឌួង កែវ មនោហា (Keo Monoha) [១៨៥៤ - មុន ១៩០៩]

១៤. ព្រះនាងម្ចាស់ អង្គឌួង ខាន់ដាម្លី (Khandamli) [១៨៥៥ - មុន ១៩០៩]

១៥. ព្រះអង្គម្ចាស់ អង្គឌួង ចន្ទធម (Chant Chhom) [១៨៥៦ - ?]

១៦. ព្រះអង្គម្ចាស់ អង្គឌួង នីឡាវង្ស (Nilawong) [១៨៥៩ - ១៨៨៦]

ក្នុងចំណោមបុត្រ២១អង្គរបស់ព្រះបាទ អង្គឌួង គឺមានតែពីរអង្គទេបានឡើងសោយរាជ្យបន្តបន្ទាប់ពីព្រះអង្គគឺព្រះបាទសម្តេចព្រះនរោត្តម និងព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ។



www.elibraryofcambodia.org






[ក] http://freepages. nealogy.rootsweb.ancestry.com/~royalty/cambodia/i582.html#i583

www.elibraryofcambodia.org





ឆ្វេង៖ មហេសីមួយអង្គ (កណ្ដាល) របស់ព្រះបាទអង្គឌួង និងអ្នកបម្រើពីរនាក់។ ស្ដាំ៖ បុត្រីមួយអង្គរបស់ព្រះបាទអង្គឌួង។ រូបក្នុង Le Palais Du Roi Du Cambodge

## ព្រះទេពកោសល្យ

ព្រះបាទ អង្គឌួង ទ្រង់ជាអ្នកនិពន្ធខ្មែរមានព្រះនាមល្បីល្បាញ ដោយទ្រង់រាជនិពន្ធកំណាព្យ និងអក្សរសិល្ប៍ជាច្រើនទៀតដែលមានគុណតម្លៃដ៏មហិមាសម្រាប់ខេមរជន និងខេមរប្រទេសរហូតមកដល់បច្ចុប្បន្ន។ ស្នាព្រះហស្តរបស់ទ្រង់រួមមានដូចជារឿងកាកី និងរឿងនាងកង្រីជាដើម។ ព្រះបាទ អង្គឌួង ជាក្សត្ររក្សាសីលយ៉ាងខ្ជាប់ខ្ជួន ទ្រង់ប្រកបដោយធម៌ និងប្រតិពលក្នុងរាជកិច្ច រាជកវីនិពន្ធ និងជាពុទ្ធសាសនិកដ៏ឆ្នើមនាសម័យឧដុង្គមានជ័យ។

## រាជបល្ល័ង្ក និងរាជកច្ច

នៅពេលព្រះបាទ អង្គអេង ជាព្រះបិតាទ្រង់ប្រឈួន ហើយបានសោយព្រះទិវង្គតទៅនាឆ្នាំ១៧៩៦ បុត្រាទាំង៦អង្គ (អង្គច័ន្ទ អង្គស្ងួន



www.elibraryofcambodia.org

អង្គអឹម/អិម អង្គកឹម អង្គឌួង និង អង្គមាធូកឆា) របស់ទ្រង់មិនអាចឡើងគ្រងរាជ្យបានទេ ដោយសារតែព្រះជន្មក្មេងពេក។ នៅពេលនោះស្តេចសៀមដែលមានឥទ្ធិពលមកលើអាណាចក្រខ្មែរក៏បានបញ្ជានាហ្មឺនមន្ត្រីខ្មែរឲ្យដង្ហែព្រះបរមសពព្រះបាទ អង្គអេង ទៅក្រុងទេពបុរី [ក្រុងបាងកក] តែនៅពេលដង្ហែទៅដល់ខេត្តមង្គលបុរី [បច្ចុប្បន្ន ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ] ស្តេចសៀមបញ្ជាឲ្យបញ្ជូនព្រះសពទៅក្រុងឧដុង្គវិញ ហើយឲ្យនាហ្មឺនមន្ត្រីខ្មែរបញ្ជូនទ័ពទៅជួយវាយទ័ពភូមាដែលបានចូលលុកលុយក្នុងទឹកដីសៀម[7]។ ដោយស្តាប់បង្គាប់ស្តេចសៀម លោកចក្រីកែបក៏បានធ្វើតាមបញ្ជាហើយបញ្ជូនទ័ពមួយម៉ឺននាក់ទៅភ្លាម រួចក៏វាយឈ្នះទទួលបានជោគជ័យ ហើយវិលមកប្រទេសវិញ។ គួរបញ្ជាក់បន្តិចថា សង្គ្រាមរវាងសៀមនិងភូមាបានកើតឡើងនៅចន្លោះឆ្នាំ ១៧៦៥-១៧៦៧។ នៅខែសីហា ឆ្នាំ១៧៦៥ ទ័ពភូមាប្រមាណ ២០.០០០ នាក់ប្រចាំនៅភាគខាងត្បូងនៃប្រទេសដែលគាំទ្រដោយប្រទេសព័រទុយហ្គាល់ផងបានវាយចូលទន្រ្ទានប្រទេសស្យាមភាគខាងត្បូង[8] ដែលពេលនោះស្តេច អយុធ្យា ជាក្សត្រគ្រងរាជ្យរបស់សៀម ខណៈដែលលោក ស៊ីន ជាចៅហ្វាយ ខេត្តតាក របស់ប្រទេសសៀមភាគខាងជើង ដែលប្រឈមនឹងសមរភូមិផ្ទាល់ជាមួយភូមា។ លោក ស៊ីន ត្រូវបានជនជាតិសៀមហៅថា "ប្រះយ៉ាតាកស៊ីន" ឬ "តាកស៊ីន" [9]។ លោក

[7] សៀវភៅ៖ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ( ទំព័រ២៧០ ) សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋាន

[8] http://en.wikipedia.org/wiki/Burmese%E2%80%93Siamese_War_%281765%E2%80%9367%29

[9] សៀវភៅ៖ ប្រវត្តិសាស្ត្រថៃនិពន្ធដោយលោក David K. Wyatt ប្រែជាភាសាខ្មែរដោយគ្រឹស្ថានបោះពុម្ពផ្សាយនគរវត្ត ( ទំព័រ១៥២-១៥៣)



www.elibraryofcambodia.org

ស៊ីន ឬ តាកស៊ីន ជាចៅហ្វាយខេត្តនិងមេទ័ពវ័យក្មេងមានយុទ្ធសាស្ត្រយោធាដ៏ពូកែ ហើយមានទេពកោសល្យចេះបញ្ចុះបញ្ចូលឲ្យគេឯងជឿថាគាត់ជាមនុស្សមានបុណ្យពីជាតិមុន ដែលអាចដឹកនាំមនុស្សនិងវាយបំបាក់គូសត្រូវបាន។ ឪពុករបស់លោក តាកស៊ីន ជាជនជាតិចិន ហើយម្តាយជាជនជាតិសៀម។ ក្រោយពីការដួលរលំក្រុងអយុធ្យា តាកស៊ីន បានធ្វើខ្លួនគាត់ឲ្យកាន់តែមានអំណាចនិងឥទ្ធិពលដែលប្រជារាស្ត្រសៀមអាចពឹងពាក់បាន ហើយក្រោយមក លោកបានឡើងគ្រងរាជ្យធ្វើជាមហាក្សត្រសៀម (១៧៦៧-១៧៨១)។ មានហេតុផលបីដែលសៀមមានលោកចៅហ្វាយខេត្តនិងមេទ័ព តាកស៊ីន បានវាយយកឈ្នះក្នុងសង្គ្រាមជាមួយភូមានៅក្នុងឆ្នាំ ១៧៦៧៖

ទី១៖ នៅឆ្នាំ១៧៦៧ ដោយសារតែនៅពេលនោះ ចិនបានធ្វើការវាយលុកចូលប្រទេសភូមានៅឯភាគខាងជើង។

ទី២៖ ដោយមានសែស្រឡាយជាប់ចិនខាងឪពុក តាកស៊ីន ក៏មានការជួយជ្រោមជ្រែងពីពួកចិន



*ព្រះបរមរូបស្តេច តាកស៊ីន នៅបាងកក (រូប ឆាយ សុផល ៖ ថ្ងៃទី២៦ វិច្ឆិកា ២០១៤)។*



www.elibraryofcambodia.org

និងសហគមន៍ពាណិជ្ជកម្មចិន ដែលបានផ្គត់ផ្គង់ក្នុងការធ្វើសឹកសង្គ្រាមជាមួយភូមា។

ទី៣៖ ជនជាតិភូមាមានដើមកំណើតជាមន ដែលមនខ្លះក៏មានអម្បូរខ្មែរដែរ ហើយខ្មែរហៅពួកគេថា "មនខ្មែរ" ឬ "ខ្មែរមន"។ ដោយឮថា មានទ័ពខ្មែរជួយសៀមវាយពួកខ្លួន ភូមាក៏មិនចង់វាយជាមួយទ័ពខ្មែរដែរ ហើយបានសម្រេចចិត្តដកកងទ័ពរបស់ខ្លួនចេញពីភាគខាងជើងប្រទេសសៀម ដើម្បីយកកម្លាំងទ័ពទៅទប់ទល់ជាមួយទ័ពចិនវិញ។

ជាការតបស្នង នៅឆ្នាំ១៧៦៩ ក្រោយពីបណ្តេញទ័ពភូមាចេញពីប្រទេសហើយ តាកស៊ីន បានចាប់ផ្តើមបញ្ជូនកងទ័ពសៀមចូលកាន់កាប់ទឹកដីខ្មែរភាគពាយ័ព្យ ក្នុងខេត្តបាត់ដំបង និងសៀមរាប ដោយរួមទាំងប្រទេសលាវផង។

ទាក់ទិននឹងជនជាតិមនដែលខ្លះមានអម្បូរខ្មែរនោះ ខ្ញុំ [អ្នកចងក្រងសៀវភៅ] មានអារម្មណ៍ភ្ញាក់ផ្អើលដែរនៅពេលដែលខ្ញុំបានទៅទីក្រុងយ៉ាំងហ្គូន ប្រទេសភូមានាថ្ងៃទី២៤-២៦ វិច្ឆិកា ឆ្នាំ២០១៤ ដែលនៅទីនោះ ប្រជាជនភូមាបានហូបជ្រក់ស្ពៃនិងជ្រក់ម្ទេសស្រស់ ហើយមានលក្ខណៈដូចគ្នានឹងខ្មែរទាំងការធ្វើទាំងរស់ជាតិ។ ចំណុចនេះបង្ហាញថា ជនជាតិភូមាមានដើមកំណើតមនក៏ពាក់ព័ន្ធនឹងអម្បូរខ្មែរខ្លះដែរ។ ជាងនេះទៅទៀត នៅទីក្រុងយ៉ាំងហ្គូនមានវត្តមួយឈ្មោះថា ស្វីដាហ្គូន (Shwedagon) ដែលបានសាងសង់ដោយជនជាតិមននៅចន្លោះសតវត្សរ៍ទី៦ និងទី៩នៃគ្រិស្តសករាជ[10] និងជាវត្តប្រវត្តិសាស្ត្រមានវ័យចំណាស់ជាងគេនៅប្រទេសភូមា និងនៅលើពិភពលោក ហើយខ្ញុំក៏បាន

---

[10] http://en.wikipedia.org/wiki/Shwedagon_Pagoda



www.elibraryofcambodia.org

ទៅទស្សនាវត្តនោះដែរ។ ដោយសារតែវត្តនេះត្រូវបានសាងសង់ដោយជនជាតិមនហើយជនជាតិមនប្រកាន់សាសនាព្រះពុទ្ធដូចខ្មែរដែរ នោះរចនាបទខ្លះនៅក្នុងវត្តនិងក្នុងវិហារមានទម្រង់ដូចខ្មែរ។ លោកសាស្ត្រាចារ្យ David Thomas និងលោកសាស្ត្រាចារ្យ Robert Headley អ្នកឯកទេសអក្សរសាស្ត្របរទេសជនជាតិអាម៉េរិកបានបែងចែក"មនខ្មែរ" ចេញជាចំនួន៩ប្រភេទ[11] ដែលបច្ចុប្បន្ន ពួកគេបាននិងកំពុងរស់នៅតាមបណ្តាប្រទេសក្នុងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។

---

[11] *http://www.photius.com/countries/cambodia/society/cambodia_society_austroasiatic_mon_kh~5.html*



www.elibraryofcambodia.org





រូបលើ៖ "ខ្ញុំ ត្រាយ សុផល្យមើលរូបព្រះពុទ្ធនៅវត្តស្វីដាហ្គុន នៅទីក្រុងយ៉ាំងហ្គុន ប្រទេសភូមានាថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ ២០១៤។ រូបឆ្វេង៖ ព្រះសង្ឃភូមាគង់នៅវត្តស្វីដាហ្គុន (រូបថតដោយ ឆាយ សុផល)។ រូបក្រោម៖ ខ្ញុំឆាយ សុផល នៅក្នុងបរិវេណវត្តស្វីដាហ្គុន





www.elibraryofcambodia.org

ងាកមករឿងកម្ពុជាវិញ។ ក្រោយពីព្រះបាទអង្គអេងសោយទិវង្គតទៅ កម្ពុជាគ្មានអ្នកស្នងរាជ្យបន្ត។ ស្ថិតក្នុងកាលៈទេសៈអន្តរកាលបែបនេះ ស្ដេចត្រាញ់ហៅថា ចៅហ្វាប៉ុក ជារាជានុសិទ្ធិ ឬជានាយករដ្ឋមន្ត្រីមានសិទ្ធិអំណាចបន្ទាប់ពីព្រះរាជា បានគ្រប់គ្រងប្រទេសបណ្ដោះអាសន្ន ដែលធ្វើឲ្យមាតុភូមិខ្មែរនាពេលនោះបានពើបប្រទះវិបត្តិរាជបល្ល័ង្ក។ ស្ថិតនៅក្នុងភាពវឹកវរនេះក៏កើតមានការប្រទាញប្រទង់គ្នាយកទឹកដីខ្មែររវាងសៀម និងយួន ដែលធ្វើឲ្យខ្មែរមានអស្ថិរភាព ហើយប្រជានុរាស្ត្រកាន់តែក្រីក្រវេទនា។ ខេត្តបាត់ដំបង និងខេត្តសៀមរាបជាខេត្តសំខាន់ជាងគេរបស់នគរខ្មែរ តែត្រូវបានស្ដេចត្រាញ់ ចៅហ្វាប៉ុក ភ្ជាប់ឲ្យទៅសៀមកាន់កាប់ក្រោមរាជ្យរបស់ស្ដេចសៀមព្រះបាទសម្ដេចព្រះពុទ្ធយ៉តហ្វាចឡាលោក ឬព្រះរាមាទី១។ អ្វីដែលគួរឲ្យសោកស្ដាយជាងនេះទៅទៀត គឺកម្ពុជាទាំងមូលត្រូវបានក្លាយទៅជាស្រុកចំណុះស្យាមទាំងស្រុង[12]។ ស្ដេចត្រាញ់រូបនោះ "ដែលស្និទ្ធនឹងសៀមបានទទួលមើលខុសត្រូវកិច្ចការរដ្ឋពីឆ្នាំ១៧៩៦ដល់ឆ្នាំ១៨០៥។......ទឹកដីបាត់ដំបងជាមហានគរចុងកាល់ធ្លាក់ទៅក្នុងអំណាចរបស់សៀម នៅ ពេលនោះ ដោយសារតែមានមន្ត្រីខ្មែរដែលស្និទ្ធនឹងសៀមចង់បំពេញចិត្តចៅហ្វាយសៀមបានញុះញង់ស្ដេចសៀមឲ្យទារសគុណក្នុងការចិញ្ចឹមព្រះអង្គអេង"[13]។

គួររម្លឹកថា ព្រះបាទ អង្គអេង បានឡើងគ្រងរាជ្យបានរយៈពេល២០ព្រះវស្សាគឺចាប់ផ្ដើមតាំងពីព្រះជន្ម៧ព្រះវស្សា គឺនៅឆ្នាំ១៧៧៩ តែដោយសារប្រទេសបានពើបប្រទះនឹងកលិយុគនៃដណ្ដើមអំណាចគ្នានា

---

[12] គេហទំព័រ CEN: http://www.cen.com.kh/culture/

[13] https://tamabloveyaymab.wordpress.com/2012/11/15/inscription-at-oudong-4/detail_culturehistory/YTA5NWJiMGVkMTQ



www.elibraryofcambodia.org

ពេលនោះ ទើបមន្ត្រីរាជវាំងបានជម្លៀសព្រះកាយមហាក្សត្រព្រះជន្មក្មេងអង្គនេះទៅប្រទេសសៀម។ ក្រោយមកគឺនៅឆ្នាំ១៧៩៤ ទើបស្តេចសៀមបានរៀបចំរាជពិធីអភិសេកជាផ្លូវការនាទីក្រុងបាងកកឲ្យព្រះបាទអង្គអេង ឡើងគ្រងរាជបល្ល័ង្កខ្មែរ ហើយក៏ឲ្យព្រះអង្គយាងមកស្រុកខ្មែរវិញ។

បន្ទាប់មក អង្គច័ន្ទ (ប្រសូតៈ១៧៩១ - សុវណ្ណគតៈ ១៨៣៤ នៅឧដុង្គ) ជាព្រះរៀមរបស់ អង្គឌួង ត្រូវបានស្តេចសៀមតែងតាំងឲ្យឡើងសោយរាជសម្បត្តិនាឆ្នាំ១៨០៦ ដោយពិធីរាជាភិសេកត្រូវបានប្រារព្ធឡើងនៅទីក្រុងឧដុង្គមានជ័យ។ បន្ទាប់ពីគ្រងរាជ្យ ព្រះអង្គបានទទួលព្រះបរមងាររថា "ព្រះបាទឧទ័យរាជា អង្គច័ន្ទ"។ នៅពេលនោះ បើទោះជាសៀមនិងយួនមានសិទ្ធិអធិរាជលើព្រះរាជាណាចក្រកម្ពុជាក្តី ក៏ព្រះបាទ អង្គច័ន្ទ បានខិតខំពង្រឹងអធិបតេយ្យភាពជាតិឡើងវិញដែរ។ ដើម្បីបញ្ចៀសបាននូវគ្រោះថ្នាក់បាត់បង់ទឹកដី ទ្រង់ត្រូវប្រើយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយ គឺការបញ្ចុះបញ្ចូលគូបដិបក្ខយួន និងសៀមដែលមានមហិច្ឆតាលេបត្របាក់ទឹកដីខ្មែរដូចគ្នាតាំងពីបុរាណកាលឲ្យច្បាំងគ្នា។ នៅគ្រានោះដែរ ព្រះបាទ អង្គច័ន្ទ ក៏បានពង្រីកអត្តសញ្ញាណជាតិឡើងវិញតាមរយៈការស្តារឡើងវិញនូវរបបរាជាធិបតេយ្យខ្មែរ[14]។

សូមបញ្ជាក់ថា នៅពេលបានគ្រងរាជ្យ ព្រះបាទ អង្គច័ន្ទ បានសាងដំណាក់មួយដែលជាទីជម្រកនៅពេលឆ្លងកាត់ ឬច្រកចេញចូលពីលង្វែកទៅឧដុង្គ និងខេត្តនានា ហើយសាងកន្លែងមួយទៀតនៅក្បែរ

---

[14] *បណ្ឌិត មីសែល ត្រាណេ៖ http://www.cen.com.kh/culture/detail_culturehistory/YTA5NWJiMGVkMTQ#sthash.8eSkauMV.dpuf*



www.elibraryofcambodia.org

ឧដុង្គសម្រាប់ពលទ័ពហាត់គុន និងដើម្បីការពារព្រះរាជដំណាក់ផង។ បច្ចុប្បន្ន ដំណាក់នោះត្រូវបានគេហៅថា "វត្តច្រកស្តេច" ឬ "វត្តអង្គច័ន្ទសុវណ្ណរាជា" ហើយកន្លែងពលទ័ពហាត់គុនត្រូវបានគេហៅថា "វត្តព្រះធាតុ" ដែលស្ថិតនៅក្នុងឃុំច្រកស្តេច ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

មានរឿងតំណាលថា នៅបរិវេណ "វត្តច្រកស្តេច" ឬ "វត្តអង្គច័ន្ទសុវណ្ណរាជា" នេះមានអណ្តូងមួយ ដែលពលរដ្ឋនៅស្រុកនោះហៅតៗគ្នាថា "អណ្តូងច្រកស្តេច"។ កាលពីរាជធានីលង្វែកដែលសៀមបានចូលវាយលុកនោះ អង្គច័ន្ទ និងអមាត្យបានរត់ខ្ចាត់ខ្ចាយបែកខ្ញែកពីលង្វែក ហើយ អង្គច័ន្ទ បានរត់ចូលពួនពេញមួយថ្ងៃនៅក្នុងអណ្តូងទំហំ៤ម៉ែត្របួនជ្រុងនោះ ដែលធ្វើឲ្យពលទ័ពសៀមរកមិនឃើញ។ ជាច្រើនឆ្នាំក្រោយមក អណ្តូងនេះត្រូវបានគេបោះបង់ចោល ហើយបាក់ដីកាន់តែរាក់ទៅៗ។ ឆ្នាំ១៩៧៩ ក្រោយសម័យ ប៉ុលពត មានកសិករម្នាក់បានព្យាយាមលប់អណ្តូងនោះដើម្បីយកដីធ្វើស្រែ តែមិនបានធ្វើឡើយ ព្រោះស្លាប់ បន្ទាប់ពីលុបអណ្តូងបានពាក់កណ្តាល។ ចាប់ពីពេលនោះមក មិនមាននរណាហ៊ានប៉ះពាល់អណ្តូងនោះទៀតទេ ដែលបច្ចុប្បន្នសភាពអណ្តូងបានរាក់ទៅហើយមើលមិនដឹងថាជាអណ្តូងនោះទេ ហើយមានព្រៃរបោះដុះព័ទ្ធជុំវិញ[15]។ នៅឆ្នាំ ២០០៦ ព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ក៏បានប្រទានព្រះរាជអំណោយសង់ស្រះទឹកមួយនៅក្បែរអណ្តូងទឹកនោះ។ ចំណែកឯកន្លែង

---

[15] *នេះជាការរៀបរាប់របស់ប្រធានអាចារ្យវត្តច្រកស្តេចក្នុងពេលលោកនាំខ្ញុំទៅមើលអណ្តូងនៅថ្ងៃទី១៥ តុលា ២០១៤*



www.elibraryofcambodia.org

ទីពហាត់គុនដែលពលរដ្ឋហៅថា "វត្តព្រះធាតុ" នោះគឺមកពីមានហេតុដែលតំណាលថា មានបងប្អូនពីរនាក់ចង់មកត្រាស់នៅវត្តនេះដែលមានផ្ទាំងថ្មធំៗ។ បងប្អូនទាំងពីរបានដាំផ្កាមួយដើមម្នាក់ ហើយសន្យានឹងគ្នាថា បើផ្កានរណារីកមុន អ្នកនោះបានត្រាស់មុន។ បន្ទាប់មក ផ្ការបស់បងបានរីកមុន តែដោយសារចង់ត្រាស់ពេក ប្អូនក៏ទៅកាច់ផ្ការបស់បងមកដាក់លើដើមរបស់ខ្លួន ហើយប្រាប់បងថា ផ្ការបស់ខ្លួនបានរីកហើយ។ ដោយមិនជំទាស់នឹងប្អូន បុរសជាបងក៏យល់ព្រម។ ស្រាប់តែពេលនោះមានបាតុភូតញ័រផ្ទាំងសីលា ដែលធ្វើឲ្យផ្អើលប្រជានុរាស្ត្រ។ ព្រះសង្ឃចំនួន៥០០អង្គបានមកសូត្រធម៌ប្រើបារមីដើម្បីបញ្ឈប់បាតុភូតនោះ តែអកុសលអី ផ្ទាំងសិលាដ៏ធំក៏បានបាក់ពីលើកំពូលភ្នំសង្កត់មកលើព្រះសង្ឃឲ្យសុគតភ្លាមៗ។ ក្រោយមក ធាតុរបស់ព្រះសង្ឃទាំងនោះត្រូវបានគេយកមកតម្កល់នៅវត្តនេះ ទើបគេហៅថា "វត្តព្រះធាតុ" រហូតមក។ វត្តនេះអ្នកស្រុកនៅទីនោះជឿណាស់ថា ពិតជាមានបារមី និងស័ក្តិសិទ្ធិ ដោយកន្លងមក មានរន្ទះបាញ់ចំគូសង្សារមួយគូដែលកំពុងឱបគ្នានៅលើកំពូលភ្នំ ដែលនាំឲ្យបុរសស្លាប់ ហើយថា នៅពេលបត់ជើងតូចឈរអាចពើបប្រទះពស់ឬក្អែបចេញមកដេញចឹក។ ជាទូទៅ អ្នកបានឡើងភ្នំនេះសុទ្ធតែជាអ្នកបានឡើងដោយចៃដន្យ[16]។

[16] *នេះជាការរៀបរាប់របស់លោក សួស សារ៉េម ប្រធានភូមិនៅទីនោះក្នុងដំណើរជូនខ្ញុំឡើងលើភ្នំ នៅថ្ងៃទី១៥ តុលា ២០១៤*



www.elibraryofcambodia.org



"អណ្តូងច្រកស្តេច" ដែលព្រះបាទអង្គច័ន្ទបានចូលពួនគេចពីការតាមចាប់របស់ទ័ពសៀម។ អណ្តូងនេះស្ថិតក្នុងឃុំច្រកស្តេច ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ (រូប ឆាយ សុផល ៖ ២៤ តុលា ២០១៤)។



ព្រះសង្ឃព្រះជន្មក្មេងពីរអង្គគង់នៅមាត់ស្រះក្បែរ អណ្តូងច្រកស្តេច។ ស្រះនេះជាព្រះរាជអំណោយរបស់ព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅឆ្នាំ ២០០៦ (រូប ឆាយ សុផល ៖ ២៤ តុលា ២០១៤)។



www.elibraryofcambodia.org



ផ្ទាំងសិលានិងបំណែកបាក់នៅលើកំពូលភ្នំព្រះធាតុ ហើយផ្ទាំងសិលាធំបញ្ឈរនេះ នៅពេលមនុស្សម្នាសំឡឹងមើលទៅអាចឃើញរូបរាងមនុស្សឬសត្វទៅតាមនិស្ស័យរៀងៗខ្លួន
(រូប ឆាយ សុផល ៖ ២៨ តុលា ២០១៤)។



www.elibraryofcambodia.org

បន្ទាប់ពីព្រះបាទ អង្គច័ន្ទ សោយព្រះសុវណ្ណគតទៅនៅក្នុងឆ្នាំ ១៨៣៤ ពួកអណ្ណាម [យួន] និងសៀមក៏បានឯកភាពគ្នាតែងតាំងអ្នកអង្គម្ចាស់ក្សត្រិយ៍ អង្គម៉ី (ប្រសូត៖១៨១៥ - ព្រះសុវណ្ណគត៖១៨៧៤) ដែលជាបុត្រីរបស់ព្រះបាទ អង្គច័ន្ទ និងជាព្រះភាគិនេយ្យា [ក្មួយស្រី] នៃព្រះអង្គម្ចាស់ អង្គឌួង ឲ្យឡើងគ្រងរាជ្យបន្តធ្វើជាព្រះមហាក្សត្រិយានីខ្មែរនាឆ្នាំនោះដែរ។ ព្រះបាទ អង្គច័ន្ទ មិនមានបុត្រាទេ គឺមានតែបុត្រីទាំង៤អង្គ៖ ម្ចាស់ក្សត្រិយ៍ បែន ម្ចាស់ក្សត្រិយ៍ អង្គម៉ី ម្ចាស់ក្សត្រិយ៍ ពៅ និងម្ចាស់ក្សត្រិយ៍ ស្ងួន។ ដំបូង ម្ចាស់ក្សត្រិយ៍ បែន ជាបងត្រូវបានគេជ្រើសរើសឲ្យស្នងរាជ្យជំនួសព្រះបិតា តែដោយព្រះនាងមានភាពរឹងត្អឹងនិងមានះ មិនចុះសម្រុងជាមួយមន្ត្រីយួន ទើបរាជការយួនតែងតាំងម្ចាស់ក្សត្រិយ៍ អង្គម៉ី ជាប្អូនស្រីបន្ទាប់ឲ្យស្នងរាជ្យ (១៨៣៤ - ១៨៤៥) ជំនួសវិញ ដែលពេលនោះមានមេទ័ពយួន៣នាក់ជាអ្នកសម្រេចការនេះ[17] ដូចនេះម្ចាស់ក្សត្រិយ៍ អង្គម៉ី ក៏បានក្លាយជាព្រះរាជាទី៩៧របស់ខ្មែរ។ ការឡើងសោយរាជ្យរបស់ អង្គម៉ី គឺមានឥទ្ធិពលពីយួន[18] ជាងសៀម ដែលពេលនោះសង្គ្រាមយួននិងសៀមកំពុងកើតមានដោយសារដណ្តើមកាន់កាប់នគរនិងស្តេចខ្មែរ។ ក្រោយមក ព្រះរៀម បែន ចង់រត់ទៅនៅប្រទេសសៀមដើម្បីបានរស់នៅជាមួយមាតា តែបែកការណ៍ ក៏ត្រូវគេចាប់ឃុំ ហើយក្រោយមក ត្រូវយួនធ្វើគុតដោយជ្រមុជទឹក[19]។

---

[17] សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ- រដ្ឋបាលប្រទេសកម្ពុជា និងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៧៩

[18] http://en.wikipedia.org/wiki/Ang_Mey

[19] សៀវភៅ៖ សំនួរនិងចម្លើយ - ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (ទំព័រ៨៧) សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋានការប្រឡងផ្សេងៗ ជាពិសេសថ្នាក់ទុតិយភូមិ



www.elibraryofcambodia.org

ចំណែកប្អូនស្រីពីរនាក់ទៀតគឺម្ចាស់ក្សត្រិយ៍ ពៅ និងម្ចាស់ក្សត្រិយ៍ សួន ត្រូវបានព្រះរៀមមហាក្សត្រិយានី អង្គម៉ី តែងតាំងជា "ឧបរាជិនី" និង "កែវហ្វា" ដែលមានអំណាចបន្ទាប់ពីមហាក្សត្រិយានី។ បងប្អូនស្រីទាំងបីគឺត្រូវរូវគ្នា និងដោយចង់បានអំណាចរាជសម្បត្តិក៏ត្រូវបានយួនបោកបញ្ឆោត ហើយយួនក៏បញ្ជូនពួកគេទាំងបីទៅស្រុកយួន[20] ឯអំណាចស្ថិតនៅក្នុងកណ្តាប់ដៃយួនទាំងអស់។ ព្រះមហាក្សត្រិយានី អង្គម៉ី ត្រូវបានពួកយួនហៅថា ម៉ីឡាំគាន់ជួ (My-lam-quan-chua) មានន័យថា "ព្រះនាង" តែនៅពេល អង្គម៉ី ឡើងគ្រងរាជ្យ អណ្ណាមបានហៅថា បាកុងជួ (Ba-cong-chua) វិញ ដែលមានន័យថា "ព្រះមហាក្សត្រិយានី"។ ការដែលយួនបានលើកតម្កើងឲ្យ អង្គម៉ី បាន ឡើងគ្រងរាជ្យ គឺខ្លួនមានផែនការលេបទឹកដីកម្ពុជា ហើយនៅពេលអង្គម៉ី បានគ្រងរាជ្យ យួនបានបង្ខំឲ្យមន្ត្រីខ្មែរស្លៀកពាក់ និងបួងសក់តាមបែបយួន ហើយក៏ផ្តល់ឋានានុក្រមតាមគន្លងយួនទៀតផង[21]។ នៅក្នុងគំនិតចង់បានទឹកដីរបស់ខ្មែរ ស្តេចយួនបានផ្លាស់ប្តូរឈ្មោះរាជធានីខេត្តស្រុករបស់ខ្មែរឲ្យទៅជា "ឈ្មោះយួន ដូចជារាជធានីភ្នំពេញទៅជាត្រានតាយ ឬត្រានណាំយ៉ាង ហើយបន្ថយចំនួនខេត្តនៃព្រះរាជាណាចក្រកម្ពុជាពី៥៦ មក ៣៣ វិញ។ យួនបានបង្ខំឲ្យព្រះសង្ឃសឹក គាស់រំលើងដើមពោធិ៍ចោល និងបានកម្ទេចចេតិយ។ល។"[22] បញ្ហានេះបាននាំឲ្យមានការបះបោរពេញផ្ទៃនគរ

---

[20] សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ- រដ្ឋបាលប្រទេសកម្ពុជា និងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៨០

[21] សៀវភៅ៖ សំនួរនិងចម្លើយ - ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (ទំព័រ៨៤-៨៥) សម្រាប់ថ្នាក់ផ្ទាំមូលដ្ឋាន ការប្រឡងផ្សេងៗ ជាពិសេសថ្នាក់ទុតិយភូមិ

[22] សៀវភៅ៖ សំនួរនិងចម្លើយ - ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (ទំព័រ៨៥)



www.elibraryofcambodia.org

ខ្មែរ តែត្រូវបានយួនបង្ក្រាប ដែលនាំឲ្យនាហ្មឺន [នាម៉ឺន] មន្ត្រីខ្មែរឯកភាពគ្នាផ្ញើសំបុត្រទៅចៅពញាបឌិន ដែលជាមេទ័ពសៀមឲ្យទូលថ្វាយដល់ព្រះរាជាសៀម ដើម្បីបញ្ជូនព្រះអង្គម្ចាស់ អង្គឌួង មកកាន់នគរខ្មែរវិញ។

**១៨៤១៖** ព្រះអង្គម្ចាស់ អង្គឌួង បានសឹកហើយក៏បានយាងមកនគរវិញ តែដំបូង ព្រះអង្គយាងមកគង់នៅត្រឹមបាត់ដំបងរៀបចំកេណ្ឌទ័ពធ្វើសង្គ្រាមដោយមានការគាំទ្រពីមេទ័ពសៀមឈ្មោះ ចៅពញាបឌិន ដើម្បីប្រឆាំងនឹងយួន។ នៅពេលនោះ យួនក៏បានប្រគល់អំណាចឲ្យទៅមហាក្សត្រិយានី អង្គម៉ី វិញ ហើយបញ្ជូនព្រះអង្គឲ្យមកគង់នៅខេត្តមាត់ជ្រូក ដើម្បីបញ្ជាទ័ពឲ្យប្រយុទ្ធជាមួយព្រះបិតុលា [មា] ឯងគឺព្រះអង្គម្ចាស់ អង្គឌួង។ ការប្រយុទ្ធគ្នារវាងទ័ពរបស់មហាក្សត្រិយានី អង្គម៉ី គាំទ្រដោយយួន និងទ័ពរបស់ព្រះអង្គម្ចាស់ អង្គឌួង គាំទ្រដោយសៀមបានប្រព្រឹត្តទៅអស់រយៈពេល៤ឆ្នាំ (១៨៤១-១៨៤៥) តែមិនមានអ្នកឈ្នះអ្នកចាញ់ឡើយ ហើយឈាមខ្មែរហូរជោបផ្ទៃនគរ ដែលតាមពិតនោះ វាគឺជាសង្គ្រាមរវាងយួននិងសៀម ដើម្បីដណ្តើមអំណាចគ្រប់គ្រងនគរនិងស្តេចខ្មែរតែប៉ុណ្ណោះ។

*"នៅសម័យកាលនោះ ប្រទេសខ្មែរបាននិងកំពុងស្ថិតនៅក្នុងស្ថានភាពជុនដាប ក្រោមការបៀតបៀនពីសំណាក់ប្រទេសអណ្ណាម និងប្រទេសសៀម ដែលប្រទេសទាំងពីរនេះតែងតែមើលមកប្រទេសខ្មែរថាជាសាច់មួយដុំដែលជាកម្មបទនៃការដណ្តើមគ្នារបស់ពួកគេ។ ព្រះបាទ អង្គឌួង ទ្រង់បានយាងទៅសាងព្រះផ្នួសជាសាមណេរក្នុងសំណាក់ព្រះមហាព្រហ្មមុនីនង នៅឆ្នាំ១៨១១។ ....ព្រះអង្គឌួង និងព្រះអង្គអឹម មានការអាក់អន់ព្រះទ័យនឹងព្រះអង្គច័ន្ទ ហើយក៏បានភៀសព្រះកាយទៅគង់នៅស្រុកស្យាម*



www.elibraryofcambodia.org

*អស់ពេលប្រមាណ១ទសវត្សរ៍។ ឯកសារខ្លះនិយាយថា ទ្រង់គង់នៅក្រុងបាងកកអស់រយៈពេល២៧ឆ្នាំ (គឺចាប់តាំងពីទ្រង់មានព្រះជន្ម១៦ហួតដល់៤៣វស្សា) ហើយទ្រង់ក៏បានយាងត្រឡប់មកស្រុកខ្មែរវិញនៅឆ្នាំ១៨៤១"*[23]។

នៅក្នុងដំណាក់កាលនោះ ខណៈដែលយួនត្រួតត្រាខ្មែរប្រជាជនខ្មែរបានបះបោរប្រឆាំងនឹងឧត្តមសេនីយ៍ និងមន្ត្រីយួនដែលបានប្រមាថខ្មែរហួសហេតុ។ បន្ទាប់មក យួននិងសៀមបានចែកទឹកដីខ្មែរឲ្យគ្នាគ្រប់គ្រង ដែលចាប់ពីពេលនោះរហូតមក បើទោះជាប្រទេសទាំងពីរត្រូវបានខ្មែរបណ្តេញចេញក៏ដោយ ក៏ពួកគេនៅតែចាត់ទុកថា ទឹកដីខ្មែរជារបស់ពួកគេរហូតមក[24]។ នៅសតវត្សរ៍ទី១៧ វិបត្តិដណ្តើមរាជបល្ល័ង្កក្នុងចំណោមរាជវង្សខ្មែរបានកើតមានក្នុងនគរ ហើយ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ "ព្រះញាតិវង្សឈ្លោះដណ្តើមរាជសម្បត្តិគ្នាគ្មានឈប់ឈរឡើយ។ ដើម្បីឈ្នះនិងសម្លាប់គូប្រជែង ព្រះអង្គម្ចាស់មួយទៅពឹងយួន ឯមួយអង្គទៀតទៅពឹងសៀម។ ក្នុងចម្បាំងសម្លាប់បងប្អូនឯងកាលនោះ ព្រះរាជវង្សលែងគិតគូរដល់បេសកកម្មរបស់ខ្លួនហើយ"[25]។

សូមរម្លឹកហេតុការណ៍មុននេះបន្តិចថា នៅក្នុងរជ្ជកាលមហាក្សត្រព្រះបាទ ស្រីសុរិយោពណ៌ (១៦០៣-១៦១៨) ទ្រង់យល់ឃើញថា ចាប់តាំងពីបោះបង់អង្គរ និងបែកបាក់លង្វែកមក សៀមតែងតែគាប

---

[23] *គេហទំព័រ CEN៖ http://library.cen.com.kh/library/read_online_html?token=NWU3ZGEwZWRjNTU2ZmU5MjZiZDE5NDQ2NjdmYjRm*

[24] *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា (ជាភាសាខ្មែរ) ទំព័រ៨១ ដោយ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍*

[25] *សៀវភៅ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់កម្មវិធីសិក្សាថ្នាក់មូលដ្ឋានឆ្នាំ ២០១២ របស់អ្នកនិពន្ធ ដៀប សុផល (ទំព័រ១៨៨)*



www.elibraryofcambodia.org

សង្កត់ខ្មែរកាត់ដីភាគខាងលិច ទើបព្រះអង្គរឹតចំណងមិត្តភាពជាមួយស្តេចយួន[26]ព្រះនាម ង្វៀន ហ៊្វុក ង្វៀន (Nguyễn Phúc Nguyên) ឬ វួង សាយ (Vuong Sai) [សោយរាជ្យ៖ ឆ្នាំ១៦១៣-១៦៣៥] ដោយស្តីដណ្តឹងបុត្រីពៅស្តេចយួនអង្គនេះមានព្រះនាមថា ង៉ុក វ៉ាន់ (Ngọc Vạn) [ព្រះនាមពេញ៖ Nguyen Phuc Ngoc Van][27] ហើយខ្មែរហៅថា ម្ចាស់ក្សត្រិយ៍ អង្គចូវ (Chúa) ធ្វើជាមហេសីរបស់ព្រះរាជបុត្រា ជ័យជេដ្ឋាទី២។ បន្ទាប់មក ព្រះបាទ ស្រីសុរិយោពណ៌ ក៏ឲ្យគេសង់ព្រះរាជវាំងមួយនៅខាងជើងស្រះកែវបង្កើតទីក្រុងថ្មីមានឈ្មោះថា ឧដុង្គមានជ័យ។ ជ័យជេដ្ឋាទី២ក៏បានរៀបអភិសេកជាមួយម្ចាស់ក្សត្រិយ៍ ង៉ុក វ៉ាន់ ឬ អង្គចូវ បុត្រីស្តេចយួននោះនៅឆ្នាំ១៦២០ ដែលឆ្នាំនោះ ជ័យជេដ្ឋាទី២ មានព្រះជន្ម៤២ព្រះវស្សា និងមានមហេសី៤អង្គ/នាក់រួចទៅហើយ ហើយម្ចាស់ក្សត្រិយ៍ អង្គចូវ ឬ ង៉ុក វ៉ាន់ មានវ័យប្រមាណ១៧ឆ្នាំជានារីស្អាតមានរូបឆោមស្រស់ ជាមហេសីចុងក្រោយ បន្ទាប់ពីមហេសីជនជាតិឡាវនាម ប៊ូស (Bous)។ បន្ទាប់ពីរៀបអភិសេកមក ម្ចាស់មហាក្សត្រិយ៍ អង្គចូវ មានឥទ្ធិពលនិងអំណាចយ៉ាងខ្លាំងក្នុងរាជវាំងនៃព្រះជ័យជេដ្ឋាទី២[28]។ ឆ្នាំ១៦២៣ នៅពេល ជ័យជេដ្ឋាទី២ កំពុងគ្រងរាជ្យនៅឧដុង្គមានជ័យ បន្ទាប់ពីព្រះបិតា ស្រីសុរិយោពណ៌ សោយព្រះទិវង្គតឆ្នាំ១៦១៩ យួនក៏បញ្ជូនរាជទូតឲ្យមកចូលគាល់ ដោយសុំខ្ចីដីខ្មែរនៅខេត្តកំពង់ក្របី និងព្រៃ

---

[26] *សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី១១ ឆ្នាំ ២០១១ (ទំព័រ១៤២-១៤៣)*

[27] *http://vi.wikipedia.org/wiki/C%C3%B4ng_n%E1%BB%AF_Ng%E1%BB%8Dc_V%E1%BA%A1n*

[28] *ឯកសារជាភាសាវៀតណាម៖ http://hanlecung.wordpress.com/2013/07/03/nhung-cong-chua-co-cong-voi-dai-viet/*



www.elibraryofcambodia.org

នគរ ដើម្បីដាក់ទ័ពយួនទប់ស្កាត់ពួកចំប៉ា (ផ្វា) និងកាន់កាប់កំពង់ផែព្រៃនគរ ដើម្បីទារពន្ធពីឈ្មួញយួនចិន។ ការសុំខ្ចីនេះគឺមានរយៈពេលតែ៥ឆ្នាំ ហើយដោយមិនហ៊ានប្រកែកជាមួយព្រះបិតាក្មេក វ្វង សាយ ព្រះជ័យជេដ្ឋាទី២ ក៏សុខព្រះទ័យប្រគល់ទឹកដីដែលមានសកម្មភាពពាណិជ្ជកម្មដ៏មមាញឹកបំផុតនោះទៅឲ្យយួន[29]តែម្តង។ មានឯកសារមួយសរសេរថា៖ *នៅពេលនោះ ស្តេចយួន វ្វង សាយ ពិតជាត្រូវការស្តេចខ្មែរ ជ័យជេដ្ឋាទី២ ដើម្បីទប់ទល់ការគំរាមកំហែងរបស់ចំប៉ា ហើយស្តេចខ្មែរ ជ័យជេដ្ឋាទី២ ក៏ត្រូវការស្តេចយួនដែរដើម្បីទប់ជាមួយពួកស្យាមឬសៀម។ បន្ទាប់មក ដោយខ្មែរមិនយកសួយសាអាករឲ្យសៀមៗក៏លើកទ័ពវាយខេត្តបរិបូរណ៌និងខេត្តបន្ទាយមាស[30]របស់ខ្មែរ តែព្រះជ័យជេដ្ឋាទី២ បានឈ្នះសង្គ្រាមនាពេលនោះ ព្រោះមានទ័ពយួនបានជួយពីក្រោយ។ ក្រោយរយៈពេល៥ឆ្នាំដែលត្រូវប្រគល់ទឹកដីឲ្យកម្ពុជាវិញ ស្រាប់តែព្រះបាទ ជ័យជេដ្ឋាទី២ បានសោយសុវណ្ណគត។ នៅឆ្នាំ ១៦៣៨ នៅពេលព្រះមហាក្សត្រថ្មី អង្គទង់ រាជាធិបតី ឡើងគ្រងរាជ្យ ទ្រង់ក៏បានស្នើឲ្យយួនប្រគល់ទឹកដីឲ្យខ្មែរវិញ តែយួនបានសុំពន្យារពេល។ ក្រោយមកនៅឆ្នាំ១៦៤១ មហាក្សត្រថ្មីព្រះបាទ អង្គច័ន្ទ បានស្នើយួនម្តងទៀតឲ្យប្រគល់ទឹកដីមកខ្មែរវិញ តែត្រូវម្ចាស់ក្សត្រិយ អង្គចូវ អតីតមហេសីព្រះបាទជ័យជេដ្ឋាទី២មកធ្វើអន្តរាគមន៍សុំពន្យារពេលជាថ្មី។ ចាប់ពីពេលនោះមក យួនបានបញ្ជូនប្រជាជនរបស់ខ្លួនមកតំបន់ទាំងនោះ ហើយនៅឆ្នាំ១៦៥៨ ម្ចាស់ក្សត្រិយយួន អង្គចូវ បានគាំទ្រជាចំហដល់ព្រះ*

---

[29] *សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី១១ ឆ្នាំ ២០១១ (ទំព័រ១៤២-១៤៣)*

[30] *ខេត្តបរិបូរណ៌ បច្ចុប្បន្ន ជាស្រុកបរិបូរណ៌ក្នុងខេត្តកំពង់ឆ្នាំង ហើយខេត្តបន្ទាយមាស គឺជា ស្រុកបន្ទាយមាស ក្នុងខេត្តកំពត*



www.elibraryofcambodia.org

*អង្គម្ចាស់ខ្មែរពីរអង្គគឺ ពញាតន់[31] និង ពញាតី ឲ្យឡើងគ្រងរាជ្យបន្តពីព្រះបាទ អង្គច័ន្ទ ដោយនឹកស្មានថា ព្រះអង្គម្ចាស់ទាំងពីរនោះជាអ្នកស្រឡាញ់យួន។ ផ្ទុយទៅវិញ នៅពេលបានគ្រងអំណាចរាជបល្ល័ង្កហើយ ព្រះអង្គតន់រួមជាមួយព្រះអង្គតី ក៏បានវាយប្រហារយួនដណ្តើមយកទឹកដីនោះមកវិញ ហើយសង្គ្រាមក៏ចាប់ផ្តើមនៅឆ្នាំ១៦៩៩ ឆ្នាំ១៧៣១ និងឆ្នាំ១៧៣៩ រហូតដល់បារាំងចូលមកនៅសតវត្សរ៍ទី១៩។ ដោយគិតថា បារាំងកំពុងឈ្លានពានវៀតណាម មហាក្សត្រថ្មីគឺព្រះបាទអង្គឌួង នៅថ្ងៃទី ២៥ វិច្ឆិកា ឆ្នាំ ១៨៥៦ ផ្ញើចុតហ្មាយជូនស្តេចបារាំង ណាប៉ូលីអុងទី៣ (Napoleon III) ដោយប្រាប់ថា ទឹកដីចាប់ពីខេត្តកំពង់ស្រកាត្រី (Dong Nai) ចុះទៅកោះត្រឡាច (Con Dao) និងកោះត្រល់ (Phu Quoc) ជាកម្មសិទ្ធិរបស់កម្ពុជា។ ព្រះបាទ អង្គឌួង បានឡាយថា "ប្រសិនបើករណីដែលអណ្ណាម [វៀតណាម] ថ្វាយដីទាំងនោះឲ្យព្រះអង្គ ខ្ញុំសូមព្រះអង្គកុំទទួលយក ព្រោះទឹកដីនោះជារបស់កម្ពុជាទេ។ នៅឆ្នាំ១៨៥៩ ព្រះបាទ អង្គឌួង បានបញ្ជូនទ័ពទៅវាយយកទឹកដីទាំងនោះវិញ តែនៅឆ្នាំ១៨៦០ ព្រះបាទ អង្គឌួង បានសោយសុវណ្ណគត ហើយបេសកកម្មរបស់ព្រះអង្គក៏បានបរាជ័យ[32]។*

ចំណែកម្ចាស់ក្សត្រិយ៍ ង៉ុក វ៉ាន់ ជាអតីតសមាជិករាជវង្សយួនវិញ គឺត្រូវបានអ្នកប្រវត្តិសាស្ត្រនិងជាតិនិយមយួនជំនាន់ក្រោយចាត់ទុកថាជាវីរនារីដែលបានពង្រីកទឹកដីរបស់ខ្លួនកាន់តែធំមកផ្នែកខាងត្បូង។

---

[31] *ពាក្យថា "ពញា" គឺសំដៅលើរាជបុត្ររបស់មហាក្សត្រ។ ក្រោយមក ពាក្យ "ពញា" នេះបានប្តូរជា "អង្គ" ហើយបច្ចុប្បន្នជា "ព្រះអង្គម្ចាស់" ឧ. ពញាច័ន្ទ ឬ អង្គច័ន្ទ ឬព្រះអង្គម្ចាស់ច័ន្ទ*

[32] *កាសែត Phnom Penh Post(ថ្ងៃសុក្រទី២១ មេសា ២០០៦)៖ http://www.phnompenhpost.com/national/jacobsen-history-challenged*



www.elibraryofcambodia.org




ផែនទីទី២៖ អាស៊ីអាគ្នេយ៍ដីគោកនៅសតវត្សទី៩និងទី១០ (រូបផែនទីនៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រថៃ" ដោយលោក David K. Wyatt ទំព័រ១៦)។



www.elibraryofcambodia.org




*កំពង់ផែព្រៃនគរ ហៅសាយហ្គន នាឆ្នាំ១៩០០ ដែលស្ថិតនៅក្រោមការកាន់កាប់របស់បារាំង តែមានជនជាតិយួននៅពេញទៅហើយ (រូបបណ្ណាល័យជាតិ)។*

**ឆ្នាំ ១៨៤៥៖** បន្ទាប់ពីសង្គ្រាម៤ឆ្នាំរវាងភាគិនេយ្យា [ក្មួយស្រី] អង្គម៉ី គាំទ្រដោយយួន និងព្រះបិតុលា [ពូ] អង្គឌួង គាំទ្រដោយសៀម មិនមានអ្នកឈ្នះអ្នកចាញ់ យួននិងសៀមនៅឆ្នាំនោះ ក៏បានឯកភាពគ្នាចុះសទ្ធិសញ្ញាស្រុះស្រួលគ្នាប្រគល់រាជបល្ល័ង្កទៅឲ្យព្រះអង្គម្ចាស់ អង្គឌួង វិញ[33] បើទោះជាព្រះមហាក្សត្រិយានី អង្គម៉ី នៅមិនទាន់ចូលពិរាល័យ [សុគត] ក៏ដោយ។ នាពេលនោះ សៀមហាក់ដូចជាមានឥទ្ធិពលវិញលើយួននៅលើទឹកដីខ្មែរ ដែលនាំឲ្យយួនយល់ព្រមជាមួយសៀមតែងតាំងអង្គឌួង ជំនួស អង្គម៉ី វិញ គឺអាចនិយាយថា អង្គម៉ី ត្រូវបានគេបណ្តេញចេញពីរាជបល្ល័ង្កមុនសោយពិរាល័យ។ តាមពិត បើទោះជា អង្គម៉ី ជា

*[33] សៀវភៅ៖ ប្រវត្តិសាស្ត្រកម្ពុជា និងរាជនខ្មែរ ទំព័រ១៤៦*



www.elibraryofcambodia.org

មហាក្សត្រិយានីនាពេលនោះក៏ដោយ ក៏មហាក្សត្រិយានីអង្គនេះគ្មានអំណាចអ្វីទាំងអស់ តែត្រូវបានស្តេចយួនឃុំព្រះកាយជាមួយប្អូនស្រី គឺព្រះនាងពៅ និងព្រះនាងស្នួន ហើយព្រះនាងប៉ែន ជាព្រះរៀមត្រូវបានយួនធ្វើគុត "ដោយជ្រមុជទឹក ដោយចោទថា ព្រះនាងក្បត់ ព្រោះព្រះមាតាព្រះនាងបានទៅពឹងសៀម"[34]។ នៅដើមឆ្នាំ ១៨៤៦ ព្រះអង្គម្ចាស់អង្គឌួង ក៏បានឡើងគ្រងរាជ្យបន្តពីភាគិនេយ្យា អង្គម៉ី តែព្រះរាជពិធីបានធ្វើឡើងនៅមួយឆ្នាំបន្ទាប់គឺឆ្នាំ១៨៤៧។ "ក្នុងប្រវត្តិសាស្ត្រ តាំងពីយូរលង់មកហើយ ពួកសក្តិភូមិសៀមបានវាយលុក រាតត្បាត និងជាន់ឈ្លីប្រទេសកម្ពុជាជាច្រើនលើកច្រើនសា។ គឺពួកសក្តិភូមិសៀមនេះហើយដែលជាអ្នកដើមភ្លើងនៃការដុនដាបរបស់អរិយធម៌អង្គរ។ នៅចុងសម័យអង្គរ ដោយនយោបាយឃោរឃៅរបស់ពួកសក្តិភូមិសៀម ស្តេចខ្មែរត្រូវបង្ខំចិត្តលើករាជធានីទៅទិសខាងត្បូងវិញ"[35]។ ពេលកន្លងមក ការចាញ់សង្គ្រាមនិងបាត់បង់ទឹកដីក៏ដោយសារតែមហាក្សត្រខ្លះដូចជា "ព្រះបាទត្រសក់ផ្អែមនិងក្សត្រតៗមកខ្វះវិជ្ជាមេទ័ព" គ្មានយុទ្ធសាស្ត្រធ្វើសង្គ្រាមដែលនាំឲ្យសត្រូវងាយបោកបញ្ឆោតនិងចូលដណ្តើមយកទឹកដីបាន[36]។ ម្យ៉ាងវិញទៀត ដោយមើលឃើញថា ខ្មែរនៅជាមួយគ្នាមានកម្លាំងនិង

---

*[34] សៀវភៅ៖ សំនួរនិងចម្លើយ - ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ( ទំព័រ៨៧ ) សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋានការប្រឡងផ្សេងៗ ជាពិសេសថ្នាក់ទុតិយភូមិ*

*[35] សៀវភៅប្រវត្តិវិទ្យាកម្ពុជាថ្នាក់ទី៩ ( ទំព័រ ១០៤-១០៥ ) របស់រង្វើកម្ពុជា ឆ្នាំ១៩៨៩*

*[36] សៀវភៅ៖ ខ្មែរលើគម្ពីស្វែងរកព្រះបាទជ័យវរ្ម័នទី២ ( ទំព័រ៥៣ )៖ http://www.elibraryofcambodia.org/khmer-leuk-kumpi-sveng-rok-preahbat-jey-voraman-ti-7/*



www.elibraryofcambodia.org

ឥទ្ធិពលខ្លាំងក្លា សត្រូវបរទេសបានព្យាយាមគ្រប់រូបភាពបំបែកកម្លាំងរួម នេះ ដើម្បីពួកគេងាយបំបាក់និងគ្រប់គ្រងខ្មែរ។



កងទ័ពខ្មែរក្នុងសម័យកាលបាក់ងនៅស្ទឹងសង្កែខេត្តបាត់ដំបង (រូបបណ្ណាល័យជាតិ)



ការចល័តរបស់កងទ័ពសៀមនាសម័យកាលមុន (រូបបណ្ណាល័យជាតិ)



www.elibraryofcambodia.org

បន្ទាប់ពីបានគ្រងរាជ្យ ព្រះបាទ អង្គឌួង មិនអាចបំភ្លេចសៀម និងយួនបានទេ គឺ "ទ្រង់បានបញ្ជូនសួយសារអាករបីឆ្នាំម្តងទៅឲ្យក្រុងវេ និងសួយសារអាករប្រចាំឆ្នាំឲ្យបាងកក" ដែរ[37]។ តែសួយសារអាករទាំងនេះត្រូវបានបញ្ចប់ នៅពេលបារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ។ បន្ទាប់ពីបានឡើងសោយរាជ្យភ្លាម ព្រះបាទ អង្គឌួង បានខំរើបម្រាសពីការត្រួតត្រារបស់សៀមនិងយួន ហើយបានចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយប្រទេសបារាំង។ គួររម្លឹកមុននេះបន្តិចថា នៅឆ្នាំ ១៦៤១ ចៅពញាច័ន្ទ (ព្រះជន្ម២៣ព្រះវស្សា) ជាព្រះរាជបុត្រពៅរបស់ព្រះជ័យជេដ្ឋាទី២ ដោយអន់ព្រះទ័យចំពោះការមិនបានឡើងសោយរាជ្យ ក៏បានឲ្យបក្ខពួកវាយលុកចូលព្រះរាជវាំងធ្វើគុតទាំងស្តេចដែលជាព្រះបិតុលា [ឪពុកមា] និងព្រះអនុជរបស់ទ្រង់ ហើយក៏បានឡើងគ្រងរាជ្យនៅ "ក្រុងឧដុង្គមានជ័យ" ឬរាជធានីឧដុង្គ ដោយតាំងខ្លួនថាជា "ព្រះបាទសម្តេចព្រះរាមាធិបតី"[38]។ ចាប់តាំងពីនោះមក សង្គ្រាមកាប់ចាក់ផ្ទៃក្នុងក៏បានកើតឡើងជាបន្តបន្ទាប់ ដែលជាឱកាសនៃការគ្រប់គ្រងរបស់យួននិងសៀមរហូតបារាំងមកធ្វើអាណានិគម។

កាលនៅគ្រងរាជបល្ល័ង្ក ព្រះបាទ អង្គឌួង ក៏ធ្លាប់បានអញ្ជើញលោក ហង់រី មូហូត (Henri Mouhot) បេសកជនការទូតបារាំងឲ្យមកជួបក្រុមប្រឹក្សារាជបល្ល័ង្ករបស់ព្រះអង្គដែរ ប៉ុន្តែសៀមបានគាបសង្កត់ព្រះអង្គមិនឲ្យជួបមន្ត្រីបារាំងនាពេលនោះ។ ទីបំផុត ជំនួបនៅតែកើតឡើង

---

[37] សៀវភៅ៖ "ប្រវត្តិសាស្ត្រថៃ ដោយលោក David K. Wyatt ប្រែជាភាសាខ្មែរដោយគ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្តឆ្នាំ២០១១ (ទំព័រ ១៩៩)

[38] សៀវភៅ៖ "ប្រវត្តិសាស្ត្រខ្មែរ - ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ មុនីវង្ស" (ទំព័រ ២១២)



www.elibraryofcambodia.org

នៅឯរាជធានីឧដុង្គនាឆ្នាំ១៨៥៦[39]។ ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជា លោក ហិនរី មូហាត់ មានការចាប់ចិត្តលើនគរខ្មែរ ពីសម្បត្តិធម្មជាតិដ៏មានតម្លៃមហាសាលពិសេសប្រាសាទអង្គរវត្ត ដែលបានរងការខូចខាត។ ក្រោយមក លោក ដេអូហ្សាក់ ឌូដាត ដឺឡាក្រេ (Geozague Doudart de Lagree) អ្នកតំណាងប្រទេសបារាំង បានមកចូលគាល់ព្រះបាទ អង្គឌួង ហើយ យល់ព្រមគាំទ្រឲ្យព្រះរាជបុត្រា នរោត្តម ជាអ្នកស្នងរាជ្យបន្ត។ ជាមួយនឹងការយល់ព្រមនេះហើយ បារាំងបានដាក់កិច្ចសន្យាមួយចំនួនជាការដោះដូរ ដូចជារុករកនិងធ្វើអាជីវកម្ម រ៉ែ និងសម្បត្តិព្រៃឈើនៅក្នុងអាណាចក្រខ្មែរ ដើម្បីនាំយកទៅបរទេស ពិសេសនាំទៅប្រទេសបារាំង ហើយបារាំងសន្យាថា ខ្លួននឹងជួយការពារប្រទេសកម្ពុជាមិនឲ្យប្រទេសយួននិងសៀមឈ្លានពាន។


លោក Henri Mouhot

ក្រោយពីប្រទេសបានឯករាជ្យពីប្រទេសយួន និងសៀម ព្រះករុណា ព្រះបាទ អង្គឌួង បានគិតគូរកសាងព្រះរាជអាណាចក្រឡើងវិញ ដូចជាការសាងសង់វត្តអារាម និងផ្លូវថ្នល់ជាដើម។ ជាងនេះទៅទៀត ព្រះអង្គបានគិតគូរក្នុងការទាក់ទងជាមួយបារាំង ដើម្បីជួយទំនុកបម្រុងកម្ពុជា ដ្បិតព្រះអង្គនៅមិនជឿទុកចិត្តសៀម និងយួនដដែល។

នៅក្នុងរយៈពេល១៣ព្រះវស្សានៃការគ្រងរាជបល្ល័ង្ករបស់ព្រះអង្គ គឺទ្រង់បានកសាងកំពង់ផែកំពត និងបញ្ជាឲ្យសាងសង់សំពៅ

[39] *សៀវភៅ៖ WHO'S WHO – The Most Influent People in Cambodia ទំព័រ ៥២)*



www.elibraryofcambodia.org

សមុទ្រធំមួយ ដើម្បីឲ្យកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសខាងក្រៅ ក្រោយពីយួនបានបិទច្រកសមុទ្រខ្មែរនៅឯព្រៃនគរតាំងពីយួនបានខ្ចីពីព្រះជេដ្ឋាទី២មកម្ល៉េះ។ ព្រះអង្គក៏បានសាងសង់ផ្លូវប្រវែង១៤០គីឡូម៉ែត្រដើម្បីភ្ជាប់កំពង់ផែកំពតទៅនឹងរាជធានីឧដុង្គ ដោយមានស្ពានធ្វើអំពីឈើ និងសង់សាលាសំណាក់នៅក្បែរត្រពាំងមួយ និងដាក់បង្គោលគីឡូម៉ែត្រជាការចំណាំ។ ព្រះអង្គក៏បានប្រគល់ឲ្យអ្នកភូមិដែលរស់នៅក្បែរៗផ្លូវនោះមើលថែរក្សាឲ្យបានល្អ ហើយត្រូវផ្លាស់វេនគ្នាយាមសាលាសំណាក់ ដើម្បីបម្រើអ្នកធ្វើដំណើរ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានចេញព្រះរាជបញ្ជាឲ្យលើកដីសង់ផ្លូវពីរាជវាំងឧដុង្គ មកកាន់កំពង់ហ្លួងក្នុងខេត្តកណ្ដាល។

រាជធានីឧដុង្គ ត្រូវបានកសាងឡើងនៅឆ្នាំ១៦០១ ដោយមហាក្សត្រព្រះបាទ ស្រីសុរិយោពណ៌ដែលគេស្គាល់ថាជា "បរមរាជាទី៤"[40] បន្ទាប់ពីបោះបង់រាជធានីលង្វែកចោល។ នៅមុននេះគឺ ក្នុងឆ្នាំ១៦១៨-១៨៦៦ រាជធានីនេះត្រូវបានគេហៅថា "ឧដុង្គមានជ័យ" ដែលមានមហាក្សត្រជាច្រើនអង្គបានគង់នៅសោយរាជ្យ ក្រោយពីចាកចេញពីរាជធានីលង្វែកដែលសៀមបានចូលឈ្លានពាន។ នៅក្នុងរជ្ជកាលនៃការគ្រងរាជ្យរបស់សម្ដេចព្រះបាទ អង្គឌួង នាចន្លោះឆ្នាំ ១៨៤២-១៨៦០ ព្រះ

[40] សៀវភៅ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់កម្មវិធីសិក្សាថ្នាក់មូលដ្ឋានឆ្នាំ ២០១២ របស់អ្នកនិពន្ធ ជៀប សុផល ( ទំព័រ ១៨៥ ) សរសេរថា ជ័យជេដ្ឋាទី២ជាស្ថាបនិកក្រុងឧដុង្គ ហើយស្ដេចខ្មែរស្ទើរគ្រប់អង្គតែងគង់នៅទីនោះ។
សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី១១ ឆ្នាំ ២០១១ ( ទំព័រ១៤២)៖ ជ័យជេដ្ឋាទី២ ជាបុត្ររបស់ ស្រីសុរិយោពណ៌ ដែលព្រះអង្គបានដាក់រាជ្យឆ្នាំ ១៦១៨ ថ្វាយដល់បុត្រា ជ័យជេដ្ឋាទី២



www.elibraryofcambodia.org

អង្គបានសាងសង់កំផែង ប្រឡាយ ស្ពាន និងវត្តអារាមជាច្រើននៅជុំវិញតំបន់នោះ។



ផ្លូវមួយចេញពីឧដុង្គទៅខេត្តកំពត សាងសង់ក្នុងរជ្ជកាលព្រះបាទអង្គឌួង (បណ្ណាល័យជាតិ)



ភ្នំឧដុង្គ អតីតតំបន់រាជធានីឧដុង្គមើលពីចម្ងាយផ្នែកខាងកើត (ថាយ សុផល ២៤ តុលា ២០១៤)

www.elibraryofcambodia.org

រាជធានីឧដុង្គត្រូវបានព្រះបាទ នរោត្តម បោះបង់ចោលនាឆ្នាំ ១៨៦៦ ទាំងស្រុងដោយបារាំងបានបង្ខំឲ្យទ្រង់យាងទៅគង់នៅឯរាជធានីថ្មីគឺ "ភ្នំពេញ"។ ចាប់ពីថ្ងៃទី៦ មិថុនា ឆ្នាំ ១៨៧៥ រាជធានីឧដុង្គក៏បានក្លាយជាទីសក្ការបូជា ប៉ុន្តែក្រោយមក អតីតរាជធានីឧដុង្គត្រូវបានបំផ្លាញដោយសង្គ្រាម មានការបាញ់ផ្លោងកាំភ្លើងតូចធំ និងការទម្លាក់គ្រាប់បែក ហើយវត្ថុបុរាណនិងមានតម្លៃដែលនៅសេសសល់ជាច្រើនក៏ត្រូវបានគេលួច។

នៅក្នុងរបបខ្មែរក្រហមចន្លោះថ្ងៃទី១៧ ខែមេសា ១៩៧៥-៦ មករា ១៩៧៩ អតីតរាជធានីនេះ និងវត្តអារាមនៅតំបន់នោះត្រូវបានបំផ្លាញចោល ហើយភ្នំឧដុង្គក៏ក្លាយជាតំបន់ដែលខ្មែរក្រហមយកមនុស្សទៅឃុំ និងសម្លាប់ចោលដែរ។ នៅថ្ងៃទី១ កញ្ញា ឆ្នាំ១៩៩២ អង្គការយូណេស្កូបានយកភ្នំឧដុង្គ ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកខាងផ្នែកវប្បធម៌។ នៅលើកំពូលភ្នំឧដុង្គដែលកាលពីពេលនោះស្ថិតនៅក្នុងខេត្តសំរោងទង[41]មានព្រះចេតិយនៃអតីតព្រះមហាក្សត្រ និងព្រះរាជវង្សានុវង្សជាច្រើនអង្គ ព្រមទាំងមានវិហារព្រះពុទ្ធសាសនា និងឥស្លាមផង។ នៅឆ្នាំ១៩១៧ សម្តេចព្រះបាទ ស៊ីសុវត្ថិ ទ្រង់បានត្រាស់បង្គាប់ឱ្យធ្វើសិលាចារឹកដាក់នៅមុខព្រះចេតិយយ៉ាងតិចពីរ។ ព្រះបាទសម្តេចព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទ្រង់ក៏បានជង្កៃព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធមកតម្កល់លើភ្នំនេះដែរ។

[41] *បច្ចុប្បន្ន សំរោងទងជាឈ្មោះស្រុកស្ថិតនៅខេត្តកំពង់ស្ពឺ ហើយភ្នំឧដុង្គគឺស្ថិតនៅក្នុងខេត្តកណ្តាល*



www.elibraryofcambodia.org

ទាក់ទិននឹងភ្នំឧដុង្គនេះគឺមានរឿងដំណាលថា៖

*"ព្រះពុទ្ធរូបនៅក្នុងព្រះវិហារអដ្ឋរស្សនេះបែរព្រះភក្ត្រទៅទិសខាងជើង គឺមិនបែរទៅទិសខាងកើតតាមទម្លាប់ ដែលជាតំណាងឱ្យប្រវត្តិនៃភាពរុងរឿងនិងរឹងមាំនៃចក្រភពខ្មែរនោះទេ។ ក្នុងសតវត្សរ៍ទី១៨ ប្រជាជនក្នុងតំបន់នោះនិយាយថា អធិរាជចិនមួយព្រះអង្គបានបញ្ជូនកងកម្លាំងរបស់ព្រះអង្គទៅទូទាំងអាស៊ីដើម្បីពិនិត្យមើលនគរផ្សេងៗដែលអាចបង្កគ្រោះមហន្តរាយដល់នគរព្រះអង្គ។ នៅពេលដែលកងកម្លាំងចិននោះមកដល់ក្រុងឧដុង្គ ពួកគេបានឃើញភ្នំឧដុង្គមានរាងដូចនាគ និងមានរូងមួយ (នៅកំពូលខាងវិហារអដ្ឋរស្ស) ហើយពួកគេបានស្គាល់ភាពសម្បូររុងរឿង និងកម្លាំងនៃសង្គមខ្មែរនាសម័យនោះ។ កងកម្លាំងចិនទាំងនោះក៏បានទៅទូលព្រះអធិរាជចិនវិញថា ជាតិខ្មែរមានអំណាចខ្លាំងក្លាហើយបើកាលណាមាននាគបង្ហាញខ្លួននៅក្នុងរូងអដ្ឋរស្សហើយ នោះពួកគេអាចគ្រប់គ្រងផែនដីទាំងមូល។ អធិរាជចិនមិនចង់ឱ្យខ្មែរក្លាយទៅជាមហាអំណាចទេ តែព្រះអង្គក៏មិនចង់ធ្វើសង្គ្រាមដែរ។ ដូច្នេះ ព្រះអង្គសួរទៅព្រះមហាក្សត្រខ្មែរថា តើព្រះអង្គអាចសង់វិហារមួយនៅលើរូងដោយឱ្យព្រះពុទ្ធរូបបែរទៅនគរចិនដើម្បីការពារនគរព្រះអង្គបានឬទេ។ វិហារនេះឈ្មោះអដ្ឋរស្ស ដែលមានន័យថា ១៨ ផ្សិតសណ្ឋានវិហារ គឺមាន១៨ជ្រុង។"*[42]

ដោយជឿពួកចិន ហើយដើម្បីតែចំណងទាក់ទងជាមួយចិនផង មហាក្សត្រខ្មែរក៏សម្រេចព្រះទ័យសង់ព្រះពុទ្ធរូបមួយអង្គបែរព្រះភក្ត្រទៅទិសខាងជើង ដែលបច្ចុប្បន្ន ព្រះពុទ្ធរូបនេះ ត្រូវបានអ្នកស្រុកហៅថា "ព្រះអង្គធំ"។

---

[42] http://km.wikipedia.org/wiki/ឧដុង្គ



www.elibraryofcambodia.org



ព្រះពុទ្ធរូបដែលខ្មែរហៅថា "ព្រះអង្គធំ" បែរព្រះភក្ត្រទៅជើងនៅក្នុងវិហារលើកំពូលភ្នំខដុង្គ ដែលគេអះអាងថា ព្រះអធិកជចិនបានឲ្យស្តេចខ្មែរសង់នៅលើរ៉ុងនាគ (រូប ឆាយ សុផល)។



វិហារសាងសង់ប្រក់ព្រះពុទ្ធរូប "ព្រះអង្គធំ" បែរព្រះភក្ត្រទៅទិសខាងជើងនៅលើកំពូលភ្នំខដុង្គ ដែលព្រះពុទ្ធរូបនោះត្រូវបានគេអះអាងថា ព្រះអធិកជចិនបានឲ្យស្តេចខ្មែរសង់នៅលើរ៉ុងនាគ (រូប ឆាយ សុផលះ ១២ តុលា ២០១៤)



www.elibraryofcambodia.org



ព្រះចេតិយនៃអតីតព្រះមហាក្សត្រខ្មែរ ពិសេសរាជបច្ឆាតិនៃ ព្រះបាទស៊ីសុវត្ថិ នៅលើកំពូលភ្នំឧដុង្គ ឬភ្នំព្រះរាជទ្រព្យ ឬ ភ្នំអង្គស្សរអតីតៈរាជធានីឧដុង្គ (រូប ឆាយសុផល៖ ២៦ មេសា ២០១៣



www.elibraryofcambodia.org

នៅក្នុងរជ្ជកាលរបស់ព្រះបាទ អង្គឌួង ព្រះអង្គបានចាត់កំណែទម្រង់ទូទាំងព្រះនគរ និងបានរៀបចំព្រះរាជវាំងឲ្យមានរបៀបរៀបរយឡើងវិញ ដើម្បីស្តារកិត្តិនាមដែលបានបាត់បង់អស់កាលជាយូរណាស់មកហើយដោយសារតែសង្គ្រាម។ ព្រះករុណា ព្រះបាទ អង្គឌួង ទ្រង់ម៉ឺងម៉ាត់ណាស់ចំពោះអ្នកណាដែលបំពានច្បាប់ ហើយបានដាក់ទោសធ្ងន់ៗដល់មន្ត្រីធំណាដែលមិនគោរពរាជបញ្ជា។ ទោះបីជាយ៉ាងនេះក្តី ព្រះអង្គប្រកបទៅដោយយុត្តិធម៌ មានព្រះទ័យល្អចំពោះអ្នកក្រីក្រ ហើយមានភាពអត់ធន់ចំពោះអ្នកទាំងនោះ។ ការគ្រប់គ្រងរបស់ព្រះអង្គត្រូវបានគិតគូរតាមបែបព្រះពុទ្ធសាសនា ដោយទ្រង់ជាអ្នកជឿជាក់លើពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ គឺថា ព្រះអង្គបានដកអ្នកល្ងង់ខ្លៅ និងអ្នកគ្មានសមត្ថភាពចេញពីកិច្ចការរាជការ ហើយបដិសេធជំនូនផ្សេងៗ ដែលពួកចៅហ្វាយខេត្តតែងតែថ្វាយព្រះរាជានៅពេលដែលទ្រង់ប្រទានត្រា។ ព្រះអង្គមិនអត់ឱនឲ្យទេចំពោះការប្តឹងផ្តល់ដែលធ្វើមិនត្រឹមត្រូវ សរសេរមិនត្រូវតាមក្បួនខ្នាត ពីព្រោះព្រះអង្គមិនចង់ឲ្យសរសេរចម្លងតាមតែគ្នាមិនច្បាស់លាស់ ហើយបើចង់ប្តឹងផ្តល់ត្រូវរត់ទៅរកអ្នកចេះដឹងឲ្យគេសរសេរពាក្យបណ្តឹងឲ្យ។ ព្រះអង្គហាមប្រាមមន្ត្រីរាជការមិនឲ្យផឹកសុរា ឯអ្នកណាជក់អាភៀនត្រូវតែបណ្តេញចោល ហើយដោយសារតែតឹងតែងត្រង់ចំណុចនេះ ទើបគ្មានមន្ត្រីណាម្នាក់ជក់អាភៀនឡើយនៅក្នុងរជ្ជកាលព្រះអង្គ។ ទ្រង់បានហាមមិនឲ្យធ្វើផ្នស់បិទជិតស្នឹងទេ ដើម្បីឲ្យមានត្រីមួយចំនួនរួចផុតពីអ្នកនេសាទ និងដើម្បីឲ្យត្រីអាចធ្វើចរាចរទៅមកបានផង ហើយទ្រង់ក៏បានហាមប្រាមការបរបាញ់សត្វផងដែរ[43]។

---

[43] *http://whoincam.wordpress.com/2009/03/12/ang-duong/*



www.elibraryofcambodia.org

១៨៤៧៖ ព្រះអង្គបានបញ្ជាឲ្យគេបង្កើតសាលាឧទ្ធរណ៍នាឆ្នាំនោះ ដែលជាតុលាការឧទ្ធរណ៍មុនដំបូងបំផុតនៅក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយទ្រង់គង់ជាព្រះអធិបតីដោយផ្ទាល់នៅក្នុងតុលាការនេះ។ ចាប់ពីឆ្នាំនោះមក ទ្រង់បានបញ្ជាឱ្យចាប់ផ្តើមពិនិត្យសើរើជាទូទៅនូវមាត្រាច្បាប់នានា ដោយព្រះអង្គបានយាងចូលប្រឡូកដោយផ្ទាល់ និងយ៉ាងសកម្ម។

១៨៤៨៖ នៅក្នុងព្រះរាជដំណាក់ ព្រះអង្គបានសម្រេចពិធីការឲ្យគេហៅព្រះរាជាថា "ព្រះករុណាវិសេស" និង "អង្គម្ចាស់ជីវិតលើត្បូង"។ ចំពោះព្រះជាយា ទ្រង់បានរៀបចំព្រះរាជសង្ការសម្គាល់អ្នកទាំងអស់ព្រមទាំងពាក្យពេចន៍ដែលត្រូវប្រើផងគឺឆ្លើយថា "ព្រះបាទម្ចាស់" ចំពោះបុរស និង "ព្រះម៉ែ" ចំពោះនារី។ ទ្រង់បានរៀបចំឋានៈស្ត្រីៗនៅក្នុងព្រះបរមរាជវាំង ហើយបានសម្រេចឲ្យហៅភរិយារបស់មន្ត្រីចាប់ពីស័ក្តិ៤ឡើងទៅថា "ជំទាវ" និងអនុញ្ញាតឲ្យអ្នកទាំងនោះបង់កន្សែងពណ៌ ពាក់រយ៉ាមាស ដោតផ្កាលើសក់ ហើយមានប្រអប់ស្លាដូចរបស់ប្តីដែរ។

នៅពេលចូលមកក្នុងវាំង ទ្រង់បានឲ្យកាត់បន្ថយក្បួនមន្ត្រីធំៗ ហើយចេញបញ្ជាឲ្យពួកមន្ត្រីទាំងនោះត្រូវស្លៀកខោវែងធំទូលាយ មានជរមាស ឬស្លៀកសំពត់សូត្រ។ នៅពេលមានពិធីផ្សេងៗ ពាក់អាវពណ៌ក្រវាត់កំណាត់សំពត់ប៉ាក់ឌិនពណ៌មាស ក្រវាត់ដាវនៅចង្កេះ ហើយទៅណាមកណាជិះគ្រែស្នែង បាំងក្លស់ [ឆត្រ] ពណ៌ក្រហមមួយជាន់។



www.elibraryofcambodia.org





រូបលើនិងក្រោម៖ ការយាងចេញ និងការធ្វើដំណើរតាមដងផ្លូវរបស់សមាជិករាជវង្ស និងមន្ត្រីដោយជិះគ្រែស្នែង និងបាំងក្លស់ (ឆត្រ) (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org

ជាងនេះទៅទៀត ព្រះអង្គបានរៀបចំខេត្តឡើងវិញជាថ្មីនៅទូទាំងនគរ គឺខេត្តណាធំត្រូវចែកជា២ឬ៣ ស្រុក ហើយដាក់ឲ្យស្ថិតនៅក្រោមឱវាទមន្ត្រីធំៗត្រួតត្រា។ ព្រះអង្គបានកំណត់កាលបរិច្ឆេទព្រះរាជពិធីទ្វារទសមាសទាំង១៧ ហើយបានឲ្យយកចិត្តទុកដាក់គោរពថ្ងៃសីល និងសិក្ខាបទ។ ព្រះអង្គជាក្សត្រតាំងនៅក្នុងព្រះពុទ្ធសាសនាយ៉ាងមាំ ហើយមានរាជបំណងឱ្យមន្ត្រីទាំងអស់រក្សាសីល៥ ឬសីល៨ គ្រប់គ្នាតាមលទ្ធភាព និងនិស្ស័យរៀងៗខ្លួន។ ចំណែកទ្រង់វិញក៏ជាក្សត្ររក្សាសីលយ៉ាងខ្ជាប់ខ្ជួន និងព្រះសណ្តាប់នូវធម្មទេសនា ដែលសំដែងដោយព្រះសង្ឃនៅក្នុងព្រះបរមរាជវាំងយ៉ាងទៀងទាត់នារាល់ថ្ងៃឧបោសថផងដែរ។ ទ្រង់បានសំណូមពរមន្ត្រីរាជការឱ្យមានចិត្តមេត្តាសន្តោស ប្រោសប្រណីចំពោះផងរាស្ត្រនិករ ក៏ដូចជាស្មូមយាចក អ្នកក្រខ្សត់ ទុរគត ទន់ខ្សោយ និងសព្វសត្វទាំងពួង។ ប្រជារាស្ត្រក្រីក្រ និងព្រះសង្ឃអាចមកទទួលអាហារស្រស់ស្រូប និងឆាន់បានរាល់ថ្ងៃ។ ហេតុនេះទើបសុវត្ថិភាពបានកើតឡើងវិញលើផ្ទៃនៃនគរ ដែលធ្វើឲ្យមានសន្តិភាព ស្ថេរភាពជាចិរកាល ហើយប្រជារាស្ត្រនិករមានឱកាសបង្កបង្កើនភោគផលបានសម្បូរសប្បាយឡើងវិញមួយកម្រិត។

**១៨៤៩៖** នៅឆ្នាំនេះ ព្រះអង្គបានបញ្ជាឲ្យសាងសង់សាលាធទានដើម្បីទ្រង់បានយាងទៅចែកបាយសម្ល និងក្រមាដល់អ្នកបួស និងទុគ៌តជន ដែលនៅពេលនោះ ព្រះនគរកំពុងរងជំងឺប៉េស្តបណ្តាលឲ្យប្រជារាស្ត្រស្លាប់ជាង៥០០នាក់។ បន្ថែមពីលើនេះ ព្រះអង្គបានសាងសង់បន្ទាយជាច្រើន ដើម្បីការពារពីការឈ្លានពានពីសត្រូវ។



www.elibraryofcambodia.org

**១៨៥៣៖** ទ្រង់បានឲ្យគេបោះពុម្ពកាក់សំប៉ែតជាប្រាក់សុទ្ធបីប្រភេទ ដែលមានតម្លៃនៅពេលនោះ១ហ្វ្រង់ស្មើនឹង៥កាក់ សម្រាប់ចាយវាយជំនួសសាច់ប្រាក់ ដោយទ្រង់ព្រះរាជបញ្ញត្តិឱ្យដាក់ពាក្យថា "ព្រះនគរក្រុងកម្ពុជាធិបតី" គឺនៅលើមុខម្ខាងមានរូបហង្សកវែងដូចរូបហង្សដែលគេដាក់នៅលើចុងដងទង់ខាងមុខព្រះវិហារដែរ។ នៅឯម្ខាងទៀតមានរូបប្រាសាទបុរាណកំពូល៣ដែលតំណាងអង្គរវត្ត។



*កាក់សម័យ ព្រះបាទ អង្គឌួង ផលិតឆ្នាំ ១៨៥៣*

មតិខ្លះយល់ថា ដោយសារតែព្រះអង្គមានទំនាក់ទំនងជាមួយបារាំង ទើបបារាំងបានប្រមូលមាស ពេជ្រ និងប្រាក់ដឹកជញ្ជូនទៅប្រទេសគេយ៉ាងសម្បើមចេញពីប្រទេសខ្មែរ ទើបទ្រង់បញ្ជាឱ្យចេញកាក់ប្រភេទនេះ ហើយក៏ជាប្រាក់មុនដំបូងបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ។

លោក ហិនរី មូហូត (Henri Mouhot) ជនជាតិបារាំងបានធ្វើដំណើរមកប្រទេសកម្ពុជា ហើយបានជួបនឹងព្រះបាទ អង្គឌួង បានសរសេរពិពណ៌នាពីព្រះអង្គថា ព្រះជន្មប្រមាណ៦០ព្រះវស្សា មានព្រះកេ



www.elibraryofcambodia.org

សា [សក់] ខ្លី និងទាបក្រអាញ។ ទឹកព្រះភក្ត្របង្ហាញប្រាជ្ញាញាណវាងវៃ និងមានសមានចិត្តល្អ.......។ ទ្រង់បានចំណាយរាជទ្រព្យជាច្រើនដើម្បីស្ថាបនា ផ្គត់ផ្គង់ និងបណ្តុះបណ្តាលផ្នែកព្រះពុទ្ធសាសនាដែលរងការខ្ទេចខ្ទាំ ដោយសារសង្គ្រាមនានា មានសង្គ្រាមបៀតបៀនពីអណ្ណាម និងស្យាមជាដើម[44]។

**១២ មេសា ១៨៥៣៖** ព្រះបាទ អង្គឌួង បានបញ្ជារាជប្រតិភូដឹកនាំដោយឧកញ៉ា ម៉ុក និង ឧកញ៉ាចក្រី មាស ធ្វើដំណើរទៅរាជ ធានីបាងកក ដើម្បីស្នើសុំឲ្យស្តេចសៀម ព្រះចៅ ចមក្លាវ បញ្ជូនបណ្ឌិតសង្ឃខ្មែរព្រះនាម ប៉ាន និងគម្ពីរព្រះត្រៃបិដក១ចប់ផងមកស្រុកខ្មែរវិញ ហើយស្តេចសៀមមានព្រះទ័យត្រេកអរណាស់ដោយសង្ឃឹមថា ខ្លួននឹងបានបន្តជះឥទ្ធិពលវប្បធម៌សៀមចូលមកក្នុងផ្នត់គំនិតខ្មែរ តាមរយៈព្រះពុទ្ធសាសនាធម្មយុត្តិកនិកាយ។

**២៨ មករា ១៨៥៥៖** បណ្ឌិតសង្ឃពុទ្ធសាសនាខ្មែរព្រះនាមប៉ាន និងព្រះត្រៃបិដក១ចប់មានសៃសិបភាគនោះត្រូវបានហែហមចូលមក តាមខេត្តកំពត ដោយមានទាំងព្រះសង្ឃ៨អង្គ និងបរិស័ទមួយចំនួន និងព្រះគ្រូរបស់ភិក្ខុបណ្ឌិតសង្ឃប៉ានផង បានមកដល់ក្រុងឧដុង្គនាថ្ងៃនោះ។ ហេតុនេះ ព្រះពុទ្ធសាសនាគណៈធម្មយុត្តិ បានមកប្រតិស្ឋនៅលើទឹកដីខ្មែរ ដោយមួយផ្នែកជាមធ្យោបាយដែលស្តេចសៀមប្រើដើម្បី

---

[44] http://library.cen.com.kh/library/read_online_html?token=NWU3ZGEwZWRjNTU2ZmU5MjZiZDE5NDQ2NjdmYjRm#sthash.RTCSoRSL.dpuf



www.elibraryofcambodia.org

ជះឥទ្ធិពលលើស្មារតីខ្មែរចាប់ពីពេលនោះ។ មិនយូរប៉ុន្មាន ភិក្ខុ ប៉ាន ត្រូវបានតែងតាំងជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិ។

ព្រះបាទ អង្គឌួង មិនត្រឹមតែជាក្សត្រប្រតិពល [វាងវៃ] នៅក្នុងរាជកិច្ចប៉ុណ្ណោះនោះទេ តែទ្រង់ថែមទាំងជាក្សត្រស្នេហាអក្សរសាស្ត្រជាតិ និងតែងតែយកព្រះទ័យទុកដាក់លើកស្ទួយអក្សរសាស្ត្រជាតិជាខ្លាំង ។ ព្រះមាតារបស់ព្រះអង្គ គឺអ្នកម្នាង រស់ ត្រូវបានទ្រង់តែងតាំងជា "សម្តេចព្រះវររាជិនី ខត្តិយាវង្ស សិរីសេង្ហោវពោត្តម បរមវពតុល្យសកលមង្គលបរមបពិត្រ" ដែលជាព្រះមាតាមានគុណបំណាច់ក្នុងការទំនុកបម្រុងកវីនិពន្ធទាំងឡាយ មានកវីសន្ធរម៉ុក ជាដើម។

**១៨៥៩៖** បន្ទាប់ពីគ្រងរាជ្យអស់ជាច្រើនព្រះវស្សាមក នគរមានភាពសុខសាន្តថ្កុំថ្កើង តែនៅឆ្នាំនោះ គឺមានការបះបោរមួយនៅខេត្តត្បូងឃ្មុំ ដែលធ្វើឡើងដោយជនជាតិចាមមួយក្រុម ដោយក្រុមនេះស្តាប់បង្គាប់តែនាយចាមប៉ុណ្ណោះ គឺប្រាថ្នាចង់បង្កើតជាខេត្តឯករាជ្យមួយរបស់ចាម តែត្រូវបានព្រះបាទ អង្គឌួង បញ្ជាទ័ពឲ្យទៅបង្ក្រាបបានស្ងប់ស្ងាត់[45]។

**១៩ តុលា ១៨៦០៖** បន្ទាប់ពីធ្លាក់ព្រះកាយប្រឈួន ទ្រង់បានសោយព្រះទិវង្គតនៅថ្ងៃនោះទៅ បន្ទាប់យាងត្រឡប់ពីខេត្តកំពតមកកាន់រាជធានីឧដុង្គវិញ។ នៅមុនសោយសុវណ្ណគត ព្រះអង្គបានយាងទៅកំពត ដើម្បីទៅទតមើលសំពៅពាណិជ្ជកម្មមួយដែលទ្រង់បានឲ្យគេធ្វើ

---

[45] *សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ- រដ្ឋបាលប្រទេសកម្ពុជា និងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៨០ រៀបរៀងដោយ ឃិន តឹមកំណ*



www.elibraryofcambodia.org

ឡើង រួចប្រគល់ឲ្យជនជាតិម៉ាឡេម្នាក់នៅកាន់កាប់។ នៅទីនោះ ព្រះអង្គបានជួបជាមួយអ្នកស្រាវជ្រាវ ហិនរី ជជែកជាមួយបានបន្តិច ទ្រង់ក៏បញ្ជាឲ្យគេផ្តល់មធ្យោបាយដល់គាត់ធ្វើដំណើរមកឧដុង្គទៀត។ ក្រោយពេលដែលលោក ហិនរី ចូលគាល់ព្រះអង្គបានបន្តិចនៅនឹងព្រះរាជដំណាក់ធ្វើពីឈើ ព្រះបាទ អង្គឌួង ក៏ធ្លាក់ព្រះកាយប្រឈួន។ ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះអង្គត្រូវបានធ្វើឡើងក្នុងរជ្ជកាលព្រះបាទ នរោត្តម ហើយទ្រង់បានថ្វាយព្រះបរមនាមបច្ឆាមរណៈថា "ព្រះបរមកោដ្ឋ"។ ចេតិយតម្កល់ព្រះអដ្ឋិព្រះអង្គត្រូវបានសាងសង់និងតម្កល់នៅឯព្រះមហាបរមរាជវាំង។



*ពីឆ្វេង៖ ស្ត្រីខ្មែរ ស្ត្រីសៀម និងស្ត្រីលាវ នារជ្ជកាលមុន (រូបបណ្ណាល័យជាតិ)។*



www.elibraryofcambodia.org



ព្រះចេតិយរបស់ព្រះបាទ អង្គឌួង និងព្រះជាយាអ្នកម្នាង ប៉ែន និងអ្នកម្នាង ពៅ នៅលើកំពូលភ្នំឧដុង្គ (ស្ថិតនៅខាងត្បូងព្រះសក្យមុនីចេតិយ) ដែលព្រះរាជបុត្រា នរោត្តម បានសាងសង់ថ្វាយសម្រាប់តម្កល់ព្រះអដ្ឋិ តែក្រោយមក ព្រះអដ្ឋិក៏ត្រូវបានយាងមករាជធានីភ្នំពេញវិញ (រូប ឆាយ សុផល ៖ ១២ តុលា ២០១៤)។

បក្រោម៖ ព្រះមហាចេតិយ ព្រះបាទ អង្គឌួង នៅក្នុងព្រះបរមរាជវាំង (រូប ឆាយ សុផល ៖ ៤ ធ្នូ ២០១៤)។





www.elibraryofcambodia.org

# ព្រះមហាក្សត្រសៃ នរោត្តម និង ស៊ីសុវត្ថិ

(១៨៦០ - ១៩៥៥)



ព្រះបាទ នរោត្តម



ព្រះបាទ ស៊ីសុវត្ថិ



ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស



ព្រះបាទ នរោត្តម សីហនុ



www.elibraryofcambodia.org

# ព្រះបាទ នរោត្តម



*ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទ នរោត្តម (១៨៦៣) ក្នុងឯកសណ្ឋានយោធា*



www.elibraryofcambodia.org



ព្រះបរមរូបព្រះបាទសម្តេច នរោត្តម នៅក្នុងព្រះបរមរាជវាំង (រូប ថតដោយ សុផល ៖ ៥ ធ្នូ ២០១៤)។
ប្រសូត៖ ១៨៣៤ - សោយទិវង្គត៖ ១៩០៤ សោយរាជ្យ (១៨៦០ - ១៩០៤)



www.elibraryofcambodia.org

**ព្រះបាទសម្តេចព្រះ នរោត្តម** សោយរាជ្យក្នុងព្រះជន្ម ២៦ព្រះវស្សា ហើយគ្រងរាជ្យបាន ៤៤ឆ្នាំ៖ ១៩ តុលា ១៨៦០ - ២៤ មេសា ១៩០៤។



ព្រះបាទ នរោត្តម (ពេលឡើងសោយរាជ្យ)

នៅពេលព្រះបិតាព្រះបាទ អង្គឌួង ទ្រង់សោយព្រះសុវណ្ណគត [សោយទិវង្គត] នាថ្ងៃទី១៩ តុលា ឆ្នាំ ១៨៦០ ក្រុមប្រឹក្សារាជបល្ល័ង្ក និងសេនាបតីមន្ត្រីជាន់ខ្ពស់ខ្មែរបាន ជំនុំគ្នាជ្រើសរើសព្រះអង្គ ដែលពេលនោះមានឋានៈជាមហាឧបរាជ ស្រាប់ ឱ្យឡើងសោយរាជ្យបន្តតាមបណ្តាំរបស់ព្រះរាជបិតា អង្គឌួង មុនព្រះអង្គបានសោយព្រះសុវណ្ណគត។ ទោះបីជាយ៉ាងនេះក្តី ពិធីអភិសេកឡើងគ្រងរាជ្យពាក់មកុដរបស់ព្រះអង្គ គឺមិនបានធ្វើឡើងនាថ្ងៃនោះទេ។ រាជពិធីនេះបានធ្វើឡើងចំនួន ២លើក ដោយលើកទី១នៅឆ្នាំ១៨៦៣ នារាជធានីបាងកកប្រទេសសៀម ក្រោមការចាត់ចែងរបស់រាជវង្សសៀម ហើយលើកទី២នៅរាជធានីឧដុង្គនាថ្ងៃទី៣ មិថុនា ឆ្នាំ១៨៦៤ ក្រោមការចាត់ចែងនៃអាណាព្យាបាលបារាំង។ សរុបមក ព្រះអង្គគ្រងរាជ្យនៅឆ្នាំ១៨៦០ - ១៩០៤។

ពាក្យថា "នរោត្តម" គឺមានសូរស័ព្ទស្រដៀងគ្នាទៅនិងពាក្យថា "នៈរោត-តៈម៉ៈ" ក្នុងភាសាសំស្ក្រឹតដែលមានន័យថា "ដែលឧត្តុង្គឧត្តមជាងមនុស្សដទៃ" ឬក៏ថា នរោត្តម = នរៈ (មនុស្ស ឬ ជន ឬ បុគ្គល



www.elibraryofcambodia.org

(សំដៅដល់មនុស្សប្រុស) + ឧត្តម (ប្រសើរ ឬ ខ្ពង់ខ្ពស់ ឬ ថ្លៃថ្លា) ដូចនេះ នរោត្តម = បុគ្គល ឬជនដ៏ប្រសើរ បុគ្គល ឬជនខ្ពង់ខ្ពស់ បុគ្គលឬជនថ្លៃថ្លា។

**ប្រសូត៖** ថ្ងៃសៅរ៍ទី១២កើត ខែមាឃ ឆ្នាំមមែ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៨៣៤ នៅក្នុងដំណាក់ហ្លួង[46] ក្នុងខេត្តមង្គលបុរី (សព្វថ្ងៃជាស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ)។ នៅពេលនោះ ប្រទេសកំពុងស្ថិតនៅក្រោមការគ្រប់របស់សៀម។ កាលទើបប្រសូត ព្រះបរមរាជបិតា ព្រះបាទ អង្គឌួង ទ្រង់សព្វព្រះទ័យនឹងបុត្រាអង្គនេះណាស់ ហើយក៏ប្រទានព្រះនាមថា "ព្រះអង្គម្ចាស់ច្រឡឹង" ដែលពាក្យ "ច្រឡឹង" មានន័យថា "មានរាងតូចស្អាតសមឥតទាស់ភ្នែក។ នៅពេលព្រះអង្គច្រឡឹងប្រសូតមក អ្នកបម្រើបានយកសុកទៅកប់ មិនយូរថ្ងៃប៉ុន្មានក៏កើតជាហេតុអស្ចារ្យ ដោយមានដើមពោធិមួយដុះនៅកន្លែងកប់សុកនោះ។ អ្នកខេត្តមង្គលបុរីនាំគ្នាហៅថា "ពោធិហ្លួង" មានន័យថា ពោធិព្រះរាជា ឬពោធិស្ដេចរហូតមក។ គួរបញ្ជាក់ថា នៅថ្ងៃទី៩ វិច្ឆិកា ២០១៤ ខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅដល់កន្លែងដែលគេអះអាងថាមានដើម "ពោធិហ្លួង" នោះ ដែលស្ថិតនៅក្នុងភូមិហ្លួង ឃុំឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ នៅទីនោះជាដំបូកស្ថិតក្នុងភូមិកររនៃកម្មសិទ្ធិរបស់អ្នកភូមិមួយគ្រួសារ ហើយដើម "ពោធិហ្លួង" នោះត្រូវបានគេអះអាងថាបានងាប់ទៅហើយក្រោយពីសម័យខ្មែរក្រហមឆ្នាំ១៩៧៩។ នៅលើដំបូកនោះ ម្ចាស់ដីបានដាំដើមញព្រៃបួនដើម និងផ្កានួនស្រីក្បែរជើងដំបូក។ បើតាមអ្នកភូមិនៅទីនោះបានឲ្យដឹងថា កាលពីសម័យសង្គ្រាម

[46] *បច្ចុប្បន្ន "វត្តហ្លួងស៊ីសុវត្ថិតេនារ៉ាម" ក្នុងភូមិហ្លួង ឃុំឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ*



www.elibraryofcambodia.org

នៅពេលទ័ពវៀតណាមវាយចូលស្រុកខ្មែរ ទ័ពខ្មែរក្រហមនិងប្រជាជនខ្លះបានចូលទៅពួនជ្រកក្រោមដើមពោធិហ្លួងនោះ ហើយបានរួចផុតពីការតាមចាប់របស់ទ័ពវៀតណាម។ មិនមានឯកសារណាផ្សេងបញ្ជាក់ឲ្យច្បាស់បន្ថែមទេ ទាក់ទិននឹងការកប់សុកបែរជាដុះដើមពោធិនេះ។ មានទស្សនៈ៣ផ្សេងគ្នានៅក្នុងសម័យកាលទំនើបនេះដែលបានលើកឡើងសម្រាប់ធ្វើការពិចារណាពីដើម "ពោធិហ្លួង" នោះគឺ៖ ទី១អាចជារឿងអច្ឆរិយៈឬក៏ជារឿងបារមីនៃព្រះបាទនរោត្តមមែន ទី២អាចអ្នកយកសុកទៅកប់នោះបានយកកូនដើមឈើទៅដាំចំណាំ តែដោយសារខ្មែរគោរពបូជាដើមពោធិ ជាដើមឈើដែលព្រះពុទ្ធគង់នៅ ទើបអ្នកយកសុកយកកូនដើមពោធិទៅដាំនៅទីនោះ។ ឯទី៣អាចជាការឃុបឃិតគ្នារបស់ក្រុមញាតិវង្សខាងអ្នកម្នាង ប៉ែន ជាមាតារបស់បុត្រា ច្រឡឹង ដោយយកកូនដើមពោធិទៅដាំនៅទីកប់សុកនោះ ហើយក្រោយមកក៏ប្រាប់គេឯងថារាជបុត្រ នរោត្តម ពិតជាអច្ឆរិយៈមែនដែលអាចគ្រងរាជសម្បត្តិ និងមានបារមីទៅថ្ងៃក្រោយ ព្រោះទីកប់សុកបានដុះដើមពោធិ ដែលបន្ទាប់មកគេក៏នាំគ្នាហៅដើមពោធិនោះថា "ពោធិហ្លួង" រហូតមក។

នៅខែពិសាខ ឆ្នាំមមែ នព្វស័ក ពុទ្ធសករាជ ២៣៩១ គ្រិស្តសករាជ ១៨៤៧ ព្រះករុណា អង្គឌួង បានរៀបចំចម្រើនព្រះកេសា [សក់] ព្រះអង្គម្ចាស់ច្រឡឹង ហើយប្រទាននាមថា "រាជាវត្តី" ហើយជួនកាលគេហៅថា "ព្រះអង្គវត្តី" ឬ "អង្គវត្តី"។ ទោះបីជាយ៉ាងនេះក្តី ក៏គេឯងនៅតែហៅថា "ព្រះអង្គម្ចាស់ច្រឡឹង" ដដែល។



www.elibraryofcambodia.org



ខ្ញុំ (អ្នកចងក្រងសៀវភៅ) នៅថ្ងៃទី៩ វិច្ឆិកា ២០១៤ បានទៅដល់អតីតៈកន្លែងដើមពោធិហ្លួង ដែលបច្ចុប្បន្នជាភូមិកម្មសិទ្ធិរបស់អ្នកភូមិមួយគ្រួសារស្ថិតនៅខាងម្ខាងនៃជង់ស្ទឹងមង្គលបុរីទល់មុខនឹង "វត្តហ្លួង" ឬ "វត្តហ្លួងស៊ីសុវត្ថិតេនាកយ"។ នៅខាងក្រោយខ្នងខ្ញុំ គឺជាដំបូកដែលដើមពោធិធ្លាប់បានដុះ ហៅថា "ពោធិហ្លួង" តែពោធិហ្លួងនោះបានងាប់ទៅហើយនៅក្រោយសម័យខ្មែរក្រហម។ នៅលើដំបូកនោះ ម្ចាស់ដីបានដាំដើមញរព្រៃបួនដើម និងផ្កាទួនទ្រស្រីក្បែរជើងដំបូក ហើយនៅក្បែរដំបូក មានផ្ទះអ្នកថែរក្សាដីតាំងពីដើមមកគឺលោកតាអាចារ្យ អ៊ុំ មៀន និងលោកយាយ ជាភរិយា។ (រូបនេះអ្នកស្រុកម្នាក់នៅទីនោះបានថតឲ្យខ្ញុំនៅព្រឹកថ្ងៃទី៩ វិច្ឆិកា ២០១៤)



www.elibraryofcambodia.org





*"វត្តហ្លួង" ឈ្មោះពេញ "វត្តហ្លួងស៊ីសុវត្ថិតេនាកម" ស្ថិតនៅត្រើយម្ខាងនៃមាត់ស្ទឹងមង្គលបុរី។ វត្តនេះជាអតីតជំណាក់ហ្លួង ហើយគេជឿថា ជាកន្លែងដែលព្រះបាទនរោត្តម បានប្រសូត្រ ហើយសុកត្រូវបានគេយកទៅកប់នៅត្រើយម្ខាងនៃមាត់ស្ទឹង។ វត្តនេះបច្ចុប្បន្នស្ថិតក្នុងភូមិហ្លួង ឃុំឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ (រូប ឆាយ សុផល ៖ ៩ វិច្ឆិកា ២០១៤)*



www.elibraryofcambodia.org

ព្រះនាមថា "នរោត្តម" គឺព្រះចៅក្រុងសៀមជាអ្នកថ្វាយ ប៉ុន្តែតាមប្រពៃណីព្រះពុទ្ធសាសនា បុគ្គលទីទៃពីព្រះឧបជ្ឈាយ៍ ព្រះគ្រូបង្រៀនធម៌ ឬព្រះគ្រូបង្រៀនច្បាប់ ទោះបុគ្គលនោះមានឋានៈជាអ្វីក៏ដោយ ក៏ពុំមានកាតព្វកិច្ចដាក់នាមបញ្ញត្តិនេះដល់ភិក្ខុដែលទើបបានបួសនោះឡើយ[47]។ យ៉ាងនេះក្តី ដោយសារព្រះអង្គម្ចាស់ រាជាវត្តី ជាសមាជិកក្នុងរាជវង្ស ហើយត្រូវបានព្រះរាជាសៀមជាអ្នកបញ្ជូនឲ្យចូលបួសនិងរៀនសូត្រផងនោះ គឺជាហេតុនាំឱ្យឧបជ្ឈាយ៍មានភាពស្ទាក់ស្ទើរមិនហ៊ានអារ កាត់ចំពោះការដាក់នាមបញ្ញត្តិដល់នវភិក្ខុអង្គនេះ ទើបទៅទូលសុំការព្រមព្រៀងសព្វព្រះទ័យពីព្រះចៅចមក្សាវ ដែលជាព្រះរាជាសៀមនាពេលនោះ។

**សោយព្រះទិវង្គត៖** ២៤ មេសា ១៩០៤ ដោយសារជំងឺមហារីកព្រះភក្ត្រក្នុងព្រះជន្ម៧០ព្រះវស្សា។ ឯកសារមួយសរសេរថា ព្រះអង្គមានព្រះរោគមហារីកថ្គាម។ នៅមុនពេលសុគត់មួយខែគឺនៅថ្ងៃ១៧មីនាពេទ្យធ្មេញមកពីទីក្រុងព្រៃនគរបានមកព្យាបាលព្រះអង្គ តែមិនមានប្រសិទ្ធភាព[48]។ មានឯកសារជាច្រើនបានបង្ហាញពីទីកន្លែងពីរខុសៗគ្នាដែលព្រះអង្គបានសោយព្រះសុវណ្ណគត។ ព្រះអង្គបានទទួលព្រះមរណនាមថា "ព្រះសុវណ្ណកោដ្ឋ"។

- ប្រភេទឯកសារទី១សរសេរថា ព្រះអង្គបានសោយព្រះសុវណ្ណគតនៅក្នុងបន្ទប់ព្រះទីនាំងព្រះមហាមន្ទីរ ក្នុងព្រះបរមរាជវាំងនារាជធានី

---

[47] *គេហទំព័រ CNC៖ http://www.cen.com.kh/local/ជុំវិញ%E2%80%8Bព្រះនាម%E2%80%8Bនៃ%E2%80%8Bព្រះបាទ-"-នរោត្តម%E2%80%8B"--03524824*

[48] *សៀវភៅ៖ FINALE – The Cremation of Norodom and Norodom Sihanouk, Kings of Cambodia (ឆ្នាំ២០១២-២០១៣) by Jim Mizerski (ទំព័រ១៨២)*



www.elibraryofcambodia.org

ចតុមុខមង្គល (រាជធានីភ្នំពេញ) បន្ទាប់ពីធ្លាក់ព្រះកាយព្រះឈួនអស់រយៈពេល៦ខែមុននេះដោយសារកើតបូសនៅថ្កាល់ខាងឆ្វេង[49]។ ឯកសារនេះដូចគ្នានឹងការរៀបរាប់របស់អតីតកុមារីម្នាក់ជាអ្នករាំល្ខោន និងជាអ្នកបម្រើ ព្រះបាទ ស៊ីសុវត្ថិ នៅក្នុងរាជវាំងដែរ ហើយនាងបញ្ជាក់ហាក់ដូចជានាងបានឃើញ ព្រះបាទ នរោត្តម សោយព្រះសុវណ្ណគតផ្ទាល់នឹងភ្នែកដោយនាងរៀបរាប់ថា ព្រះបាទនរោត្តម បានសោយព្រះសុវណ្ណគតនៅក្នុងរាជធានីភ្នំពេញ។ តាមរយៈការសរសេររបស់ស្វាមីនាង នាងបានរៀបរាប់ថា "នៅពេលស្លឈាមមែនទែន ហ្លួងបង្គាប់ឲ្យគេលើកលោកដាក់គ្រែស្នែងសែងចេញទៅក្រៅទាំងយប់អាធ្រាត្រងងឹតឈឹង ដើរកាត់ស្មៅព្រៃពតីមពពើមអស់ចិត្ត ទើបបង្គាប់ឲ្យត្រឡប់មករាជមន្ទីរ ហើយឲ្យគេផ្ទេរលើកដាក់ទៅលើកៅអីមានកង់ រុញទៅរុញមកឥតឈប់ឈរ។ សភាពស្ងប់ស្ងាត់គ្របដណ្តប់ពេញវាំងទាំងមូល.......គេឮតែសំឡេងព្រះសង្ឃសូត្រការាតាយ៉ាងអន្លង់អន្លោច គួរឲ្យស្រងេះស្រងោចក្រៃលែង និងសំឡេងមនុស្សខ្សឹបខ្សៀវគ្នា។ ហ្លួងលើកដៃឡើងប្រាប់ឲ្យគេនៅស្ងៀម ហើយមានបន្ទូលខ្សាវៗថា៖ 'អញអត់ភ្លេចទេ!' បន្ទាប់មកលោកហៅ ម៉មសួន មកប្រាប់ឲ្យយកលុយប្រាំរៀលមកថ្វាយ ប៉ុន្តែ ម៉មសួន ទើបនឹងចូលទៅជិតដល់គ្រែលើកជើងពានថ្វាយ ស្រាប់តែហ្លួងទន់ដៃទម្លាក់លុយទៅលើខ្នើយហើយមាត់និយាយថាដូចម្តេចក៏ពុំរួច ងាកបត់កមកខាងឆ្វេងបន្តិច ហើយផុតដង្ហើមទៅ[50]"។ នាងបន្តថា "គេឲ្យយើងស្លៀកពាក់ស ព្រមទាំងកោរសក់ទាំងអស់គ្នា ទាំងអ្នករបាំទាំងអ្នក

---

[49] *សៀវភៅ៖ FINALE – The Cremation of Norodom and Norodom Sihanouk, Kings of Cambodia (ឆ្នាំ២០១២-២០១៣) by Jim Mizerski (ទំព័រ១៦)*

[50] *សៀវភៅ៖ សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ២៨*



www.elibraryofcambodia.org

បម្រើផ្ទាល់។....នៅជុំវិញកោដ្ឋមាសដែលក្នុងនោះ គេបញ្ចុះសពហ្លួង ដោយយកកាំបិតកាត់ផ្តាច់សរសៃដៃសរសៃជើង ដើម្បីស្រណុកទាញឲ្យអង្គុយរបៀបលុតជង្គង់សំពះ។ កោដ្ឋនេះដំកល់នៅក្នុងប្រាសាទព្រះធម្មសង្វេក ទុកសម្រាប់ធ្វើបុណ្យបូជានៅឆ្នាំក្រោយ[51]"។ សៀវភៅមួយទៀតក៏បានបញ្ជាក់ដែរថា ព្រះបាទនរោត្តម ទ្រង់សោយព្រះសុវណ្ណគតនៅក្រោមព្រះមហាស្វេតឆត្រក្នុងព្រះបរមរាជវាំងចតុមុខមង្គល រាជធានីភ្នំពេញ[52]។ ក្រៅពីនោះ ក៏មានឯកសារនិងសៀវភៅមួយចំនួនទៀតដែលអះអាងថា ព្រះអង្គបានសោយព្រះទិវង្គតនៅរាជធានីភ្នំពេញ។

- ប្រភេទឯកសារទី២សរសេរថា ព្រះបាទ នរោត្តម បានសោយព្រះសុវណ្ណគតនៅក្រុងទេពមហានគរ [បាងកក] ប្រទេសសៀម ព្រោះ "ពេទ្យប្រកបថ្វាយព្រះឱសថមិនដល់" ហើយថា ពីរឆ្នាំក្រោយមកគឺនៅខែមករា ឆ្នាំ១៩០៦ ព្រះបរមសពរបស់ព្រះអង្គត្រូវបាននាំយកមករាជធានីភ្នំពេញវិញ ហើយព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះអង្គបានប្រារព្ធធ្វើឡើងតាមប្រពៃណីខ្មែរ[53]។ ក្រៅពីនេះ ក៏មានគេហទំព័រមួយចំនួនទៀតដូចជា Wikipedia[54] ជាដើម បានសរសេរថា ព្រះអង្គបានសោយព្រះសុវណ្ណគតនៅទីក្រុងបាងកក ប្រទេសសៀម។

សម្រាប់សៀមវិញ ពួកគេស្គាល់ព្រះអង្គថាជា "ព្រះអង្គម្ចាស់ព្រហ្ម បូរីរក្ស (Phrom Borirak)" ដែលមានន័យថា "អ្នករក្សាបុរី"។ ក្រោយពីសោយព្រះសុវណ្ណគតមក បារាំងមិនឲ្យបុត្រាព្រះអង្គបានឡើង

---

[51] *សៀវភៅៈ សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ២៩*

[52] *សៀវភៅៈ មហាបុរសខ្មែរ (រាជពង្សាវតារ) ទំព័រទី៧៤ កហ៊ខណ្ឌទី២ ភាគទី៧*

[53] *សៀវភៅ "ពង្សាវតារនៃប្រទេសកម្ពុជា" (ទំព័រ១០៤) របស់ក្រសួងសិក្សាធិការឆ្នាំ១៩៥២*

[54] *គេហទំព័រ Wikipedia៖ Kehttp://en.wikipedia.org/wiki/Norodom_of_Cambodia*



www.elibraryofcambodia.org

គ្រងរាជ្យបន្តទេ តែបែរជាឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជាព្រះអនុជព្រះបាទ នរោត្តម (មាតាទីទៃពីគ្នា) ឡើងគ្រងរាជ្យជំនួសទៅវិញ។ ជាការពិត មុនសោយព្រះសុវណ្ណគត ព្រះអង្គបានតែងតាំងរាជបុត្រា យុគន្ធរ ឲ្យស្នងរាជ្យបន្ត តែដោយសារព្រះអង្គម្ចាស់ យុគន្ធរ ជាបុគ្គលដែលបារាំងមិនពេញចិត្ត បារាំងក៏មិនគាំទ្រឲ្យទ្រង់បានឡើងគ្រងរាជ្យឡើយ ហើយក៏ឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឡើងគ្រងរាជ្យជំនួសវិញ ដែលបញ្ហានេះក៏បានធ្វើឲ្យញាតិវង្សខាង នរោត្តម មិនពេញហឫទ័យដែរ។

ព្រះបាទ នរោត្តម មានមហេសី៤៧អង្គ/នាក់ ហើយមានបុត្រសរុបចំនួន៦២អង្គ (បុត្រា ២៨ អង្គ និងបុត្រី ៣៤អង្គ)[55] នេះនៅមិនទាន់គិតពីស្នំរាប់សិបនាក់ទៀតផង។ ក្នុងចំណោមបុត្រទាំង៦២អង្គនោះ គឺមិនមានបុត្រអង្គណាបានឡើងសោយរាជ្យបន្តឡើយ គឺមានតែព្រះរាជនត្តា [ចៅ] នរោត្តម សុរាម្រិត ព្រះរាជនត្តាទួត នរោត្តម សីហនុ និងព្រះរាជនត្តាលួត នរោត្តម សីហមុនី ទេដែលបានឡើងគ្រងរាជ្យជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។

**មហេសីរបស់ព្រះបាទ នរោត្តម រួមមាន[56]៖**

**មហេសីទី១៖** ម្ចាស់ក្សត្រិយ៍ យុនចម បុស្សា (Phatchoni) ជាបុត្រីនៃអ្នកអង្គម្ចាស់ស្យាម (១៨២៧-បាត់ព្រះកាយនាឆ្នាំ១៩០៩)

**មហេសីទី២៖** ម្ចាស់ក្សត្រិយ៍ សង់កុន (Sangun) ជាស្ត្រីមេម៉ាយត្រូវជាបុត្រីពៅនៃព្រះមហាក្សត្រ អង្គច័ន្ទទី២ (សោយរាជ្យឆ្នាំ ១៧៩១-១៨៣៧) ហើយអតីតស្វាមីគឺព្រះអង្គម្ចាស់ ប៊ីម៉ា (Bhima)។

[55] http://www.royalark.net/Cambodia/camboa9.htm

[56] http://www.royalark.net/Cambodia/camboa9.htm



www.elibraryofcambodia.org

**មហេសីទី៣៖** នាង ទិត្យាចម ម៉ុនដា នុម ( Ditya Jama-manda Nom ) នៅឆ្នាំ ១៨៥០ ជាកូនស្រីកាត់ចិនកុកងឺ។

**មហេសីទី៤៖** អ្នកម្នាង ម៉ម យាយ ( Mom Yeay ) ឆ្នាំ ១៨៥៧

**មហេសីទី៥៖** នាង ម៉ម ក្រាង ( Mom Krang ) ឆ្នាំ ១៨៥៨ ជាកូនស្រីគ្រួសារសាមញ្ញរបស់ជនជាតិសៀម។

**មហេសីទី៦៖** នាង ម៉ម វ៉ាន់ ( Mom Vann ) ជាកូនស្រី គ្រួសារសាមញ្ញរបស់ជនជាតិសៀម។

**មហេសីទី៧៖** អ្នកម្នាង កន្និយា មាលី ភួក ( Kanthamali Phouk ) នៅឆ្នាំ ១៨៥៨។

**មហេសីទី៨៖** នាង ចៅ ស៊ូហ្កាន់ដារ៉ាសា នារី អេប ( Chau Sugan-da rasa Nari Ep ) នៅឆ្នាំ១៨៥៨ ជាកូនចិនកុកងឺ។

**មហេសីទី៩៖** ម្ចាស់ក្សត្រិយ៍ ផល្លាទេវី សុទ្ធចន្ទ្រា ប៉ុស ( Baladevi Sudachatri Pos ) នៅឆ្នាំ១៨៥៨ ហើយត្រូវជាបងប្អូនជីដូនមួយរបស់ព្រះអង្គ ( ១៨៤០-១៩២៥ )។

**មហេសីទី១០៖** នាង គន្ធរតនា នារី ( Kantharatna Nari ) នៅឆ្នាំ ១៨៥៨។

**មហេសីទី១១៖** ព្រះមហាក្សត្រិយានី តារាកា ( Darakara ) ( ១៨៤៣-១៨៦៨ នៅឧដុង្គ ) នៅឆ្នាំ ១៨៥៨ ដែលជាបុត្រីពៅរបស់សម្តេចព្រះស្រីជេដ្ឋាមហាឧបរាជា អ៊ីម៉ា ( Imaya )។

**មហេសីទី១២៖** នាង ចម សុដាដួងសាផាន់ ( Jama Suda Duang- sa Phan ) ជាកូនស្រីគ្រួសារសាមញ្ញជនជាតិសៀម។

**មហេសីទី១៣៖** ព្រះនាង ចមសុជាតិបុស្បា នារី ថាន់ ( Jama Sujati Puspa Nari Than ) នៅឆ្នាំ១៨៦១ ជាមាតាចុងរបស់ព្រះអង្គ ( អតីតមហេសីព្រះបាទ អង្គឌួង )។

**មហេសីទី១៤៖** នាង មហាហង្សា យ៉េង ( Maha-hangsa Yeng ) នៅឆ្នាំ ១៨៦២ ជាកូនស្រីគ្រួសាររាស្ត្រសាមញ្ញ។



www.elibraryofcambodia.org

**មហេសីទី១៥៖** នាង អន (An) នៅឆ្នាំ ១៨៦២ ជាកូនស្រីគ្រួសាររាស្ត្រសាមញ្ញជនជាតិសៀម។

**មហេសីទី១៦៖** ម្ចាស់ក្សត្រិយ៍ ឧបល (Ubol) នៅឆ្នាំ ១៨៦៣។ ប្រសូត៖ ១៨៤៩ - ១៩០៩ ជាបុត្រីរបស់ព្រះបិតារបស់ទ្រង់គឺសម្តេចព្រះបាទអង្គឌួង តែមានមាតាទីទៃពីគ្នា។

**មហេសីទី១៧៖** នាង ស្រីទេវីកញ្ញារ៉ា (Sri Devi Kanhara) នៅឆ្នាំ ១៨៦៤ ជាកូនស្រីចិនកុកងឺ។

**មហេសីទី១៨៖** នាង ឃុន ញ៉ឹក (Khun Nhek) ឆ្នាំ ១៨៦៥។

**មហេសីទី១៩៖** នាង ប៉ុក (Pok) ឆ្នាំ១៨៦៦។

**មហេសីទី២០៖** ព្រះនាងម្ចាស់ យូរ៉ា ទេវីអប្សរី (Uraya Devi Apsari) នៅឆ្នាំ ១៨៦៦។

**មហេសីទី២១៖** អ្នកម្នាង សោមា ឬ សោម ( Soma/Soum) នៅឆ្នាំ ១៨៦៧។

**មហេសីទី២២៖** នាង អៀម បុស្បា (Iem Busba) ឆ្នាំ ១៨៦៤ ជាបុត្រីរបស់ព្រះចៅ Banam Abhayadipati ឬ Nhonh ដែលធ្លាប់ធ្វើជាអភិបាលខេត្តបាត់ដំបង។

**មហេសីទី២៣៖** អ្នកម្នាង ជ័យ (Chey) ឆ្នាំ ១៨៦៥ ជាស្ត្រីមានសញ្ជាតិដើមម៉ាឡេស៊ី។

**មហេសីទី២៤៖** នាង នុ (Nu) រៀបអភិសេកនៅឆ្នាំ ១៨៦៩ ជាកូនស្រីរាស្ត្រសាមញ្ញ។

**មហេសីទី២៥៖** អ្នកម្នាង ម៉ុម (Mom) រៀបអភិសេកនៅ ឆ្នាំ១៨៦៩ ជាកូនស្រីចិនកុកងឺ។

**មហេសីទី២៦៖** នាង កូឡាប (Kolap) រៀបអភិសេកនៅ ឆ្នាំ១៨៧០ ជាកូនស្រីចិនកុកងឺ។



www.elibraryofcambodia.org

**មហេសីទី២៧៖** នាង ផ្ទាល់ ( Phtal ) រៀបអភិសេកនៅឆ្នាំ១៨៧១។

**មហេសីទី២៨៖** នាង ផាយូ ( Phayou ) ប្រសូត៖ ១៨៥០-១៩១៥។ ជាចៅស្រីរដ្ឋមន្ត្រីហិរញ្ញវត្ថុ រៀបអភិសេកឆ្នាំ១៨៧១។

**មហេសីទី២៩៖** ម្ចាស់ក្សត្រិយ៍ អាកកញ្ញារី ឯក-ណ ( Akkhanari Ek-nor )។ ប្រសូត៖ ១៨៥០ បាត់ព្រះកាយក្រោយឆ្នាំ១៩០៩ ជាបុត្រីរបស់ព្រះអង្គម្ចាស់ស្យាមមួយអង្គ ដែលធ្លាប់ធ្វើជារដ្ឋមន្ត្រីឲ្យមហាក្សត្រសៀមដែរ។

**មហេសីទី៣០៖** អ្នកម្នាង នឹម រៀមឥសរ ( Nim Ream Eysor ) រៀបអភិសេកនៅឆ្នាំ១៨៧១។

**មហេសីទី៣១៖** អ្នកអង្គម្ចាស់ សិរី ទេវីអប្សរី ( Siri Devi Apsari )។

**មហេសីទី៣២៖** ព្រះនាង សុដា បាវរី ( Suda Bavari ) រៀបអភិសេកនៅឆ្នាំ១៨៧៣។

**មហេសីទី៣៣៖** អ្នកម្នាង នឹម ក្រុងពាន ( Nim Krong Pean ) រៀបអភិសេកនៅឆ្នាំ១៨៧៣។

**មហេសីទី៣៤៖** នាង កន្ធថារា បុស្បា ម៉ាកផួង ( Khandara Puspa Mac Phuong ) ហៅ អ្នកម្នាង ឃ្លីត ( Khlit ) រៀបអភិសេកនៅឆ្នាំ១៨៧៤ ជាកូនស្រីចិនកុកងឺ។

**មហេសីទី៣៥៖** អ្នកម្នាង មុត ( Mot ) រៀបអភិសេកនៅឆ្នាំ១៨៧៨ ជាកូនស្រីរាស្ត្រសាមញ្ញ។

**មហេសីទី៣៦៖** នាង ម៉ម នុម៉ាន ( Mom Numan ) រៀបអភិសេកឆ្នាំ១៨៨៥ ជាស្ត្រីជនជាតិសៀម។

**មហេសីទី៣៧៖** នាង តាត ( Tat ) រៀបអភិសេកឆ្នាំ១៨៩២ ជាកូនស្រីគ្រួសារចិនកុកងឺកាត់សៀម។

**មហេសីទី៣៨៖** នាង សង្វាន ( Sangvan ) រៀបអភិសេកនៅឆ្នាំ១៨៩២ ជាកូនស្រីគ្រួសារសៀម។

**មហេសីទី៣៩៖** នាង ម៉ម សោម ( Mom Saum ) រៀបអភិសេកនៅឆ្នាំ១៨៩២។



www.elibraryofcambodia.org

**មហេសីទី៤០៖** នាង ម៉ម ចៅ (Mom Chieu) ជាកូនរាស្ត្រសាមញ្ញរបស់ជនជាតិសៀម។

**មហេសីទី៤១៖** អ្នកអង្គម្ចាស់ក្សត្រិយ៍ សោម អង្គ (Som Angk) (ប្រសូត៖ ១៨៧៧ បាត់ព្រះកាយក្រោយឆ្នាំ១៩០៩) ជាបុត្រីទេសរដ្ឋមន្ត្រីស្យាម ដែលមានសែរាជវង្សសៀមដែរ។

**មហេសីទី៤២៖** អ្នកនាង ចៅ ស្មាម (Chau Smam) នៅឆ្នាំ១៨៩២។

**មហេសីទី៤៣៖** នាង ម៉ម ឈឺវ (Mom Chhueu) រៀបអភិសេកនៅឆ្នាំ ១៨៩៣ ជាកូនស្រីរាស្ត្រសាមញ្ញ។

**មហេសីទី៤៤៖** នាង ធីម (Thim) ជាកូនស្រីគ្រួសារសៀម (ស្លាប់ក្រោយឆ្នាំ ១៩០៩)។

**មហេសីទី៤៥៖** អ្នកម្នាង យីម ចាប៉ី (Yima Japi) ស្លាប់ក្រោយឆ្នាំ ១៩០៩)។

**មហេសីទី៤៦៖** អ្នកម្នាង យីម ស្រីកញ្ញា (Yima Sri Kanhara) ស្លាប់ក្រោយឆ្នាំ១៩០៩។

**មហេសីទី៤៧៖** នាង ចម ប៉ាស្សា (Jama Passara ឬ បូសូឡា Bossola) ជាកូនស្រីគ្រួសារសៀម (ស្លាប់ក្រោយឆ្នាំ ១៩០៩)។




*រូបភាពខាងលើត្រូវបានគេអះអាងថា ជាស្នំម្នាក់របស់ព្រះបាទ សម្តេចព្រះ នរោត្តម។ រូបនៅគេហទំព័រ*

*http://www.skyscrapercity.com/showthread.php?t=1166805&page=3*



www.elibraryofcambodia.org

## ព្រះបុត្រា ទាំង២៨អង្គរបស់ព្រះបាទ នរោត្តម៖

1. នរោត្តម ហាសកណ្ឋ
2. នរោត្តម យុគន្ធរ
3. នរោត្តម ប៉ាក
4. នរោត្តម ផ័ត្តពង្ស
5. នរោត្តម ផ្សងចក្រ
6. នរោត្តម ហេមរា
7. នរោត្តម មករ៉ៃ
8. នរោត្តម មយូរ៉ា
9. នរោត្តម កេតសរ៉ា
10. នរោត្តម ព្រីយ
11. នរោត្តម សាឡាវ៉ៃ
12. នរោត្តម សុទ្ធារស
13. នរោត្តម កេតាជា
14. នរោត្តម ក្រៃសុង សាវីវង្ស
15. នរោត្តម ស័ក្តិសាវីវង្ស
16. នរោត្តម មតារី
17. នរោត្តម សុតាវង្ស
18. នរោត្តម សការីយ៉ាវង្ស
19. នរោត្តម រ៉ាយ៉ា
20. នរោត្តម ចន្ទាលក្ខណ៍
21. នរោត្តម សុកនបុត្រ
22. នរោត្តម ចម្រើនឫទ្ធិ
23. នរោត្តម ឧរ៉ាយ
24. នរោត្តម មយូរ៉េត
25. នរោត្តម រតនេត
26. នរោត្តម បថម៉ា
27. នរោត្តម ផ្សងសាមុន
28. នរោត្តម ផានុវង្ស

## ព្រះបុត្រីទាំង៣៤អង្គរបស់ព្រះបាទ នរោត្តម៖

1. នរោត្តម កម្ពុជាសូជាផ្សង
2. នរោត្តម ពង្សកម្ពុជា សូជារតនា
3. នរោត្តម ក្សងម៉ាលី
4. នរោត្តម កុសុម៉ា
5. នរោត្តម ភ័ក្តិ
6. នរោត្តម ច័ន្ទ្រកម្ពុជ
7. នរោត្តម លួងនួន
8. នរោត្តម កុយ
9. នរោត្តម អច្ឆន
10. នរោត្តម កវិនីកកេវ
11. នរោត្តម វណ្ណា
12. នរោត្តម ត្រាលូ
13. នរោត្តម ជ័យកន្ធា
14. នរោត្តម សុតាវតី
15. នរោត្តម សុម៉ាលី
16. នរោត្តម កញ្ញនារី
17. នរោត្តម សុម៉ាវតី
18. នរោត្តម ម៉ារី
19. នរោត្តម ប្រថម៉ាន
20. នរោត្តម ក្របាង
21. នរោត្តម ប្រាថមមេត
22. នរោត្តម យេផានី
23. នរោត្តម មល្លិកា
24. នរោត្តម ធរ៉ាំន់
25. នរោត្តម ឧម៉ា
26. នរោត្តម ស្រីសូម៉ា
27. នរោត្តម វិចរ៉ារតនា
28. នរោត្តម ផង៉ាង៉ាម
29. នរោត្តម នឹមនុងល័ក្សណ៍
30. នរោត្តម សុផាណា
31. នរោត្តម សុម៉ាម៉ាន
32. នរោត្តម ថាសួងសារីកាន
33. នរោត្តម ផ្លើមខ្វាន់
34. នរោត្តម ជាតិជីង

ប្រភព៖ http://whoincam.wordpress.com/2008/03/23/norodom/

ក្នុងចំណោមបុត្រទាំង២០អង្គរបស់ព្រះបាទ អង្គឌួង មានតែពីរ



www.elibraryofcambodia.org

អង្គគត់ ដែលបានឡើងគ្រងរាជ្យបន្តបន្ទាប់ពីព្រះអង្គគឺព្រះបាទ នរោត្តម និងព្រះបាទ ស៊ីសុវត្ថិ។

## ការសិក្សា

**មុន១៨៤៨៖** ព្រះអង្គម្ចាស់ នរោត្តម និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដែលជាព្រះជេដ្ឋានិងព្រះអនុជនឹងគ្នា (បិតាតែមួយតែមាតាទីទៃ) ត្រូវបានព្រះបិតាព្រះបាទអង្គឌួងបញ្ជូនទៅបួសរៀនសូត្រនៅរាជធានីបាងកក ខណៈដែលទ្រង់ទាំងពីរកំពុងបួសរៀននៅវត្តក្រាំងពន្លៃ ក្រុងឧដុង្គមានជ័យ។ នៅទីនោះជាលើកដំបូង ពួករាជវង្សសៀមបានចាត់ទុកព្រះអង្គម្ចាស់ទាំងពីរដូចជាមនុស្សល្ងង់ខ្លៅមិនសូវសំខាន់ ហើយឲ្យព្រះអង្គទាំងពីរបួសជាព្រះសង្ឃ និងរៀនសូត្រនៅវត្តបូវ៉ននីវេត (Bovorn Niwet) ក្នុងរាជធានីបាងកករហូតដល់ឆ្នាំ១៨៥៦[57]។ វត្តបូវ៉ននីវេតគឺជាវត្តដ៏សំខាន់មួយមានអាយុកាលចំណាស់ ដែលបច្ចុប្បន្នស្ថិតនៅក្នុងខណ្ឌប្រាណាខន (Phra Nakhon) ក្នុងរាជធានីបាងកក ហើយមានឈ្មោះពេញថា វត្តបូវ៉ននីវេត វីហារ៉ា រ៉ាចាវ៉ារ៉ាវីហារ៉ា (Wat Bowonniwet Vihara Rajavaravihara)។ វត្តនេះមានញាតិវង្សានុវង្សថៃជាច្រើនអង្គ ដោយរួមទាំងព្រះហាក្សត្រ ភូមិបុល អាដុលយ៉ាដេត (Bhumibol Adulyadej) ផងបានបួសរៀនសូត្រដែរ[58]។ កាលពីថ្ងៃទី២៦ វិច្ឆិកា ឆ្នាំ ២០១៤ ខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅដល់វត្តនោះ ដែលវត្តនោះ

[57] *http://www.royalark.net/Cambodia/camboa9.htm ឯកសារខ្មែរខ្លះសរសេរថា "វត្តបរមនិវេស" តែខ្ញុំ [អ្នកចងក្រងសៀវភៅ] សរសេរតាមសូរសៀងរបស់ប្រជាជនថៃ*

[58] *http://en.wikipedia.org/wiki/Wat_Bowonniwet_Vihara*



www.elibraryofcambodia.org

ត្រូវបានរដ្ឋាភិបាលថៃទុកធ្វើជាវត្តសម្រាប់ជាទីសក្ការៈ ហើយនៅក្នុងវត្ត មានព្រះពុទ្ធរូបលាបពណ៌មាសនិងជាំត្បូងចម្រុះពណ៌ ដែលប្រជាជនថៃ តែងតែមកបួងសួងនិងបន់ស្រន់តាមសេចក្ដីប្រាថ្នារៀងៗខ្លួន។



*ខ្ញុំ ឆាយ សុផល នៅក្នុងវិហារនៃវត្តប៉ូវនិវេត នៅថ្ងៃទី២៦ វិច្ឆិកា ២០១៤ ដែលនៅវត្តនោះ ប្រជាជនថៃចាត់ទុកជាបន់ស្រន់បានស័ក្ដិសិទ្ធិ។*



www.elibraryofcambodia.org



រូបលើ៖ ទិដ្ឋភាពខាងក្រៅខ្លោងទ្វារវត្តបូវ៉រនីវេត (Bovorn Niwet) គឺជាវត្តដែលព្រះបាទ នរោត្តម និងព្រះបាទ ស៊ីសុវត្ថិ ធ្លាប់បានបួសនិងរៀនសូត្រ (រូប ឆាយ សុផល)។
រូបពីរខាងក្រោម៖ ទិដ្ឋភាពនៅក្នុងវត្តបូវ៉រនីវេតនាថ្ងៃទី២៦ វិច្ឆិកា ២០១៤ (រូប ឆាយ សុផល )។







www.elibraryofcambodia.org

វត្តនេះ ស្ដេចសៀមព្រះនាម ជូឡាឡុងកន (Chulalongkorn) ឬព្រះបាទរាមាទី៥ ក៏បានបួសរៀនជាមួយព្រះបាទ នរោត្តម ដែរកាលពីនៅរាជកុមារ។ ស្ដេច ជូឡាឡុងកន (ប្រសូត៖ ១៨៥៣ - សោយទិវង្គត៖ ២៨ តុលា ១៩១០)។ ស្ដេច ជូឡាឡុងកន ជាសិស្សប្អូនរបស់ព្រះបាទ នរោត្តម គឺថា ស្ដេចជូឡាឡុងកន មានព្រះជន្មតិចជាងព្រះបាទ នរោត្តម ១៩ ព្រះវស្សា។ ទោះបីជាយ៉ាងនេះក្ដី ទាំងព្រះបាទ នរោត្តម និងព្រះបាទ ស៊ីសុវត្ថិ មានទំនាក់ទំនងយ៉ាងស្និទ្ធជាមួយនឹងស្ដេចសៀម ជូឡាឡុងកន និងសមាជិករាជវង្សានុវង្សសៀមច្រើនអង្គទៀតដែរ នៅក្នុងពេលដែលទ្រង់ទាំងពីរអង្គបានបួស និងរៀនសូត្រនៅឯវត្តបវរនីវេតនោះ។ ស្ដេច ជូឡាឡុងកន ជាមហាក្សត្រសៀម ដែលធ្វើកំណែទម្រង់យ៉ាងខ្លាំង ដោយពង្រឹងប្រព័ន្ធយុត្តិធម៌ តាមរយៈការប្រតិបត្តិនូវគោលការណ៍សីលធម៌ព្រះពុទ្ធសាសនា។ ពិសេសជាងនេះ ទ្រង់បានចេញរាជក្រឹត្យលុបចោលទម្លាប់ក្រាបក្បាលចុះ នៅពេលព្រះរាជាយាងកាត់ ដែលទ្រង់អះអាងថា ជាការមើលងាយដល់ភាពថ្លៃថ្នូររបស់មនុស្ស[59]។ ក្រោយមក ខ្មែរក៏ទទួលបានឥទ្ធិពលនេះដែរ។ ព្រះនាម ជូឡាឡុងកន ត្រូវបានថៃ/សៀមយកទៅដាក់ឈ្មោះសាកលវិទ្យាល័យនៅក្នុងរាជធានីបាងកកដែរ គឺ "សាកល



*ព្រះបរមរូបស្ដេចសៀម ស្ដេច ជូឡាឡុងកន ឬព្រះបាទរាមាទី៥ មុខវិមានរដ្ឋសភាជាតិថៃនាទីក្រុងបាងកក (រូប ឆាយ សុផល៖*

[59] *សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ និពន្ធដោយលោក David K. Wyat (ប្រែជាភាសាខ្មែរទំព័រ៖ ទំព័រ២២៨)*



www.elibraryofcambodia.org

វិទ្យាល័យជូឡាឡុងកន" ដែលខ្ញុំ [អ្នកចងក្រងសៀវភៅ] ក៏បានទៅសិក្សានៅទីនោះដែរកាលពីឆ្នាំ១៩៩៦។

**១៨៥៧៖** រាជបុត្រា នរោត្តម ដែលសៀមហៅថា ព្រះអង្គម្ចាស់ព្រហ្ម បុរីក្ស [អ្នករក្សាបុរី] នោះ បានចូលបម្រើទ័ពរបស់ព្រះរាជាសៀម ហើយក៏បានក្លាយជាទីប្រឹក្សាផ្នែកយោធា និងទទួលបានកិត្តិយសជាមេបញ្ជាការកងទ័ពដំរីស (Order of the White Elephant)។ ការផ្តល់ការសិក្សានិងកិត្តិយសដល់ទ្រង់ នរោត្តម នាពេលនោះ គឺព្រះរាជាសៀមមានបំណងចង់ឲ្យព្រះរាជាខ្មែរទុកចិត្តលើសៀម ហើយបានពង្រឹងចំណងទាក់ទងជាមួយនិងពួកសៀមផង[60]។

## រាជបល្ល័ង្ក និង រាជកិច្ច

ព្រះបាទ នរោត្តម ជាក្សត្រដែលត្រូវបានគេចាត់ទុកថា ជាព្រះរាជាក្នុងរជ្ជកាលខ្មែរដ៏ទំនើបដំបូងគេ បន្ទាប់ពីព្រះបិតាព្រះបាទ អង្គឌួង។ ទ្រង់ក៏ត្រូវគេផ្តល់កិត្តិយសថា ជាមហាក្សត្រជួយសង្គ្រោះប្រទេសកម្ពុជាពីការបែកបាក់កន្លងមក[61]។ នៅពេលព្រះអង្គប្រសូត ប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម។ នៅរជ្ជកាលនោះ រាជធានីខ្មែរគឺនៅឧដុង្គមានជ័យស្ថិតនៅក្បែរភ្នំឧដុង្គ (ភ្នំព្រះរាជទ្រព្យ ឬភ្នំអដ្ឋរស្ស) ប៉ុន្តែទីតាំងរដ្ឋបាលនៃការគ្រប់គ្រងដ៏សំខាន់ គឺស្ថិតនៅក្នុងក្រុងទេព [ក្រុងបាងកក] ប្រទេសសៀមឯណោះ។

---

*60 http://angkor1431.tripod.com/index/id14.html*

*61 http://en.wikipedia.org/wiki/Norodom_of_Cambodia*



www.elibraryofcambodia.org

**មិថុនា ១៨៥៨៖** សៀមបានអនុញ្ញាតឲ្យព្រះអង្គយាងចេញពីក្រុងទេព មកប្រទេសកម្ពុជាវិញ ហើយព្រះអង្គយាងមកតាមច្រកក្នុង"ខេត្តប្រាចិណបុរី" ដោយស្តេចសៀមបញ្ជាឲ្យមន្ត្រី និងទ័ពខ្មែរចំនួន ៥៣៣នាក់ចេញពីរាជធានីឧដុង្គ ព្រមទាំងមន្ត្រី និងទ័ពសៀមចំនួន ៦៧២នាក់ផង ដើម្បីយាងព្រះមហាក្សត្រខ្មែរថ្មីចេញពីក្រុងទេពមកកាន់រាជធានីឧដុង្គ[62]។


រូបបានពីបណ្ណាល័យជាតិ

**១៩ តុលា ១៨៦០៖** នៅពេលព្រះបាទ អង្គឌួង បានសោយព្រះសុវណ្ណគតនាថ្ងៃនោះ ព្រះអយ្យិកា [យាយ] របស់ព្រះអង្គម្ចាស់បានកោះប្រជុំក្រុមប្រឹក្សាមន្ត្រីធំៗ ដើម្បីជ្រើសតាំងអ្នកអង្គម្ចាស់ នរោត្តម ដែលជាព្រះរៀម និងជាព្រះឧបរាជផងឲ្យឡើងគ្រងរាជ្យបន្តតាមរាជបណ្តាំបិតា។ ទោះបីជាយ៉ាងនេះក្តី ព្រះអង្គនៅតែមិនបានពាក់មកុដគ្រងរាជ្យជាផ្លូវការដដែល ហើយនេះក៏ដោយសារតែក្រុមប្រឹក្សារាជវង្សសៀមមិនបានប្រគល់សម្លៀកបំពាក់ ឬឯកសណ្ឋានមហាក្សត្រខ្មែរមកឲ្យព្រះអង្គដោយទ្រង់បន្តធ្វើជាទីប្រឹក្សាព្រះមហាក្សត្រសៀមដដែល។ នៅក្នុងគ្រានោះ បើទោះជានៅមិនបានរៀបចំពិធីគ្រងរាជ្យជាផ្លូវការក៏ដោយ ក៏ព្រះបាទ នរោត្តម ត្រូវបានគេស្គាល់ថា ជាព្រះមហាក្សត្រខ្មែរដែរ។ បន្ទាប់ពី

---

[62] សៀវភៅ "រាជ្យពង្សាវតារនៃប្រទេសកម្ពុជា" (ទំព័រ១០៣) របស់ក្រសួងសិក្សាធិការឆ្នាំ១៩៥២



www.elibraryofcambodia.org

បានក្លាយជាមហាក្សត្រ ក៏ស្រាប់តែមានការបះបោរដ៏ធំមួយរបស់ពួកចាមមួយក្រុមបានផ្ទុះឡើងប្រឆាំងនឹងខ្មែរម្តងទៀត ដែលក្រុមនេះត្រូវបានព្រះបិតារបស់ទ្រង់បានបង្រ្កាបឲ្យស្ងប់ស្ងាត់លើកមុនរួចមកហើយ តែនៅមិនទាន់បានបង្រ្កាបឲ្យអស់ទាំងស្រុងនៅឡើយ មុនពេលព្រះអង្គសោយព្រះសុរិវណ្ណគត។ បន្ទាប់មក ក្រុមនោះក៏ត្រូវបានបង្រ្កាប ហើយបងប្អូនជនជាតិចាម បានរស់នៅដោយសុខសាន្តក្រោមព្រះរាជដឹកនាំរបស់មហាក្សត្រខ្មែរ។ មានវិហារចាមមួយត្រូវបានអនុញ្ញាតឲ្យសាងសង់នៅលើភ្នំឧដុង្គដែរនៅផ្នែកខាងត្បូង ហើយវិហារនេះស្ថិតនៅក្នុងបរិវេណវត្តព្រះធម្មកេរ្តិ៍របស់ព្រះពុទ្ធសាសនា។ សូមរម្លឹករឿងរ៉ាវមុននេះបន្តិចថា នៅឆ្នាំ១៦៤១ មានស្តេចមួយអង្គព្រះនាមថា ពញាចន្ទ ឬអង្គចន្ទទី១ បានឡើងគ្រងរាជ្យនៅក្រុងឧដុង្គដោយ "មានព្រះនាមល្បីថាកាចសាហាវ និងឆាប់ក្រេវក្រោធ។ ទ្រង់ស្រឡាញ់ក្រមុំចាមស្រស់ស្អាតម្នាក់ ហើយលើកនាងជាស្នំឯក។ ដោយហេតុនេះ ព្រះអង្គក៏ប្តូរទៅគោរពសាសនាអ៊ីស្លាមវិញ រួចយកព្រះនាមថា អ៊ីប្រាហ៊ីម។ ឯប្រជារាស្ត្រខ្មែរដែលជាពុទ្ធសាសនិកនោះក៏មានការអាក់អន់ចិត្ត ហើយហៅទ្រង់ថា ស្តេចរាមចូលសាសន៍"[63]។ ពញាចន្ទទី១ ដែលមាននាមថា ព្រះបាទរាជាធិបតីទី១ នោះគឺនៅពេលបានចូលសាសន៍អ៊ីស្លាមហើយ ទ្រង់ឲ្យគេ "កាត់ចុងអង្គជាតិ" របស់ទ្រង់ និងប្រកាសថា ជាអ្នកកាន់សាសនាអ៊ីស្លាម ហើយធ្វើអ្វីៗសព្វបែបយ៉ាងដើម្បីទាក់ទាញពួកចាម[64]។

---

[63] *សៀវភៅ៖ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់កម្មវិធីសិក្សាថ្នាក់មូលដ្ឋានឆ្នាំ ២០១២ (ទំព័រ ១៨៧-១៨៨)*

[64] *សៀវភៅ៖ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់កម្មវិធីសិក្សាថ្នាក់មូលដ្ឋានឆ្នាំ ២០១២ (ទំព័រ១៨៨)*



www.elibraryofcambodia.org







រូបពីរឆ្វេង៖ ព្រះបដិមានិងចេតិយព្រះពុទ្ធសាសនា នៅលើកំពូលភ្នំឧដុង្គផ្នែកខាងត្បូង។ (រូប ឆាយ សុផល៖ ១១ តុលា ឆ្នាំ២០១៤)

រូបក្រោម៖ វិហារឥស្លាមឈ្មោះ "វិហារព្រះអ៊ីម៉ុំសាន់" នៅលើកំពូលភ្នំឧដុង្គផ្នែកខាងត្បូង ស្ថិតក្នុងបរិវេណវត្ត "ព្រះធម្មកេរ្តិ៍" ព្រះពុទ្ធសាសនា (រូប ឆាយ សុផល៖ ១១ តុលា ឆ្នាំ២០១៤)

រូបស្តាំលើ៖ ក្រុមជនជាតិចាមនាជំនាន់មុននៅកម្ពុជា (រូបបណ្ណាល័យជាតិ)។

រូបស្តាំក្រោម៖ បុរសជនជាតិចាម (រូបបណ្ណាល័យជាតិ)





www.elibraryofcambodia.org

ក្រោយពីព្រះបាទ នរោត្តម បង្ក្រាបការបះបោរនោះរួចមក ក៏មានការស្ងប់ស្ងាត់ ហើយចាប់ពីពេលនោះមក ជនជាតិចាមភាគច្រើនដែលរស់នៅលើទឹកដីកម្ពុជាជាពលរដ្ឋស្លូតបូត ហើយបច្ចុប្បន្ន ពួកគេបានប្រកាន់យកសាសនាសន្តិភាពនិយមស្វែងរកនូវសេចក្ដីសុខ។ ជាច្រើនឆ្នាំមកនេះតំណាងរបស់ពួកគេបានទៅចូលរួមប្រកួតប្រជែងប្រចាំឆ្នាំយកពានរង្វាន់ Quran Reciters អន្តរជាតិ នៅទីក្រុងកូឡាឡាំពួរ (Kuala Lumpur) ប្រទេសម៉ាឡេស៊ី។ ជាងនេះទៅទៀត កូនចៅជនជាតិចាម (Chams) ប្រកាន់សាសនាមូស្លីម (Muslim) ក៏បានទៅរៀនសូត្រនៅបណ្ដាប្រទេសនៅអារ៉ាប់ក្នុងតំបន់មជ្ឈឹមបូព៌ាដែរ ហើយសហគមន៍របស់ពួកគេបានសាងសង់វិហារសាសនារបស់ខ្លួនជាច្រើនកន្លែងនៅក្នុងប្រទេសកម្ពុជា ដោយមានការគាំទ្រពីរដ្ឋាភិបាល និងប្រទេសអារ៉ាប់ លើកលែងតែសម័យខ្មែរក្រហមមួយគត់ ដែលបានកាប់សម្លាប់ជនជាតិមិនរើសមុខនិងបំផ្លាញចោលសាសនានានានៅទូទាំងនគរ។ ចំណែកឯជនជាតិចាមវិញ ពិសេសអ្នករស់នៅខេត្តកំពង់ចាម ត្រូវបានធ្វើទារុណកម្ម បង្ខំឲ្យបរិភោគសាច់ជ្រូក និងសម្លាប់ស្ទើរផុតពូជ។

**មករា ១៨៦២៖** ព្រះអង្គបានសម្រេចព្រះទ័យចាកចេញពីរាជធានីឧដុង្គ[65] រួចក៏ភៀសព្រះកាយទៅខេត្តបាត់ដំបង។

---

[65] ឯកសារមួយសរសេរថា នរោត្តម បោះបង់រាជធានីឧដុង្គចោលនៅមុនដាច់ឆ្នាំ១៨៦១ ហើយនិរទេសទៅសៀមនៅឆ្នាំ១៨៦២ (*http://angkor1431.tripod.com/index/id14.html*)



www.elibraryofcambodia.org



ព្រះបាទ នរោត្តម ទតការសម្តែងរបាំជាមួយភ្ញៀវនៅដំណាក់បាត់ដំបងនាឆ្នាំ ១៨៦៦
(រូបក្នុងគេហទំព័រ៖ http://www.earthinflower.com/gallery/3/med/4-5King_Norodom_and_Guests_Viewing_Kennari_Dance__July_1866.htm)



ព្រះរាជដំណាក់ស្ថិតនៅក្នុងសាលាខេត្តបាត់ដំបងដែលត្រូវបានជួសជុលឡើងវិញនាឆ្នាំ១៩៩០។ ព្រះបាទសម្តេច នរោត្តម សីហនុ បានយាងមកគង់ម្តងម្កាលនៅទីនេះក្រោយឆ្នាំ១៩៩៣ (រូប ឆាយ សុផល ៖ ៩ វិច្ឆិកា ២០១៤)។



www.elibraryofcambodia.org

បន្ទាប់មកទៀត ព្រះអង្គក៏បាននិរទេសព្រះកាយយាងទៅរាជធានីបាងកក ជាកន្លែងដែលព្រះអង្គគិតថា មានសុវត្ថិភាព ហើយម្យ៉ាងទៀត ការយាងចេញទៅនេះក៏ជាការស្នើពីសំណាក់មហាក្សត្រសៀមដែរ។ គួររម្លឹកថា ចាប់តាំងពីឆ្នាំ១៨០២មក ប្រទេសកម្ពុជា ស្ថិតនៅក្រោមប្រព័ន្ធសក្តិភូមិនិងការលូកដៃរួម និងប្រទាញប្រទង់គ្នារវាងមួយផ្នែកខាងសៀមនិងមួយផ្នែកខាងយួន។ ជាទូទៅ ព្រះមហាក្សត្រខ្មែរដែលបានឡើងសោយរាជ្យ គឺតែងតែមានវត្តមានតំណាងនៃអ្នកលូកដៃនៃប្រទេសទាំងពីរនោះ។ នៅពេលព្រះបាទ អង្គឌួង សោយព្រះសុវណ្ណគត ហើយព្រះបាទ នរោត្តម ឡើងគ្រងរាជ្យបន្តនោះ គឺរាជវង្សខ្មែរនៅចន្លោះឆ្នាំ ១៨៦០-១៨៦១ ស្ទើរតែរលាយ ដោយសារតែជម្លោះផ្ទៃក្នុងដើម្បីរាជបល្ល័ង្កផង ការលូកដៃពីសៀមនិងយួនផង និងបញ្ហាអាណានិគមបារាំងផង។ នៅពេលនោះ ប្រទេសត្រូវបានហែកហួរដោយសារពួកបះបោរ ដែលមានក្រុមអ្នកប្រកាន់ខាង នរោត្តម និងក្រុមអ្នកប្រកាន់ខាងស៊ីវត្ថា។ បន្ថែមពីលើនេះក៏មានក្រុមប្រឆាំងបារាំងផងដែរ និងមានក្រុមចោរព្រៃជាច្រើនក្រុមទៀតផង[66] ហើយក្រុមពួកចោរព្រៃទាំងនោះតែងតែបានលួចវាយឆ្មក់ធក់ប្លន់ប្រជារាស្ត្រនិងមន្ត្រីនៅពេលធ្វើដំណើរ។ ចំណែកឯព្រះអង្គម្ចាស់ ស៊ីសុវត្ថិ នាពេលនោះមិនបានធ្វើអ្វីដើម្បីបង្ហាញថា ទ្រង់ជួយព្រះបាទ នរោត្តម ឡើយ[67] ដែលធ្វើឲ្យព្រះបាទ នរោត្តម ទប់ទល់ស្ថានការណ៍មិនបាន ក៏សម្រេចបោះបង់ចោលរាជធានីឧដុង្គ

[66] *http://angkor1431.tripod.com/index/id14.html*

[67] *http://angkor1431.tripod.com/index/id14.html*



www.elibraryofcambodia.org

យាងទៅគង់នៅខេត្តបាត់ដំបង ហើយបន្ទាប់មក ក៏និរទេសព្រះកាយទៅគង់នៅរាជធានីបាងកកប្រទេសសៀម។

១៨៦៣៖ នៅឆ្នាំនោះ ដោយសារតែបារាំងជាប្រទេសមហាអំណាចនៅអឺរ៉ុប បានចាប់ផ្ដើមចូលក្នុងតំបន់ឥណ្ឌូចិន ដោយមានទាំងកម្ពុជាផងនោះ ព្រះរាជានិងក្រុមប្រឹក្សារាជបល្ល័ង្កសៀមនៅរាជធានីបាងកក ក៏សម្រេចព្រះទ័យព្រមប្រគល់គ្រឿងសម្រាប់រាជ្យថ្វាយជូនដល់ព្រះបាទនរោត្តម ដើម្បីឡើងអភិសេកគ្រប់គ្រងរាជបល្ល័ង្កខ្មែរជាផ្លូវការ ហើយពិធីអភិសេកឡើងគ្រងរាជ្យនោះក៏បានធ្វើឡើងនៅរាជធានីបាងកកក្នុងប្រាសាទ ឬ វត្តប្រាឈិធូផន (Wat Phra Chetuphon)[68] ឬ ហៅ វត្តផូ (Pho)។ ទោះបីជាយ៉ាងនេះក្ដី ពួកសៀមបានរក្សាទុកនូវគ្រឿងប្រដាប់គ្រងរាជ្យរបស់ខ្មែរនៅបាងកកដដែល ហើយអនុញ្ញាតឲ្យព្រះបាទសម្ដេចព្រះ នរោត្តម គង់នៅតែបាត់ដំបងប៉ុណ្ណោះ ដែលជាការងាយស្រួលដល់ពួកគេទាក់ទង។ គួររម្លឹកបន្តិចថា Wat Phra Chetupho [ឈ្មោះពេញ៖ Wat Phra Chetuphon Wimonmangkha-laram Ratcha-



*ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទសម្ដេចព្រះ នរោត្តម ឡើងគ្រងរាជបល្ល័ង្កជាផ្លូវការលើកដំបូងនៅទីក្រុងបាងកកនាឆ្នាំ ១៨៦៣។*

---

[68] http://www.royalark.net/Cambodia/camboa9.htm



www.elibraryofcambodia.org

worama-hawiharn] ជាវត្តដ៏ចំណាស់មួយនៅក្នុងរាជធានីបាងកកក្នុងរជ្ជកាលស្ដេចអាយុធ្យា ដែលពេលនោះ វត្តនេះមានឈ្មោះថា វត្តផូថារាម (Wat Photharam) ពោលគឺ វត្តនេះមានអាយុកាលចាស់ជាងរាជធានីបាងកកទៅទៀត[69]។ នៅឆ្នាំ១៨០១ក្នុងរជ្ជ កាលស្ដេចរាមាទី១ វត្តនេះត្រូវបានប្ដូរមកឈ្មោះ "វត្តប្រាឈីធូផន" តែជនជាតិថៃហៅថា វត្តផូ[70]។ ស្ដេចរាមាទី១ (១៧៨២-១៨០៩) ដែលថៃស្គាល់ថា ជាស្ដេច "ចក្រី" ឬ "រាមាធិបតី" ជាក្សត្រដែលគោរពនិងលើកតម្កើងព្រះពុទ្ធសាសនាយ៉ាងខ្លាំង ហើយ "នៅឆ្នាំ១៧៨៨-១៧៨៩ ព្រះអង្គក៏លើកទឹកចិត្តព្រះសង្ឃឲ្យបង្កើតគណកម្មការ ដើម្បីពិនិត្យនិងសរសេរអត្ថបទព្រះត្រៃបិដកជាភាសាបាលី ដែលជាគម្ពីរព្រះពុទ្ធសាសនាឲ្យរួចជាស្ថាពរ"[71]។ វត្តនេះត្រូវបានបំផ្លាញដោយពួកភូមាក្នុងសង្គ្រាមសៀម-ភូមានាឆ្នាំ១៧៦៧ តែក្រោយមកត្រូវបានស្ដេចរាមាទី៣ខំស្តារឡើងវិញនិងពង្រីកបរិវេណវត្តឲ្យកាន់តែធំ។ គួរបញ្ជាក់ថា កាលពីថ្ងៃទី២៦ វិច្ឆិកា ឆ្នាំ ២០១៤ ខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅដល់វត្តផូ ដោយវត្តនោះស្ថិតនៅក្បែរប្រាសាទព្រះកែវជាប់នឹងរាជវាំងថៃ។ វត្តផូជារមណីយដ្ឋានទេសចរណ៍ ដែលមានភ្ញៀវទេសចរណ៍អន្តរជាតិយ៉ាងច្រើនដោយមានលក់សំបុត្រសម្រាប់ចូលទស្សនា។

---

[69] http://www.thaiwebguide.com/bangkok/places/wat-pho/

[69] http://www.roughguides.com/destinations/asia/thailand/bangkok/ratanakosin/wat-pho-wat-phra-chetuphon/

[70] សៀវភៅ៖ ប្រវត្តិសាស្ត្រថៃនិពន្ធដោយលោក David K. Wyatt(ប្រែជាភាសាខ្មែរ៖ទំព័រ១៦១)



www.elibraryofcambodia.org



*រូបលើ៖ ព្រះបដិមាព្រះពុទ្ធដ៏ធំនៅក្នុងវិហារក្នុងវត្ត ប្រាឈឺធូផន (Wat Phra Chetuphon) ឬវត្តផូ នៅក្នុងរាជធានីបាងកក ជាវត្តដែលព្រះបាទសម្តេច នរោត្តម ត្រូវបានស្តេចសៀមរៀបចំឲ្យឡើងគ្រងរាជបល្ល័ង្កនាឆ្នាំ១៨៦៣ (រូប ឆាយ សុផល ៖ ២៦ វិច្ឆិកា ២០១៤)។ រូបក្រោមឆ្វេង៖ ខ្ញុំ ឆាយ សុផល ឈរនៅមុខវិហារក្នុងវត្តផូ នាថ្ងៃទី២៦ វិច្ឆិកា ២០១៤។ រូបក្រោមស្តាំ៖ ព្រះបរមរូបស្តេចរាមាទី១ ស្ថិតនៅក្នុងរាជធានីបាងកក។ រូបនេះស្ថិតនៅឆ្ងាយពីវត្តផូ (រូបថតដោយ ឆាយ សុផល ៖ ២៦ វិច្ឆិកា ២០១៤)។ ស្តេចរាមាទី១ជាអ្នកសាងសង់វត្តផូមុនគេ។*





www.elibraryofcambodia.org

ដើម្បីការពារពីការប៉ុនប៉ងលេបត្របាក់ទឹកដីពីសៀម និងយួន នៅឆ្នាំនោះ ព្រះបាទសម្តេចព្រះ នរោត្តម ក៏បានអនុញ្ញាតឲ្យបារាំងធ្វើជាប្រទេសអាណាព្យាបាលទាំងស្រុង ហើយ "នៅថ្ងៃទី១១ សីហា ១៨៦៣ ព្រះអង្គក៏បានឡាយព្រះហស្តលេខាលើកតិកាសញ្ញាដែលត្រូវទទួលយកបារាំងធ្វើជាអាណាព្យាបាល"[72]។ ទោះបីជាយ៉ាងនេះក្តី ព្រះអង្គបានលួចផ្ញើចុតហ្មាយ (រាជសារ) ជាច្រើនច្បាប់ឲ្យស្តេចសៀមព្រះនាម ព្រះបាទមង្គុដ ឬព្រះបាទរាមាទី៤ ដោយអះអាងថា ឧត្តមនាវិកបារាំង Pierre-Paul de La Grandière បានបង្ខំព្រះអង្គឲ្យឡាយព្រះហស្តលេខាពីការទទួលយកបារាំងធ្វើជាអាណាព្យាបាលនេះ តែ "ព្រះអង្គក៏បានលួចឡាយព្រះហត្ថលេខាជាសម្ងាត់ ដោយការទទួលស្គាល់អំណាចគ្រប់គ្រងរបស់ពួកសៀម" ដែរ[73]។ នៅពេលនោះ ពួកមន្ត្រីក្រោមឱវាទរបស់ព្រះបាទ នរោត្តម បានយល់ឃើញថា នេះជាល្បិចកលដ៏ឈ្លាសវៃមួយ ហើយពួកគេជឿជាក់ថា ល្បិចកលដ៏ប៉ិនប្រសប់នេះ គឺព្រះអង្គពិតជាអាចសង្គ្រោះប្រទេសឲ្យរួចផុតពីការវិនាសបាត់បង់ទៅសៀមនិងយួន។



ស្តេចមង្គុដ របស់សៀម (រូបចេញពីសៀវភៅ៖ ប្រវត្តិសាស្ត្រថៃ)

[72] http://en.wikipedia.org/wiki/French_Protectorate_of_Cambodia

[73] សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ (ប្រែជាភាសាខ្មែរ៖ ទំព័រ២១៤-២១៥)



www.elibraryofcambodia.org

ចំណែកឯបារាំងវិញ ខណៈដែលសៀមនិងយួនកំពុងជម្រុញឲ្យកម្ពុជាធ្លាក់ក្នុងអស្ថិរភាពផ្ទៃក្នុង ហើយបារាំងបានមើលឃើញថា កម្ពុជាមានសម្បត្តិធម្មជាតិនិងភោគផលកសិកម្មដ៏មហាសាល ដែលខ្លួនអាចទទួលបានផលចំណេញច្រើននោះ បារាំងក៏បានបង្ខំឲ្យព្រះបាទ នរោត្តម បានយាងត្រឡប់ពីបាត់ដំបងមករាជធានីឧដុង្គវិញនៅចុងឆ្នាំ១៨៦៣[74] ហើយបារាំងបានលើកទង់ជាតិរបស់ខ្លួននៅក្នុងរាជវាំងខ្មែរ។ យាងមកដល់រាជធានីឧដុង្គបារាំងបានឲ្យព្រះបាទនរោត្តម ឡាយព្រះហស្តលេខាលើកតិកាសញ្ញា ដែលចែងថា ព្រះមហាក្សត្រខ្មែរនៅតែបន្តគ្រងរាជបល្ល័ង្កដដែល តែអំណាចគ្រប់គ្រងរដ្ឋបាលភាគច្រើនគឺអាស្រ័យលើការចាត់ចែងរបស់លោក Pierre Paul de La Grandière ជាទេសាភិបាលបារាំងដែលស្នាក់នៅភ្នំពេញ ហើយទំនាក់ទំនងពាណិជ្ជកម្មនិងការបរទេសក៏ស្ថិតនៅក្រោមការចាត់ចែងរបស់បារាំងដែរ តែថា កម្ពុជាស្ថិតនៅក្នុងការការពារផ្នែកយោធាពីបារាំង។ ចំណែកឯសៀមវិញក៏បានទទួលស្គាល់កតិកាសញ្ញានេះដែរ "បន្ទាប់ពីបារាំងព្រមប្រគល់ខេត្តបាត់ដំបងឲ្យខ្លួនបន្តកាន់កាប់ និងទទួលស្គាល់ពីការដែលសៀមកំពុងគ្រប់គ្រងប្រាសាទអង្គរវត្ត"[75]ខ្មែរនោះ។

**៣ មិថុនា ១៨៦៤៖** បន្ទាប់ពីបានធ្វើជាអាណាព្យាបាលកម្ពុជាពេញលេញរួចមក បារាំងបានជួយសម្រួលឲ្យរៀបចំពិធីឡើងគ្រងរាជ្យរបស់ព្រះបាទ នរោត្តម ឡើងវិញនៅរាជធានីឧដុង្គ ដែលមានការចូលរួម

[74] ឯកសារមួយសរសេរថា ព្រះអង្គបានយាងមកឧដុង្គវិញនៅខែ មីនា ឆ្នាំ ១៨៦២ គឺ២ខែបន្ទាប់ពីការយាងចេញ

[75] http://en.wikipedia.org/wiki/French_Protectorate_of_Cambodia



www.elibraryofcambodia.org

ពីមន្ត្រីបារាំងដែលជាអ្នកត្រួតត្រា។ អ្វីជាការកត់សម្គាល់គឺថា មហាក្សត្រអង្គនេះបានគ្រងរាជ្យនៅពេលដែលប្រទេសស្ថិតក្នុងជម្លោះផ្ទៃក្នុង ដែលជាចំណុចដ៏ល្អសម្រាប់ពួកសៀមធ្វើការប្រទាញប្រទង់អំណាចពីបារាំង។ បន្ទាប់ពីសន្ធិសញ្ញាឆ្នាំ១៨៦៣ ដែលទទួលយកបារាំងជាអាណាព្យាបាល បារាំងនៅឆ្នាំ១៨៦៤នេះក៏ឲ្យព្រះបាទសម្តេចព្រះនរោត្តមឡាយលើអនុសញ្ញាមួយទៀតដើម្បីអនុវត្តការងារអាណានិគម ពោលគឺ កម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងទាំងស្រុង។ គួរបញ្ជាក់ថា ឯកសារមួយរបស់សង្គមរាស្ត្រនិយមសរសេរថា ព្រះបាទ នរោត្តម ទ្រង់ព្រមទទួលឲ្យបារាំងឋិតនៅក្នុងប្រទេសខ្មែរ តែក្នុងឋានៈជាភ្ញៀវគឺមិនមែនឲ្យនៅត្រួតពីលើ ហើយបង្គាប់បញ្ជាជាចៅហ្វាយនោះទេ តែថា "ព្រះបាទនរោត្តម បានសម្រេចតាមសន្ធិសញ្ញាពីឆ្នាំ១៨៦៣ និងអនុសញ្ញាឆ្នាំ១៨៦៤ ជាដើម ដោយសារតែព្រះអង្គត្រូវបានគេកំហែងបង្ខំ" ហើយថាវាជា "ការភាន់ច្រឡំធំបំផុត បើជឿថា ព្រះបាទ ព្រះនរោត្តម មិនបានការពារឯករាជ្យនៃប្រទេសខ្មែរ..."[76]។ នៅក្នុងឆ្នាំ១៨៦៤នោះដែរ ព្រះរាជានិងក្រុមប្រឹក្សារាជបល្ល័ង្កសៀមនៅឯរាជធានីបាងកក ក៏សុខចិត្តយល់ព្រមប្រគល់គ្រឿងសម្រាប់គ្រងរាជ្យថ្វាយជូនព្រះបាទ នរោត្តម។ ទោះបីជាយ៉ាងនេះក្តី ពីធីនេះបានធ្វើស្តេចមង្កុដ ឬរាមាទី៤ របស់ប្រទេសសៀមខ្វាល់នឹងព្រះបាទ នរោត្តម ដោយស្តេចមង្កុដគិតថា ព្រះបាទ នរោត្តមរមិលគុណ និងមិនមានភាពស្មោះត្រង់ចំពោះសៀម[77]។

---

[76] ព្រឹត្តិបត្រ៖ ព្រះរាជពិធីសម្ពោធមណ្ឌលដែលសង់ថ្វាយព្រះបរមរូបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមក្នុងព្រះសុវណ្ណកោដ្ឋ (៨-១១ វិច្ឆិកា ១៩៥៥) ទំព័រ២

[77] សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ (ប្រែជាភាសាខ្មែរ៖ ទំព័រ២១៥)



www.elibraryofcambodia.org



*ព្រះបរមរាជាភិសេកនៃព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម ព្រហ្មបរិក្សព្រះចៅព្រះរាជអាណាចក្រកម្ពុជានាថ្ងៃទី៣ មិថុនា ១៨៦៤ (រូបគំនូរ Royal Khmer Cremation Ceremony)*

**១៨៦៦៖** ដើម្បីជាការងាយស្រួលគ្រប់គ្រងខ្មែរហើយនៅក្បែរកម្ពុជាក្រោមផង បា រាំងបានបង្ខំឲ្យព្រះបាទ នរោត្តម បោះបង់ចោលរាជធានីឧដុង្គ ហើយយាងមកគង់នៅរាជធានីថ្មីគឺភ្នំពេញ ព្រោះភ្នំពេញមានទន្លេបតុមុខដែលងាយស្រួលក្នុងការដឹកជញ្ជូនទាំងផ្លូវទឹកនិងផ្លូវគោកទៅកម្ពុជាក្រោម។ ក្រោយពីយាងមកគង់នៅភ្នំពេញ ព្រះអង្គក៏បានឲ្យគេកែលម្អវត្តអារាមដែលមានពីមុនៗមក។ វត្តឧបតាយ៉ាងស្ថិតនៅខាងត្បូងរាជវាំងមិនមានកុដិ





www.elibraryofcambodia.org

សាលា និងវិហារទេ ហើយទ្រង់បានបង្គាប់មេការឲ្យជញ្ជូនឈើដែលជាព្រះរាជទ្រព្យនៅក្រុងឧដុង្គមានជ័យយកមកសាងសង់អគារសាសនាទាំងនោះនៅវត្តនេះ។ បន្ទាប់ពីកែលម្អរួច ទ្រង់ក៏ប្តូរឈ្មោះវត្តឧបតាយ៉ាងនេះថា "វត្តបទុមវតីរាជវរារាម" ប្រែថា "វត្តមានឈូកជារបងដែលជាអារាមដ៏ប្រសើររបស់ព្រះរាជា"[78]។ បច្ចុប្បន្ន អ្នករាជធានីភ្នំពេញនិងអ្នកខេត្តភាគច្រើនហៅវត្តនេះនូវឈ្មោះកាត់ខ្លីតែប៉ុណ្ណោះគឺ "វត្តបទុម" ឬអាចថា "វត្តបទុមវតី"។

**១៥ កក្កដា ១៨៦៧៖** បន្ទាប់ពីមួយផ្នែកធំរបស់ប្រទេសយួនត្រូវបានគ្រប់គ្រងដោយបារាំង បារាំងនៅថ្ងៃនោះក៏បានបង្ខំសៀមឲ្យប្រគល់ទឹកដីបាត់ដំបង និងសៀមរាបអង្គរដែលខ្លួនកំពុងតែគ្រប់គ្រងនោះមកឲ្យបារាំងកាន់កាប់ជាផ្លូវការតាមរយៈការចុះសន្ធិសញ្ញាមួយ។ ដោយមើលឃើញថា បារាំងជាប្រទេសមហាអំណាចយោធានិងមានអាវុធយុទ្ធោបករណ៍ទំនើបនៅអឺរ៉ុប ហើយធ្លាប់គ្រប់គ្រងផ្នែកខ្លះរបស់ សៀមដែរនោះ ព្រះរាជាសៀមក៏សុខព្រះទ័យធ្វើតាមសំណើបារាំង ដោយប្រគល់ទឹកដីខ្មែរមកឲ្យខ្មែរវិញក្រោមអាណាព្យាបាលបារាំង។ នៅឆ្នាំនោះដែរ បារាំងក៏បានឲ្យព្រះមហាក្សត្រព្រះបាទ នរោត្តម ឡាយព្រះហស្តលេខាស្តីពីការត្រួតត្រារបស់បារាំង មានន័យថា ជាការផ្ទេរអាណានិគមរបស់សៀមមកនៅក្រោមអាណានិគមបារាំងវិញ។ ចាប់ពីពេលនោះមក តំបន់ពាយ័ព្យនៃប្រទេសខ្មែរបានមកខ្មែរវិញ។ នៅក្នុងរជ្ជកាលនៃព្រះបាទ នរោត្តម ប្រសិនបើបារាំងមិនបានធ្វើជាអាណាអាព្យាបាល

---

[78] សៀវភៅ៖ ធម្មនុញ្ញជីវិត (ទំព័រ២៥-២៦)



www.elibraryofcambodia.org

របស់កម្ពុជាទេ នោះកម្ពុជាមិនអាចរួចផុតពីការគ្រប់គ្រងរបស់សៀមនិងយួនបានឡើយ។

**១៨៧២៖** សម្តេចព្រះបាទ នរោត្តម បានយាងទៅកោះហុងកុង ទីក្រុងម៉ានីលប្រទេសហ្វីលីពីន និងប្រទេសសិង្ហបូរី។ នៅទីក្រុងម៉ានីល ព្រះអង្គដែលជាព្រះមហាក្សត្រខ្មែរបានសព្វព្រះទ័យ នឹងជំនាញតន្ត្រីរបស់ជនជាតិហ្វីលីពីន ហើយបានសម្រេចព្រះទ័យនាំតន្ត្រីករហ្វីលីពីនមួយចំនួនមកប្រទេសកម្ពុជា ដើម្បីឲ្យពួកគេបង្រៀនតន្ត្រីសម័យទំនើបដល់កូនខ្មែរ។ ទឹកព្រះទ័យដ៏ទូលាយរបស់សម្តេចព្រះបាទ នរោត្តម បានចាប់ផ្តើមទាក់ទាញសិល្បករជនជាតិផ្សេងៗទៀតមកកាន់ប្រទេសកម្ពុជា ហើយពួកគេតែងតែត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅពីព្រះអង្គ និងក្រុមប្រឹក្សារាជបល្ល័ង្កនៅឯព្រះបរមរាជវាំង។ ពួកគេភាគច្រើនមានចំណាប់អារម្មណ៍នឹងរបាំព្រះរាជទ្រព្យ ដូច្នេះហើយពួកគេត្រូវបានផ្តល់ឱកាសបានរៀនតន្ត្រីនិងរបាំខ្មែរ។ នៅក្រោមរជ្ជកាលរបស់ព្រះអង្គ កងនាវាចរណ៍ភូមិន្ទខ្មែរត្រូវបានបង្កើតឡើងក្រោមការជ្រោមជ្រែងពីបារាំង ដើម្បីការពារទឹកដី។

**១៧ ឧសភា ១៨៨៤៖** អាជ្ញាបារាំងបានបង្ខំឲ្យព្រះមហាក្សត្រព្រះបាទ នរោត្តម ឡាយព្រះហស្តលេខាលើសន្ធិសញ្ញាមួយទៀតដោយឲ្យព្រះអង្គបោះបង់ចោលការគ្រប់គ្រងថវិការដ្ឋ ចំណូលពន្ធគយនិងកិច្ចការសាធារណៈជាច្រើនទៀត ហើយត្រូវផ្តល់សិទ្ធិនិងតួនាទីទាំងនេះទៅឲ្យមន្ត្រីបារាំងដែលមានវត្តមាននៅកម្ពុជាជាអ្នកទទួលរ៉ាប់រង។ នៅពេលនោះ ព្រះមហាក្សត្រព្រះបាទ នរោត្តម គ្មានជម្រើសក៏បង្ខំព្រះទ័យឡាយ



www.elibraryofcambodia.org

ព្រះហស្តលេខា ហើយទង្វើរបស់បារាំងនេះបានបញ្ឆេះកំហឹងប្រជាជននៅទូទាំងប្រទេស។ នៅឆ្នាំ១៨៨៤នេះ គឺអស់ពេលប្រមាណជាងពីរទសវត្សរ៍មកហើយដែលបារាំងបានគ្រប់គ្រងខ្មែរ ដោយរយៈពេលនេះបារាំងបានធ្វើកំណែទម្រង់លើកិច្ចការនយោបាយខ្លះរបស់ប្រទេសដូចជាកាត់បន្ថយអំណាចរបស់មហាក្សត្រ និងលុបបំបាត់ចោលអំពើទាសករ។ ជាងនេះទៅទៀតនៅឆ្នាំនេះ បារាំងបានបង្ខំព្រះអង្គឲ្យផ្លាស់ប្តូរការកាន់សាសនាពីសាសនាព្រះពុទ្ធទៅជាសាសនាគ្រិស្ត ដោយបារាំងបានបន្តព្យាយាមកែប្រែប្រពៃណីកម្ពុជាឲ្យទៅជាបែបបស្ចឹមប្រទេសទៀតផង។ បញ្ហានេះបានធ្វើឲ្យព្រះមហាក្សត្រព្រះបាទ នរោត្តម ជំទាស់យ៉ាងខ្លាំងនឹងលោក ហិនរី ហ្វេលិក្ស ឡាម៉ូដ (Henri Félix de Lamothe[79]) ទេសាភិបាលបារាំងប្រចាំកម្ពុជា និងលោក ឆាឡែស អាន់ថូនី ហ្វ្រង់ស្ថោចំសុន (Charles Anthoine François Thomson) ទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន។ កាលពីឆ្នាំនោះ លោក ឆាឡែស ទេសាភិបាលបារាំងប្រចាំឥណ្ឌូចិនបានចូលរួមផ្តួលព្រះរាជាខ្មែរ និងបង្កើតរបបមួយដែលជាចំណុះទាំងស្រុងដោយរួមទាំងប្រពៃណី និងសាសនាផង ដោយបារាំងបញ្ជូនកម្លាំងមួយក្រុមតូចចូលទៅរាជវាំងនៅក្នុងរាជធានីភ្នំពេញ។ ចលនានេះបានជោគជ័យតិចតួចដែរ តែដោយសារបារាំងមានការបារម្ភពីលទ្ធភាពដែលកើតមានជម្លោះជាមួយប្រជាជននិងព្រះរាជាខ្មែរ[80] ខ្លួនក៏បន្ធូរដៃខ្លះវិញ។ គួររម្លឹកថា ជនជាតិអឺរ៉ុបដែលមកទាក់ទងខ្មែរពីដំបូងគេ គឺបព្វជិតជាតិព័រទុយហ្គាល់មាននាមថា ហ្គាស់ស្ប៉ា ដា គ្រូស

[79] គ្រប់គ្រងប្រទេសកម្ពុជានៅចន្លោះថ្ងៃទី ២៦ តុលា ១៩០២ -១៦ ធ្នូ ១៩០៦ http://fr.wikipedia.org/wiki/Henri-F%C3%A9lix_de_Lamothe

[80] http://en.wikipedia.org/wiki/French_Protectorate_of_Cambodia



www.elibraryofcambodia.org

(Gaspar Da Gruz) ដែលមកដល់ក្រុងលង្វែកនាឆ្នាំ១៥៥៥ ក្នុងគោលបំណងផ្សព្វផ្សាយសាសនាគ្រិស្ត ហើយបើទោះជាព្រះរាជាបានទទួលស្វាគមន៍លោកដោយរាក់ទាក់ក៏ដោយ ក៏បំណងរបស់បព្វជិតរូបនេះមិនបានសម្រេចឡើយ ព្រោះប្រជានុរាស្ត្រខ្មែរនាសម័យនោះបានជឿយ៉ាងមុតមាំលើសាសនាព្រះពុទ្ធជាម្ចាស់។ បន្ទាប់ពីមិនបានជោគជ័យ បព្វជិតរូបនោះក៏បានធ្វើដំណើរទៅប្រទេសចិន[81]។ ក្រោយៗមក ក៏មានជនជាតិអេស្បាញ (ឆ្នាំ១៥៩៣) និងអង់គ្លេស (១៦១២) បានមកទាក់ទងមហាក្សត្រខ្មែរជាបន្តបន្ទាប់ ហើយទីបំផុត បារាំងក៏មានឱកាសសាបព្រោះសាសនាគ្រិស្តនៅស្រុកខ្មែរ។

**១៨៨៥៖** ព្រះអង្គម្ចាស់ ស៊ីវត្ថា ដែលជាព្រះអនុជ [ប្អូន] របស់ព្រះមហាក្សត្រព្រះបាទ នរោត្តម ដែលមានបិតាតែមួយតែមាតាទីទៃពីគ្នានោះ បានដឹកនាំធ្វើបដិវត្តន៍ប្រឆាំងការគ្រប់គ្រងរបស់បារាំង ហើយបារាំងបានសង្ស័យថា ព្រះមហាក្សត្រ នរោត្តម ជាអ្នកគាំទ្ររាល់សកម្មភាពរបស់ព្រះអង្គម្ចាស់ ស៊ីវត្ថា ហើយបារាំងបានបន្ទោសខ្លាំងៗដល់ព្រះបាទ នរោត្តម ថាជាអ្នកអុជអាលឲ្យមានបដិវត្តន៍នេះ។ ជាការពិត ព្រះមហាក្សត្រព្រះបាទ នរោត្តម ពិតជានៅពីក្រោយសកម្មភាពនោះមែន ព្រោះបារាំងបានធ្វើផ្ដុលហួសហេតុ ពិសេសរឿងគ្រប់គ្រងចំណូលចំណាយរបស់អាណាចក្រខ្មែរទាំងមូល តែក៏ជាព្រះទ័យរបស់ព្រះអង្គម្ចាស់ ស៊ីវត្ថា ដែរ ព្រោះទ្រង់មិនសូវពេញចិត្តនឹងអាណានិគមបារាំងផង ខណៈដែលទ្រង់ក៏ចង់បានរាជបល្ល័ង្កមកគ្រប់គ្រងទៀត។

[81] *សៀវភៅ៖ ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀមចាប់ពីទសវត្ស១៦ (ទំព័រ១២)*



www.elibraryofcambodia.org

ម្យ៉ាងវិញទៀត ការដែលទ្រង់ ស៊ីវត្ថា មិនពេញព្រះទ័យនឹងបារាំង ក៏ដោយសារតែនៅពេលព្រះបិតាព្រះបាទ អង្គឌួង បានសោយព្រះសុវណ្ណគតទៅ បារាំងជួយជ្រោមជ្រែងឲ្យព្រះជេដ្ឋា [បង] នរោត្តម ឡើងគ្រងរាជ្យស្របតាមបណ្តាំរបស់ព្រះបិតា។

យ៉ាងណាក្តី ក្នុងព្រះនាមជាព្រះជេដ្ឋា ព្រះបាទនរោត្តម បានបញ្ជាឲ្យរាជការសាងសង់ដំណាក់មួយនាទិសឦសាននៃព្រះរាជវាំងព្រះរាជទានដល់ព្រះអនុជ ស៊ីវត្ថា និងព្រះរាជទានប្រាក់មួយរយណែន និងគ្រឿងមាសសម្រាប់កិត្តិយស។ ទ្រង់ ស៊ីវត្ថា ក៏ទទួលព្រះរាជអំណោយទាំងនោះ ហើយបានរៀបចំដំណាក់គង់នៅជាមួយព្រះអនុជមួយអង្គទៀត គឺទ្រង់ សិរីវង្ស[82]។ ប៉ុន្តែ ទ្រង់ស៊ីវត្ថា មិនបោះបង់គំនិតចង់បានរាជបល្ល័ង្កនោះទេ។ នៅចន្លោះឆ្នាំ ១៨៨៥ - ១៨៨៦ មានការបះបោររបស់ទ្រង់ ស៊ីវត្ថា ហើយព្រះបាទនរោត្តម បានស្នើឲ្យបារាំងជួយបង្ក្រាបពួកបះបោរនេះ តែបារាំងមិនព្រមលុះត្រាណាព្រះបាទ នរោត្តម យល់ព្រមគោរពតាមនយោបាយនិងបញ្ជាមួយចំនួនរបស់បារាំង។ ដោយគ្មានជម្រើស ព្រោះអំណាចក្នុងរាជបល្ល័ង្កកំពុងស្ថិតនៅក្នុងស្ថានភាពផុយស្រួយពីការគំរាមកំហែងដណ្តើមយកពីពួក បះបោរដែលដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីវត្ថា នោះព្រះបាទនរោត្តម ក៏យល់ព្រមធ្វើតាមបារាំង។ ព្រះអង្គម្ចាស់ ស៊ីវត្ថា ត្រូវបានគេ


*កងទ័ពបារាំង (រូបពីបណ្ណាល័យជាតិ)*

---

[82] សៀវភៅៈ "មហាបុរសខ្មែរ-ព្រះរាជពង្សាវតារខ្មែរ" (ភាគ៧ទំព័រ២២) នៃអ្នកនិពន្ធ អេង ហួត



www.elibraryofcambodia.org

មើលឃើញថា ទ្រង់មិនពេញហឫទ័យនឹងការធ្វើអាណានិគមរបស់បារាំងនោះទេ ហើយទ្រង់ជាអ្នករិះគន់បារាំងមិនសំចៃដែរ។ នៅឆ្នាំ ១៨៨៥ ក្រុមវាយឆ្មក់មួយក្រុមដែលស្មោះត្រង់នឹងព្រះអង្គម្ចាស់ ស៊ីវត្ថា បានលបវាយប្រហារបន្ទាយទាហានបារាំងមួយកន្លែង ហើយចាប់ពីពេលនោះមក ការប្រឆាំងនឹងការគ្រប់គ្រងបារាំងក៏កើតមានកាន់តែច្រើន ប៉ុន្តែចលនានេះមិនបានជោគជ័យទេ[83] ដោយត្រូវបារាំងបង្ក្រាប។ ទោះបីជាយ៉ាងនេះក្តី ការបះបោររបស់ទ្រង់ ស៊ីវត្ថា ដែល "មានជំនួយពីកងទ័ពសៀម"[84]ផង គឺទំនងជាប្រឆាំងនឹងព្រះបាទ នរោត្តម ដើម្បីដណ្តើមរាជបល្ល័ង្ក ជាជាងដណ្តើមយកឯករាជ្យពីអាណានិគមបារាំង[85]។ នៅក្នុងចន្លោះឆ្នាំ១៨៨៥-១៨៨៦ បន្ទាប់ពីការខិតខំប្រឹងប្រែងរបស់ទ្រង់បានបរាជ័យជាបន្តបន្ទាប់ អ្នកគាំទ្ររបស់ទ្រង់ក៏ដូចជាម្ចាស់ជំនួយសៀមក៏បានបាត់បង់ការគាំទ្រ ដែលធ្វើឲ្យទ្រង់នៅឯកោ។ ទ្រង់ក៏បានព្យាយាមចរចាជាមួយបារាំង តែបារាំងមិនព្រម ហើយដោយមានសត្រូវជាមួយមហាក្សត្រជាព្រះជេដ្ឋារបស់ទ្រង់ផង និងជាមួយអាណានិគមបារាំងផង ខណៈដែលសៀមលែងគាំទ្រទៀត ទ្រង់ក៏បានរត់គេចព្រះកាយជាមួយអ្នកស្មោះត្រង់ពីរបីនាក់ទៅតំបន់ភាគខាងជើងជាប់ព្រំដែនលាវ។ ទីបំផុតព្រះអង្គម្ចាស់ ស៊ីវត្ថា បានសុគតនាថ្ងៃទី៣១ ធ្នូ ឆ្នាំ១៨៩១ នៅក្នុងព្រៃនាតំបន់ព្រំដែនខ្មែរ-ឡាវ ដោយធ្លាក់ព្រះកាយប្រឈួន គ្មានថ្នាំសង្កូវនិង

[83] http://nsd.007.free.fr/A/Arch_histo/Regions/Asie/Cambodge/Si_Votha.htm

[84] http://www.britannica.com/EBchecked/topic/542490/Si-Votha

[85] http://en.wikipedia.org/wiki/Si_Votha



www.elibraryofcambodia.org

ស្បៀងគ្រប់គ្រាន់[86]។ ព្រះអង្គមានតែបុត្រីមួយអង្គគត់គឺអ្នកអង្គម្ចាស់ អង្គឌួង រ័ត្នវត្ថា (Rath Votha)។ ទោះបីជាយ៉ាងនេះក្តី ព្រះនាមរបស់ព្រះអង្គម្ចាស់ ស៊ីវត្ថា ក៏ត្រូវបានគេយកមកដាក់ឈ្មោះផ្លូវមួយនៅក្នុងក្រុងសៀមរាបដែរ ដែលផ្លូវនោះមានឈ្មោះថា "វិថីស៊ីវត្ថា"។

**១៨៨៦៖** បន្ទាប់ពីបដិវត្តន៍អស់ពេលមួយឆ្នាំបានបញ្ចប់ បារាំងតាមរយៈ ព្រះមហាក្សត្រព្រះបាទ នរោត្តម បានអះអាងជូនដល់មន្ត្រី និងប្រជារាស្ត្រខ្មែរថា បារាំងនឹងផ្តល់សម្បទានខ្លះដល់ព្រះអង្គ។ បន្ទាប់ពីការស្តារឡើងវិញ ក្រោយពីបដិវត្តន៍នាឆ្នាំ នោះមក ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ នរោត្តម ក៏មានអំណាចខ្លះជាបណ្តោះអាសន្ន ហើយដើម្បីបង្ការមិនឲ្យមានបដិវត្តន៍ជាលើកទីពីរ បារាំងបានគិតថា ខ្លួននឹងមិនត្រូវបង្ខំឲ្យមហាក្សត្រខ្មែរទ័លច្រកផ្ទប់នឹងជញ្ជាំងទៀតឡើយ។

**១៨៨៧៖** ក្រោយពីសង្គ្រាមចិន-បារាំងនាចន្លោះឆ្នាំ១៨៨៤-១៨៨៥ បារាំងនៅឥណ្ឌូចិនបានបង្កើតទឹកដីអណ្ណាម តុងកឹង និងកូសាំងស៊ីនឲ្យក្លាយវៀតណាមដ៏ទំនើបមួយ និងព្រះរាជាណាចក្រកម្ពុជា។ នៅកម្ពុជានាពេលនោះ អ្វីៗគឺស្ថិតនៅក្រោមខ្សែញាក់របស់អាណាព្យាបាលបារាំង។ មុនព្រះអង្គសោយព្រះសុវណ្ណគត ព្រះបាទ នរោត្តម បានតែងតាំងរាជបុត្រាព្រះនាម យុគន្ធរ ឲ្យឡើងគ្រងរាជបល្ល័ង្កបន្តពីព្រះអង្គ

---

[86] *A Biography of Prince Si Votha: http://webcache.googleusercontent.com/search?q=cache:wuXaDzDkvsUJ:khmerization.blogspot.com/2008/01/biography-of-prince-si-votha-1841-1891.html+&cd=2&hl=en&ct=clnk&gl=kh*



www.elibraryofcambodia.org

ប៉ុន្តែបារាំងមិនយល់ព្រម ព្រោះព្រះអង្គម្ចាស់ យុគន្ធរ មិនមែនជាបុគ្គលដែលជាទីពេញចិត្តរបស់បារាំងឡើយ ហើយដោយសារតែការមិនពេញចិត្តនេះ ទើបព្រះអង្គម្ចាស់ យុគន្ធរ មិនដែលបានឡើងគ្រងរាជ្យម្តងណាទេ។ កាលពីឆ្នាំ១៨៦៦ បារាំងបានផ្លាស់រាជធានីឧដុង្គមកភ្នំពេញវិញ ហើយការផ្លាស់ប្តូរនេះ ព្រះបាទ នរោត្តម មិនអាចប្រកែកបានឡើយ។ បន្ទាប់មក បារាំងបានគាំទ្រព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដែលជាព្រះអានុជរបស់មហាក្សត្រ ព្រះបាទ នរោត្តម (បិតាតែមួយតែមាតាទីទៃ) ឲ្យឡើងសោយរាជ្យជំនួស។ នាពេលនោះ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ទ្រង់មានទំនោរទៅរកហ្វ្រង់កូហ្វីនី (Francophile) ឬអ្នកបារាំងនិយម។ កន្លងមក ទាំងព្រះបាទ នរោត្តម និងព្រះរាជបុត្រា យុគន្ធរ មិនសូវពេញព្រះទ័យនឹងការរបៀបគ្រប់គ្រងរបស់បារាំង ហើយទ្រង់តែងតែសួរនាំបារាំងពីបញ្ហាទឹកដីខ្មែរកម្ពុជាក្រោមដែលបារាំងបានដាក់បញ្ចូលក្នុងដែនដីកូសាំងស៊ីន។


នរោត្តម យុគន្ធរ


Jourdan ទេសាភិបាលបារាំងប្រចាំកម្ពុជា

**១៨៩២៖** នៅឆ្នាំនោះ ព្រះវិហារព្រះកែវមរកតត្រូវបានកសាងឡើង។ ព្រះបាទ នរោត្តម ត្រូវបានគេចងចាំ ហើយកោតសរសើរនិងពេញចិត្តពីស្នាព្រះហស្តរបស់ព្រះអង្គទាក់ទិននឹងសិល្បៈ។ នៅពេលដែលព្រះអង្គបានឡើងគ្រងរាជបល្ល័ង្ក របាំបុរាណបានស្តារតម្លៃរបស់ខ្លួន ហើយមិនយូរប៉ុន្មាន កិត្តិយស



www.elibraryofcambodia.org

ដ៏អស្ចារ្យក៏បានកើតមានឡើងក្នុងចំណោមឧត្តមមន្ត្រីនៃក្រុមប្រឹក្សារាជបល្ល័ង្ក និងសព្វនាហ្មឺនមន្ត្រីរហូតពួកគេបានគាំទ្រឲ្យមានសាលារបាំប្រចាំរាជវាំង ដើម្បីឲ្យកូនៗរបស់ខ្លួនបានចូលរៀន។ ក្នុងរជ្ជកាលរបស់ព្រះអង្គ កំណែទម្រង់រដ្ឋបាលនិងប្រព័ន្ធយុត្តិធម៌ត្រូវបានកែលម្អបន្ថែមពីលើព្រះបិតាព្រះបាទអង្គឌួង ដើម្បីជួយកាត់បន្ថយតម្លៃចំណាយលើរដ្ឋបាលនិងស្វែងរកយុត្តិធម៌ជូនរាស្ត្រ។ ព្រះអង្គបានលុបបោលនូវការធ្វើជំនួញផ្តាច់មុខ និងអំពើទាសករ ហើយរាស្ត្រក៏អាចបម្រើការនៅក្នុងព្រះរាជវាំងបានដែរ។ នៅក្នុងការគ្រប់គ្រងរបស់ព្រះអង្គ តម្លៃផលិតផលកសិកម្មមួយចំនួនដូចជា ស្លា ម្រេច និងស្ករបានកាត់បន្ថយ។ ទោះបីជាយ៉ាងនេះក្តី "បារាំងមិនបានអួតសរសើរពីព្រះអាកប្បកិរិយា និងនយោបាយរបស់ព្រះបាទសម្តេចព្រះ នរោត្តម ទេ" ដែលនេះជាភស្តុតាងមួយបង្ហាញថា បារាំងមិនចូលចិត្តព្រះអង្គឡើយ ព្រោះព្រះអង្គមិនបានអបអរសាទរ និងទទួលបារាំងដោយស្មោះស្ម័គ្រក្នុងការចូលមកជិះជាន់កម្ពុជានោះ[87]។ ម្យ៉ាងទៀត បារាំងបានដឹងថា ព្រះអង្គបានលួចផ្ញើរាជសារសម្ងាត់ទៅឲ្យស្តេចសៀមកាលពីមុនមក។


*ព្រះវិហារព្រះកែវមរកតសាងឡើងក្នុងរជ្ជកាលនៃការគ្រងរាជ្យរបស់ព្រះបាទ នរោត្តម។*

[87] *ព្រឹត្តិបត្រ៖ ព្រះរាជពិធីសម្ពោធមណ្ឌលដែលសង់ថ្វាយព្រះបរមរូបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមក្នុងព្រះសុវណ្ណកោដ្ឋ (៨-១១ វិច្ឆិកា ១៩៥៥) ទំព័រ២*



www.elibraryofcambodia.org



កន្លែងដោះដូរទំនិញមួយនៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញនាឆ្នាំ១៨៨៥ (រូបបណ្ណាល័យជាតិ)



ព្រះបរមរាជវាំងនារាជធានីភ្នំពេញ ក្រោមការគ្រប់គ្រងរបស់បារាំង (រូបពីបណ្ណាល័យជាតិ)។



ព្រះបរមរាជវាំង
នាឆ្នាំ១៩០០។

www.elibraryofcambodia.org



ក្រុមរបាំព្រះរាជទ្រព្យខ្មែរវ័យក្មេងប្រចាំព្រះបរមរាជវាំងនាឆ្នាំ១៩០០ ( រូបបណ្ណាល័យជាតិ )។



www.elibraryofcambodia.org

# គ្រឿងឥស្សរិយយស

- គ្រឿងឥស្សរិយយសថ្នាក់មហាសេនា កងពលកិត្តិយស (មេកងធំ ឆ្នាំ ១៨៦៩ - ១៨៧២)
- មេកងទ័ពសេះឆ្នាំ១៨៦៥ ពីប្រទេសបារាំង។
- គ្រឿងឥស្សរិយយសថ្នាក់មហាសេនាគជេន្ទ្រស ពីប្រទេសសៀម។
- គ្រឿងឥស្សរិយយសសេនាថ្នាក់មហាចក្រីពី ប្រទេសសៀម។



*ព្រះបរមឆាយាល័ក្ខណ៍ ព្រះបាទ នរោត្តម ពីរបីថ្ងៃមុនព្រះសុវណ្ណគត (១៩០៤)*

*រូបក្រោមត្រូវគេអះអាងថា ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទ នរោត្តម យាងកម្សាន្តហែហមដោយស្នំរបស់ព្រះអង្គ។ រូបក្នុងគេហទំព័រ*

*http://www.skyscrapercity.com/showthread.php?t=1166805&page=3*






www.elibraryofcambodia.org



*ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទសម្តេច នរោត្តម យាងចេញក្រៅដោយគង់ប្រថាប់លើព្រះទីនាំងអស្សតរ (រទេះសេះ) នៅក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ១៩០០។ រូបក្នុងគេហទំព័រ៖ http://www.pinterest.com/pin/463378249132528432/*

**២៤ មេសា ១៩០៤៖** ព្រះបាទ នរោត្តម បានសោយព្រះទិវង្គត ហើយព្រះបរមសពត្រូវបានបូជានៅឆ្នាំ១៩០៦។ នៅក្នុងព្រះរាជពិធីបុណ្យព្រះសពនោះមានការយាង និងទៅចូលរួមដោយព្រះអង្គម្ចាស់ ១១៦អង្គ ម្ចាស់ក្សត្រិយ៍និងស្ត្រីត្រកូលអភិជនចំនួន៦៦២អង្គ/នាក់ រដ្ឋមន្ត្រីនិងអភិជនចំនួន១.៣៧៩នាក់ អ្នករបាំ តន្ត្រីករនិងកវីចំនួនសរុប ២.១៧១នាក់ ដោយមានដំរីចំនួន២១ក្បាល។ ព្រះសពនៃសមាជិករាជវង្សពីរអង្គទៀតក៏បានបូជានានៅថ្ងៃនោះដែរ[88]។ ព្រះនាមរបស់ទ្រង់ត្រូវបានមន្ត្រីជំនាន់ក្រោយៗយកមកដាក់ឈ្មោះផ្លូវមួយនៅក្នុងរាជធានីភ្នំពេញ ដែលផ្លូវនោះមានឈ្មោះថា "មហាវិថីនរោត្តម"។ ព្រះនាមរបស់ព្រះអង្គក៏ត្រូវបានគេយកទៅដាក់ឈ្មោះសាលារៀនជាច្រើនទៀតនៅតាមបណ្តាខេត្តនានាទូទាំងប្រទេស៕

---

[88] *សៀវភៅ៖ FINALE – The Cremation of Norodom and Norodom Sihanouk, Kings of Cambodia (ឆ្នាំ២០១២-២០១៣) by Jim Mizerski (ទំព័រ១៨២)*



www.elibraryofcambodia.org



ព្រះបរមសពព្រះបាទ នរោត្តម ត្រូវបានតម្កល់ត្រៀមនឹងបូជា។ រូបដកស្រង់ពីគេហទំព័រ
http://www.asiafinest.com/forum/lofiversion/index.php/t124449.htm



រូបឆ្វេង៖ ព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះបាទ នរោត្តម។ រូបដកស្រង់ពីគេហទំព័រ http://www.asiafinest.com/forum/lofiversion/index.php/t124449.htm



រូបស្តាំ៖ ព្រះមហាចេតិយព្រះបាទសម្តេចព្រះ នរោត្តម នៅក្នុងព្រះមរោជវាំងក្នុងរាជធានីភ្នំពេញ (រូប ឆាយ សុផល៖ ៥ ធ្នូ ២០១៤)



www.elibraryofcambodia.org



ទូកដែលនាំព្រះអដ្ឋិព្រះបាទ នរោត្តម យាងទៅថ្វាយព្រះគង្គានៅទន្លេចតុមុខ ជាទម្លាប់របស់ព្រះមហាក្សត្រខ្មែរពីបុរាណ។ (រូបក្នុងសៀវភៅ៖ សារៈសំខាន់នៃក្បាច់លម្អរបស់ឧបករណ៍និងសំភារៈប្រើប្រាស់ក្នុងជីវភាពខ្មែរ)



www.elibraryofcambodia.org

# ព្រះបាទ ស៊ីសុវត្ថិ





www.elibraryofcambodia.org

## ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ

គ្រងរាជបល្ល័ង្កបាន២៣ព្រះវស្សា៖

២៤ មេសា ១៩០៤ - ៩ សីហា ១៩២៧

ព្រះអង្គបានគ្រងរាជ្យ បន្ទាប់ពីសម្តេចព្រះជេដ្ឋា [បង] មាតាទីទៃគឺព្រះមហាក្សត្រ ព្រះបាទ នរោត្តម ដែលសោយព្រះទិវង្គតនាថ្ងៃទី ២៤ មេសា ឆ្នាំ ១៩០៤ ប៉ុន្តែពិធីពាក់មកុដឡើងគ្រងរាជ្យជាផ្លូវការបានធ្វើឡើងនៅឯព្រះទីនាំងទេវាវិនិច្ឆ័យនៃប្រាសាទខេមរិន្ទ្រក្នុងព្រះបរមរាជវាំង រាជធានីភ្នំពេញនាថ្ងៃទី២៨ មេសា១៩០៦[89]។ ទ្រង់មាន "មាឌធំនិងសម្បុរណ៏សាច់ឈាមជាងស្តេចច្បង"[90]។

រាជអំណាចរបស់ព្រះបាទ ស៊ីសុវត្ថិ គ្រាន់តែជាម្លប់គង់ប្រថាប់លើរាជបល្ល័ង្កប៉ុណ្ណោះ ឯអំណាចពិតប្រាកដគឺលោកប្រឹក្សាភិបាលបារាំងដែលមានគេហដ្ឋាននៅជាបមាត់ទន្លេមុខវាំង[91]។ តាមពិត រាជបល្ល័ង្កនេះគឺត្រូវបានសម្តេចព្រះបាទ នរោត្តម ចង់ផ្ទេរទៅឲ្យរាជបុត្រា យុគន្ធរ ទេ តែបារាំងមិនព្រម ព្រោះព្រះអង្គម្ចាស់ យុគន្ធរ ដូចជាមិនសូវចុះសម្រុងនឹងបារាំង ហើយកន្លងមក បារាំងក៏មិនសូវពេញចិត្តនឹងព្រះបាទសម្តេច នរោត្តម ដែរពីរឿងការគ្រប់គ្រងសេដ្ឋកិច្ចនិងថវិកាជាតិដែលនាំឲ្យមានការធ្វើបដិវត្តន៍ប្រឆាំងបារាំងកន្លងមក។ មុនឡើងគ្រងរាជ្យ តាមលេចឮពាក្យចរចាមរាមគឺទ្រង់ "ដូចជាឆ្កួតឡប់ម្តងៗផង គឺមានយប់ខ្លះ លោកស្រាតខោអាវ លបរត់ចេញទៅក្រៅវាំងតែម្នាក់ឯង ទាល់តែពួកនាម៉ឺន

---

[89] http://www.royalark.net/Cambodia/camboa13.htm

[90] សៀវភៅ៖ សាក់មីនី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ២៦។

[91] http://www.gutenberg.org/files/27404/27404-h/27404-h.htm



www.elibraryofcambodia.org

ដេញតាមចាប់ប្រអូសប្រទាញ ទើបព្រមចូលមកវិញ។ លោកមានវ័យចំណាស់បន្តិចមែន ប៉ុន្តែកម្លាំងលោកនៅមាំមួនណាស់។ គេនិយាយប្រាប់ខ្ញុំថា ល្ងាចមួយនោះ មានបុរសម្នាក់កាន់ថ្មោងជំចូលមកអុកឡុកកូនចៅលោកដល់ក្នុងផ្ទៃវាំង លោកក៏ស្ទុះងើបឡើង ប្រៀតែខ្សៀអាកៀនប្រយុទ្ធជាមួយជននោះ វាយវាទាល់តែសន្លប់ ហើយបង្គាប់ឲ្យគេយកទៅកាត់កចោលភ្លាមមួយរំពេច"[92]។

**ប្រសូត៖** ៧ កញ្ញា ១៨៤០ នៅក្រុងទេពមហានគរ [ទីក្រុងបាងកក] ប្រទេសសៀម ខណៈដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងការគ្រប់គ្រងពីសំណាក់មួយផ្នែកដោយពួកសៀម និងមួយផ្នែកដោយពួកយួន តែព្រះរាជវង្សានុវង្សជាច្រើនសុខព្រះទ័យគង់នៅតំបន់ដែលសៀមកាន់កាប់ជាជាងគង់នៅតំបន់ដែលយួនគ្រប់គ្រង[93]។

**សោយព្រះទិវង្គត៖** ៩ សីហា ១៩២៧ ក្នុងព្រះជន្ម៨៧ព្រះវស្សា ដោយព្រះរោគថ្លាម[94] នៅឯព្រះបរមរាជវាំង រាជធានីភ្នំពេញ ហើយព្រះអង្គបានទទួលព្រះបច្ឆាមរណនាមថា "ព្រះរាជានុកោដ្ឋ"។

---

*[92] សៀវភៅ៖ សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ២៧។ សាក់ម៉ានី ជាឈ្មោះមេហសីទី១ របស់ស្តេចភូមាមួយអង្គ ដែលហ្លួងស៊ីសុវត្ថិ បានដាក់ឲ្យក្មេងស្រីអាយុ១២ឆ្នាំជាអ្នករាំបាំនៅក្នុងរាជវាំងនិងជាអ្នកបម្រើទ្រង់ (សៀវភៅ៖ អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៤២។ លោក Rolang MEYER ជាអ្នកសរសេរសៀវភៅនេះ។ លោកបានរស់នៅស្រុកខ្មែរក្នុងវគ្គកាលហ្លួងស៊ីសុវត្ថិ ដែលក្រោយមកបានក្លាយជាប្តីនាង សាក់មីនី ហើយក៏នាំគ្នាទៅរស់នៅស្រុកបារាំង។ សម្រាប់ខ្ញុំ ឆាយ សុផល អាចជឿខ្លះមិនជឿខ្លះ ព្រោះថា នៅក្នុងសៀវភៅនោះដែលជាប្រភេទសៀវភៅរឿងប្រលោមលោក គឺ Rolang MEYER បានរៀបរាប់អំពើល្អកាតច្រើនពីនាង សាក់ម៉ានី ដែលជាភរិយារបស់ខ្លួន។*

*[93] http://km.wikipedia.org/wiki/ស៊ីសុវត្ថិ*

*[94] សៀវភៅប្រវត្តិសាស្ត្រខ្មែរ (ទំព័រ៤១១)*



www.elibraryofcambodia.org

ក្នុងចំណោមបុត្រាបុត្រីទាំង២៩អង្គគឺមានតែមួយអង្គគត់ ដែលបានឡើងសោយរាជ្យ គឺព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស ហើយចាប់ពីព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មក គឺមានតែព្រះរាជជនត្តា [ចៅ] មួយអង្គគត់ដែលបានឡើងគ្រងរាជ្យ គឺព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ។ មហេសីព្រះបាទសម្តេច ស៊ីសុវត្ថិ រួមមាន[95]៖

១. នាង មុំ យាយនាម (Mom Yeay Niem) ជាកូនស្រីគ្រួសារសាមញ្ញសៀម (ស្លាប់នៅខែមករាឆ្នាំ ១៨៦៥ នៅសៀម)។

២. អ្នកម្នាង ពុយ (Puy)

៣. ម្ចាស់ក្សត្រិយ៍ ចង់កុលណី (Changkoloney) នៅភ្នំពេញក្នុងឆ្នាំ១៨៥៨ (ប្រសូតឆ្នាំ១៨៣៦)។ ក្រោយមកព្រះអង្គបានរៀបការជាមួយបុរសជនជាតិចិន។ ម្ចាស់ក្សត្រិយ៍ជាបុត្រីរបស់ព្រះមហាក្សត្រ អង្គដ៏ា ឌួង (Angga Duong) និងម្ចាស់ក្សត្រិយានី ជាម៉ា អច្ចារា (Dharma Acharya) ហៅ ប៉ែន ដែលជាកូនស្រីរបស់ឯកឧត្តម អាការាចា ស៊ូផាឌីបាទី (Akkaraja Suphadipati) រដ្ឋមន្ត្រីយុត្តិធម៌ជនជាតិសៀមកាត់ចិនកុកងឺ។ ម្ចាស់ក្សត្រិយ៍ ចង់កុលណី សុគតឆ្នាំ១៩០៦។

៤. ម្ចាស់ក្សត្រិយ៍ សាម៉រ (Samor) ប្រសូត៖ ១៨៣១ សុគត៖ ១៩១៥ ជាបុត្រីនៃម្ចាស់ក្សត្រិយានី រតនា ធីតាវ៉ារ៉ាមិក (Ratna Thida Varamik) និងសម្តេច Brhat Sri Jaya Jatha Maha Uparaja Imaya នៃប្រទេសសៀម។

៥. អ្នកម្នាង កែស (Kês)

៦. អ្នកម្នាង កេស (Kés) បងប្អូនបង្កើត អ្នកម្នាង កែស (Kês)

៧. ម្ចាស់ក្សត្រិយ៍ ធីតា ស្រីវរា អ៊ូ (Thida Sri Vora Ou) ជាបុត្រីទី៣នៃសម្តេចព្រះបាទ អង្គឌួង ជាមួយអ្នកម្នាង អ៊ុង (Ong)។ ម្ចាស់ក្សត្រិយ៍ ធីតា ប្រសូតឆ្នាំ ១៨៣០ និងសុគតឆ្នាំ ១៨៦៦ នៅបាត់ដំបង។

---

[95] *http://www.royalark.net/Cambodia/camboa13.htm*



www.elibraryofcambodia.org

៨. អ្នកម្នាង ខេន (Khain)។

៩. អ្នកម្នាងយេង(Yeng)។

១០. អ្នកម្នាង អ៊ីម (Im) ស្លាប់ឆ្នាំ១៩០៤ ជាកូនស្រីគ្រួសារចិនកុកងឺ

១១. អ្នកម្នាង វ៉ាន់ (Van) ស្លាប់នៅប្រាសាទខេមរិន្ទ្រ រាជធានីភ្នំពេញនៅថ្ងៃ១៥ កញ្ញា ១៩៣០ កូនស្រីគ្រួសារចិនកុកងឺ។



ស្នំឯករបស់ព្រះបាទស៊ីសុវត្ថិ (ប្រភពបណ្ណាល័យជាតិ)

១២. នាង សោមជីន (Somchin) ជាកូនស្រីគ្រួសារចិនកុកងឺ។

១៣. នាង ស្រគំ (Srakom) ជាកូនស្រីគ្រួសារសាមញ្ញ។

១៤. នាង កានដារ៉ា ពូសា ម៉ាកផួង (Kandara Puspa Mac Phuong) ជាកូនស្រីគ្រួសារចិនកុកងឺកាត់សៀម។

១៥. អ្នកម្នាង សម្រិត (Samrit)

១៦. នាង ម្លិស (Mlis) ជាកូនស្រីគ្រួសារចិនកុកងឺ។

១៧. អ្នកម្នាង ឡាញ់ឈី (Lanchi) ស្លាប់នៅឆ្នាំ១៩០៤។

១៨. អ្នកម្នាង ព្រីម (Prim) ជាកូនស្រីគ្រួសារចិនកុកងឺ។

១៩. អ្នកម្នាង មិត្ត (Mett) ជាបុត្រីរបស់លោក Buor និងម្ចាស់ក្សត្រិយ៍ បាម៉ាវីឡាទី (Bamavilati) ដែលជាបុត្រីរបស់ព្រះអង្គម្ចាស់ ហាស្សាការ៉ា (Hassakara)។

២០. អ្នកម្នាង សោម (Som) ជាបុត្រីទី៣របស់លោក បួរ (Buor) ផងដែល។ ក្រោយមក នាងក៏បានរៀបការជាមួយបុរសម្នាក់ទៀតឈ្មោះ ថ្លាង (Thlang) ជារាស្ត្រសាមញ្ញ)



www.elibraryofcambodia.org






រូបឆ្វេងលើនិងរូបស្ដាំ៖ ស្រីដែលគេអះអាងថាជាស្នំ របស់ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ (បណ្ណាល័យជាតិ)

រូបក្រោមពីឆ្វេង៖ ព្រះអង្គម្ចាស់ក្សត្រិយ៍សម្ពន្ធី បុត្រីច្បង និងបុត្រី២អង្គទៀតរបស់ព្រះបាទស៊ីសុវត្ថិ (រូបបណ្ណាល័យជាតិ)។







www.elibraryofcambodia.org

## ការសិក្សា

ព្រះអង្គបានសិក្សានៅឯរាជធានីបាងកក ដូចព្រះបាទសម្ដេចព្រះ នរោត្តម ដែរដែលជាព្រះជេដ្ឋារបស់ទ្រង់ ប៉ុន្តែព្រះអង្គមិនបានយាងមកប្រទេសវិញតាមសម្ដេចព្រះរៀមព្រះបាទ នរោត្តម ទេ គឺគង់នៅរាជធានីបាងកករហូតព្រះបិតាគឺព្រះបាទ អង្គឌួង សោយសុវណ្ណគតនាឆ្នាំ ១៨៦០ នៅរាជធានីឧដុង្គ។ ការយាងមករាជធានីឧដុង្គគឺធ្វើឡើងដោយភាពប្រញាប់ប្រញាល់ ព្រោះព្រះអង្គបង្ការមិនឲ្យព្រះអង្គម្ចាស់ ស៊ីវត្ថា ដែលជាព្រះអនុជ (ប្អូន) មានព្រះមាតាទីទៃអាចឆក់ឱកាសដណ្ដើមរាជសម្បត្តិ[96] ហើយប្រការនេះគឺព្រះអង្គបានសម្រេចដូចបំណង និងពេញព្រះទ័យឲ្យព្រះជេដ្ឋា នរោត្តម ដែលមានព្រះមាតាទីទៃពីគ្នាដែរនោះបានឡើងគ្រងរាជសម្បត្តិបន្តពីព្រះបិតា។

សូមរម្លឹកថា ព្រះអង្គម្ចាស់ ស៊ីវត្ថា ក៏ចង់បានរាជបល្ល័ង្កមកគ្រប់គ្រងដែរ ហើយទ្រង់តែងតែរកវិធីផ្ដួលព្រះជេដ្ឋា នរោត្តម ដែលមានមាតាទីទៃ ដើម្បីរាជតំណែងនេះ ប៉ុន្តែមិនបានជោគជ័យ ព្រោះព្រះអង្គម្ចាស់ នរោត្តម មានការគាំទ្រពីព្រះអនុជ ស៊ីសុវត្ថិ។ បន្ទាប់មក ទាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ និងមហាក្សត្រព្រះបាទ នរោត្តម បានបណ្ដេញព្រះអង្គម្ចាស់ ស៊ីវត្ថា ចេញពីរាជធានីឧដុង្គ តែព្រះអង្គម្ចាស់ ស៊ីវត្ថា ត្រូវបានពួកសៀមហៅឲ្យយាងទៅរាជធានីបាងកក ដែលនៅទីនោះ ទ្រង់បានបង្កើតចលនាបះបោរប្រឆាំងនឹងរាជបល្ល័ង្ក នរោត្តម[97]។ បន្ទាប់មក ព្រះអង្គម្ចាស់ ស៊ីវត្ថា បានវិលមកនគរវិញក្នុងបំណងប៉ុនប៉ងដណ្ដើមរាជ

---

[96] http://www.topix.com/forum/world/cambodia/T5JM169K6PJ5611N2

[97] http://www.britannica.com/EBchecked/topic/542490/Si-Votha



www.elibraryofcambodia.org

សម្បត្តិ ហើយជាការពិត ប្រសិនបើបារាំងមិនគាំទ្រអំណាចរបស់ព្រះមហាក្សត្រព្រះបាទ នរោត្តម នៅគ្រានោះទេ នោះព្រះអង្គម្ចាស់ ស៊ីវត្ថា ដែលមានការគាំទ្រពីសៀមផងនោះ ទំនងជាអាចដណ្ដើមយកអំណាចរាជបល្ល័ង្កបាន។

## រាជបល្ល័ង្ក និងរាជកិច្ច

នៅក្រោមរាជបល្ល័ង្ករបស់ព្រះបាទ ស៊ីសុវត្ថិ ក៏មិនខុសគ្នាពីព្រះបាទ នរោត្តម ប៉ុន្មានដែរ ពោលគឺ នគរបានស្ថិតនៅក្នុងកណ្ដាប់ដៃបារាំង តែខុសត្រង់ថា សៀមនិងយួនហាក់ដូចជាបន្ថយឥទ្ធិពលរបស់ខ្លួននៅអាណាចក្រកម្ពុជា។ "ចាប់តាំងពីពេលទើបនឹងឡើងសោយរាជ្យភ្លាមមកម្ល៉េះ ចិត្តគំនិតហ្លួងប្រែជាស្រពាប់ស្រពោន លងបន្លាចអារម្មណ៍លោកទាំងយប់ទាំងថ្ងៃ ទោះបីលោកខំសោយអាភៀនយ៉ាងណា ក៏ពុំអាចរំសាយអារម្មណ៍រវើរវាយផ្ដេសផ្ដាស់អស់នេះបានដែរ....។ លោកមិនមែនជាស្ដេចសោយរាជ្យទេ ប៉ុន្តែជាអ្នកទោស ដែលគេឃោមល្បាតជាប់ទាំងយប់ទាំងថ្ងៃយ៉ាងប្រយ័ត្នប្រយែងក្រៃលែង។ ក្នុងវាំងមិនដឹងថាមានគិញបារាំងប៉ុន្មាននាក់ទេ ពួកនោះយកលេសថា មកមើលត្រួតត្រាកិច្ចការក្នុងវាំង ប៉ុន្តែតាមពិតគឺគេមកឃ្លាំមើលហ្លួងនេះឯង។ លោកមហាមន្ត្រីប្រសប់លើកជើងបារាំងណាស់ដើម្បីការពារអំណាចគាត់ ហើយគាត់បានល្បួងលួងលោមទាល់តែហ្លួងសុខចិត្តលះបង់ឯករាជ្យ លះបង់ប្រទេសទាំងមូលឲ្យជនបរទេស ដើម្បីជាថ្នូរយករាជបល្ល័ង្កមកអង្គុយសោយរាជ្យត្រួតត្រាតែលើផ្ទៃវាំងមួយក្រវិចតូចប៉ុណ្ណោះ។....វាំងគឺគុកនៅកណ្ដាលទីក្រុង ជាលំនៅនៃមនុស្សខ្វាក់ដែលឥតមើលឃើញដល់



www.elibraryofcambodia.org

ទុក្ខវេទនានៃរាស្ត្រប្រជាដែលត្រូវគេជិះជាន់។ ហ្លួងខ្លួនឯងក៏ដឹងច្បាស់ថា លោកមានអំណាចធ្វើអ្វីបានតាមចិត្តតែនៅក្នុងវាំងនេះទេ។ ម្លោះហើយ ហ្លួងមិនដឹងធ្វើអ្វី មួយថ្ងៃៗគិតតែពីផ្ទុំ សោយអាភៀន សោយក្រយាជជែកលេង ហើយផ្ទុំទៀត...”[98]។ ព្រះអង្គមានព្រះរាជបន្ទូលលេងសើចជាមួយស្នំនិងអ្នកបម្រើពី "...រឿងដែលលោកទើបនឹងចេះលេងស្រីជាលើកដំបូង ដោយឆ្លៀតអួតថា ពេលកំពុងពេញកម្លាំង មួយយប់លោកអាចលេងស្រីដប់នាក់ក៏បានដែរ....[99]"។ ហ្លួងក៏តែងតែ "សោយអាភៀន ចាក់ម៉ាស៊ីនច្រៀងស្តាប់ សើចលេងជាមួយស្រីអ្នកគាល់បម្រើ។....ស្លៀកសារុងសំយេះហួសផ្ចិត....អាកប្បកិរិយាអាវ៉ាឫករបស់ខ្លួន" ក្នុងចំណោមស្រីស្នំនិងបាវបម្រើជនជាតិម៉ាឡាយូ (ម៉ាឡេស៊ី) ដែលជាបញ្ជាកប៉ាល់ឲ្យទ្រង់ នាពេលដំណើរយាងតាមកប៉ាល់ទៅខេត្តដំបងនិងសៀមរាបជាដើម[100]។ ចំណែកឯព្រះរាជបុត្រាខ្លះទៀតដូចជា អ្នកអង្គម្ចាស់ ឥស្សរាវង្ស អ្នកអង្គម្ចាស់ សូរីវង្ស និងអ្នកអង្គម្ចាស់ ចិន្តាវង្ស ជាដើមចូលចិត្តលេងស្រីនៅក្នុងរាជវាំង និងលើនាវាធ្វើដំណើរទៅប្រទេសបារាំងកប៉ាល់ សូម្បីតែទៅប្រទេសបារាំងជាមួយព្រះបិតា ក៏អ្នកអង្គម្ចាស់ ចិន្តាវង្ស មានបន្ទូលថា ព្រះរៀម សូរីវង្ស បានទៀនញទូលថាបានបារាំងក៏បាន "នាំទៅផ្ទះសំផឹងបារាំង"[101]ដែរ។

រហូតដល់មានពាក្យថា "ចំកួតហ្លួង" មានន័យថា "ស្តេចឆ្កួត"។

---

[98] សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៧២

[99] សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៧៣

[100] សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៧៥

[101] សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៥២ និង៦១



www.elibraryofcambodia.org

គួរបញ្ជាក់ថា ពាក្យ "ចំកួតហ្លួង" នេះក្រោយមក ពលរដ្ឋខ្មែរឲ្យតែខឹងគ្នា ច្រើនតែជេរៀល ឬប្រមាថគ្នាថា "អាចំកួតហ្លួង"។

ទោះបីជាយ៉ាងនេះក្តី ក្រុមសមាជិកខ្លះដែលការពារញាតិវង្សនិង រាជានិយមបានអះអាងថា ពួកអ្នកប្រឆាំងនឹងហ្លួង [ព្រះរាជា ឬស្តេច] និងរាជានិយមបានបង្កើតពាក្យប្រមាថនេះឡើង ដើម្បីធ្វើឲ្យព្រះរាជកិត្យានុភាពនិងឥទ្ធិពលរបស់ព្រះរាជាធ្លាក់ចុះ។ សមាជិកញាតិវង្សខ្លះ បានប្រាប់ខ្ញុំ [អ្នកចងក្រងសៀវភៅ] ថា ពួកគាត់ទទួលស្គាល់ថា ព្រះរាជាជំនាន់មុនៗពិតជាមានមហេសីនិងស្រីស្នំច្រើនមែន តែមិនអាសគ្រាមហួសហេតុដូចពាក្យលើកឡើងនោះទេ។ ជាការពិតមិនអាចប្រកែកបាន ព្រះបាទ ស៊ីសុវត្ថិ គឺជាហ្លួងខ្មែរដំបូងគេដែលបានធ្វើឲ្យសិល្បៈវប្បធម៌ខ្មែរចាប់ផ្តើមល្បីរន្ទឺនៅអឺរ៉ុប ហើយកម្ពុជាបានបើកទ្វារឈានទៅរកពិភពខាងក្រៅដ៏ទំនើបកាន់តែទូលំទូលាយជាងមុន។

នៅក្នុងរាជវាំងនារជ្ជកាលនោះ ស្រីបម្រើ និងស្រីរបាំ ពិសេសព្រះរាជបុត្រីរបស់ហ្លួងស៊ីសុវត្ថិព្រះនាម រ៉ែមធីតា អ្នកដឹកនាំក្រុមល្ខោននិងរបាំដ៏ល្បីឈ្មោះនោះក៏មានស្នេហាគ្នាដោយដេកអាក្រាតកាយឱបរឹតនិងជិះលើគ្នាដូចជាប្តីប្រពន្ធ ដោយអ្នកខ្លះដើរតួជាប្រុស ហើយអ្នកខ្លះទៀតម្តងធ្វើជាប្រុសម្តងធ្វើជាស្រីដេកប្រឡែងគ្នាជាគូសង្សារផ្តើលពេញវាំង ដែលចំណុចនេះបានចម្លងចេញពីប្រទេសសៀម ហើយប្រុសនៅទីក្រុងនាពេលនោះបានចំអកឲ្យស្រីៗនៅក្នុងរាជវាំង ហើយម្ចាស់ក្សត្រី រ៉ែមធីតា ចូលចិត្តជក់អាភៀន និងសោយក្រយាដូចព្រះបិតាដែរ[102]។

---

[102] *សាក់ម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ ២៦; ៩៦ និង៩៧*



www.elibraryofcambodia.org

**១៨៦០-១៨៦១៖** នៅចន្លោះឆ្នាំនេះ ខណៈដែលនគរស្ថិតក្នុងស្ថានភាពច្របូកច្របល់ ដោយសារតែជម្លោះផ្ទៃក្នុងដើម្បីរាជបល្ល័ង្កផង ការលូកដៃពីសៀមនិងយួនផង ពីសំណាក់អាណានិគមបារាំងផង និងពួកចោរព្រៃជាច្រើនក្រុមទៀត[103] បែរជាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ហាក់ដូចជាមិនបានធ្វើអ្វីដើម្បីបង្ហាញថា ទ្រង់ជួយ ព្រះបាទ នរោត្តម ឡើយ[104] ដែលធ្វើឲ្យព្រះបាទ នរោត្តម បោះបង់ចោលរាជធានីឧដុង្គ យាងទៅគង់នៅបាត់ដំបង ហើយបន្ទាប់មក ក៏និរទេសព្រះកាយយាងទៅគង់នៅរាជធានីបាងកក។

**១៨៦៤៖** នៅពេលនោះព្រះអង្គម្ចាស់ ស៊ីសុវត្ថិ បានព្រះពិរោធ [ខឹង] ហើយទ្រង់បាននិរទេសព្រះអង្គឯងដោយដំបូងយាងទៅសៀមតែក្រោយមកទៅសាយហ្គន (ក្រុងព្រៃនគរនៅកម្ពុជាក្រោម) ដែលជាអតីតដែនដីនៃអាណាចក្រខ្មែរ។ ការនិរទេសនេះទំនងជា ទ្រង់ចង់បង្ហាញការតវ៉ាប្រឆាំងនឹងបារាំងដែលបានបង្ខំព្រះបាទ នរោត្តម ឲ្យទទួលយកគំនាបមួយ ពិសេសការគ្រប់គ្រងផ្នែកសេដ្ឋកិច្ច។ នៅឆ្នាំនោះ បើទោះជាបារាំងបានច្បាំងឈ្នះសៀមក៏ដោយ ក៏បារាំងមិនកាន់កាប់ប្រទេសសៀមដែរ តែសៀមត្រូវប្រគល់ទឹកដីដែលខ្លួនឈ្លានពាន និងគ្រប់គ្រងមកឲ្យខ្មែរវិញ។ នាពេលនោះដែរ បារាំងបានគ្រប់គ្រងសាយហ្គន ហើយបានស្វែងរកព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដែលកំពុងគង់នៅទីនោះ ព្រោះបារាំងចង់បង្ហាញថា ខ្លួនមានបំណងការពារព្រះអង្គ ពោលគឺ សង្ខាររបស់ទ្រង់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយពួកបះបោរនៅកម្ពុជា។ តែការដាក់ស្ដែង

---

[103] *http://angkor1431.tripod.com/index/id14.html*

[104] *http://angkor1431.tripod.com/index/id14.html*



www.elibraryofcambodia.org

បារាំងចង់ស្វែងរកព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដើម្បីប្រើប្រាស់ព្រះអង្គជាកូនអុក សម្រាប់គំរាមកំហែងដល់ព្រះបាទ នរោត្តម ទៅវិញ ដោយហេតុថាប្រសិនបើព្រះបាទ នរោត្តម មិនយល់ព្រមតាមគោលនយោបាយរបស់បារាំងទេ នោះបារាំងទំនងជាអាចពិចារណាលើការគាំទ្រព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឲ្យឡើងសោយរាជ្យជំនួសព្រះបាទ នរោត្តម វិញ។ គួររម្លឹកថា ចាប់ពីសតវត្សរ៍ទី១៦ ដល់ដើមសតវត្សរ៍ទី២០ ព្រះរាជវង្សានុវង្សបានដើរតួយ៉ាងសំខាន់នៅក្នុងវិស័យរដ្ឋបាលសាធារណៈ ពិសេសនៅថ្នាក់រដ្ឋបាលកណ្តាលតែម្តង ហើយ "សមាជិកព្រះញាតិវង្សទាំងអស់សុទ្ធតែមានប្រាថ្នាឡើងគ្រងរាជសម្បត្តិ សូម្បីតែព្រះរាជាកំពុងគង់នៅលើរាជបល្ល័ង្កនៃអំណាចកណ្តាលជាធរមានក៏ដោយ"[105]។

**១៨៦៧៖** នៅឆ្នាំនោះ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ត្រូវបាន ព្រះជេដ្ឋា នរោត្តម ស្នើឲ្យយាងត្រឡប់មកប្រទេសវិញ ដើម្បីរួមគ្នាបង្ក្រាបពួកបះបោរ និងពួកចោរព្រៃ។ តបតាមព្រះរាជសំណើនេះ ព្រះអនុជ ស៊ីសុវត្ថិ ក៏បានយាងមកប្រទេសវិញ ហើយបានជួយកិច្ចការនេះដល់ព្រះជេដ្ឋា។

**១៨៦៦៖** នៅពេលបារាំងគ្រប់គ្រងប្រទេសឡាវ និងយួនបានដូចបំណងរួចមក ហើយអាជ្ញាធរបារាំងកាន់កាប់កម្ពុជាបានរឹងមាំហើយនោះ បារាំងនៅឆ្នាំនោះក៏បានបង្ខំឲ្យព្រះបាទសម្តេចព្រះ នរោត្តម ផ្លាស់ប្តូររាជធានីពី "ឧដុង្គ" មក "ភ្នំពេញ"។ ខណៈដែលព្រះអង្គម្ចាស់ ស៊ីសុវត្ថិ កំពុងគាំទ្របារាំងស្រាប់ ទ្រង់ក៏មិនបានប្រកែកពីការផ្លាស់ប្តូររាជ

---

*105 សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ - រដ្ឋបាលប្រទេសកម្ពុជានិងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៣៥*



www.elibraryofcambodia.org

ធានីនោះទេ ហើយ ដោយសារតែចំណុចនេះហើយ បារាំងកាន់តែពេញចិត្តនឹងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ថែមទៀត។

**៣ តុលា ១៨៩៣៖** ស្តេចសៀមបានឡាយព្រះហស្តលេខាលើកតិកាសញ្ញាបញ្ចប់សង្គ្រាមជាមួយបារាំង បន្ទាប់ពីខ្លួនបានទាល់ច្រកដោយសារប្រយុទ្ធគ្នាចាញ់បារាំង។ នៅក្នុងកតិកាសញ្ញានោះ បារាំងក៏បានបញ្ជាឲ្យពួកសៀមដកទាហានរបស់ខ្លួនចេញពីខេត្តបាត់ដំបង និងខេត្តសៀមរាបរបស់ប្រទេសកម្ពុជាផងដែរ ហើយឲ្យចេញចម្ងាយ២៥គីឡូម៉ែត្រពីត្រើយខាងលិចទន្លេមេគង្គ[106]។ បញ្ហានេះបានធ្វើឲ្យមហាក្សត្រខ្មែរពេញព្រះទ័យយ៉ាងខ្លាំង។ រឿងសំខាន់នៃកតិកាសញ្ញានោះ គឺបារាំងឲ្យសៀមផ្ទេរប្រទេសលាវដែលខ្លួនកំពុងគ្រប់គ្រងមកឲ្យបារាំងជាអ្នកត្រួតត្រាវិញ ព្រោះបារាំងចង់ពង្រីកអំណាចអាណានិគមរបស់ខ្លួននៅក្នុងតំបន់ឥណ្ឌូចិន។ គួររម្លឹកថា កាលពីថ្ងៃទី **១៣ កក្កដា** ឆ្នាំដដែលនេះ មានសង្គ្រាមបារាំង-សៀមមួយបានកើតឡើង បន្ទាប់ពីនាវារបស់បារាំងចំនួនបីគ្រឿងដែលបានបើកចេញពីមាត់ច្រកសមុទ្រប៉ាកណាម (Paknam) ដែលខ្មែរហៅថា "មាត់ពាម" ក្នុងខេត្តសមុទ្រប្រាកាន



*កាំភ្លើងធំទាហាននៅប៉មបន្ទាយស្យាមបាញ់សំដៅទៅនាវាបារាំង។ រូបគំនូរនៅគេហទំព័រ*
*http://en.wikipedia.org/wiki/Paknam_incident*

---

[106] *http://en.wikipedia.org/wiki/Franco-Siamese_War*



www.elibraryofcambodia.org

(Samut Prakan) ហើយចង់ឆ្លងចូលក្នុងទន្លេចៅប្រាយ៉ា (Chao Phraya River) ឆ្ពោះទៅរាជធានីបាងកក ដើម្បីជួបចរចាជាមួយពួកសៀមពីរឿងការផ្ទេរទឹកដីលាវដែលសៀមកំពុងតែគ្រប់គ្រងមកឲ្យបារាំងគ្រប់គ្រងវិញ។ ប៉ុន្តែនាវាទាំងនោះត្រូវបានពួកសៀម ពិសេសក្រុមទាហានសៀមដែលប្រចាំការនៅប៉មបន្ទាយក្នុងចំណុចច្រកសមុទ្រប៉ាកណាមនិងទន្លេចៅប្រាយ៉ា បដិសេធមិនអនុញ្ញាតឲ្យឆ្លងចូលទន្លេឡើយ។ សៀមបានព្រមានក្រុមនាវិកបារាំងមិនឲ្យចូល បើហ៊ានងនឹងមានបញ្ហា ព្រោះទាហានសៀមបានត្រៀមប្រយុទ្ធរួចរាល់បានល្អហើយ។ ដោយអាងខ្លួនជាប្រទេសមហាអំណាច ឯឧត្តមនាវីឯក រ៉ េ អាត់មីរ៉ាល អ៊ីតហ្គា ហ៊ូមាន់ (Rear Admiral Edgar Humann) មេបញ្ជាការកងនាវាបារាំងដែលមានបំពាក់អាវុធទំនើបៗនៅតែចចេស ដោយបើកនាវាឆ្លងរបារកាត់មុខប៉មបន្ទាយរបស់ទាហានសៀមនោះនៅពេលល្ងាច បន្ទាប់ពីព្រះអាទិត្យលិច។ មុនទាហានសៀមបាញ់សំដៅលើនាវា ពួកគេក៏បានបាញ់ព្រមានបីបួនគ្រាប់ចូលក្នុងទឹកដែរ ដែលជាសញ្ញាថា កុំឲ្យនាវាបារាំងបន្តទៅមុខទៀត។ ដោយសារតែនាវាបារាំងបន្តទៅមុខ ហើយយប់នោះមានភ្លៀងធ្លាក់ផង កងទាហានសៀម ដែលបញ្ជាដោយលោក ប្រាយ៉ា ឆនឡាយុទ្ធយ៉ូធីន (Phraya Chonlayutyothin) ក៏បានបាញ់សំដៅទៅនាវាបារាំងដែលធ្វើឲ្យនាវាពីរគ្រឿងក្នុងចំណោមបីបានឆេះខូចខាត ហើយទំនិញដែលបារាំងនាំមកធ្វើអាជីវកម្មនោះត្រូវបានលិចអស់ចូលក្នុងទឹកទន្លេ[107]។ ពេលព្រឹកឡើង សៀមបានចាប់បុគ្គលិកនាវាបារាំងហើយយកទៅដាក់គុកនៅបាងកក ចំណែកឯឧត្តមនាវីឯក រ៉េ អាត់មីរ៉ាល

[107] http://en.wikipedia.org/wiki/Paknam_incident



www.elibraryofcambodia.org

បានដកថយតាមទូកមួយគ្រឿងសំដៅទៅសមុទ្រប៉ាកណាមវិញ ដែលនៅទីនោះ នាវាប្រយុទ្ធរបស់បារាំងឈ្មោះ ហ្វតហ្វេត (Forfait) បំពាក់ដោយកាំភ្លើងទំនើបៗក៏បានមកដល់ដែរ។ ការប្រយុទ្ធគ្នានេះបានធ្វើឲ្យទាហានបារាំង៣នាក់ស្លាប់ និង២នាក់ទៀតរងរបួស ខណៈទាហានសៀម១០នាក់ស្លាប់និង១២នាក់រងរបួស។ ពេលនាវាប្រយុទ្ធ ហ្វតហ្វេតមកដល់ក៏បានបាញ់សន្ធាប់ទៅលើទាហានសៀម ហើយដោយសារតែនាវានេះមានអាវុធទំនើបៗ ទាហានសៀមក៏បានបរាជ័យ ដែលធ្វើឲ្យនាវាបារាំងបើកចូលតាមទន្លេចៅប្រាយ៉ាឆ្ពោះទៅបាងកកបានដូចបំណង។ នៅពេលលោកឧត្តមនាវីឯក រ៉េ អាត់មីរ៉ល បានទៅដល់បាងកកនៅថ្ងៃទី២២ កក្កដា លោកបានបញ្ជាឲ្យនាវាបិទផ្លូវទឹកក្នុងច្រកសមុទ្រប៉ាក់ណាមមិនឲ្យមានទំនិញ និងអ្នកដំណើរចេញចូលបាងកកឡើយ សូម្បីតែនាវាអង់គ្លេសក៏មិនអាចចូលបានផង ហើយនាវាបារាំងបានតម្រង់កាំភ្លើងផ្ដោងសំដៅទៅរាជវាំងសៀម។ ដោយមិនអាចទប់នឹងស្ថានការណ៍បាន ខណៈដែលមិនអាចស្វែងរកការគាំទ្រពីអង់គ្លេសបានទេ



*នាវាប្រយុទ្ធForfaitបារាំងមកដល់ច្រកសមុទ្រប៉ាក់ណាមបាញ់សន្ធាប់ទៅលើទាហានសៀម។ រូបគំនូរនៅគេហទំព័រ*
*http://en.wikipedia.org/wiki/Paknam_incident*

ស្ដេចសៀមក៏បានបង្ខំព្រះទ័យឡាយព្រះហស្ដលេខាលើកតិកាសញ្ញាទៅតាមសំណើរបស់បារាំងនៅថ្ងៃទី៣ តុលា ឆ្នាំនោះទៅ។ នៅក្នុងកតិកា



www.elibraryofcambodia.org

សញ្ញានោះ បារាំងក៏បានឲ្យសៀមសងថ្លៃខូចខាតចំនួន២លានហ្វ្រង់ ចំពោះថ្លៃខូចខាតពីការវាយប្រហារគ្នានៅមាត់សមុទ្រប៉ាកណាម។ ជាង នោះទៅទៀត ប្រទេសបារាំងបានឲ្យសៀមបំពេញលក្ខខណ្ឌ ដោយទាម ទារពីការធានាឲ្យបារាំងនៅកាន់កាប់ជាបណ្ដោះអាសន្នក្នុងខេត្តចន្ទបុរី (Chantaburi) របស់សៀម ហើយសៀមក៏បានយល់ព្រមទៀត។

**២៤ មេសា ១៩០៤៖** នៅថ្ងៃនោះ ក្រោយពីព្រះមហាក្សត្រព្រះ បាទ នរោត្តម បានសោយព្រះសុវណ្ណគតទៅ បារាំងក៏បានបង្ខំឲ្យក្រុម ប្រឹក្សារាជបល្ល័ង្កខ្មែរថ្វាយរាជសម្បត្តិជូនព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជាជាង ថ្វាយជូនព្រះអង្គម្ចាស់ យុគន្ធរ ដែលជាបុត្រារបស់ព្រះបាទ នរោត្តម។ បើទោះជាព្រះបាទ នរោត្តម បានគិតទុកថា ក្រោយពេលព្រះអង្គសោយ ព្រះសុវណ្ណគតទៅ រាជបល្ល័ង្កត្រូវថ្វាយជូនព្រះរាជបុត្រាគឺព្រះអង្គម្ចាស់ យុគន្ធរ ក៏ដោយ ក៏បារាំងមិនខ្វល់ដែរ ព្រោះរវាងព្រះអង្គម្ចាស់ យុគន្ធរ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មើលទៅមានស្វាមី ភក្តិចំពោះបារាំងជាងព្រះអង្គម្ចាស់ យុគន្ធរ។ នៅថ្ងៃនោះ ក្រុមប្រឹក្សារាជ សម្បត្តិខ្មែរបានជួបប្រជុំគ្នាដោយមានសមាសភាពមន្ត្រី និងវីរជនជា ច្រើននាក់នៃប្រទេសដើម្បីជ្រើសតាំងព្រះមហាក្សត្រថ្មី។ ដោយមាន គំនាបពីបារាំង ក្រុមប្រឹក្សារាជសម្បត្តិបានសម្រេចជ្រើសតាំងសម្ដេច ឧបរាជព្រះ ស៊ីសុវត្ថិ ដែលទីបំផុត ព្រះអង្គបានគ្រងរាជសម្បត្តិ ហើយ ក្លាយជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយពីបានគ្រង រាជសម្បត្តិ ព្រះបាទ ស៊ីសុវត្ថិ ស្ដេចទ្រង់បន្តព្រះរាជកិច្ចតាមលំអាននៃ ព្រះបាទ នរោត្តម។ ព្រះអង្គបានបន្តផ្គាប់ផ្គុនបារាំង ដោយមានទំនាក់ ទំនងយ៉ាងពិសេសជាមួយពួកបារាំង ហើយបារាំងបានសាងសង់ព្រះរាជ



www.elibraryofcambodia.org



*ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ យាងចេញក្រៅប្រាសាទក្នុងអំឡុងពេលព្រះរាជពិធីឡើងគ្រងរាជ្យនាឆ្នាំ១៩០៤។ រូបដកស្រង់ចេញពីគេហទំព័រ*
*http://cambodiaphilately.blogspot.com/2012_01_01_archive.html*



www.elibraryofcambodia.org

ដំណាក់ថ្មីៗ និងផ្តល់អំណោយនាវាដែលដើរដោយចំហាយទឹក និងការផ្គត់ផ្គង់អាភៀនទម្ងន់២៥០ផោន (ប្រហែលជាង១១៣គីឡូក្រាម) ក្នុងមួយឆ្នាំៗ[108]។ ជាងនេះទៅទៀត រាល់ការចំណាយផ្សេងៗនៅក្នុងរាជវាំង និងលើរាជកិច្ចផ្សេងៗទៀតក៏បារាំងជាអ្នកទទួលរ៉ាប់រងដែរ។

ឯកសារមួយ[109]បានសរសេរថា៖

*"នៅឆ្នាំ១៨៦៣ដែលព្រះបាទនរោត្តមបានឡាយព្រះហស្តលេខាទទួលស្គាល់អាណាព្យាបាលបារាំងមកលើកម្ពុជាដើម្បីការពារទឹកដីនោះ ព្រះអង្គនៅមានសិទ្ធិអំណាចពេញដៃ។ ប៉ុន្តែនៅពេលដែលព្រះបាទ ស៊ីសុវត្ថិ ឡើងសោយរាជ្យនោះ ព្រះអង្គគឺគ្រាន់តែជានិមិត្តរូបតែប៉ុណ្ណោះ។ សូម្បីតែថវិកាចំណាយរបស់ព្រះអង្គសម្រាប់រាជវាំង និងកិច្ចការទាំងអស់ក៏ត្រូវបានបារាំងគ្រប់គ្រងដែរ។ ប្រវត្តិវិទូបារាំង អាឡាំង ហ្វរ៉េសត៍ (Alain Forest) បានសរសេរថា បើគិតលើចំនួនទឹកប្រាក់ក្នុងកញ្ចប់ថវិការបស់ព្រះបាទស៊ីសុវត្ថិ គឺច្រើនជាងព្រះបាទនរោត្តម តែតាមការពិតគឺតិចជាង ដោយព្រះអង្គត្រូវចំណាយឲ្យទៅពួកមន្ត្រី និងញាតិវង្សព្រះអង្គ ព្រោះបារាំងបានកាត់បន្ថយប្រាក់ខែរបស់ពួកគេ។ នៅក្នុងបញ្ជីកញ្ចប់ថវិកានៅឆ្នាំ១៩០៦ របស់ ព្រះបាទ ស៊ីសុវត្ថិ ដែលរាល់ចំណាយនិងចំណូលត្រូវបានកត់ត្រាយ៉ាងប្រុងប្រយ័ត្ន ដោយមន្ត្រីអាណានិគមបារាំង ហើយមានជំនួយពីក្រុមការខ្មែរដែលបានបញ្ជាក់ថា ការចំណាយនោះរួមមានការឧបត្ថម្ភដល់សមាជិករាជវង្សមុន (សមាជិករបស់ព្រះបាទ នរោត្តម) និងបច្ចុប្បន្ន (សមាជិករបស់ព្រះអង្គផ្ទាល់) ការបង់ថ្លៃសិក្សារបស់ព្រះអង្គម្ចាស់ និងកូនរបស់ឥស្សរជនខ្មែរជាច្រើននៅស្រុកបារាំងឬនៅសាយហ្គន។*

---

[108] *Norman G. Owen, The Emergence of Modern Southeast Asia, p. 363 ( http://en.wikipedia.org/wiki/Sisowath_of_Cambodia )*

[109] *The Cambodia Daily លេខពិសេសក្នុងឱកាសចម្រើនព្រះជន្មព្រះករុណា នរោត្តម សីហនុ ( ១៤-១៥ ឧសភា ២០១១ )៖ http://tamabloveyaymab.wordpress.com/2011/05/16/a-legacy-of-a-king/*



www.elibraryofcambodia.org

នៅឆ្នាំ ១៩២៧ ព្រះបាទ ស៊ីសុវត្ថិ បានយាងទៅស្រុកបារាំងជាមួយនឹងរាជបរិពារ [បរិវារ] ៦០នាក់ ដើម្បីទៅចូលរួមការតាំងពិពណ៌របស់អាណានិគមនៅឯទីក្រុង ម៉ាសីយ៍ (Marseille) ដែលចំណាយត្រូវបានចេញរួមគ្នាដោយអាជ្ញាធរអាណានិគមបារាំងនិងខ្មែរ ដែលគេយល់ថា នេះជាការផ្សព្វផ្សាយព័ត៌មានយ៉ាងល្អមួយសម្រាប់សកម្មភាពរបស់ពួកគេនៅឯឥណ្ឌូចិន។ ព្រះរាជទស្សនកិច្ចនេះគ្រាន់តែជាកិច្ចទំនាក់ទំនងសាធារណៈប៉ុណ្ណោះ។ មិនមែនមានតែប្រជារាស្ត្រទេដែលចង់ឃើញស្តេចនៃប្រទេសមួយដែលអំណាចនិងសេដ្ឋកិច្ចត្រូវបានកំណត់ សូម្បីតែអ្នកកាសែតក៏តាមព្រះអង្គគ្រប់ជំហានដែរ ពីព្រោះពិធីពិសេសៗត្រូវបានធ្វើឡើងសម្រាប់ស្វាគមន៍ព្រះអង្គគ្រប់កន្លែងដែលទ្រង់យាងទៅ។ ព្រះរាជាត្រូវបានរដ្ឋាភិបាលបារាំងទទួលក្នុងនាមជាព្រះប្រមុខរដ្ឋដ៏ធំមួយ ហើយគ្រប់ដំណើរយាងរបស់ព្រះអង្គសុទ្ធតែត្រូវបានគេថតទុកនិងសម្រាប់ប្រើប្រាស់នៅលើតែមប្រៃសណីយ៍។ នៅសាលាក្រុងប៉ារីសចុងខែមិថុនា ភ្ញៀវមានមុខមានមាត់ជាច្រើននាក់បានព្យាយាមជល់គ្នាចុះឈ្មោះចូលរួមពិធីមួយដែលធ្វើឡើងក្រោមព្រះនាមព្រះអង្គ។ អ្នកស្រាវជ្រាវជាតិបារាំង អូលីវើ ដឺ បែរណុន (Oliver de Bernon) បានសរសេរក្នុងបទបង្ហាញនៅក្នុងសៀវភៅ 'ដំណើរមកស្រុកបារាំងរបស់ស្តេចស៊ីសុវត្ថិ' របស់គាត់ថា អ្វីដែលបញ្ជីកញ្ចប់ថវិកាមិនបានបង្ហាញនោះគឺអ្នកបម្រើសាធារណៈបារាំងម្នាក់បានព្យាយាមទាមទារឲ្យព្រះអង្គបង់ថ្លៃលើអំណោយដែលទ្រង់ទទួលបានមានដូចជាបាច់ផ្ការបស់លោក អាម៉ង់ដ៍ ហ្វាលីយេ ប្រធានាធិបតីបារាំង (Armand Fallieres)។ ឧកញ៉ា រ៉ាំង.ជួន មន្ត្រីសេដ្ឋកិច្ចនិងវិចិត្រសិល្បៈ និងមន្ត្រីរដ្ឋបាលធំរបស់បារាំងនៅកម្ពុជា គឺលោកប៉ូល ល្វីស លូសស៍ (Paul Louis Luce) បានទប់ទល់និងរាំងបញ្ហានេះមុនពេលដែលវាអាចបង្កឲ្យមានរឿងអាម៉ាស់កើតឡើង។

ដំណើរទស្សនកិច្ចនោះបានធ្វើឲ្យរដ្ឋបាលបារាំងនិងខ្មែរចំណាយរួមគ្នាអស់ប្រហែល៦០ភាគរយ។ បើទោះជាយ៉ាងណាក៏ដោយ ក៏មានការចំណាយដោយប្រយោលនៅពេលដែលរោងជាងទងមាសនិងប្រាក់បានចំណាយពេលធ្វើវត្ថុអនុស្សាវរីយ៍សម្រាប់ឲ្យព្រះបាទស៊ីសុវត្ថិ ប្រទានឲ្យឥស្សរជនបារាំង។ ដំណើរទស្សន



www.elibraryofcambodia.org

*កិច្ចនោះបានធ្វើឲ្យប្រជាជនបារាំងស្គាល់និងចាប់អារម្មណ៍ពីស្រុកខ្មែររហូតមកដល់សព្វថ្ងៃ*។

នៅក្នុងព្រះរាជដំណើរយាងទស្សកិច្ចនោះ ព្រះបាទ ស៊ីសុវត្ថិ ក៏បានប្រាប់មន្ត្រីជាន់ខ្ពស់បារាំងដែរថា បារាំងនៅឯស្រុកខ្មែរបានធ្វើបាបប្រជារាស្ត្ររបស់ទ្រង់ ហេតុនេះ បារាំងនៅទីនេះត្រូវតែជួយសម្រួលពីបញ្ហានោះផង ដើម្បីសេចក្ដីសុខរបស់ប្រជានុរាស្ត្រខ្មែរនៅទូទាំងនគរ។



*ព្រះបាទ ស៊ីសុវត្ថិ យាងចេញពីរាជពិធីចម្រើនព្រះកេសា (កាត់សក់)។ រូបបណ្ណាល័យជាតិ*



www.elibraryofcambodia.org





រូបលើ៖ ព្រះបាទ ស៊ីសុវត្ថិ (គង់នៅខាងមុខផ្នែកខាងស្ដាំ)។ រូបស្ដាំ៖ ព្រះបាទ ស៊ីសុវត្ថិ (ស្ដាំ) ថតរូបអនុស្សាវរីយ៍ជាមួយមន្ត្រីបារាំងកាលពីពេលយាងបំពេញព្រះរាជទស្សនកិច្ចនៅបារាំងក្នុងឆ្នាំ ១៩០៦ (រូបបណ្ណាល័យជាតិ)





ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទសម្ដេចព្រះ ស៊ីសុវត្ថិ យាងបំពេញព្រះរាជទស្សនកិច្ចនៅបារាំងនាឆ្នាំ១៩០៦ (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org

នៅឆ្នាំ ១៩០៤ នេះដែរ អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញសម្រាប់ថ្នាក់មធ្យមសិក្សា។ នៅថ្ងៃទី១១ ខែ មេសា ឆ្នាំ១៩១២ ព្រះអង្គបានចេញព្រះរាជបញ្ញត្តិមួយឲ្យឪពុកម្តាយត្រូវតែបញ្ជូនកូនៗទៅកាន់សាលារៀន បើពុំដូច្នោះទេ នឹងត្រូវទទួលទណ្ឌកម្ម[110]។ ក្រៅពីសាលាវត្ត រាជការបានបង្កើតសាលានៅតាមឃុំជាច្រើនទៀត ដើម្បីឲ្យក្មេងសិក្សាភាសាជាតិខ្លួន។ ចំពោះក្មេងណាដែលចង់បន្តការសិក្សាថែមទៀត រដ្ឋការអាណាព្យាបាលបារាំង បានបង្កើតសាលាបឋមសិក្សាថ្នាក់ដំបូងខ្លះដែលនៅទីនោះ គេបានផ្តើមការបង្រៀនភាសាបារាំង។ នៅថ្នាក់កម្រិតលើនេះគឺមានសាលាវិជ្ជាជាន់ខ្ពស់នៅតាមទីរួមខេត្ត ហើយមានចាងហ្វាងជាជនជាតិបារាំង។

ក្នុងវិស័យសិក្សាអប់រំ និងវប្បធម៌នេះ គេបានដឹងថាតាមរាជបញ្ញត្តិថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩១៥ ព្រះបាទ ស៊ីសុវត្ថិ ទ្រង់បានបង្កើតគណៈកម្មការមួយ ដែលមាននាទីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង ហើយនៅឆ្នាំ១៩២១ ព្រះអង្គទ្រង់បានសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ។ ឯកសារមួយ[111]បានសរសេរថា ក្នុងរជ្ជកាលរបស់ព្រះបាទ ស៊ីសុវត្ថិ ចម្ការកៅស៊ូត្រូវបានបង្កើតជាលើកដំបូងនៅត្រង់តំបន់ជប់នៅក្នុងឆ្នាំ១៩២១។ ដោយការសាកល្បងនេះមានជោគជ័យ ពួកមូលធននិយមបារាំងបានបង្កើតចម្ការកៅស៊ូធំៗផ្សេងទៀតត្រង់តំបន់ដីក្រហមក្នុងខេត្តកំពង់ចាម និងក្រចេះដែលក្រោយៗមក ទំហំដីដាំកៅស៊ូឡើងដល់ទៅរាប់ម៉ឺនហិកតា។

---

[110] http://whoincam.wordpress.com/2009/04/30/sisowath/

[111] http://whoincam.wordpress.com/2009/04/30/sisowath/



www.elibraryofcambodia.org





រូបលើ៖ ការចៀរយកជ័រកៅស៊ូនៅកំពង់ចាម និងការផលិតកៅស៊ូនៅក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ។ រូបស្តាំ៖ លោក HCA Elmige កើតនៅទីក្រុង Lucerne ប្រទេសស្វីស ជាអ្នកជំនាញដាំកៅស៊ូ និងជាអ្នកជួយអភិវឌ្ឍសេដ្ឋកិច្ចកសិ-ឧស្សាហកម្មនៅកម្ពុជានៅចុងទសវត្សរ៍១៩២០-ទសវត្សរ៍១៩៥០ (រូបបណ្ណសារដ្ឋានជាតិកម្ពុជា)។







រូបឆ្វេងលើនិងក្រោម៖ ក្រុមរបាំព្រះរាជទ្រព្យត្រៀមសម្តែងក្នុងព្រះបរមរាជវាំងក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org

**២២ មករា ១៩០៧៖** បារាំងបានបន្តគាបសង្កត់សៀម ហើយទាមទារត្រួតត្រាខេត្តត្រាត (Trat) ទៀត បន្ទាប់ពីគ្រប់គ្រងខេត្តចន្ទបុរី (Chantaburi) កាលពីខែតុលាឆ្នាំ១៨៩៣មក។ ដើម្បីបានខេត្ត ចន្ទបុរីមកវិញ សៀមសុខចិត្តប្រគល់ខេត្តត្រាតឲ្យបារាំងគ្រប់គ្រង។

**២៣ មីនា ១៩០៧៖** បារាំងក៏បានបង្ខំឲ្យសៀមចុះហត្ថលេខាលើកតិកាសញ្ញាមួយដើម្បីប្រគល់ទឹកដីខេត្តសៀមរាប បាត់ដំបង និងស៊ីសុផុនដែលសៀមបានចូលទន្ទ្រានកាន់កាប់អស់ប្រមាណ១០០ឆ្នាំមុននេះ មកឲ្យខ្មែរវិញ។ បើទោះជាមិនមានឯកសារណាមួយបញ្ជាក់ថា ព្រះបាទ ស៊ីសុវត្ថិ បានពិភាក្សាជាមួយបារាំងពីរឿងទឹកដីទាំងនេះក្តី ក៏នៅថ្ងៃទី២៣មីនាឆ្នាំនោះ សៀមបានយល់ព្រមចុះកតិកាសញ្ញាជាមួយបារាំង ដោយព្រមប្រគល់ខេត្តទាំងបីពិសេសប្រាសាទអង្គរវត្ត ដោយរួមទាំងប្រាសាទព្រះវិហារផងដែរឲ្យខ្មែរវិញក្រោមអាណាព្យាបាលរបស់បារាំង។ កតិកាសញ្ញានេះមិនត្រឹមតែបានបង្ហាញថា ពួកបារាំងមានសិទ្ធិអំណាចយ៉ាងខ្លាំងក្លានៅក្នុងតំបន់ប៉ុណ្ណោះនោះទេ តែក៏បានបង្ហាញពីអំណាចរបស់ខ្មែរទៀតផង ហើយចាប់ពីពេលនោះមក កតិកាសញ្ញានេះ



*បារាំងចូលកាន់កាប់ខេត្តត្រាតរបស់សៀម។ រូបគំនូរនៅគេហទំព័រ http://en.wikipedia.org/wiki/Trat_Province*



www.elibraryofcambodia.org

បានធ្វើឲ្យអង្គរវត្តនៅស្ថិតជាសម្បត្តិរបស់ខ្មែរមកដល់បច្ចុប្បន្ន[112]។ ជាការដោះដូរ សៀមបានទទួលបានខេត្តត្រាតពីបារាំងមកវិញ[113]។



មហាក្សត្រសៀមត្រូវបានមន្ត្រីបារាំងចូលគាល់នៅក្នុងរាជវាំងបាងកក (រូបបណ្ណាល័យជាតិ)។

គួររម្លឹកថា ការដែលស្តេចសៀមសុខចិត្តព្រមប្រគល់ទឹកដីខ្មែរមកឲ្យបារាំងកាន់កាប់វិញ គឺជាថ្នូរនឹងការយកឯករាជ្យមិនឲ្យបារាំងគ្រប់គ្រងប្រទេសរបស់ខ្លួន។ កាលពីពេលដែលសៀមចូលទន្ទ្រាននិងកាន់កាប់ទឹកដីខ្មែរ ពួកសៀមបាននាំយកស្ថាបត្យករខ្មែរនិងកម្មករខ្មែរទៅសាងសង់វត្តឬព្រះវិហារមួយចំនួននៅទីក្រុងបាងកក ហើយយកលំនាំរចនាបទវប្បធម៌ខ្មែរទៀតផង[114]។ វត្តអារុណ (Wat Arun) មានកម្ពស់

[112] http://webcache.googleusercontent.com/search?q=cache:Of6fMuC5Z3UJ:campropost.org/wp-content/uploads/2011/05/Treaty-of-March-23-1907-Between-France-and-Siam-and-the-Return-of-Battambang-and-Angkor-to-Cambodia-Ed.pdf+&cd=1&hl=en&ct=clnk&gl=kh

[113] http://en.wikipedia.org/wiki/France%E2%80%93Thailand_relations

[114] Sacred Destinations: www.sacred-destinations.com/thailand/bangkok-wat-arun



www.elibraryofcambodia.org

៨០ម៉ែត្រ ដែលមានឈ្មោះដើមថា វត្តម៉ាកុក (Wat Makok) ហើយទីតាំងវត្តនេះមានតាំងពីរជ្ជកាលអាយុធ្យា (ឆ្នាំ១៣៥០-១៧៦៧) មកដែលស្តេចក្រុងអាយុធ្យាបានទទួលឥទ្ធិពលពីវប្បធម៌ខ្មែរ។ បន្ទាប់មកវត្តអារុណត្រូវបានចាប់ផ្តើមសាងសង់ដោយស្តេចរាមាទី២ (ឆ្នាំ១៨០៩-១៨២៤) និងត្រូវបានបញ្ចប់ដោយស្តេចរាមាទី៣ (ឆ្នាំ១៨២៤-១៨៥១)[115]។ ចុងក្រោយ ឈ្មោះវត្តនេះក៏បានប្តូរទៅជាវត្តអារុណរាត់ឆាយ៉ាវ៉ារ៉ារ៉ាម (Wat Arunratchawararam) វិញ។ សូមបញ្ជាក់ដែរថា ខ្ញុំ



រូបសំណាកស្តេចរាមាទី២នៅបាងកក (រូបថតដោយ ឆាយ សុផល ៖ ២៦ វិច្ឆិកា ២០១៤)

[អ្នកចងក្រងសៀវភៅ] បានឈរសំឡឹងមើលវត្តនោះ ដែលស្ថិតខាងលិចជាប់ដងទន្លេចៅប្រាយ៉ា (Chao Phraya) ហើយត្រូវបានអ្នកសារព័ត៌មានថៃម្នាក់ធ្វើអត្ថាធិប្បាយប្រាប់ពីប្រវត្តិនៃការសាងសង់វត្តនេះ គឺបានធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះប្រវត្តិសាស្ត្រមហានគរខ្មែរនាអតីតកាល។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលថៃបានលើកស្ទួយវត្តនេះនៅលើឆាកអន្តរជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរ។ នៅក្នុងរជ្ជកាលស្តេចរាមាទី២ សន្តិភាពបានកើតឡើងពេញផ្ទៃនគរសៀម ហើយស្តេច

---

[92] សៀវភៅ៖ ប្រវត្តិសាស្ត្រថៃនិពន្ធដោយលោក David K. Wyatt (ទំព័រ១៨១)



www.elibraryofcambodia.org

អង្គនេះសព្វព្រះទ័យនឹង "ស្ថាបត្យកម្ម រដ្ឋបាល និងជំនួញ"។

ចំណែកឯនៅក្នុងរាជវាំងរបស់សៀម ស្តេចសៀមព្រះនាម មង្កុដ (Mongkut) ប្រសូត៖ ១៨០៤ សុគត៖១៨៦៨ បានបញ្ជូនក្រុមជំនាញស្ថាបត្យកររបស់ទ្រង់ឲ្យមកមើលប្រាសាទអង្គរវត្តខ្មែរ ថាតើពួកគេអាចនាំយកបំណែកថ្មទាំងអស់នៃប្រាសាទ មកកាន់ប្រទេសសៀមបានដែរឬក៏អត់ តែត្រូវបានអ្នកជំនាញទាំងនោះឆ្លើយថាពិតជាមិនអាចទៅរួចនោះទេ[116]។ ដោយហេតុនេះហើយ ទើបស្តេចសៀមអង្គនោះបានបញ្ជាឲ្យស្ថាបត្យកររបស់ទ្រង់សាងសង់កូនប្រាសាទអង្គរវត្តមួយជាគំរូនៅក្នុងព្រះរាជវាំងរបស់ទ្រង់។ បច្ចុប្បន្ន កូនប្រាសាទអង្គរវត្តនៅតែស្ថិតនៅក្នុងរាជវាំងថៃដដែល ហើយមគ្គុទេសក៍ទេសចរណ៍ថៃទាំងអស់បច្ចុប្បន្នបាននិយាយប្រាប់ទេសចរបរទេសដូចៗគ្នាថា ប្រាសាទនេះគ្រាន់តែជានិមិត្តរូបទេ ឯប្រាសាទពិតប្រាកដគឺស្ថិតនៅឯខេត្តសៀមរាប ដោយពួកគេអះអាងដូចៗគ្នាថា ជាអតីតទឹកដីថៃ ដែលថៃបានបាត់បង់មកកម្ពុជាដោយសារតែបារាំង។ សម្រាប់ខ្ញុំ [អ្នកចងក្រងសៀវភៅ] ខ្ញុំមិនមានយោបល់ទេនៅពេលដែលឮពួកគេនិយាយបែបនេះ។ នៅក្នុងទីក្រុងបាងកក ខ្ញុំក៏បានធ្វើបទសម្ភាសជាមួយជនជាតិថៃមួយចំនួនផងដែរ ដូចជាបុគ្គលិកសណ្ឋាគារ អ្នកបើករថយន្តតាក់ស៊ី ដោយរួមទាំងអ្នកសារព័ត៌មានវ័យក្មេងៗផងពីបញ្ហាប្រាសាទអង្គរវត្តនេះ។ ពួកគេក៏មិនខុសគ្នានឹងក្រុមមគ្គុទេសក៍ទេសចរណ៍ថៃឡើយ គឺពួកគេអះអាងថា ថៃបានបាត់បង់ទឹកដីភាគខាងកើតទៅឲ្យកម្ពុជាដោយសារតែបារាំង ហើយបានបាត់

---

[116] *Highlight Thailand: http://www.highlightthailand.com/main/detail_content/Miniature-Replica-of-Angkor-Wat-in-Wat-Phra-Kaew/226.html*



www.elibraryofcambodia.org

បង់មួយផ្នែកនៅភាគខាងត្បូងទៅឲ្យម៉ាឡេស៊ីដោយសារតែប្រទេសអង់គ្លេស។

គួរបញ្ជាក់ថា រឿងរ៉ាវរបស់ជនជាតិសៀមមួយចំនួនទាក់ទិននឹងប្រាសាទអង្គរវត្តខ្មែរចេះតែបន្តនៅរាប់សិបឆ្នាំក្រោយៗមកទៀត។ នៅល្ងាចថ្ងៃទី ២៩ មករា ឆ្នាំ ២០០៣ មានបញ្ហាមួយនឹកស្មានមិនដល់នៅកណ្តាលរាជធានីភ្នំពេញ។ នៅល្ងាចនោះ ពួកបាតុករខ្មែររាប់រយនាក់បានដុតស្ថានទូតថៃ សណ្ឋាគារ និងអាគារក្រុមហ៊ុនមួយចំនួនដែលមានម្ចាស់ជាជនជាតិថៃ។ ជាលទ្ធផល ការខូចខាតត្រូវបានគេវាយតម្លៃអស់ទឹកប្រាក់ប្រមាណជា ៥៦ លានដុល្លារអាម៉េរិក ដែលប្រទេសថៃទាមទារឲ្យប្រទេសកម្ពុជាសង។ មុនព្រឹត្តិការណ៍នេះ កាសែតក្នុងស្រុកមួយបានចុះផ្សាយដោយដកស្រង់សំដីជនអនាមិកថា តារាភាពយន្តស្រីជនជាតិថៃម្នាក់ដែលប្រជាជនកម្ពុជាខ្លះស្គាល់ឈ្មោះក្នុងរឿងថា "នាងផ្កាយព្រឹក" បាននិយាយថា នាងមិនមកលេងប្រទេសកម្ពុជាឡើយ បើនាងមក លុះត្រាតែប្រទេសកម្ពុជាប្រគល់អង្គរវត្តទៅឲ្យប្រទេសថៃវិញ ព្រោះប្រាសាទអង្គរវត្តជារបស់ថៃ។ ព័ត៌មាននេះត្រូវបានកាសែត និងវិទ្យុក្នុងស្រុកជាច្រើនយកមកផ្សាយបន្ត ដែលបានធ្វើឲ្យប្រជាជនកម្ពុជាភាគច្រើនលើសលប់មានការខឹងសម្បា ហើយទាមទារឲ្យតារារូបនោះត្រូវតែសូមទោសប្រទេសកម្ពុជា។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់មកបានប្រកាសជាសាធារណៈថា តម្លៃនាងផ្កាយព្រឹកមិនស្មើនឹងស្មៅមួយគុម្ពនៅឯប្រាសាទអង្គរវត្តឡើយ។ ទោះជាបែបនេះក្តី ក៏មិនមានការសូមទោសណាមួយ ឬក៏មានប្រតិកម្មឆ្លើយតបពីបញ្ហានេះឡើយពីប្រទេសថៃ ឬស្ថានទូតរបស់ខ្លួនប្រចាំប្រទេសកម្ពុជា។ នៅព្រឹកបន្ទាប់ នារាជធានី



www.elibraryofcambodia.org

បាងកក ប្រទេសថៃ ក៏មានការវាយបំផ្លាញស្ថានទូតកម្ពុជាប្រចាំរាជធានីបាងកកដែរ ដែលជាការសងសឹករបស់ប្រជាជនថៃមកលើការដុតស្ថានទូតរបស់គេនៅក្នុងរាជធានីភ្នំពេញ។ រាជរដ្ឋាភិបាលថៃ ដែលកាលពីពេលនោះដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា ក៏បានបិទច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត មិនឲ្យប្រជាជនប្រទេសទាំងពីរចេញចូលរកស៊ីដូចសព្វដងឡើយ។ ដោយមានប្រតិកម្មតបវិញ នាយករដ្ឋមន្ត្រីកម្ពុជាគឺសម្តេច ហ៊ុន សែន ក៏បានបិទច្រកខ្លះនៅតាមបណ្តោយព្រំដែនរវាងកម្ពុជា-ថៃ វិញដែរ ហើយថា អ្នកដែលខាតច្រើនបំផុតនៃការបិទច្រកព្រំដែននេះគឺជាប្រជាជនថៃ មិនមែនកម្ពុជាទេ ព្រោះទំនិញដែលនាំចូលមកពីប្រទេសថៃមកកម្ពុជាគឺមានចំនួនច្រើនលើសលប់ជាងទំនិញដែលកម្ពុជានាំចេញទៅថៃ។ ក្រោយមក ដោយមានការចរចាគ្នារវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ច្រកព្រំដែនទាំងអស់ក៏បានបើកជាថ្មី ដែលធ្វើឲ្យចំណងការទូតនៃប្រទេសទាំងពីរបានប្រសើរឡើងវិញ។ នៅក្នុងដំណាក់កាលនោះ ប្រទេសកម្ពុជាក៏កំពុងស្ថិតនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជាតិ ដើម្បីជ្រើសរើសអ្នកតំណាងរាស្ត្រ និងរាជរដ្ឋាភិបាលថ្មី។ បន្ទាប់ពីព្រឹត្តិការណ៍ដុតស្ថានទូតថៃនោះរួចមក អ្នកសារព័ត៌មានពីររូបគឺលោក ឥន្ទ ចាន់ស៊ីវត្ថា ចាងហ្វាងកាសែតរស្មីអង្គរដែលចុះអត្ថបទដើម និងលោក ម៉ម សូណង់ដូ នាយកស្ថានីយវិទ្យុសម្បុកឃ្មុំ FM១០៥ ត្រូវបានចាប់ខ្លួន ពីបទផ្សាយព័ត៌មានញុះញង់ដែលនាំឲ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ហើយសកម្មជនបាតុកម្មមួយចំនួនក៏ត្រូវបានចាប់ខ្លួន ប៉ុន្តែក្រោយមកក៏ត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។



www.elibraryofcambodia.org



វត្តអរុណដែលត្រូវបានសាងសង់ដោយមានលំនាំចេទាបទវប្បធម៌ខ្មែរ (រូប ឆាយ សុផល ថ្ងៃទី២៦ វិច្ឆិកា ឆ្នាំ ២០១៤)។



មគ្គុទេសក៍ទេសចរណ៍ថៃ (កណ្តាល) អត្ថាធិប្បាយប្រាប់ដល់ទេសចរបរទេសពីប្រវត្តិប្រាសាទអង្គរវត្ត ដោយនិយាយថា ប្រាសាទតូចនេះគ្រាន់តែជានិមិត្តរូបទេ ឯប្រាសាទពិតប្រាកដគឺស្ថិតនៅឯខេត្តសៀមរាប ដែលថៃបានបាត់បង់មកកម្ពុជាដោយសារតែបារាំង (រូប ឆាយ សុផល ៖ ២៨ មករា ២០០៤)។



www.elibraryofcambodia.org





សកម្មជនអ្នកជាតិនិយមកម្ពុជាបានធ្វើបាតុកម្មដុតស្ថានទូតនិងទង់ជាតិថៃនៅល្ងាចថ្ងៃទី ២៩ មករា ឆ្នាំ ២០០៣ ដោយសារតែព័ត៌មានស្តីពីប្រាសាទអង្គរវត្ត។ រូបលើ៖ The Cambodia Daily រូបក្រោម៖ REUTERS/ Chor Sokunthea





ឆ្វេង៖ សកម្មជនអ្នកជាតិនិយមថៃបានធ្វើបាតុកម្មបំផ្លាញខ្លោងទ្វារស្ថានទូតកម្ពុជានៅទីក្រុងបាងកកដែលនៅព្រឹកថ្ងៃទី៣០ មករា ឆ្នាំ ២០០៣ ដែលជាការសងសឹក (AP/Sakchai Lalit)។ ស្តាំ៖ ជនជាតិថៃហែកនិងដាក់ទង់ជាតិខ្មែរជាការសងសឹក។ (REUTERS/Sukree Sukplan)



www.elibraryofcambodia.org

**១៨ មេសា ១៩២៥៖** នៅមុនថ្ងៃនោះ ប្រជារាស្ត្រខ្មែរក្រោមរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ បានខឹងសម្បាយ៉ាងខ្លាំងចំពោះបារាំង ដែលដំឡើងពន្ធដារខ្ពស់ហួសហេតុ រហូតដល់នាំឲ្យប្រជារាស្ត្រទូទាំងប្រទេសក្តៅក្រហាយជាពន់ពេក ហើយទីបំផុតអត់ទ្រាំមិនបាន ក៏នាំឲ្យប្រជារាស្ត្រមួយក្រុមនៅខេត្តកំពង់ឆ្នាំងបានព្រួតគ្នាសម្លាប់លោក បារដេស (Bardsdey) ជនជាតិបារាំងជារ៉េស៊ីដង់ [ប្រធាន] ប្រចាំខេត្តកំពង់ឆ្នាំង ដែលបានទៅទារពន្ធដោយផ្ទាល់ជាមួយថៃបក [អ្នកបកប្រែ] ម្នាក់ឈ្មោះ សួន និងកងរក្សាស្រុក [អង្គរក្ស] ម្នាក់ឈ្មោះ ឡាច។ ការសម្លាប់នេះបានធ្វើឡើងដោយវាយនឹងស្ទ័យកាំភ្លើង ព្រនង់ គប់ដុំថ្ម វាយទាត់ជាក់កាប់នឹងពូថៅ ចាក់នឹងបៃយ៉ោណែត [ចំពុះទុង] របស់កាំភ្លើងវែង និងកាំបិតស្នៀត នៅក្នុងវត្តក្រាំងលាវ ក្បែរសាលាឃុំក្នុងភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ឯអង្គរក្ស ឡាច បានស្លាប់ដោយសារកាប់នឹងកូនពូថៅ ហើយថៃបក សួន ស្លាប់ដោយសារចាក់នឹងកាំបិតស្នៀត ក្រោយពីការវាយដំយ៉ាងចាស់ដៃពីពលរដ្ឋ។ ចំពោះ បារដេស វិញ ដែល កំពុងនៅលើសាលាឃុំ ភ័យស្លន់ស្លោដើរចុះដើរឡើងលេចនោមដាក់ខោ ហើយត្រូវស្ត្រីម្នាក់ទាញរនុកទ្វារវាយក្បាលឲ្យដួល តែនៅតែអាចងើបបានហើយរត់លោតចេញតាមបង្អួច។ អ្នកភូមិរាប់សិបនាក់ដែលនៅខាងក្រោមស្រាប់ ក៏ដេញតាមវាយនឹងដំបងរហូតដល់ដួលសន្លប់ ហើយក្រោយមកក៏យកកាំបិតចាក់ស្ទើរសុសសាច់ស្លាប់បាត់ទៅ។

គួររម្លឹកបន្តិចថា នៅមុនឧប្បត្តិហេតុនេះ ដោយដឹងគុណបារាំង ព្រះបាទ ស៊ីសុវត្ថិ បានអនុញ្ញាតឲ្យបារាំងកែនរាស្ត្រខ្មែរនៅឆ្នាំ១៩១៦



www.elibraryofcambodia.org

ទៅធ្វើទាហាននៅបារាំងក្នុងសង្គ្រាមលោកលើកទីមួយជាមួយអាល្លឺម៉ង់ (១៩១៤-១៩១៨) ហើយបានធ្វើឲ្យប្រជារាស្ត្រខ្មែរប្រមាណមួយសែននាក់បានបះបោរប្រឆាំងនឹងកំណែននេះ តែហ្លួង [ព្រះរាជា] ស៊ីសុវត្ថិបានធ្វើអន្តរាគមន៍យ៉ាងមានប្រសិទ្ធភាព[117]។ ទោះបីជាយ៉ាងនេះក្តី ស្ថានភាពនាពេលនោះ អំណាចស្ថិតនៅក្នុងកណ្តាប់ដៃបារាំង ដែលព្រះបាទស៊ីសុវត្ថិ មិនហ៊ានប្រឈមឡើយ។ បន្ទាប់ពីសង្គ្រាមឈ្នះអាល្លឺម៉ង់ បារាំងបានជួបប្រទះវិបត្តិសេដ្ឋកិច្ចនិងចុះដុនដាប ដែលនាំឲ្យអាណានិគមបារាំងដំឡើងពន្ធ និងរឹតបន្តឹងការទារពន្ធដារឲ្យខាងតែបានពីប្រជារាស្ត្រខ្មែរ ខណៈដែលជីវភាពរបស់ពលរដ្ឋខ្មែរកាន់តែយ៉ាប់យឺននាពេលនោះ ហើយបើអ្នកណាមិនបង់តាមការកំណត់ទេ នោះត្រូវទទួលរងការធ្វើទារុណកម្ម។ បញ្ហានេះ បណ្តាលឲ្យពលរដ្ឋអត់ទ្រាំមិនបាន ហើយក៏ឈានទៅបង្កហេតុការណ៍នៅភូមិក្រាំងលាវនោះទៅនាថ្ងៃទី១៨ មេសា។ ការបះបោរនោះមិនមែនតែអ្នកភូមិក្រាំងលាវទេ គឺមានអ្នកភូមិនិងឃុំផ្សេងៗទៀតនៅខេត្តកំពង់ឆ្នាំ ក្រោមការ "ដឹកនាំរបស់បុរសពីរនាក់គឺម្នាក់ឈ្មោះ ជួន និងម្នាក់ទៀតឈ្មោះ នៅ ដែលមានដើមកំណើត និងទីលំនៅក្នុងភូមិបន្ទាយអំពិល ឃុំព្រៃខ្មែរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង"[118]។ មុនមកដល់ភូមិក្រាំងលាវ លោកបារដេស ថៃបក សួន អង្គរក្ស ឡាច និងចុងភៅម្នាក់ទៀតដែលមិនស្គាល់ឈ្មោះបានធ្វើដំណើរទស្សនាភូមិនានាតាំងពី "ថ្ងៃទី១៣ - ១៤ - ១៥ មេសា"[119] ដោយចៅហ្វាយខេត្តខ្មែរមិនបាន

---

*[117] សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ - រដ្ឋបាលប្រទេសកម្ពុជានិងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៨៤*

*[118] http://km.wikipedia.org/wiki/រឿង_ភូមិតិរច្ឆាន*

*[119] សៀវភៅ: ភូមិតិរិច្ឆាន របស់ក្រសួងអប់រំ យុវជននិងកីឡា ឆ្នាំ២០០៣ ទំព័រ៨៤*



www.elibraryofcambodia.org

ដឹងផង។ នៅក្នុងដំណាក់កាលនោះ ប្រជារាស្ត្រខ្មែរជួបការលំបាកយ៉ាងធ្ងន់ធ្ងរ ខ្វះខាតស្បៀងអាហារ ហើយគ្រួសារខ្លះគ្មានសម្លៀកបំពាក់រហូតយកបាវមកដេរធ្វើជាសំពត់ស្លៀក គ្មានថ្នាំព្យាបាលជំងឺ គឺថា ខ្វះអ្វីៗគ្រប់យ៉ាង[120]។ មុនឈានដល់ការសម្លាប់នេះ បារដេសបានបញ្ជាឲ្យអង្គរក្ស ឡាច បាញ់សម្លាប់ស្ត្រី២នាក់ដែលរឹងទទឹងនិងតវ៉ាដោយប្រើសំដីខ្លាំងៗមិនព្រមបង់ពន្ធ។ ពេលអង្គរក្ស ឡាច ភ្ជង់កាំភ្លើងទៅស្ត្រីទាំងនោះរៀបនឹងបាញ់ ក៏ស្រាប់តែមានមនុស្សម្នាក់វាសចុងកាំភ្លើងឡើងលើ ក៏ស្រាប់តែកាំភ្លើងផ្ទុះទៅលើមេឃតែម្តង។ ដោយមើលឃើញអំពើឃោរឃៅរបស់ បារដេស និងអង្គរក្ស ឡាច បែបនេះ អ្នកភូមិរាប់សិបអ្នកដែលកំពុងមានកំហឹងស្រាប់បានស្ទុះចូលដូចស្រមោចសំដៅយ៉ាងរហ័សទៅរក បាដេស អង្គរក្ស ឡាច និងថៃបក សួន ហើយក៏វាយសម្លាប់ចោលតែម្តង[121]។

នៅក្នុងសម័យកាលនោះ បារាំងបានធ្វើបាបខ្មែរមែនទែន ដោយប្រើយុទ្ធសាស្ត្រមនុស្សតិចត្រួតត្រាមនុស្សច្រើន ប្រើវិធីមិនឲ្យខ្មែររៀនចេះដោយក្តិចត្រួយមិនឲ្យលូតលាស់កើត ខណៈដែលរចនាសម្ព័ន្ធគ្រប់គ្រងត្រូវបានបារាំងក្តោបក្តាប់យ៉ាងណែនចម្រាញ់យកផលប្រយោជន៍ទាំងអស់ ហើយនៅឆ្នាំ១៩២១ បារាំងមានជាង៧០០នាក់ប៉ុណ្ណោះ (ប្រុស៤៨៧

---

[120] *សៀវភៅ៖ ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ - ផ្ទៃបាលប្រទេសកម្ពុជានិងបុព្វហេតុសង្គ្រាម (VI-XX) ទំព័រ៨៤*

[121] *សៀវភៅ: ភូមិគិរីវិទ្ធាន របស់ក្រសួងអប់រំ យុវជននិងកីឡា ឆ្នាំ២០០៣ ទំព័រ៥៤*



www.elibraryofcambodia.org

នាក់និងស្រី២៨៦នាក់)បានត្រូវគ្រាប្រជាជនខ្មែរជាង២លាននាក់ (២.៤០២.៥៨៥នាក់)[122]។

ព្រះរាជាខ្មែរ ក្រោមគំនិតផ្តួចផ្តើមរបស់បារាំងក៏បានឡាយព្រះហស្តលេខាប្តូរឈ្មោះភូមិក្រាំងលាវនេះថាជា "ភូមិតិរច្ឆាន" វិញនៅថ្ងៃទី២៣ មេសា ដោយប្រកាសជាផ្លូវការនៅថ្ងៃទី២៧ មេសា ព្រមទាំងបញ្ជាឲ្យគេសង់ចេតិយមួយសម្រាប់អ្នកស្លាប់ទាំងបីនាក់នោះ និងតាមចាប់ជនបះបោរ ដែលនាំឲ្យប្រជាជនជាច្រើនរត់ចូលព្រៃ។ មានពលរដ្ឋជាច្រើនពិសេសអ្នកភូមិក្រាំងលាវត្រូវបានចាប់ខ្លួន។ តាមដំណឹង មានតែចុងភៅទេដែលរួចខ្លួន និងបានរត់ទៅសាលាខេត្តចម្ងាយជាង១០គីឡូម៉ែត្រ ហើយបានរាយការណ៍ពីហេតុការណ៍នេះដល់មន្ត្រីខេត្ត។ នៅឆ្នាំ១៩២៥ ហ្លួង ស៊ីសុវត្ថិ មានព្រះជន្ម៨៥ព្រះវស្សា និងមានព្រះរោគាពាធផងគឺមិនហ៊ានជាមួយពួកបារាំងទេ ហើយម្យ៉ាងទៀត ព្រះអង្គកំពុងតែយកចិត្តបារាំងឲ្យជួយគាំទ្រព្រះរាជបុត្រា ស៊ីសុវត្ថិ មុនីវង្ស បានឡើងគ្រងរាជ្យបន្តផង។ ក្រោយមក ដោយមានអន្តរាគមន៍ពីមហេសីម្នាក់របស់ហ្លួង ស៊ីសុវត្ថិ ព្រោះអ្នកម្នាងមានដើមកំណើតនៅឃុំបន្ទាយព្រាលក្បែរឃុំក្រាំងលាវដែរ ទើបព្រះអង្គបានចេញព្រះរាជប្រកាសលុបឈ្មោះ "ភូមិតិរិច្ឆាន" នេះ ដោយដាក់ថា ភូមិនិងឃុំក្រាំងលាវវិញនៅថ្ងៃទី៩ ខែមេសា ឆ្នាំ ១៩២៦[123]។

---

[122] *សៀវភៅ៖ ខ្មែរលើគម្ពីស្វែងរកព្រះបាទជ័យវរ្ម័នទី២ (ទំព័រ១៤-១៥) ដោយ ជៀប គឹមហ៊ាង http://www.elibraryofcambodia.org/khmer-leuk-kumpi-sveng-rok-preahbat-jey-voramanti-7/*

[123] *សៀវភៅ: ភូមិតិរិច្ឆាន របស់ក្រសួងអប់រំ យុវជននិងកីឡា ឆ្នាំ២០០៣ ទំព័រ៩២*



www.elibraryofcambodia.org



អ្នកទោសនៅសម័យអាណានិគមបារាំង (រូបបណ្ណសារជាតិកម្ពុជា)



រូបស្តាំ៖ ចេតិយត្រូវបានសាងសង់នៅភូមិក្រាំងលាវសម្រាប់គោរពវិញ្ញាណក្ខន្ធលោក បារដេស។ បច្ចុប្បន្ន ចេតិយនេះត្រូវបានគេបោះបង់ចោល ដោយព័ទ្ធបន្លាលួសនៅក្រោយរបងខាងម្ខាងមុខវត្តបល្ល័ង្កស្បៀ ក្នុងភូមិក្រាំងលាវ តែមានដំណឹងថា មានគេចង់ប្រែក្លាយចេតិយនេះឲ្យជាសារមន្ទីរ។ (រូបថតដោយ ទាយ សុផល ៖ ២៩ តុលា ២០១៤)

រូបក្រោម៖ ខ្ញុំ (អ្នកចងក្រងសៀវភៅ) មើលរូបសំណាកស្ត្រីម្នាក់កាន់ដំបងតំណាងឲ្យស្ត្រីជាច្រើនដែលបានយកដំបងវាយ លោក បារដេស ហើយបើតាមការកត់ត្រាគឺស្ត្រីម្នាក់ដែលគេហៅថា "នាងប៊ី" បានទាញនុកឡាវាយ បារដេស មុនគេ។ នៅពីក្រោយរូបសំណាកស្ត្រីនោះគឺចេតិយ បារដេស។ (រូបថតលោក លាក់ តេនាះ ២៩ តុលា ២០១៤)



www.elibraryofcambodia.org



ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទ ស៊ីសុវត្ថិ នៅក្នុងបន្ទប់បំពេញរាជកិច្ច។ រូបថតស្រង់ចេញពីគេហទំព័រ http://www.postcardman.net/cambodia/260037.jpg





រថយន្ត Bus ដំបូងគេនៅឆ្នាំ ១៩១២ ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ ហើយរថយន្ត Bus ប្រភេទនេះគឺដឹកភ្ញៀវពីរាជធានីភ្នំពេញទៅកំពតដែរ (បណ្ណាល័យជាតិ)។





ព្រះបាទ ស៊ីសុវត្ថិ យាងទស្សនាទីប្រាសាទអង្គរវត្តជាមួយមន្ត្រីបារាំងនាឆ្នាំ១៩២១។ រូបថតស្រង់ចេញពីវីដេអូខ្លីបបារាំងក្នុង YouTube http://mobile.ztopics.com/Sisowath%20Monivong/



www.elibraryofcambodia.org

**៩ សីហា ១៩២៧៖** ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ ក្នុងព្រះជន្ម ៨៧ព្រះវស្សា បានសោយព្រះសុវណ្ណគតដោយព្រះរោគថ្លាមនៅឯព្រះបរមរាជវាំងក្រុងចតុមុខមង្គល [ភ្នំពេញ] ហើយបានទទួលព្រះបច្ឆាមរណនាមថា "ព្រះករុណាព្រះបរមរាជានុកោដ្ឋ" ឬថា "ហ្លួងរាជានុកោដ្ឋ"។ ឯរាជសម្បត្តិត្រូវបានធ្លាក់ទៅលើព្រះរាជបុត្រា គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីវង្ស។ ព្រះនាមរបស់ព្រះបាទ ស៊ីសុវត្ថិ ត្រូវបានមន្ត្រីជំនាន់ក្រោយយកទៅដាក់ឈ្មោះផ្លូវ និងសាលារៀននៅក្នុងរាជធានីភ្នំពេញដែលមានឈ្មោះថា "មហាវិថីព្រះស៊ីសុវត្ថិ" និង "វិទ្យាល័យព្រះស៊ីសុវត្ថិ"។

មានសៀវភៅមួយក្បាលដែលសរសេរដោយជនជាតិបារាំងឈ្មោះ Rolang MEYER ជាប្តីនាង សារ៉ាម៉ានី[124] អតីតអ្នកបម្រើ ហ្លួងស៊ីសុវត្ថិ រៀបរាប់ពីអាថ៌កំបាំងនៅក្នុងព្រះរាជវាំងខ្មែរក្នុងរជ្ជកាលព្រះអង្គ ដោយបង្ហាញថា ទ្រង់ គ្មានអំណាច ជក់អាភៀនរាប់រយខ្សៀក្នុងមួយថ្ងៃ[125] វក់នឹងក្រយា [ស្រា] និងស្រីស្នំក្មេងៗ ដោយបានប្រព្រឹត្តអំពើអាសអាភាសកាមគុណនៅចំពោះមុខភីលៀង និងអាមាត្យក្នុងរាជវាំង។ កាលណាហ្លួងសោយអាភៀនអស់កម្លាំង ហើយសម្ងំផ្ទុំ មានស្នំឈ្មោះ "ម៉មនូ ក៏ឡើងទៅសម្រាន្តលើគ្រែជិតលោកឱបរឹតគ្នាទៅវិញទៅមក គ្មានគិតខ្មាស់អៀនពួក

[124] សារ៉ាម៉ានី ជាឈ្មោះមេហសីទី១របស់ស្តេចកុមាមួយអង្គ ដែលហ្លួងស៊ីសុវត្ថិបានដាក់ឲ្យក្មេងស្រីអាយុ ១២ឆ្នាំជាអ្នករាំបាំនៅក្នុងរាជវាំងនិងជាអ្នកបម្រើទ្រង់ (សៀវភៅ៖ អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ ៤២។ Rolang MEYER បានរស់នៅស្រុកខ្មែរក្នុងរជ្ជកាលហ្លួងស៊ីសុវត្ថិ។ សម្រាប់ខ្ញុំ ឆាយ សុផល អាចជឿខ្លះមិនជឿខ្លះ ព្រោះថានៅក្នុងសៀវភៅនោះដែលជាប្រភេទសៀវភៅរឿងប្រលោមលោក គឺ Rolang MEYER បានរៀបរាប់អំពើល្អគាត់ច្រើនពីនាង សារ៉ាម៉ានី ដែលជាភរិយារបស់ខ្លួន។

[125] សៀវភៅ៖ សារ៉ាម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៤២



www.elibraryofcambodia.org

យើងដែលអង្គុយត្រៀបត្រានេះសោះ.....”[126]។ ជាទូទៅ សៀវភៅបានរៀបរាប់ពីអំពើអាសអាភា ការប្រើបន្ទូលអាមឹងដល់អ្នកបម្រើ តែទ្រង់មានព្រះទ័យសន្តោសប្រណីដល់អ្នកបម្រើ និងស្លៀកពាក់សតមមិនសោយអាហារនៅពេលថ្ងៃសីលម្តងៗ។



ព្រះបរមឆាយាល័ក្ខណ៍ ព្រះបាទ ស៊ីសុវត្ថិ

## ព្រះរាជគោរមងារ

- ព្រះជន្ម១៨វស្សា៖ ទ្រង់បានទទួលព្រះសុវណ្ណប័ដជាសម្តេចព្រះហរិរាជតណៃក្រៃកែវហ្វា។
- ព្រះជន្ម២៤វស្សា៖ ទ្រង់ឧបសមបទជាព្រះភិក្ខុនៅឯវត្តបវរនិវេស ក្រុងបាងកក ចំនួន១វស្សា។
- ព្រះជន្ម៣៦វស្សា៖ ទទួលការតែងតាំងជាសម្តេចព្រះមហាឧបរាជបរមបពិត្រក្រុងកម្ពុជា។
- ព្រះជន្ម៦៥ព្រះវស្សា៖ (២៤ មីនា ១៩០៤) គ្រងសិរីរាជសម្បត្តិជាព្រះចៅក្រុងកម្ពុជាធិបតី បន្តពីព្រះជេដ្ឋា [បងដែលមានមាតាទីទៃ] ព្រះបាទ នរោត្តម

## គ្រឿងឥស្សរិយយស

- មេដាយព្រះកិត្តិយសនៃប្រទេសបារាំង ឆ្នាំ១៩០៦
- គ្រឿងឥស្សរិយយសស្តេចការូលទី៣នៃប្រទេសអេស្ប៉ាញឆ្នាំ១៩១២
- គ្រឿងឥស្សរិយយសនាគរាជនៃប្រទេសអណ្ណាម [យួន] ឆ្នាំ១៩១២
- គ្រឿងឥស្សរិយយសវាសានៃប្រទេសស៊ុយអែត ឆ្នាំ១៩១២

---

[126] *សៀវភៅ៖ សារ៉ាម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ) ទំព័រ៤២*



www.elibraryofcambodia.org

- គ្រឿងឥស្សរិយយសជំរឹស និងគ្រឿងឥស្សរិយយសមហាមកុដនៃរាជាណាចក្រសៀម ឆ្នាំ១៩០០
- គ្រឿងឥស្សរិយយសឥណ្ឌូចិនថ្នាក់មាស ឆ្នាំ១៩០០
- គ្រឿងឥស្សរិយយសជំរឹរាប់លាន និងជំរឹសនៃព្រះរាជអាណាចក្រលាវ ឆ្នាំ១៩០៩



*ព្រះបរមសពព្រះបាទសម្ដេចព្រះ ស៊ីសុវត្ថិ (បណ្ណាល័យជាតិ)។*



*ព្រះរាជពិធីបុណ្យព្រះសពនៃព្រះបាទសម្ដេចព្រះ ស៊ីសុវត្ថិ នាឆ្នាំ១៩២៨ នៅក្នុងរាជធានីភ្នំពេញ។ រូប បណ្ណាល័យជាតិ*

www.elibraryofcambodia.org







ព្រះរាជពិធីបុណ្យព្រះសព
នៃព្រះបាទសម្តេច ស៊ីសុវត្ថិ។
រូបថតស្រង់ចេញពីគេហទំព័រ
*http://www.skyscrapercity.com/showthread.php?t=1491230&page=59*



ព្រះកោដ្ឋព្រះបាទ ស៊ីសុវត្ថិ
(បណ្ណាល័យជាតិ)



www.elibraryofcambodia.org





ព្រះបាទ ស៊ីសុវត្ថិ (រូបបណ្ណាល័យជាតិ)





ព្រះចេតិយរបស់ព្រះបាទ ស៊ីសុវត្ថិ និង ព្រះជាយាអ្នកម្នាង ៣៧ នៅលើកំពូលភ្នំឧដុង្គ (ស្ថិតនៅខាងត្បូងជាប់ព្រះចេតិយព្រះបាទអង្គឌួង) ដែលព្រះរាជបុត្រា ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស បានសាងសង់ថ្វាយសម្រាប់តម្កល់ព្រះអដ្ឋិ (រូប ឆាយ សុផល)



www.elibraryofcambodia.org





ព្រះបរមឆាយាលក្ខណ៍ព្រះបាទ ស៊ីសុវត្ថិ ទ្រង់យាងចូលព្រះជន្មចំណាស់ (រូបបណ្ណាល័យជាតិ)




ព្រះបរមរូបព្រះបាទ ស៊ីសុវត្ថិ ត្រូវបានសាងសង់នៅវត្តភ្នំ ហើយត្រូវបានសម្ពោធនាថ្ងៃទី២៣ កុម្ភៈ ឆ្នាំ១៩០៦។ រូបបណ្ណាល័យជាតិ។



www.elibraryofcambodia.org

# ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស





www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ មុនីវង្ស** គ្រងរាជបល្ល័ង្កបាន ១៤ព្រះវស្សា៖ ៩ សីហា ១៩២៧ - ២៤ មេសា ១៩៤១។ ព្រះអង្គឡើងគ្រងរាជ្យនៅពេលទ្រង់មានព្រះជន្មក្នុង៥២ព្រះវស្សា ហើយរាជពិធីពាក់មកុដឡើងគ្រងរាជបល្ល័ង្កជាផ្លូវការត្រូវបានរៀបចំនៅថ្ងៃទី២០ កក្កដា ឆ្នាំ ១៩២៨ នៅព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំងនារាជធានីភ្នំពេញ។ បន្ទាប់ពីគ្រងរាជសម្បត្តិមក ព្រះអង្គបានទទួលព្រះគោរមងារថា "ព្រះករុណា ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស ចមចក្រពង្ស ហរិរាជបរមិន្ទរភូវណៃក្រៃកែវហ្វា សុឡាឡៃ ព្រះចៅក្រុងកម្ពុជាធិបតី"។


ព្រះរាជរូប ស៊ីសុវត្ថិ មុនីវង្ស Le Palais Du Roi Du cambodge

**ប្រសូត៖** ២៧ ធ្នូ ១៨៧៥ នៅរាជធានីភ្នំពេញ ខណៈដែលនគរស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង។

**សោយព្រះសុវណ្ណគត៖** ២៤ មេសា ១៩៤១ ក្នុងព្រះជន្ម៦៥ព្រះវស្សានៅលើភ្នំបូកគោ ខេត្តកំពត។ នោះគឺជាព្រះសុវណ្ណគតដែលមហេសីនិងស្នំរាប់រយរបស់ព្រះអង្គបានដឹងជាមុន ពិសេសកាលនៅពីរបីឆ្នាំមុននេះ ដែលធ្វើឲ្យពួកគេក្រៀមក្រំជាខ្លាំង[127]។ ព្រះបានទទួលព្រះមរណនាមថា "ព្រះបរមខត្តិយកោដ្ឋ"[128]។

---

[127] *http://sopheak.wordpress.com/2009/04/24/sisowaths-body/*

[128] *សៀវភៅ៖ ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង (ទំព័រ៣០)*



www.elibraryofcambodia.org



**ព្រះបិតា៖ ស៊ីសុវត្ថិ**

ក្រៅពីអ្នកម្នាង វ៉ាន់ និងរាជបុត្រ ស៊ីសុវត្ថិ មុនីវង្ស ព្រះបាទ ស៊ីសុវត្ថិ មានមហេសី១៥អង្គ/នាក់ និងបុត្រ២៨អង្គផ្សេងទៀត (បុត្រា១៥អង្គ និងបុត្រី១៣អង្គ)។ នេះមិនទាន់គិតពីស្នំផ្សេងៗនៅឡើយទេ។

អ្នកម្នាង វ៉ាន់



**ស៊ីសុវត្ថិ មុនីវង្ស**



នរោត្តម កានវិមាន នរល័ក្ខទេវី

ក្រៅពីម្ចាស់ក្សត្រិយ៍ នរោត្តម កានវិមាន នរល័ក្ខទេវី ជាមួយនិងបុត្រ៤អង្គ៖

- ស៊ីសុវត្ថិ ជារេត រង្សី នារីវង្ស
- ស៊ីសុវត្ថិ កុសមៈ
- ស៊ីសុវត្ថិ មុនីរ៉េត
- ស៊ីសុវត្ថិ មុនីពង្ស

គឺព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មានមហេសី១៥អង្គ/នាក់ និងបុត្រ២៤អង្គផ្សេងទៀត នេះមិនទាន់គិតស្នំផ្សេងៗនៅឡើយទេ។

ស៊ីសុវត្ថិ ជារេត រង្សី នារីវង្ស

ស៊ីសុវត្ថិ កុសមៈ



ស៊ីសុវត្ថិ មុនីរ៉េត



ស៊ីសុវត្ថិ មុនីពង្ស





www.elibraryofcambodia.org

ព្រះបិតា៖ ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ

ព្រះមាតា៖ អ្នកម្នាង វ៉ាន់ ដែលក្រោយមកមានព្រះគោរមងារជា "សម្តេចព្រះវររាជិនី"។

ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មានមហេសីចំនួន១៦អង្គ/នាក់ និងព្រះរាជបុត្រាបុត្រីចំនួន២៤អង្គ[129]៖


នរោត្តម កាញ្ចនវិមាន

**មហេសីទី១៖** សម្តេចព្រះមហាក្សត្រិយ៍ នរោត្តម កានវិមាន នរលក្ខណ៍ទេវី មានបុត្រីបួនអង្គគឺ៖

- សម្តេចព្រះរៀម ស៊ីសុវត្ថិថាវេត រង្សី នារីវង្ស (៣០ មីនា ១៨៩៩ - ១៩៧៥)
- សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (០៩ មេសា ១៩០៤-២៨ មេសា១៩៧៥)
- សម្តេចក្រុមព្រះស៊ីសុវត្ថិ មុនីរ៉េត (២៥ វិច្ឆិកា ១៩០៩ - ១៩៧៥??)
- ព្រះអង្គម្ចាស់ព្រះអង្គក្រុមហ្លួង ស៊ីសុវត្ថិ មុនីពង្ស (២៥ សីហា ១៩១២- ៣១ សីហា ១៩៥៦)

**មហេសីទី២៖** ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ស៊ីសូដា (Sisoda) មានបុត្រីមួយអង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ សូដារួនស៊ី (Sodaruonsi) ប្រសូត៖ ១៣ វិច្ឆិកា ១៩០៣- សុគត៖ ១៩៧៥

---

[129] *ឯកសារមួយសរសេរថា សម្តេចព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មានបុត្រ២៦អង្គ (បុត្រា១៣អង្គ និងបុត្រី១៣អង្គ)៖ http://www.royalark.net/Cambodia/camboa17.htm ប៉ុន្តែឯកសារមួយទៀតសរសេរថា មានបុត្ររហូតដល់ទៅ៦៨អង្គ៖ http://en.wikipedia.org/wiki/Sisowath_Monivong*



www.elibraryofcambodia.org

**មហេសីទី៣៖** អ្នកម្នាង គីម ហូ (Kim Ho) មានបុត្រាមួយអង្គគឺ៖
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីជាតិ (Monicheat) ប្រសូត៖ ៨ តុលា ១៩២២- សុគត៖ ១៩៧៥

**មហេសីទី៤៖** ព្រះនាង សុវត្ថិធំ នរល័ក្ខ មាឃ (Sowathchhom Norleak Meakh) មានបុត្រាមួយអង្គគឺ៖
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ Kussarak (២១ ឧសភា ១៩២៦ - ១៩៧៥)

**មហេសីទី៥៖** ព្រះនាង នរល័ក្ខ បវរ សៅខុន (Norleak Bavar Saokhon) មានបុត្រាមួយអង្គគឺ៖
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សដារ៉ក (Pongdarak) ប្រសូត៖ ៣១ កក្កដា ១៩២៨- សុគត៖ ១៩៧៥

**មហេសីទី៦៖** ព្រះនាង អាណុង លក្ខណាបានយេន (Anong Leakhana Ban Yen) មានបុត្រាមួយអង្គគឺ៖
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វង្សមុនី (២២ កុម្ភៈ ១៩២៩- ១៩៧៥)

**មហេសីទី៧៖** អ្នកម្នាង បុប្ផានរល័ក្ខ តាត មានបុត្រ៤អង្គ៖
- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ មុនីកេសន (៦ មេសា ១៩២៩-១៩៤៦)
- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សាមានវរពង្ស (១៣ មេសា ១៩៣១- ១៩៧៥)
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វង្សជីវន្ត័ (១៥ មិថុនា ១៩៣៣-១៩៧០)
- សម្តេច ស៊ីសុវត្ថិ ជីវន្តមុនីរក្ស (០១ កុម្ភៈ ១៩៣៦ - ?)

**មហេសីទី៨៖** អ្នកម្នាង កេសរ មាលី ណាត (Kessar Meali Nat) មានបុត្រ២អង្គគឺ៖
- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ពង្សសានមុនី (Pongsanmoni ៖ ២៦ មិថុនា ១៩២៩-១៩៧៤)
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីលក្ខណា (Monileakhana) ប្រសូត៖ ១១ មិថុនា ១៩៣១- សុគត៖ ១៩៧១



www.elibraryofcambodia.org

**មហេសីទី៩៖** ព្រះនាង នារី កេសរ ត្រយង់យឹម (Neary Kessar Trayang Yem) មានបុត្រ២អង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ រិនមុនី (Rinmoni) ប្រសូត៖ ៨ មករា ១៩៣០ - សុគត៖ ១៩៨៤

- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីជីវន្ត (Monichivan) ប្រសូត៖ ២៩ តុលា ១៩៣២ - សុគត៖ ១៩៧៥

**មហេសីទី១០៖** ព្រះនាង នារីន កេតសន អុល (Nearin Ketsan Ol) មានបុត្រាមួយអង្គគឺ៖

- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ រ័ត្នមុនី (Rothmoni) ប្រសូត៖ ២ មករា ១៩៣១ - សុគត៖ ១៩៧៥

**មហេសីទី១១៖** អ្នកម្នាង បវរមាលី ភាង (Bavar Meali Phieng) មានបុត្រីមួយអង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ សាមនរក្ស (Samanrak៖ ៩ ឧសភា ១៩៣០-១៩៧៥)

**មហេសីទី១២៖** អ្នកម្នាង នារី បុប្ផាភាព (Neary Bopha Pheap) មានបុត្រីមួយអង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ សុភាព នារី (Sopheap Neary) ប្រសូត៖ ៣ តុលា ១៩៣១ - សុគត៖ ១៩៧៥

**មហេសីទី១៣៖** អ្នកម្នាង កានីន (Kanin) មានបុត្រីមួយអង្គ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ភួងមុនី (Phuongmoni) ប្រសូត៖ ១៦ មេសា ១៩៣២ - សុគត៖ ១៩៧៥

**មហេសីទី១៤៖** អ្នកម្នាង ឆវី កេសរ សាមូ (Chhavi Kessar Samoo) មានបុត្រីមួយអង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ លម្អរ កេសរ (Lomarkessar) ប្រសូត៖ ៣ តុលា ១៩៣២- សុគត៖ ២០០៦

**មហេសីទី១៥៖** អ្នកម្នាង មុំដួង មុនីរក្ស អ៊ិស (Mam Duong Monirak



www.elibraryofcambodia.org

Ous) មានបុត្រាមួយអង្គគឺ៖

- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដួង ជីវិន (Duong Chivin) ប្រសូត៖ ២១ ឧសភា ១៩៣៣- សុគត៖ ១៩៧៥

**មហេសីទី១៦៖** អ្នកម្នាង ស៊ីសាម៉ន នារី (Nearisisaman Neary) មានបុត្រីមួយអង្គគឺ៖

- ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ នារីបុងង៉ា (Nearibonga) ប្រសូត៖ ១០ កញ្ញា ១៩៣៥ - សុគត៖ ?

ក្រៅពីនោះ ព្រះបាទសម្ដេច ស៊ីសុវត្ថិ មុនីវង្ស ក៏មានស្នំជាច្រើននាក់ទៀតដែរ តែមានយ៉ាងតិច៦នាក់ត្រូវបានទទួលស្គាល់ជាផ្លូវការ ក្រោយពីបានប្រសូតបុត្រថ្វាយជូនព្រះអង្គ។ នៅក្នុងចំណោមស្នំទាំងនោះ ស្ត្រីម្នាក់ត្រូវបានគេហៅថា "មាឃ" ហើយនាងជាសមាជិកនៃក្រុមរបាំព្រះរាជទ្រព្យ ដែលទទួលបានងារថា "ឃុនព្រះម្នាងបុប្ផានរល័ក្ខ មាឃ"។ នៅក្នុងឆ្នាំ១៩៣៤/១៩៣៥ ប្អូនជីដូនមួយ២នាក់របស់អ្នកម្នាងមាឃបានមករស់នៅជាមួយ ក្នុងនោះប្អូនជីដូនមួយដែលអាយុក្មេងជាងគេប្រហែល៦ទៅ៧ឆ្នាំ ត្រូវបានគេស្គាល់ឈ្មោះថាជា "សាឡុត ស" ដែលក្រោយមកដូរឈ្មោះជា ប៉ុល ពត។ ក្រោយមក ប៉ុល ពត ដែលធ្លាប់បានចូលវាំងនិងស្គាល់មហាក្សត្រនោះបានក្លាយជាស្ថាបនិកនៃរបបខ្មែរក្រហមប្រល័យពូជសាសន៍នាឆ្នាំ ១៩៧៥-១៩៧៩។



ព្រះបរមឆាយាល័ក្ខណ៍ ស៊ីសុវត្ថិ មុនីវង្ស (បណ្ណាល័យជាតិ)



www.elibraryofcambodia.org

## ការសិក្សា

**១៩០៥៖** ព្រះអង្គបានចូលសិក្សានៅក្នុងសាលាយោធាសាំងមេហ្សង់ (Saint-Maixent) នៅទីក្រុងប៉ារីស ប្រទេសបារាំង។

**១៩០៥ - ១៩០៦៖** បន្តការសិក្សាអនុបណ្ឌិតផ្នែកគ្រប់គ្រងគ្រួសាររាជវង្ស។ បន្ទាប់ពីបញ្ចប់ការសិក្សារយៈពេល២ឆ្នាំមក ព្រះអង្គបានទទួលឋានន្តរសក្តិជា "អនុសេនីយ៍ត្រី" នៅក្នុងជួរកងទ័ពបារាំង (French Foreign Legion) ហើយត្រូវបានឲ្យយាងទៅកាន់ទីក្រុងប្រ៊ីវ (Brive) និងបន្ទាប់មកទៅកាន់ទីក្រុងប៉ារីសវិញ។

## រាជបល្ល័ង្ក និងរាជកិច្ច

**១៨៩៣ - ១៩០៥៖** ជាមន្ត្រីជំនួយការផ្នែកយោធាឲ្យព្រះបិតារបស់ទ្រង់ គឺព្រះមហាក្សត្រព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ។

**១៩០៩៖** ព្រះអង្គបានយាងត្រឡប់មកកម្ពុជាវិញ ហើយក៏ត្រូវបាន តម្លើងឋានន្តរសក្តិជា "អនុសេនីយ៍ទោ"។ នៅឆ្នាំនោះ សៀមក៏បានសាងសង់រាជដំណាក់មួយសម្រាប់ព្រះរាជារាមាទីបួន (Rama IV) របស់ខ្លួនក្នុងខេត្ត ប្រាជីនបុរី (Prachin Buri)។ ដំណាក់នេះមានឈ្មោះថា ចៅប្រាយ៉ា អាបាយប៊ូបេត (Chao Phraya Ab-haibhubate)



ព្រះបរមសាលយាល័យខ្លាំ ស៊ីសុវត្ថិ ឧទ័យ (បណ្ណាល័យជាតិ)



www.elibraryofcambodia.org

ទុកសម្រាប់ឲ្យព្រះរាជាអង្គនោះគង់នៅពេលទ្រង់យាងមកខេត្តប្រាជីនបូរីម្តងៗ។ ខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅទស្សនាអគារនោះដែរ ដែលមើលទៅមានសណ្ឋានប្រហាក់ប្រហែលនឹងអគារចាស់របស់សាលាខេត្តបាត់ដំបងដែរ។ បច្ចុប្បន្ន អគារនេះបានក្លាយជាសារមន្ទីរ ហើយមួយផ្នែកក្នុងបរិវេណអគារយកធ្វើជាកន្លែងព្យាបាលរោគនិងធ្វើសរសៃតាមបែបបុរាណរបស់សៀម។ ដំណាក់នោះគឺជាទីតាំងយុទ្ធសាស្ត្រមួយសំខាន់ដែរសម្រាប់ស្តេចស្យាមនាពេលនោះក្នុងការធ្វើទំនាក់ទំនងក្នុងការគិតគូរពីបញ្ហាទឹកដីកម្ពុជាក្នុងតំបន់ភាគពាយ័ព្យ។



www.elibraryofcambodia.org



ដំណាក់ចៅព្រាយ៉ា អាបាយប៊ូបេតក្នុងខេត្តប្រាជីនបុរី ប្រទេសថៃ (រូប ឆាយ សុផល៖ ៣ សីហា ២០០៥)



បុគ្គលិកនៅអគារអតីតៈដំណាក់ចៅព្រាយ៉ា អាបាយប៊ូបេត ក្នុងខេត្ត ប្រាជីនបុរី ពន្យល់ប្រាប់អ្នកទស្សនា អំពីប្រវត្តិនៃអគារនោះ (រូប ឆាយ សុផល ៖ ៣ សីហា ២០០៥)



www.elibraryofcambodia.org




ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីវង្ស (ឆ្វេង) ជួយរាជកិច្ចព្រះបិតាព្រះបាទ ស៊ីសុវត្ថិ (រូបបណ្ណាល័យជាតិ)



ព្រះរាជបុត្រា ស៊ីសុវត្ថិ មុនីវង្ស (រូបគង់នៅកណ្ដាល) ក្នុងឯកសណ្ឋានយោធាជាមួយកងទ័ពបារាំងនាឆ្នាំ ១៩២០ (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org

**១៩១០៖** ទទួលបានឋានន្តរសក្តិជា "អនុសេនីយ៍ឯក"។

**១៩១៦៖** ទទួលបានឋានន្តរសក្តិជា "មេបញ្ជាការកងវរសេនាតូច។

**១៩២២៖** ព្រះអង្គបានរួចផុតពីកាតព្វកិច្ចយោធា។ ក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទី១ ព្រះអង្គបានបំពេញតួនាទី ជានាយទាហានស្ម័គ្រចិត្តយ៉ាងសកម្ម។ ការបំពេញភារកិច្ចយោធានេះដែលនាំឲ្យព្រះអង្គបានទទួលមេដាយ Cross of Commander of the Foreign Legion និងមានព្រះគោរមងារជា "សម្តេចព្រះកែវហ្វា"។ បន្ទាប់មក ព្រះអង្គបានទទួលព្រះតំណែងជា "អគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រី" និងជា "អធិបតីនៃក្រុមសង្គហៈ [ការពារ] ព្រះរាជវង្សានុវង្ស"។

**១៩១៦ - ១៩២៧៖** បន្តធ្វើជាមន្ត្រីជំនួយការផ្នែកយោធាឲ្យព្រះបិតារបស់ទ្រង់ជាថ្មី។

**៩ សីហា ១៩២៧៖** ព្រះអង្គត្រូវបានជ្រើសតាំងឲ្យឡើងគ្រងរាជ្យបន្តពីព្រះបិតា គឺព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ តែរាជពិធីពាក់មកុដឡើងគ្រងរាជបល្ល័ង្កជាផ្លូវការត្រូវបានរៀបចំនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩២៨។



www.elibraryofcambodia.org



រាជពិធីឡើងគ្រងរាជ្យរបស់ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស។ រូបលើនៅក្នុងសៀវភៅ *Le Palais Du Roi Du Cambodge* រូបក្រោមបានមកពីបណ្ណាល័យជាតិ ។






www.elibraryofcambodia.org







រាជពិធីឡើងគ្រងរាជ្យរបស់ព្រះបាទ
សម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស ដោយ
មានក្បួនដំរីដង្ហែក្នុងព្រះរាជពិធីផង។
(រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org





ព្រះបរមឆាយាលក្ខណ៍ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស គង់ប្រថាប់លើគជបល្ល័ង្ក។

រូបលើ៖ Le Palais Du Roi Du cambodge
រូបក្រោម៖ បណ្ណាល័យជាតិ



www.elibraryofcambodia.org



*ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស ជិះសេះនៅក្នុងរាជពិធីឡើងគ្រងរាជ្យ (រូប បណ្ណាល័យជាតិ)។*

នៅក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស គឺប្រទេសកម្ពុជាហាក់ដូចជាបានបើកចំហនូវឥទ្ធិពលកុម្មុយនីស្តមកពីខាងក្រៅ ដែលប្រការនេះធ្វើឲ្យបារាំងមិនសូវសប្បាយចិត្ត។ ដូចអំណាច ព្រះបិតារបស់ទ្រង់ដែរ គឺព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ពុំសូវមានអំណាចផ្នែករដ្ឋបាលឡើយ ព្រោះអំណាចស្ថិតនៅក្នុងកណ្តាប់ដៃនៃអគ្គទេសាភិបាលបារាំងភាគច្រើន។

**១៩៣០៖** ហូ ជីមិញ មេដឹកនាំកុម្មុយនីស្តវៀតណាមបានស្វែងយល់ថា "បក្សកុម្មុយនីស្តឥណ្ឌូចិន" ដែលខ្លួនបានបង្កើតឡើងដើម្បីប្រឆាំងនឹងអាណានិគមបារាំងពិតជាទទួលបានប្រជាប្រិយភាពគួរឲ្យកត់



www.elibraryofcambodia.org

សម្គាល់នៅក្នុងប្រទេសកម្ពុជា ព្រោះថា នៅកម្ពុជាក៏មានចលនាបះបោរប្រឆាំងបារាំងដែរ។ ការបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់ ហូ ជីមិញ មានគោលបំណងជាអាទិភាពមួយ គឺការវាយផ្តួលរំលំពួកអាណានិគមបារាំង។ ដោយស្របគ្នានឹងគំនិតរបស់ខ្លួនដែរ ចលនាអ្នកប្រឆាំងបារាំងនៅកម្ពុជាដែលបានកើតមានតាំងពីមុនមកនោះ ក៏បានចូលរួមជាមួយបក្សកុម្មុយនីស្តឥណ្ឌូចិននាឆ្នាំ១៩៤០ ហើយបានបង្កើតសាខា "បក្សកុម្មុយនីស្តកម្ពុជា" នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក នៅខែ មេសា ឆ្នាំ ១៩៥០ គឺក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីមួយ គណប្រតិភូចំនួនពីររយនាក់បានជួបជុំគ្នានៅស្រុកកំពង់ត្រាច ខេត្តកំពត ហើយបានបង្កើតរណសិរ្សឯកភាពឥស្សរៈ ឬហៅថា ខ្មែរឥស្សរៈ ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត ដោយរណសិរ្សនេះបានសហការជាមួយវៀតណាមដើម្បីធ្វើការប្រឆាំងអាណានិគមបារាំងជាចំហ[130]។ ចំណែកនៅប្រទេសសៀមវិញ ចលនាកុម្មុយនីស្តដឹកនាំដោយ ហូជីមិញ ក៏មានឥទ្ធិពលដែរ ហើយសៀមក៏ជាមូលដ្ឋានសម្រាប់ជនជាតិយួន ខ្មែរ លាវ និងភូមា ដើម្បីតស៊ូរំដោះប្រទេសរបស់ខ្លួនចេញពីអាណានិគមបារាំង[131]។

[130] *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទំព័រ៦ របស់ DC-Cam*
[131] *សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ (ប្រែជាភាសាខ្មែរ៖ ទំព័រ២៨៩)*



www.elibraryofcambodia.org





រូបឆ្វេងគឺទិដ្ឋភាពនៃល្អាងស្ថិតនៅខាងក្នុងភ្នំគិរីសិលា ក្នុងភូមិ តំណាក់កន្ទួត (ក្បែរភូមិកន្ទោរ) ឃុំតំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ដែលអ្នកប្រវត្តិសាស្ត្រខ្លះសង្ស័យថា ជាកន្លែងលាក់ខ្លួនរបស់ពួកកុម្មុយនីស្តបង្កើតរណសិរ្សឯកភាពឥស្សរៈ ឬ ខ្មែរឥស្សរៈ ដំបូងគេនាខែមេសា ឆ្នាំ ១៩៥០ ដែលមានពួកកុម្មុយនីស្តវៀតណាមជាមេខ្យល់។ ភ្នំនេះមើលពីខាងក្រៅមិនដឹងថាមានទីធ្លាធំនៅខាងក្នុងឡើយ ដោយមានរូងតូចៗជាច្រើនងងឹតសូន្យសុងចូលទៅទីធ្លានោះ ដែលជាទីយុទ្ធសាស្ត្រប្រកបដោយសុវត្ថិភាពសម្រាប់លាក់ខ្លួននិងប្រមូលផ្តុំគ្នា។ នៅលើផ្ទាំងសិលាខាងក្នុងល្អាងភ្នំក៏មានគេសរសេរអក្សរវៀតណាមដែរ។ បច្ចុប្បន្នភ្នំនេះក្លាយជារមណីយដ្ឋាន ហើយពេលចូលទៅទីធ្លាខាងក្នុងត្រូវដើរឱនៗនិងប្រើពន្លឺបំភ្លឺ។ រូបថត ឆាយ សុផល (១ វិច្ឆិកា ២០១៤)។ រូបលើគឺទិដ្ឋភាពខាងក្រៅនៃ "ភ្នំគិរីសិលា" ហៅ "ភ្នំកំពង់ត្រាច"។



www.elibraryofcambodia.org





រូបលើ៖ ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស យាងចេញពីព្រះបរមរាជវាំង។

រូបឆ្វេង៖ ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស (ស្តាំ) និងអភិបាលបារាំងលោក M. Le Vo នាឆ្នាំ១៩២៨ (រូបបានមកពីបណ្ណាល័យជាតិ)។



www.elibraryofcambodia.org







មន្ត្រីអាណាព្យាបាលបារាំងមកទស្សនកិច្ចនៅព្រះបរមរាជវាំងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស និងទស្សនារបាំព្រះរាជទ្រព្យ (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org










រូបពីរខាងលើ៖ ទិដ្ឋភាពព្រះបរមរាជវាំងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស។ (រូបបណ្ណាល័យជាតិ)។

រូបឆ្វេង៖ ត្រូវបានគេអះអាងថា ជាអ្នកថែសួនក្នុងព្រះបរមរាជវាំងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស (រូបបណ្ណាល័យជាតិ)។



www.elibraryofcambodia.org





រូបឆ្វេង៖ បារាំងសង់ស្តូបរំលឹកវិញ្ញាណក្ខន្ធអ្នកដែលបានបាត់ជីវិតនៅក្នុងសង្គ្រាមលោកលើកទី១នៅក្បែរស្ពានខុតបារាំងនាឆ្នាំ១៩៣៩ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស តែត្រូវខ្មែរក្រហមកម្ទេចចោលនាឆ្នាំ១៩៧៥ (រូបបណ្ណាល័យជាតិ)។ រូបស្តាំ៖ រូបសំណាកកាំភ្លើងក្ងកាណុងត្រូវបានសាងសង់នៅឆ្នាំ១៩៩៩ ជំនួសស្តូបរំលឹកវិញ្ញាណក្ខន្ធអ្នកដែលបានបាត់ជីវិតនៅក្នុងសង្គ្រាមលោកលើកទី១ (រូប ឆាយ សុផល)។



www.elibraryofcambodia.org

**ចុងឆ្នាំ១៩៤០៖** ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស បានកត់សម្គាល់អំពីការលុកលុយរបស់ពួកជប៉ុនចូលទៅវៀតណាម បន្ទាប់ពីបារាំងបានចាញ់សង្គ្រាមពួកណាហ្ស៊ី (Nazi) អាល្លឺម៉ង់ កាលពីដើមឆ្នាំ ដែលអាចនាំឲ្យប្រទេសធ្លាក់ចូលក្នុងកណ្តាប់ដៃជប៉ុន។

**ដើមឆ្នាំ១៩៤១៖** ដូចការគិត ពួកជប៉ុនបានឈ្លានពាននិងកាន់កាប់ទឹកដីកម្ពុជា ហើយបានឲ្យពួកមន្ត្រីខ្មែរដែលនិយមបារាំងកន្លងមកបន្តកាន់កិច្ចការដដែល តែស្ថិតនៅក្រោមការត្រួតត្រារបស់ជប៉ុនទាំងអស់។ ចំណែកឯព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ពិតជាគ្មានជម្រើសឡើយ ពោលគឺ ព្រះអង្គដែលធ្លាប់តែគោរពតាមបារាំងពីមុនមក ត្រូវតែងាកមកគោរពជប៉ុនវិញម្តង។ នៅភាគខាងលិចនិងពាយ័ព្យនៃប្រទេសកម្ពុជានាពេលនោះ ដែលឆក់ឱកាសបារាំងជាប់ដៃធ្វើសង្គ្រាមជាមួយអាល្លឺម៉ង់ហើយឥទ្ធិពលដូចជាថម ថយនៅឥណ្ឌូចិន ថៃបានឱកាសក៏ចូលមកកាន់កាប់ដែនដីដូចជាកោះកុង បាត់ដំបង និងសៀមរាបសារជាថ្មី[132]។ សៀមក៏បានចូលមកគ្រប់គ្រងប្រាសាទព្រះវិហារ និងតំបន់នៅជុំវិញប្រាសាទដែរ។ ក្រោយពីបានជ្រាបថា សៀមបានចូលមកកាន់កាប់ដែនដីខ្មែរជាថ្មី ខណៈដែលមានព្រះជន្មកាន់តែច្រើនផង (៦៥ព្រះវស្សា) ហើយកំពុងប្រឈួនផងនោះ ទ្រង់បានខ្វាល់ជាពន់ពេក ហើយព្រះអង្គក៏យាងទៅព្រះរាជដំណាក់នៅលើកំពូលភ្នំបូកគោនាខេត្តកំពតក្នុងបំណងសម្រាកព្រះកាយពីព្រះរាជកិច្ច។ គួរបញ្ជាក់ថា ចាប់ពីថ្ងៃទី៧ ធ្នូ ១៩៤១ លោក ភិបុលសង្គ្រាម ក្នុងនាមជាសេនាប្រមុខផងនិង

[132] *ឆ្នាំ១៩៣៩ សៀម បានប្តូរឈ្មោះប្រទេសរបស់ខ្លួនទៅជា "ថៃ" ព្រោះពាក្យថា "សៀម" អាចមានន័យថា ជាជនជាតិភាគតិច (សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ ទំព័រ៣១៥)*



www.elibraryofcambodia.org

នាយករដ្ឋមន្ត្រីសៀមផងបានចេញដំណើរពីបាងកកមកកាន់បណ្តាខេត្ត ដែលប្រទេសខ្លួនទើបតែយកបាននាពេលថ្មីៗពីកម្ពុជា[133]។

**២៤ មេសា ១៩៤១៖** ក្នុងព្រះជន្ម ៦៥ ព្រះវស្សា ទ្រង់បានសោយព្រះសុវណ្ណគតនៅក្នុងដំណាក់លើកំពូលភ្នំបូកគោនោះទៅ។ ក្រុមអាចារ្យខ្មែរបានយកព្រះបរមសពរបស់ព្រះអង្គដាក់អប់នឹងទឹក ពិសេសដើម្បីរក្សាសាច់របស់ទ្រង់ និងយកសរីរាង្គខាងក្នុងរបស់ទ្រង់ទាំងអស់ចេញ លើកលែងតែបេះដូងនិងព្រះខួរ។ បន្ទាប់មក ពួកគេចងព្រះសពដាក់ក្នុងព្រះកោដ្ឋក្នុងស្ថានភាពដូចទារកដែលមិនទាន់ប្រសូត ហើយជាសញ្ញាណថា កំពុងប្រុងប្រៀបយាងទៅប្រសូតជាថ្មី[134]។ ក្រោយមកមួយសប្តាហ៍ ក្រុមអាចារ្យបានយកព្រះបរមសពចេញមកសម្អាតទឹក ហើយទ្រង់ព្រះភូសា [គ្រឿងស្លៀកពាក់] ដោយមានគ្រឿងរាជឥស្សរិយយសដំរីរាប់លាន (គ្រឿងរាជឥស្សរិយយសរបស់ព្រះរាជអាណាចក្រលាវ) និងក្លស់ [ឆត្រ] ពណ៌ស ហើយដាក់ព្រះសពវិញទៅក្នុងកោដ្ឋធ្វើពីកែវយ៉ាងប្រណីត។ ព្រះសង្ឃក្នុងសំពត់ពណ៌លឿងរាប់ពាន់អង្គបានហែហមព្រះកោដ្ឋនៅតាមដងផ្លូវនានាក្នុងរាជធានីភ្នំពេញ ដោយព្រះបរមសពត្រូវបានផ្លាស់យកទៅដាក់ក្នុងមឈូសដ៏ប្រណីតធ្វើអំពីមាសនិងប្រាក់។ ព្រះមហាក្សត្រថ្មី គឺព្រះបាទនរោត្តម សីហនុ បានថ្វាយព្រះភ្លើងរំលាយព្រះបរមសពនៃព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស។ លោក Jean Decoux ដែលធ្លាប់ជាឧត្តមនាវីឯកបារាំងប្រចាំឥណ្ឌូចិនក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ និងឧត្តមសេនីយជប៉ុន តំណាងអធិរាជប្រទេសជប៉ុន Hirohito ផងដែរ។ ព្រះអង្គបានទទួលព្រះបរមបច្ឆាមរណនាមថា "ព្រះបរមខត្តិយកោដ្ឋ"។

---

[133] *សៀវភៅ៖ ប្រវត្តិសាស្ត្រថៃ (ប្រែជាភាសាខ្មែរ៖ ទំព័រ៣១៩)*

[134] *http://sopheak.wordpress.com/2009/04/24/sisowaths-body/*



www.elibraryofcambodia.org





ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស

រូបលើ៖ អតីតព្រះរាជដំណាក់ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស នៅលើកំពូលភ្នំបូកគោ (រូប ឆាយ សុផល៖ ២ វិច្ឆិកា ២០១៤)។

រូបក្រោម៖ ខ្ញុំអ្នកចងក្រងសៀវភៅ (ស្តាំ) និង អូន ឆេងប៉េ និស្សិតសារព័ត៌មាននៅក្នុងក្រឡាព្រះបន្ទំ (បន្ទប់ដំណេក) របស់ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ក្នុងអតីតព្រះរាជដំណាក់ព្រះអង្គលើកំពូលភ្នំបូកគោ។ ក្រឡាព្រះបន្ទំនេះក៏អាចជាកន្លែងដែលព្រះអង្គបានសោយព្រះទិវង្គតដែរ (រូប សេង ម៉ាណេត និស្សិតសារព័ត៌មាន ៖ ២ វិច្ឆិកា ២០១៤)



**២៥ មេសា ១៩៤១៖** មួយថ្ងៃក្រោយពីសោយព្រះសុវណ្ណគត ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កក៏បានជ្រើសតាំងនិងថ្វាយរាជសម្បត្តិជូនស្តេចអង្គថ្មី។ នៅពេលនោះ បើទោះបីជាព្រះរាជបុត្រព្រះនាម ស៊ីសុវត្ថិ មុនីរ៉េត សក្តិសមនឹងគ្រងរាជសម្បត្តិបន្តពីព្រះបិតា ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស ក៏ដោយ ក៏អាជ្ញាធរបារាំងមិនបានជ្រើសរើសយកព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ដែរ តែបែរជាជ្រើសរើសយកព្រះអង្គម្ចាស់ នរោត្តម សីហនុ ដែលជាព្រះរាជនត្តា [ចៅ] របស់សម្តេចព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ទៅវិញ។ ព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាបុត្រាតែមួយអង្គគត់របស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ កុសុមៈ និងព្រះអង្គម្ចាស់ នរោត្តម សុរាម្រិត ក៏បានស្នងព្រះរាជបល្ល័ង្កបន្តទៅវិញ តែពិធីពាក់មកុដឡើងគ្រងរាជបល្ល័ង្កជាផ្លូវការបានធ្វើឡើងនៅថ្ងៃទី២៨តុលាឆ្នាំដដែល[135]។ ការជ្រើសរើសយកព្រះអង្គម្ចាស់ នរោត្តម សីហនុ នេះ គឺពួកបារាំងជឿថា ទ្រង់មានព្រះជន្មក្មេង (១៩ព្រះវស្សា) ដែលងាយស្រួលក្នុងការបញ្ចុះបញ្ចូលជាងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ដែលមានព្រះជន្មចាស់ (៣២ព្រះវស្សា) ប៉ុន្តែក្រោយមក ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត បានឡើងធ្វើជានាយករដ្ឋមន្ត្រីដែរ[136]នៅក្នុងរជ្ជកាលដែលព្រះបាទសម្តេចព្រះនរោត្តម សីហនុ គ្រងរាជបល្ល័ង្ក។

---

*[135] សូមអានចំណុចនេះលម្អិតនៅក្នុងព្រះរាជជីវប្រវត្តិរបស់សម្តេច នរោត្តម សីហនុ នៅទំព័រក្រោយ និងនៅក្នុងសៀវភៅ៖ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា ?"*

*[136] សូមអានប្រវត្តិព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត នៅក្នុងសៀវភៅ៖ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា ?"*



www.elibraryofcambodia.org



ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស (បណ្ណាល័យជាតិ)



ព្រះរាជពិធីបុណ្យព្រះសពព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស នាឆ្នាំ១៩៤១ ។ រូបដកស្រង់ចេញពីគេហទំព័រ http://www.ebay.com/itm/King-Sisowath-Monivong-cremation-CAMBODIA-Norodom-Sihanouk-coronation-27-photos-/161101229349



www.elibraryofcambodia.org



ព្រះរាជពិធីបុណ្យព្រះសពព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស នាឆ្នាំ១៩៤១។ រូបថតស្រង់ចេញពីគេហទំព័រ

*http://www.ebay.com/itm/King-Sisowath-Monivong-cremation-CAMBODIA-Norodom-Sihanouk-coronation-27-photos-/161101229349*





www.elibraryofcambodia.org



ព្រះរាជពិធីបុណ្យព្រះសពព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស នាឆ្នាំ១៩៤១។ រូបថតស្រង់ចេញពី គេហទំព័រ

*http://www.ebay.com/itm/King-Sisowath-Monivong-cremation-CAMBODIA-Norodom-Sihanouk-coronation-27-photos-/161101229349*





www.elibraryofcambodia.org



រូបលើ៖ ព្រះរាជពិធីបុណ្យព្រះសពព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស នាឆ្នាំ១៩៤១។ រូបក្រោម៖ ក្រុមរបាំព្រះរាជទ្រព្យចូលរួមក្នុងព្រះរាជពិធីបុណ្យព្រះសព។ រូបដកស្រង់ចេញពីគេហទំព័រ *http://www.ebay.com/itm/King-Sisowath-Monivong-cremation-CAMBODIA-Norodom-Sihanouk-coronation-27-photos-/161101229349*





www.elibraryofcambodia.org





រូបលើ៖ ព្រះរាជពិធីបុណ្យព្រះសពព្រះបាទ សម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស នាឆ្នាំ១៩៤១។ រូបដកស្រង់ចេញពីគេហទំព័រ http://www.skyscrapercity.com/showthread.php?t=1166805&page=3

រូបក្រោម៖ ព្រះបាទ នរោត្តម សីហនុ (ស្តាំ) ព្រះមហាក្សត្រថ្មីព្រះជន្មក្មេង និងមន្ត្រីបាក់ងផ្ញើព្រះអដ្ឋិរបស់ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ព្រះខត្តិយកោដ្ឋដាក់ក្នុងព្រះកោដ្ឋទៅតម្កល់នៅចេតិយលើកំពូលភ្នំឧដុង្គ (រូបបណ្ណាល័យជាតិ)



www.elibraryofcambodia.org




ព្រះចេតិយរបស់ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស រាជបុត្រា ស៊ីសុវត្ថិ មុនីពង្ស និងព្រះបិតាព្រះបាទ ស៊ីសុវត្ថិ នៅលើកំពូលភ្នំឧដុង្គ (ស្ថិតនៅខាងត្បូងជាប់ព្រះចេតិយព្រះបាទអង្គឌួង)។ រូប ឆាយ សុផល ៖ ២៥ ឧសភា ២០១៣



www.elibraryofcambodia.org

## គ្រឿងឥស្សរិយយស

- គ្រឿងឥស្សរិយយស Legion of Honour នៃសាធារណរដ្ឋបារាំង
- គ្រឿងឥស្សរិយយសនាគរាជនៃប្រទេសអណ្ណាម ( យួន )
- គ្រឿងឥស្សរិយយសដំរីរាប់លាន និងសេតក្លស់នៃព្រះរាជអាណាចក្រលាវ
- គ្រឿងឥស្សរិយយស Leopold ប្រទេសបែលហ្ស៊ិក ឆ្នាំ១៩៣៥
- គ្រឿងឥស្សរិយយសថ្នាក់លេខមួយនៃប្រទេសស៊ុយអែត ឆ្នាំ១៩១២
- គ្រឿងឥស្សរិយយសព្រះអាទិត្យរះថ្នាក់លេខ២ នៃប្រទេសជប៉ុន
- គ្រឿងឥស្សរិយយស Nichan el-Anouar



ព្រះបរមឆាយាល័ក្ខណ៍ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស

- គ្រឿងឥស្សរិយយសផ្នែកអក្សរសាស្ត្រ និងសិល្បៈ និងកសិកម្មនៃសាធារណរដ្ឋបារាំង
- គ្រឿងឥស្សរិយយសថ្នាក់មាសរបស់សហព័ន្ធឥណ្ឌូចិន

## កំណត់សម្គាល់ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស

នៅក្នុងរជ្ជកាលរបស់ព្រះអង្គនាចន្លោះឆ្នាំ១៩២៧-១៩៤១ កម្ពុជាបានចាប់ផ្តើមទទួលជាចំហនូវនយោបាយកុម្មុយនីស្តពីក្រៅប្រទេស ហើយនៅឆ្នាំ១៩៣០ លោក ហូជីមិញ មេដឹកនាំចលនាតស៊ូរំដោះទឹកដីវៀតណាមឲ្យចេញពីអាណានិគមបារាំងក៏បានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន



www.elibraryofcambodia.org

ហើយបក្សនេះមានឥទ្ធិពលនិងប្រជាប្រិយ៍យ៉ាងខ្លាំងនៅកម្ពុជា ព្រោះថាកម្ពុជានាពេលនោះក៏ចង់រំដោះខ្លួនចេញពីនឹមត្រួតត្រារបស់អាណានិគមបារាំងដែរ[137]។

នៅក្នុងការគ្រប់របស់ព្រះអង្គ សមិទ្ធផលធំៗមួយចំនួនបានកើតឡើងហើយបានបន្សល់រហូតមកដល់សព្វថ្ងៃដូចជា៖

- មួយឆ្នាំក្រោយពីបានគ្រងរាជសម្បត្តិ ស្ពានឆ្លងទន្លេបាសាក់ក្រោមនៅម្តុំក្បាលថ្នល់ត្រូវបានសម្ពោធនាថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ១៩២៨ ហើយដាក់ឈ្មោះថា "ស្ពានព្រះមុនីវង្ស" ព្រះនាមព្រះអង្គក៏ត្រូវបានគេយកទៅដាក់ឈ្មោះផ្លូវដែរ គឺ "មហាវិថីព្រះមុនីវង្ស"។ មន្ទីរពេទ្យមួយនៅខាងត្បូងផ្សារថ្មីលើវិថីត្រសក់ផ្អែមក្នុងរាជធានីភ្នំពេញក៏ត្រូវបានដាក់ឈ្មោះថា "មន្ទីរពេទ្យយោធាព្រះមុនីវង្ស" ដែរ តែនៅឆ្នាំ១៩៧៩ ក្លាយជាពេទ្យនគរបាល។ នៅទសវត្សរ៍១៩៩០ មន្ទីរពេទ្យនេះបានដោះដូរជាមួយក្រុមហ៊ុនឯកជនបាត់ហើយ ដែលទីនោះក្លាយជាអគារក្រុមហ៊ុនឯកជនទៅវិញ។
- ស្ថានីយ៍រថភ្លើងដោយមានខ្សែរថលើកដំបូងពីភ្នំពេញទៅប៉ោយប៉ែតឆ្លងកាត់ពោធិសាត់និងបាត់ដំបងភ្ជាប់ទៅថៃដែលសម្ពោធនៅឆ្នាំ១៩៣២ (ចាប់ផ្តើមសាងសង់ឆ្នាំ១៩៣០) ហើយខ្សែរថពីរទៀតចេញពីភ្នំពេញទៅកំពតនិងពីភ្នំពេញទៅក្រុងព្រះសីហនុបានស្ថាបនាបន្តនៅរជ្ជកាលព្រះបាទ នរោត្តម សីហនុ។
- ផ្សារធំថ្មីបានសាងសង់នៅឆ្នាំ១៩៣៧

[137] http://en.wikipedia.org/wiki/Sisowath_Monivong



www.elibraryofcambodia.org

- ឧទ្យានលើកំពូលភ្នំបូកគោសម្រាប់ជាការកម្សាន្តសប្បាយ ហើយបារាំងក៏បានសង់រាជដំណាក់មួយសម្រាប់ព្រះបាទ មុនីវង្ស ផងដែរ។ ឧទ្យានដ៏ត្រកាលនៅភ្នំបូកគោត្រូវបានគេប្រសិទ្ធិនាមថា ជាឧទ្យានជាតិព្រះមុនីវង្ស ឬសួនឧទ្យានជាតិបូកគោ។

សណ្ឋាគារ និងកាស៊ីណូ (Casino) ដ៏ទំនើបក៏បានសាងសង់នៅក្បែរអតីតព្រះរាជដំណាក់ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ដែរ។ នៅទីនោះមានជនបរទេសជាច្រើន ពិសេសជនជាតិបារាំងបានមកស្នាក់នៅលំហែកាយ និងលេងល្បែងស៊ីសងផងដែរ។ គួររម្លឹកបន្តិចថា ឧទ្យានជាតិលើភ្នំបូកគោនេះត្រូវបានលោកវរសេនីយ៍បារាំងម្នាក់ចាប់ផ្តើមស្ថាបនាឡើងនៅឆ្នាំ ១៩២១ (សម្ភោធឆ្នាំ១៩២៥) ដើម្បីលោកបានស្នាក់នៅលំហែកាយគេចពីអាកាសធាតុដ៏ក្តៅនាខែប្រាំង ព្រោះនៅលើកំពូលភ្នំនោះមានអាកាសធាតុត្រជាក់ជាមួយខ្យល់បរិសុទ្ធក្បែរមាត់សមុទ្រ។ ម្យ៉ាងទៀត នៅលើកំពូលភ្នំនេះមានផ្ទៃទំនាបធំទូលាយខុសប្លែកពីកំពូលភ្នំផ្សេងទៀត ដែលមានកំពូលស្រួចនិងមានផ្ទៃរាបតូចៗ។ មានមនុស្សប្រមាណ៩០០នាក់បានស្លាប់នៅក្នុងរយៈពេល៩ខែនៃអំឡុងពេលស្ថាបនាទីលំហែកាយមួយនេះ[138]។ ជាបន្តបន្ទាប់ អគារជាច្រើនដោយមានទាំងវិហារសាសនាកាតូលិកផងត្រូវបានសាងសង់។ នៅចន្លោះឆ្នាំ ១៩៤០-១៩៤៥ ឧទ្យានជាតិនេះត្រូវបានបោះបង់ចោលជាលើកដំបូង ដោយសារបារាំងជាប់ដៃធ្វើសង្គ្រាមលោកលើកទី២ ខណៈដែលជប៉ុនកំពុងមានឥទ្ធិពលនៅអាស៊ី និងដោយឡែកនៅឥណ្ឌូចិន [កម្ពុជា វៀតណាម ឡាវ]។ ចាប់តាំងពីឆ្នាំ១៩៧២ រហូតមកដល់ដើមទសវត្សរ៍១៩៩០ ទីតាំងនេះបានក្លាយជាតំបន់ខ្មែរក្រហម ហើយអ្វីៗគ្រប់យ៉ាង

---

[138] *Michael Vickery, Cambodia 1975-1982, quoted from David Chandler at: http://en.wikipedia.org/wiki/Bokor_Hill_Station*



www.elibraryofcambodia.org

នៅទីនោះត្រូវបានបំផ្លាញ។ នៅឆ្នាំ២០១២ សណ្ឋាគារ និងកាស៊ីណូថ្មីមួយទៀតត្រូវបានសម្ពោធឡើងដែលសាងសង់ដោយក្រុមហ៊ុនសុខារបស់លោកឧកញ៉ា សុខ គង់ (ជាសេដ្ឋីសញ្ជាតិកម្ពុជាកាត់វៀតណាម) ដោយបោះបង់សណ្ឋាគារនិងកាស៊ីណូចាស់ចោល។ ក្រុមហ៊ុនបានកែលម្អហេដ្ឋារចនាសម្ព័ន្ធថ្មី ពង្រីកផ្លូវឡើងភ្នំ និងសង់រូបសំណាកយាយម៉ៅដ៏ធំ។ នៅឆ្នាំ២០១៤ ក៏មានជនជាតិវៀតណាមមកធ្វើពិធីបួងសួងនិងតាំងអាសនៈជាសក្ការៈរបស់ពួកគេនៅលើភ្នំនោះដែរ។

ក្រោយពីនោះ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ សភាសម្រាប់ឲ្យយោបល់មួយ (សភាខ្មែរ) ត្រូវបានបង្កើតឡើងតាមរាជបញ្ញត្តិថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩២៨ មានភារៈផ្តល់យោបល់ពីបញ្ហាពន្ធដារ បញ្ហារដ្ឋបាល ឬបញ្ហាបង្កើតផលទាក់ទងនឹងជីវភាពប្រជារាស្ត្រខ្មែរ។ សភានេះមានសមាជិក៤៦រូបៈ ៤១រូបត្រូវបានបោះឆ្នោតជ្រើសរើសចេញពីបញ្ញវន្តខ្មែរ និង៥រូបត្រូវបានតែងតាំងដោយគណៈរដ្ឋមន្ត្រី។ បន្ថែមពីលើនេះ ក្រុមជំនុំព្រះត្រៃបិដកក៏ត្រូវបានបង្កើតដែរនៅថ្ងៃទី១៤ វិច្ឆិកា ឆ្នាំ១៩២៩ ដោយក្រុមនេះមានភារកិច្ចបកប្រែព្រះត្រៃបិដក (វិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក)។ សព្វថ្ងៃនេះ គម្ពីរទាំង៣នោះត្រូវបានបកប្រែចប់សព្វគ្រប់ ហើយមានទាំងអស់ ១១០ក្បាល។ នៅឆ្នាំ១៩៣០ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យត្រូវបានបង្កើតដើម្បីបំពេញការងារសិក្សា និងស្រាវជ្រាវពីព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ដោយមិនបាច់ចេញទៅបរទេសដូចមុនៗទៀតទេ។ ក្នុងឆ្នាំនោះដែរ តាមរាជបញ្ញត្តិថ្ងៃទី១៦ ខែធ្នូ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ទ្រង់បានរៀបចំឲ្យមានការសិក្សាភាសាបាលី និងព្រះពុទ្ធលទ្ធិនៅទូទាំងប្រទេស ដែលជាហេតុនាំឲ្យមានការបង្កើតសាលាអនុវត្តសម្រាប់ព្រះសង្ឃ ផ្តល់ឱកាសឲ្យព្រះសង្ឃជាគ្រូបាននិមន្តទៅសិក្សាពីវិធីបង្រៀនតាមបែបទំនើបនៅទីនោះ៕



www.elibraryofcambodia.org



បូកគោ៖ សណ្ឋាគារនិងកាស៊ីណូ ក្នុងឆ្នាំ១៩២១ (រូបបណ្ណាល័យជាតិ)



សណ្ឋាគារនិងកាស៊ីណូ នៅថ្ងៃទី១ វិច្ឆិកា ២០១៤ (រូប ឆាយ សុផល)



បូកគោ៖ សណ្ឋាគារនិងកាស៊ីណូ ក្នុងឆ្នាំ១៩២១ (រូបបណ្ណាល័យជាតិ)



សណ្ឋាគារនិងកាស៊ីណូ នៅថ្ងៃទី១ វិច្ឆិកា ២០១៤ (រូប ឆាយ សុផល)

www.elibraryofcambodia.org

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ





www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានឡើងគ្រងរាជបល្ល័ង្កដោយចៃដន្យនិងដោយមិនដឹងខ្លួន ហើយចាប់តាំងពីបានគ្រងរាជ្យមក ព្រះអង្គបានសាងព្រះនាមល្បីល្បាញនៅក្នុងឆាកនយោបាយជាតិនិងអន្តរជាតិក្នុងសម័យកាលដ៏ទំនើបអស់រយៈពេល៧១ព្រះវស្សា។ ក្នុងមួយសង្វាររបស់ព្រះអង្គ គឺទ្រង់បានពើបប្រទះរសជាតិក្អាកក្អាយផ្អែមល្ហែមផងនិងល្វីងជូរចត់ផង ទាំងពីសំណាក់អ្នកនយោបាយជាតិ និងអ្នកនយោបាយបរទេស។ ព្រះអង្គក៏ធ្លាប់ទទួលរងការប្រមាថពីបុត្រ និងសមាជិករាជវង្សានុវង្សជាច្រើនអង្គផងដែរ។


ព្រះរាជកុមារ នរោត្តម សីហនុ ក្នុងឆ្នាំ១៩៣០

**ប្រសូត៖** ថ្ងៃអង្គារទី ៣១ តុលា ១៩២២ នៅរាជធានីភ្នំពេញ វេលាម៉ោង ៧ យប់។ បន្ទាប់ពីប្រសូតចេញពីផ្ទៃព្រះមាតាក្សត្រី សម្តេច នរោត្តម សុធារស ដែលត្រូវជាព្រះអយ្យកោ [ជីតា] បានដាក់ព្រះនាមឲ្យទារកមួយអង្គនេះថា "សីហនុ" គឺព្រះនាមដែលយកលំនាំតាមព្រះរាជាមួយអង្គនៅក្នុងរឿងព្រេងនិទានរបស់ប្រទេសឥណ្ឌា។ នៅពេលដែលរាជបុត្ររបស់ទ្រង់បានទទួលព្រះនាមហើយ នោះព្រះមាតាបានយាងមកកាន់ព្រះបរមរាជវាំង ដើម្បីឲ្យក្រុមហោរាទស្សន៍ទាយពីជោគជាតារាសីរបស់ព្រះរាជកុមារ "សីហនុ" នៅពេលអនាគត។ ពួកក្រុមហោររបស់ព្រះបរមរាជវាំងបានទស្សន៍ទាយថា អនាគតរបស់ព្រះរាជកុមារ សីហនុ នឹងមានជោគជាតារាសីខ្ពស់ ព្រះអង្គនឹងទទួលបានតំណែងធំនៅក្នុងរាជការ ក៏ប៉ុន្តែ ព្រះអង្គមានគូសត្រូវច្រើនតាមព្យា



www.elibraryofcambodia.org

បា១ តែនៅទីបំផុត ព្រះអង្គបានផ្ដួលពួកគេដោយជោគជ័យ[139]។

**សោយព្រះទិវង្គត៖** ១៥ តុលា ២០១២ នៅក្នុងទីក្រុងប៉េកាំង ប្រទេសចិន ដោយសារគាំងបេះដូងក្នុងព្រះជន្ម៩០ព្រះវស្សា។ មុនសោយព្រះទិវង្គត ព្រះអង្គធ្លាប់មានរាជបណ្ដាំថា ព្រះសពរបស់ព្រះអង្គត្រូវដាក់ក្នុងបរមមឈូសផ្ដេកធម្មតា គឺមិនមែនក្នុងព្រះកោដ្ឋបញ្ឈរដូចដាក់ព្រះសពស្ដេចអង្គមុនៗនោះទេ ព្រោះថា បើកោដ្ឋបញ្ឈរគឺត្រូវតែដាក់សពបញ្ឈរឬក៏អង្គុយដែរ ដែលពិបាកភ្នែកមើលណាស់។

**ព្រះបិតា៖** ព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត[140]

**ព្រះមាតា៖** ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈ

## ព្រះរាជតំណែងក្នុងរាជបល្ល័ង្ក និងជាព្រះប្រមុខរដ្ឋ

**២៥ មេសា ១៩៤១ - ៣ មីនា ១៩៥៥៖** ព្រះអង្គគ្រងរាជបល្ល័ង្កលើកទី១៖ ដែលនៅចន្លោះឆ្នាំនោះ ព្រះអង្គក៏ជាព្រះប្រមុខរដ្ឋដែរ។



ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

**៣ មេសា ១៩៦០ - ១៨ មីនា ១៩៧០៖** ព្រះអង្គជាព្រះប្រមុខរដ្ឋ ខណៈដែលព្រះមាតារបស់ព្រះអង្គជាព្រះមហាក្សត្រិយានីគ្រងព្រះរាជបល្ល័ង្ក។ ទោះបីជាយ៉ាងនេះក្ដី ក៏មន្ត្រីនិងប្រជានុរាស្ត្រនៅតែគិតថា ព្រះអង្គនៅតែជាព្រះប្រមុខរដ្ឋដ៏មានអំណាចក្នុងរាជបល្ល័ង្កដដែល។

---

[139] DAP ផ្សាយនៅគេហទំព័រ http://www.khmerload.com/news/6792

[140] ឯកសារខ្លះសរសេរ "សុរាម្រឹត" តែនៅលើចំណារភ្ជាប់នឹងព្រះមហាចេតិយរបស់ព្រះអង្គនៅក្នុងព្រះបរមរាជវាំងសរសេរថា "សុរាម្រិត"



www.elibraryofcambodia.org

**១៩៧៥-១៩៧៦៖** បើទោះជាព្រះអង្គត្រូវបានបណ្តេញចេញពីព្រះប្រមុខរដ្ឋនាថ្ងៃទី ១៨ មីនា ១៩៧០ ហើយយាងនិរទេសព្រះកាយជាមួយអគ្គមហេសី មុនិនាថ យាងទៅគង់នៅទីក្រុងប៉េកាំងប្រទេសចិនក៏ដោយ ក៏ព្រះអង្គអាចបានធ្វើជាប្រមុខរដ្ឋជាថ្មីរបស់របបខ្មែរក្រហមប៉ុលពតនៅក្នុងឆ្នាំ ១៩៧៥ ប៉ុន្តែនៅពេលដែលព្រះអង្គលាចេញពីតំណែងនេះនៅឆ្នាំ១៩៧៦ ប៉ុលពតក៏បានឃុំព្រះកាយព្រះអង្គនៅក្នុងវាំងរហូតដល់ថ្ងៃទី៦ មករា ឆ្នាំ ១៩៧៩។

**២៤ កញ្ញា ១៩៩៣៖** ព្រះអង្គបានក្លាយជាព្រះមហាក្សត្រនិងជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាម្តងទៀត រហូតដល់ព្រះអង្គបានដាក់រាជ្យនាថ្ងៃទី៧ តុលា ២០០៤ ហើយព្រះរាជបុត្រា នរោត្តម សីហមុនី ក៏បានឡើងគ្រងរាជ្យជាព្រះមហាក្សត្រនិងជាព្រះប្រមុខរដ្ឋបន្ត។ បន្ទាប់ពីបានដាក់រាជ្យជាផ្លូវការនៅថ្ងៃទី៧ តុលា នោះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានថ្វាយព្រះឋានៈព្រះអង្គជា "ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដីនិងឯកភាពជាតិខ្មែរ"។ ការថ្វាយនេះគឺដើម្បីរំលឹកដល់ព្រះគុណចំពោះការទទួលខុសត្រូវក្នុងព្រះរាជបូជនីយកិច្ចបម្រើជាតិមាតុភូមិរបស់ព្រះអង្គកន្លងមក។

## ព្រះតំណែងជានាយករដ្ឋមន្ត្រី

សម្តេចឪ នរោត្តម សីហនុ បានកាន់ព្រះតំណែងនាយករដ្ឋមន្ត្រីចំនួន១០លើក៖



www.elibraryofcambodia.org

**លើកទី១៖** ១៨ មីនា - ១៣ សីហា ១៩៤៥ ខណៈដែលព្រះអង្គកំពុងគ្រងរាជបល្ល័ង្កផង ហើយនគរបានស្ថិតនៅក្រោមអាណានិគមជប៉ុន (ចន្លោះ ១៩៤១ - ១៩៤៥)[141]។

**លើកទី២៖** ថ្ងៃទី ៣ - ៣១ ឧសភា ១៩៥០ ខណៈដែលព្រះអង្គជាព្រះមហាក្សត្រ ហើយប្រទេសបានស្ថិតក្រោមអាណានិគមបារាំងជាថ្មី។

**លើកទី៣៖** ១៦ មិថុនា ១៩៥២ - ២២ មករា ១៩៥៣ ខណៈដែលប្រទេសនៅតែស្ថិតក្រោមអាណានិគមបារាំងដដែល។

**លើកទី៤៖** ៧ - ១៧ មេសា ១៩៥៤ ដែលអំឡុងពេលនោះប្រទេសបានទទួលឯករាជភាពពីប្រទេសបារាំង គឺតាំងពីថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ មកម្ល៉េះ។

**លើកទី៥៖** ៣ តុលា ១៩៥៥ - ៥ មករា ១៩៥៦ ហើយព្រះអង្គក៏ជារដ្ឋមន្ត្រីការបរទេស និងមហាផ្ទៃដែរ។

**លើកទី៦៖** ១ មីនា - ៣ មេសា ១៩៥៦។ នៅពេលនោះ ព្រះអង្គនៅតែបន្តព្រះតំណែងជារដ្ឋមន្ត្រីការបរទេសនិងមហាផ្ទៃ។

**លើកទី៧៖** ១៥ កញ្ញា - ២៥ តុលា ១៩៥៦ ខណៈដែលព្រះអង្គក៏ជារដ្ឋមន្ត្រីការបរទេស និងមហាផ្ទៃដែរ។

**លើកទី៨៖** ៩ មេសា - ២៦ កក្កដា ១៩៥៧។ ព្រះអង្គក៏ជារដ្ឋមន្ត្រីការបរទេស ឧស្សាហកម្ម និងផែនការ។

**លើកទី៩៖** ១០ កក្កដា ១៩៥៨ - ១៩ មេសា ១៩៦០

**លើកទី១០៖** ១៧ វិច្ឆិកា ១៩៦១ - ១៣ កុម្ភៈ ១៩៦២

សម្តេចឪគឺជាព្រះប្រមុខដឹកនាំប្រទេសប្រកបដោយប្រសិទ្ធភាពចាប់ពីចុងឆ្នាំ ១៩៥៣ (ក្រោយប្រទេសទទួលបានឯករាជ្យពីបារាំង) ដល់

---

[141] *http://en.wikipedia.org/wiki/Japanese_occupation_of_Cambodia*



www.elibraryofcambodia.org

ឆ្នាំ ១៩៧០ (នៅពេលព្រះអង្គត្រូវបានទម្លាក់ចេញពីព្រះប្រមុខរដ្ឋ)។ ព្រះអង្គបានកាន់ព្រះតំណែងជាច្រើនចាប់តាំងពីឆ្នាំ ១៩៤១ ដែលសៀវភៅកំណត់ត្រាពិភពលោក Guinness Book បានចារព្រះនាមព្រះអង្គថា ជាអ្នកនយោបាយដែលបម្រើ 'សង្គមនយោបាយខុសៗគ្នាដ៏អស្ចារ្យនៅក្នុងពិភពលោក'។ បុជនីយកិច្ចទាំងនេះរួមមាននៅក្នុងរយៈពេលដែលព្រះអង្គជាព្រះមហាក្សត្រ ជាព្រះប្រមុខរដ្ឋ ជានាយករដ្ឋមន្ត្រី ជាព្រះប្រធានចលនាតស៊ូ និងជាព្រះប្រធានរដ្ឋាភិបាលចម្រុះជាដើមទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ទោះជាព្រះអង្គស្ថិតនៅក្នុងស្ថានភាពនិរទេសព្រះកាយដែលយ៉ាងហោចណាស់ពីរដងក៏ដោយ។

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ មានរាជដំណាក់នៅទីក្រុងប៉េកាំង ប្រទេសចិន និងនៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ដែលមេដឹកនាំនៃប្រទេសទាំងពីរនេះបានថ្វាយជូនព្រះអង្គក្នុងនាមជាមិត្តភក្តិ។

## ការសិក្សា

១៩៣០-១៩៤០៖ ព្រះរាជកុមារ នរោត្តម សីហនុ បានចូលសិក្សានៅសាលាបឋមសិក្សា Francois Baudoin និងអនុវិទ្យាល័យព្រះស៊ីសុវត្ថិ (បច្ចុប្បន្ន វិទ្យាល័យព្រះស៊ីសុវត្ថិ) រាជធានីភ្នំពេញ។ បន្ទាប់មក ព្រះអង្គបានបន្តនៅឯវិទ្យាល័យ សាសលូ ឡូបា (Chasseloup Laubat)[142] ទី

---

[142] *បច្ចុប្បន្នវិទ្យាល័យ Chasseloup Laubat បានប្តូរឈ្មោះជាវិទ្យាល័យ ឡេ គុយដុង (Lê Quý Đôn)។ ឡេ គុយដុង ជាឈ្មោះទស្សនៈវិទូ កវី អ្នកក្រងសៀវភៅអក្សរសាស្រ្ត និងជាមន្ត្រីរដ្ឋាភិបាលវៀតណាមក្នុងសតវត្សរ៍ទី១៨។ លោក ឡេ គុយដុង (ប្រសូតឆ្នាំ១៧២៦ និងស្លាប់ឆ្នាំ១៧៨៤)។*

*http://en.wikipedia.org/wiki/L%C3%AA_Qu%C3%BD_%C4%90%C3%B4n*



www.elibraryofcambodia.org

ក្រុងព្រៃនគរ [បច្ចុប្បន្ន៖ ទីក្រុងសាយហ្គ៉ន ឬទីក្រុងហូជីមិញ ប្រទេសវៀតណាម] រហូតដល់ពេលព្រះអង្គបានសោយរាជ្យនៅថ្ងៃទី២៨ តុលា ១៩៤១[143] ហើយនៅឆ្នាំ ១៩៤៦-៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់នៅសាលាអនុវត្តទ័ពសេះនិងកងរថពាសដែកនៅទីក្រុង Saumur ប្រទេសបារាំង។

## ទេពកោសល្យ

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ មានចំណាប់អារម្មណ៍លើតន្ត្រី ហើយព្រះអង្គបានតែងនិពន្ធបទចម្រៀងជាច្រើនមានទាំងភាសាខ្មែរ បារាំង និងអង់គ្លេស ហើយអាចច្រៀងដោយអង្គឯងទៀតផង។ ព្រះអង្គចេះផ្លុំប៉ែត (clarinet) ផ្លុំត្រែ (saxophone) លេងព្យ៉ាណូ និងលេងអាគ័រដេអុង (accordion)។ កាលនៅព្រះរាជកុមារ ព្រះអង្គចាប់ព្រះទ័យលើភាពយន្ត ព្រមទាំងសិល្បៈ ល្ខោននិងរបាំ។ ក្រោយមក ព្រះអង្គបានក្លាយជាផលិតករ ជាអ្នកដឹកនាំ ជាអ្នកនិពន្ធភាពយន្តដ៏ចំណាន ហើយក៏ជាតួសម្តែងដោយអង្គឯងទៀតផងក្នុងខ្សែភាពយន្តមនោសញ្ចេតនាក្នុងខ្លឹមសារជាភាពយន្តឯកសារនិងប្រវត្តិសាស្ត្ររបស់ខ្មែរ ហើយព្រះអគ្គមហេសី មុនិនាថ[144] សីហនុ ក៏បានសម្តែងភាពយន្តជាមួយព្រះអង្គដែរ។ នៅឆ្នាំ ១៩៦៧ ភាពយន្តរឿង "ព្រៃប្រសិទ្ធ" ដែលជាស្នាព្រះហស្តរបស់ព្រះអង្គនៅក្នុងឆ្នាំ១៩៦៦ បានយកទៅចូលរួមក្នុងពិធីមហោស្រពភាពយន្តអន្តរជាតិលើកទី៥នាទីក្រុងម៉ូស្គូ ប្រទេសរុស្ស៊ី។

---

*[143] ២៥ មេសា ១៩៤១៖ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសតាំងនិងថ្វាយព្រះរាជឋានៈព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

*[144] ឯកសារខ្លះសរសេរថា "មុនីនាថ"*



www.elibraryofcambodia.org



*រូបខាងលើ៖ ទិដ្ឋភាពខាងក្រៅនិងខាងក្នុងវិទ្យាល័យ ឡឺ គ្វីដុង (Lê Quý Đôn) អតីតវិទ្យាល័យ Chasseloup Laubat ដែលសម្តេចព្រះ នរោត្តម សីហនុ ធ្លាប់បានសិក្សា (រូប ឆាយ សុផល ៖ ២១ វិច្ឆិកា ២០១៤)។ មានសមាជិកពជវង្សខ្មែរជាច្រើនអង្គនិងអ្នកនយោបាយខ្មែរជាច្រើននាក់ទៀតក៏បានរៀននៅសាលានេះដែរ។*



*ព្រះបរមឆាយាល័ក្ខណ៍ ព្រះបាទនរោត្តម សីហនុ*

www.elibraryofcambodia.org



រូបឆ្វេង៖ សម្តេចឪសម្តែងភាពយន្តជាមួយព្រះអគ្គមហេសី មុនិនាថ។ រូបក្នុងព្រឹត្តិបត្រអនុស្សាវរីយ៍នៃកម្ពុជាសង្គមរាស្រ្តនិយម (ច្បាប់លេខ៣)



រូបលើ៖ សម្តេចឪ (ស្តាំ) ដឹកនាំការថតដោយព្រះអង្គផ្ទាល់នូវភាពយន្តរឿង "ឆាយាលើអង្គរ" នៅក្នុងរបបសង្គមរាស្រ្តនិយម។ រូបក្នុងព្រឹត្តិបត្រ អនុស្សាវរីយ៍នៃកម្ពុជាសង្គមរាស្រ្តនិយម (ច្បាប់លេខ៣)។




រូបឆ្វេង៖ សម្តេចឪ នរោត្តម សីហនុ លេងព្យាណូឲ្យព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ សណ្តាប់ក្នុងភាពយន្តមួយ។ រូបផ្សាយនៅកាសែតភ្នំពេញប៉ុស្តិ៍៖ http://www.postkhmer.com/10/ស្នាព្រះហស្ត%E2%80%8B សិល្បៈ%E2%80%8Bអង្គ-នរោត្តម-សីហនុ



www.elibraryofcambodia.org

# ជីវិតផ្ទាល់ព្រះកាយ ស្នេហា និងគ្រួសារ[145]

ក្រៅពីរឿងនយោបាយ និងប្រទេសជាតិ ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ជាក្សត្រដែលមានមនោសញ្ចេតនាជ្រាលជ្រៅចំពោះការងារសិល្បៈនិងកីឡា។ ព្រះអង្គគាប់ព្រះទ័យនឹង កីឡាស្ទើរគ្រប់ប្រភេទ ហើយនៅក្នុងរបបសង្គមរាស្ត្រនិយមនៅឆ្នាំ១៩៥៥-១៩៧០ របស់ព្រះអង្គ កីឡាគ្រប់ប្រភេទបានរីកចម្រើនគួរឲ្យមានមោទនភាព ហើយកីឡាមានភាពល្បីល្បាញខ្ចរខ្ចារនៅក្នុងតំបន់អាស៊ីទាំងមូល។ ព្រះអង្គសព្វព្រះទ័យលេងបាល់ទាត់ បាល់ទះ វាយសី និងជិះសេះ ហើយចំពោះម្ហូបខ្មែរវិញ ព្រះអង្គចូលចិត្តសោយសម្លម្ជូរ និងស្ងោរជ្រក់[146]។ ព្រះអង្គមិនចេះសោយឬជក់បារីទេ ហើយក៏មិនសូវសោយសុរាច្រើនដែរពេលមានពិធីតែសព្វព្រះទ័យច្រៀងច្រើន។



*សម្ដេចព្រះ នរោត្តម សីហនុ (កណ្ដាល) មុជទឹកជាមួយជនបរទេសនៅអាងហែលទឹកក្នុងកីឡាមណ្ឌលហែលទឹកខេត្តបាត់ដំបងនៅក្នុងរបបសង្គមរាស្ត្រនិយម ដើម្បីលើកស្ទួយកីឡាហែលទឹករបស់ប្រទេស។ រូបក្នុងព្រឹត្តិបត្រអនុស្សាវរីយ៍នៃកម្ពុជាសង្គមរាស្ត្រនិយម (ច្បាប់លេខ៣)*

---

[145] *ជីវិតស្នេហារបស់មហាក្សត្រ សម្ដេចព្រះ នរោត្តម សីហនុ បានដកស្រង់ចេញពីសៀវភៅព្រះរាជនិពន្ធដោយព្រះអង្គផ្ទាល់ "អនុស្សាវរីយ៍ ផ្អែមល្ហែម និងជូរចត់" និងសៀវភៅ "អ្នកទោសខ្មែរក្រហម និងកម្ពុជាក្នុងព្យុះសង្គ្រាម" ដែលផ្សាយនៅគេហទំព័រ http://www.khmer-note.com/archives/31569 និងសៀវភៅ "ប្រវត្តិសាស្ត្រនិងរាជនខ្មែរ" (ទំព័រ៣១៤-៣១៥)*

[146] *បទសម្ភាសន៍របស់ខ្ញុំ (អ្នកចងក្រងសៀវភៅ) នៅថ្ងៃទី ២៣ ឧសភា ២០១៤ ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ អតីតជំនួយការព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ*



www.elibraryofcambodia.org




www.elibraryofcambodia.org

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ មានស្នេហាផ្លូវការជាមួយញាតិវង្សនិងរាស្ត្រចំនួន៦អង្គ/រូប៖

**ស្នេហាទី១៖** អ្នកម្នាង ផាត់ កាញ៉ុល ជានាដកា [នារីរបាំ] ព្រះរាជទ្រព្យ ដោយបានរួមរស់ជាមួយគ្នាបន្ទាប់ពីព្រះអង្គសោយរាជ្យបានប្រមាណ៥ខែមក។ កាលពីដំបូង ស្នេហារវាងសម្ដេចព្រះ នរោត្តម សីហនុ និងអ្នកម្នាង ផាត់ កាញ៉ុល (១៩២០-១៩៦៩) ត្រូវបានលោកអគ្គទេសាភិបាលប្រចាំប្រទេសកម្ពុជា ធីបូដូ (Tibaudau) និងព្រះអយ្យកោ [តា] សុជាតិ ជំទាស់[147]។ ពីរឆ្នាំក្រោយមក ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ និងអ្នកម្នាង ផាត់ កាញ៉ុល មានបុត្រពីរអង្គ៖



អ្នកម្នាង ផាត់ កាញ៉ុល

១. ព្រះអង្គម្ចាស់ក្សត្រីយ៍ព្រះរៀម នរោត្តម បុប្ផាទេវី (១៩៤៣)។ ម្ចាស់ក្សត្រិយ៍ បុប្ផាទេវី បានរៀបអភិសេកជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស ហើយក្រោយមកក៏បានបែកគ្នា ដោយម្ចាស់ក្សត្រិយ៍បានមករៀបអភិសេកជាមួយលោក ខែក វណ្ណី វិញ។ ព្រះអង្គម្ចាស់ក្សត្រីយ៍ព្រះរៀម បុប្ផាទេវី គឺជាព្រះរាជនាដកាមួយអង្គដ៏ចំណាននៅក្នុងរបាំព្រះរាជទ្រព្យ។ ព្រះអង្គម្ចាស់ក្សត្រីយ៍ក៏ធ្លាប់បានធ្វើជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ



នរោត្តម បុប្ផាទេវី

[147] http://www.khmer-note.com/archives/31569



www.elibraryofcambodia.org

សិល្បៈផងដែរនៅក្នុងទសវត្សរ៍១៩៩០។

២. សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ (១៩៤៤)។ ព្រះអង្គបានរៀបអភិសេកជាមួយអ្នកម្នាង អេង ម៉ារី តែស្នេហាបានបែកបាក់នាឆ្នាំ ២០០៦ ហើយព្រះអង្គមានមហេសីវ័យក្មេងម្នាក់ទៀតគឺអ្នកម្នាង អ៊ុក ផល្លា។ ព្រះអង្គធ្លាប់បានធ្វើជាប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី[148]។ ព្រះអង្គបានទទួលបរមងារជាសម្តេចក្រុមព្រះដែរ ហើយព្រះអង្គក៏ត្រូវបានពិភពលោកស្គាល់ដែរថា ជាអ្នកនាំលទ្ធិប្រជាធិបតេយ្យមកកម្ពុជានាឆ្នាំ១៩៩៣។ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានបញ្ជាក់ថា នៅពេលព្រះអង្គប្រសូតមក ព្រះបិតារបស់ព្រះអង្គគឺព្រះមហាក្សត្រសម្តេចព្រះ នរោត្តម សីហនុ មានមហេសី៣អង្គ/នាក់រួចទៅហើយ[149]។



នរោត្តម រណឫទ្ធិ

**ស្នេហាទី២៖** អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ពង្សសានមុនី (គង់នៅជាមួយគ្នា៖១៩៤២-១៩៥១) ដែលត្រូវជាព្រះមាតុច្ឆា [មីង] បង្កើតរបស់ព្រះអង្គ។ អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ពង្សសានមុនី (១៩២៩-១៩៧៤) ជាព្រះបុត្រីរបស់អតីតព្រះរាជា ស៊ីសុវត្ថិ មុនីវង្ស និងអ្នកម្នាង យុន ណាត។



ស៊ីសុវត្ថិ ពង្សសានមុនី

ដូចកាលពីគ្រាមុនដែរ ស្នេហានេះក៏ត្រូវបានជំទាស់យ៉ាងដាច់

[148] សូមអានប្រវត្តិព្រះអង្គនៅក្នុងសៀវភៅ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"

[149] សៀវភៅ៖ Worrior Prince - Norodom Ranariddh, Son of King Sihanouk of Cambodia ទំព័រ១



www.elibraryofcambodia.org

អហង្ការពីសំណាក់ព្រះមាតារបស់ទ្រង់ គឺសម្តេចព្រះមហាក្សត្រិយ៍ កុសមៈ និងលោក ហ្សក ហ្កាតទា អគ្គទេសាភិបាលបារាំងថ្មីប្រចាំកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ក៏ព្រះអង្គនៅប្រឹងជម្នះតស៊ូចង់រៀបការជាមួយម្ចាស់ក្សត្រិយ៍ ពង្សសានមុនី រហូតដល់ព្រះអង្គគំរាមថានឹងដាក់រាជ្យសម្បត្តិ ប្រសិនបើមិនបានម្ចាស់ក្សត្រិយ៍ ពង្សសានមុនី។ ចំណងស្នេហ៍ជាមួយម្ចាស់ក្សត្រិយ៍ ពង្សសានមុនី អស់រយៈពេល៩ឆ្នាំបានបន្សល់ទុកនូវបុត្រ៧អង្គ។ ក្នុងចំណោមបុត្រាបុត្រីទាំង៧អង្គនេះ បច្ចុប្បន្ននៅមានព្រះជន្មតែពីរព្រះអង្គប៉ុណ្ណោះ គឺព្រះអង្គម្ចាស់ នរោត្តម យុវនាថ និងព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស (គិតត្រឹមឆ្នាំដែលសៀវភៅបោះពុម្ព)។ ដោយឡែកបុត្រាបុត្រី៥អង្គទៀតគឺ ម្ចាស់ក្សត្រិយ៍ នរោត្តម គន្ធបុប្ផា បានសោយទិវង្គតតាំងពីមានព្រះជន្ម៤ព្រះវស្សាដោយជំងឺគ្រុនឈាម (ឬឈាមសស៊ីឈាមក្រហម) ហើយ៤អង្គទៀតត្រូវបានពួកខ្មែរក្រហមធ្វើគុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩ ដោយគ្មានបន្សល់ទុកនូវបុត្រាបុត្រីនោះទេ ប៉ុន្តែមានតែម្ចាស់ក្សត្រិយ៍ សូរិយារង្សី មួយអង្គគត់ដែលនៅមានសល់បុត្រា១ព្រះអង្គ គឺព្រះអង្គម្ចាស់ នរោត្តម សូរិយារង្សី មីស្ហែល នៅមានព្រះជន្មរហូតដល់បច្ចុប្បន្ន ហើយទ្រង់បានធ្វើការជាមួយសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា។



នរោត្តម យុវនាថ



នរោត្តម ចក្រពង្ស (ព្រះអង្គបានប្រាប់ខ្ញុំ [ឆាយ សុផល] នៅល្ងាចថ្ងៃសៅរ៍ទី៣ មករា ថា ទ្រង់នៅសល់តែបងម្នាក់គត់គឺ នរោត្តម យុវនាថ ក្រៅពីនោះ ទ្រង់គ្មានសល់រូបថតបងប្អូនទេ ព្រោះបាត់បង់អស់នៅក្នុងសម័យសង្គ្រាម)

*នរោត្តម រក្សវង្ស*



*នរោត្តម ខេមានុរក្ស*



*នរោត្តម សុរិយារង្សី*



*នរោត្តម គន្ធបុប្ផា*





បុត្រីពៅ នរោត្តម បុទុមបុប្ផា



www.elibraryofcambodia.org

គួររម្លឹកថា ព្រះអយ្យកោ [តា] សុធារស របស់សម្តេច សីហនុ ចង់ឲ្យព្រះអង្គរៀបអភិសេកជាមួយម្ចាស់ក្សត្រិយ៍ជនជាតិថៃ តែដោយខ្មែរអគ្គទេសាភិបាលបារាំងប្រចាំនៅកម្ពុជា លោក ហ្សក ហ្គាតទា ចង់ឲ្យសម្តេច សីហនុ រៀបការជាមួយកញ្ញា ជួន ជឿម ជាចៅស្រីបង្កើតរបស់អតីតនាយករដ្ឋមន្ត្រី ជួន ដ៏ល្បីល្បាញដែលបានអុកឡុកមហាក្សត្រអស់បីជំនាន់មកហើយ។ លោក ហ្គាតទា បានប្រៀបប្រដូចកញ្ញា ជួន ជឿម នឹងម្ចាស់ក្សត្រិយ៍ ណាំផ្វង (Nam Phuong) ព្រះរាជបុត្រីព្រះចៅ បាវ ដាយ (Bao Dai) នៃប្រទេសអណ្ណាម [យួន] និងបានចាត់ទុកគ្រួសារ ជួន ជាត្រកូលដែលមានការអប់រំបានខ្ពស់ជាងគេនៅក្នុងប្រទេសកម្ពុជា ដោយក្នុងនោះមាន ជួន ជឿន វេជ្ជបណ្ឌិតដ៏ល្បីល្បាញ ជួន ប្រសិទ្ធិ អ្នកការទូតខ្មែរក្រហម និង ជួន មុំ គឺជាវិស្វករអាតូមិច។ ប៉ុន្តែជាការគួរឲ្យសោកស្តាយដែលសម្រស់របស់កញ្ញា ជួន ជឿម មិនបានទាក់ទាញព្រះទ័យសម្តេច សីហនុ បានទាល់តែសោះ ហើយការប្រកែកមិនទទួលយកកញ្ញា ជួន ជឿម មកធ្វើជាមហេសីវាមានន័យស្មើនឹងការប្រមាថចំពោះគ្រួសារអភិជនមួយនេះផងដែរ។ ព្រះអង្គបានឡាយថា "កញ្ញា ជឿម មិនមានរូបសម្ផស្សស្អាតឡើយ ប៉ុន្តែថានាងប្រកបដោយគុណសម្បត្តិដូចគ្នានឹងអធិរាជនី ណាំផ្វង នៃអណ្ណាម ត្រង់មានការសិក្សាជ្រៅជ្រះ មានវប្បធម៌ទូទៅដ៏ទូលំទូលាយ និងជា មេផ្ទះដ៏ចំណាន។...ខ្ញុំក៏ស្គាល់កញ្ញា ជឿម ដែរ។ នាងមានសមានចិត្តគួរឱ្យរាប់អាន


ម្ចាស់ក្សត្រិយ៍ ណាំផ្វង នៃប្រទេសវៀតណាម



www.elibraryofcambodia.org

និងមានអត្តចរិតគួរឱ្យគោរព។ល។ ប៉ុន្តែរូបសម្បត្តិនាងមិនទាក់ទាញខ្ញុំបន្តិចទាល់តែសោះ។ បើខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយនាង នោះខ្ញុំនឹងក្លាយជាស្វាមីមួយដ៏សែនអាក្រក់។ ខ្ញុំនឹងទៅរកការត្រេកត្រអាលនៅទីកន្លែងដទៃ"[150]។ ទំនងជាបញ្ហានេះហើយបានជាក្រោយមក ក្រុមគ្រួសារត្រកូល "ជួន" បានក្លាយជាអ្នកប្រឆាំងសម្តេច សីហនុ យ៉ាងផ្តាច់មុខតែម្តង ដែលក្នុងនោះ ប៊ុន ច័ន្ទម៉ុល មេខ្មែរឥស្សរៈហាក់ដូចជាចេញមុខជាងគេ[151]។ គ្រួសារដ៏មានឥទ្ធិពលនេះ បានខកចិត្តម្តងហើយពេលដែលអាណាព្យាបាលបារាំងបានលើកសម្តេច សីហនុ ឲ្យឡើងសោយរាជ្យរំលងបុត្រាច្បងរបស់សពព្រះមហាក្សត្រ មុនីវង្ស គឺសម្តេចក្រុមព្រះ ស៊ីសុវត្ថិ មុនីរ៉េត ដែលមានមហេសីឈ្មោះ ប៉ុក វ៉ាណេ កូនស្រីលោក ប៉ុក ហ៊ែល ជាកូនប្រសាអតីតនាយករដ្ឋមន្ត្រី ជួន។ កញ្ញា ជួន ជឿម ក្រោយមកបានរៀបការជាមួយ លោក ឈាន វ៉ម ដែលត្រូវបានគណបក្សប្រជាធិបតេយ្យបោះឆ្នោតតែងតាំងជានាយករដ្ឋមន្ត្រី[152]។

**ស្នេហាទី៣៖** ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ មុនីកេសន (១៩២៩-១៩៤៦) ត្រូវជាព្រះមាតុច្ឆា (មីង) របស់ព្រះអង្គ។ ស្នេហាជាមួយម្ចាស់ក្សត្រិយ៍ មុនីកេសន និងសម្តេច សីហនុ (គង់នៅជាមួយគ្នា៖១៩៤៤-១៩៥០) គឺទទួលបានបុត្រាមួយអង្គគឺព្រះអង្គម្ចាស់ នរោត្តម នរៈទីប៉ោ។ សម្តេច សីហនុ បានឡាយថា ក្នុងចំណោមបុត្រទាំងអស់ នរៈទីប៉ោ ទ្រង់

---

[150] *សៀវភៅ៖ "អនុស្សាវរីយ៍ ផ្អែមល្ហែម និងជូចត់" ព្រះរាជនិពន្ធដោយសម្តេចឪផ្ទាល់ http://kkhmer.com/?p=2551*

[151] *ឯកសារខ្មែរៈសារសោធ ប៊ុន ច័ន្ទម៉ុល និងត្រកូល ជួន ជាអ្នកស្នេហាជាតិហ៊ានប្រឆាំងស្តេចរាជានិយម និងរបបសក្តិភូមិ*

[152] *សូមអានប្រវត្តិ ឈាន វ៉ម នៅក្នុងសៀវភៅ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"*



www.elibraryofcambodia.org

កម្សត់ជាងគេ ព្រោះគ្រាន់តែប្រសូតបានប៉ុន្មានម៉ោងមាតារបស់ទ្រង់ក៏បានលាចាកលោកនេះគួរឲ្យរន្ធត់ ហើយព្រះអង្គម្ចាស់ផ្ទាល់ត្រូវបានខ្មែរក្រហមសម្លាប់នៅក្នុងរបបខ្មែរក្រហម បើទោះបីជាព្រះអង្គជាអ្នកកុម្មុយនិស្តនិយមយ៉ាងណាក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី ចាប់ពីទសវត្សរ៍១៩៩០ មកមានបុរសមិនតិចជាង៦នាក់ទេដែលអះអាងថា ខ្លួនជាព្រះអង្គម្ចាស់ នរៈទីប៉ោ តែសម្តេចព្រះ នរោត្តម សីហនុ មិនទទួលស្គាល់ឡើយ ហើយបុរសខ្លះត្រូវបានអាជ្ញាធរចាប់ឃុំខ្លួន និងដោះលែងវិញបន្ទាប់ពីធ្វើការអប់រំ។ ព្រះអង្គម្ចាស់ នរៈទីប៉ោ អាចក្លាយជាព្រះរាជទាយាទ ប្រសិនព្រះអង្គនៅមានព្រះសង្ខារ[153]។ ប្រសិនបើរបបសង្គមរាស្ត្រនិយមនៃព្រះបិតា សម្តេចព្រះ នរោត្តម សីហនុ មិនត្រូវបានពួក លន់ នល់ ផ្តួលរំលំនាថ្ងៃទី១៨ មីនា ឆ្នាំ១៩៧៩ទេ នោះព្រះអង្គម្ចាស់ នរៈទីប៉ោ អាចស្នងរាជ្យជាព្រះមហាក្សត្រ។ ដោយសារតែព្រះអយ្យកោ (ជីតា) សម្តេចព្រះ នោត្តម សុរាម្រិត ព្រះអយ្យកា (ជីដូន) ស៊ីសុវត្ថិ កុសុមៈ និងព្រះបិតា នរោត្តម សីហនុ សព្វព្រះទ័យព្រមទាំងមានមាតាជាសែរាជវង្សផង នោះព្រះអង្គម្ចាស់ នរៈទីប៉ោ អាចក្លាយជាព្រះមហាក្សត្រ បន្ទាប់ពីព្រះអយ្យកោមហាក្សត្រិយានី ស៊ីសុវត្ថ កុសុមៈ។ នៅមុនឆ្នាំ១៩៧០ ក៏មានជម្លោះជាច្រើននៅក្នុងសែរាជវង្សដែរ ហើយសមាជិករាជវង្សខ្លះមិនសព្វព្រះទ័យនឹងអ្នកម្នាង ម៉ូនិក ឡើយ[154] គឺថាមានការច្រណែននិន្ទាឈ្នានីសត្នា ហើយព្រះមាតានីមួយៗចង់ឲ្យព្រះរាជបុត្រាខ្លួនក្លាយជាព្រះរាជទាយាទ។

---

[153] លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (១៣ មករា ២០១៥)

[154] ឯកឧត្តម ខៀវ កញ្ញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន (២៣ កុម្ភៈ ២០១៥)



www.elibraryofcambodia.org



ព្រះអង្គម្ចាស់ នរៈទីប៉ោ (ស្តាំ) ២១ ព្រះវស្សា និងម្ចាស់ក្សត្រី បុទុមបុប្ផា ២៧ព្រះវស្សា អង្គុយនៅក្នុងតុលាការក្រុងភ្នំពេញនាថ្ងៃទី១មេសា ឆ្នាំ១៩៧១ ដែលពេលនោះត្រូវបានគេចោទប្រកាន់ពីការផ្តល់ប្រាក់គាំទ្រព្រះបិតារបស់ខ្លួនដែលកំពុងគង់នៅដោយកាសព្រះកាយក្នុងទីក្រុងប៉េកាំង។ រូប AP



www.elibraryofcambodia.org

**ស្នេហាទី៤៖** ម្ចាស់ក្សត្រិយ៍ នរោត្តម នលក្ខណ៍ (១៩២៧-?) ត្រូវជាបងប្អូនជីដូនមួយបង្កើតរបស់ព្រះអង្គ (គង់នៅជាមួយគ្នា៖១៩៤៦-១៩៦៨) ហើយត្រូវជាបុត្រីរបស់ម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ កន្ថាវេត បងស្រីរបស់ព្រះមហាក្សត្រិយ៍ ស៊ីសុវត្ថិ កុសមៈ។ ម្ចាស់ក្សត្រិយ៍ នលក្ខណ៍ ជាស្ត្រីមេម៉ាយ ជាអតីតព្រះជាយារបស់ព្រះអង្គម្ចាស់ នរោត្តម មត្តវិណ្ណ ប្រធានពិធីការរបស់ព្រះបរមរាជវាំង។ ព្រះអង្គនិងម្ចាស់ក្សត្រិយ៍ នលក្ខណ៍ មិនមានបុត្រទេ។

**ស្នេហាទី៥៖** កញ្ញា ម៉ានីវណ្ណ ផានីវង្ស ហៅ ម៉មលាវ (១៩៣៤-១៩៧៥) ជាក្រមុំឡាវ គង់នៅជាមួយគ្នានៅឆ្នាំ ១៩៤៩-១៩៥២។ នៅក្នុងដំណើរយាងទស្សនកិច្ចទៅកាន់ប្រទេសឡាវក្នុងឆ្នាំ១៩៤៩ សម្រស់របស់យុវតីឡាវម្នាក់នេះបានឆាបយកបេះដូងរបស់ព្រះអង្គមួយរំពេច។ ដោយសារប្រពៃណីជនជាតិឡាវដែលត្រូវតែឲ្យមានពិធីរៀបអភិសេកនោះ សម្តេច សីហនុ បានរៀបអភិសេកជានិមិត្តរូបជាមួយយុវតីឡាវរូបនេះ ដោយមានការចូលរួមពីព្រះមាតុច្ឆា (មីង) របស់ព្រះអង្គគឺម្ចាស់ក្សត្រិយ៍ នរោត្តម រស្មីសុផាណា និងម្ចាស់ក្សត្រិយ៍ នរោត្តម មុំកេតកញ្ញា។ ព្រះអង្គនិងអ្នកម្នាង ម៉ានីវណ្ណ ផានីវង្ស មានបុត្រីពីរព្រះអង្គ៖



ម៉ានីវណ្ណ ផានីវង្ស ហៅ ម៉មលាវ

១. ម្ចាស់ក្សត្រិយ៍ នរោត្តម សុជាតា ឬ សុផាវត្ថិយា (ត្រូវបានខ្មែរក្រហមសម្លាប់ ក្នុងការចាប់ខ្លួនជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ នៅរាជធានីភ្នំពេញ។

២. ម្ចាស់ក្សត្រិយ៍ នរោត្តម អារុណរស្មី (បានភៀសព្រះកាយទៅកាន់សហរដ្ឋអាម៉េរិកជាមួយព្រះស្វាមីគឺទ្រង់ ស៊ីសុវត្ថិ សេរីវ័ន្ត ដែលជាបុត្រា



www.elibraryofcambodia.org

របស់ព្រះអង្គម្ចាស់ សិរិមតៈ តែក្រោយមក ម្ចាស់ក្សត្រិយ៍ អារុណរស្មី និង ទ្រង់ សេរីរ័ត្ន បានលែងលះគ្នា ដោយម្ចាស់ក្សត្រិយ៍ក៏បានរៀបការជាមួយ លោក កែវ ពុទ្ធិរស្មី។ អ្នកអង្គម្ចាស់ក្សត្រិយ៍ អារុណរស្មី ជាប្រធានគណបក្សហ៊្វុនស៊ីនប៉ិច ឯលោក ពុទ្ធិរស្មី ក៏ជាសមាជិកជាន់ខ្ពស់នៃគណបក្សនេះដែរ (គឺគិតត្រឹមឆ្នាំសៀវភៅបោះពុម្ព) ហើយលោកក៏ធ្លាប់ធ្វើជាឧបនាយករដ្ឋមន្ត្រីដែរនាឆ្នាំ២០០៨។ នៅក្នុងរាជរដ្ឋាភិបាលកម្ពុជាអណត្តិទី៥នាឆ្នាំ ២០១៣-២០១៨ អ្នកអង្គម្ចាស់ក្សត្រិយ៍ អារុណរស្មី ក៏បានធ្វើជាឯកអគ្គរាជទូតប្រចាំប្រទេសម៉ាឡេស៊ីដែរ។


ក្សត្រិយ៍ នរោត្តម អារុណរស្មី

អ្នកម្នាង ម៉ានីវណ្ណ ផានីវង្ស ក្រោយមកបានចូលរួមជាមួយលោក លន់ នល់ ដោយសារតែខឹងព្រះអង្គដែលបានបោះបង់អ្នកម្នាងចោល ហើយក្រោយមកត្រូវបានខ្មែរក្រហមសម្លាប់ចោលដែរ។

**ស្នេហាចុងក្រោយ៖** កញ្ញា អ៊ុំ មុនិនាថ ឬ ប៉ូល ម៉ូនិក[155] អ៊ីស្ស៊ី (១៩៣៦-បច្ចុប្បន្ន) ជាកូនស្រីរបស់លោក អ៊ីស្ស៊ី ជនជាតិបារាំងកាត់អ៊ីតាលី និងលោកស្រីថៅយុន ប៉ុម ពាង[156] (គង់នៅជាមួយគ្នា៖ មេសា ១៩៥២- តុលា ២០១២)។ លោក អ៊ីស្ស៊ី គឺជាមិត្តម្នាក់របស់ព្រះអង្គម្ចាស់ សុរាម្រិត ព្រះបិតាសម្ដេច សីហនុ ហេតុដូច្នោះ


ថៅយុន ប៉ុម ពាង

[155] ឯកសារខ្លះសរសេរ "ម៉ូនីក"

[156] ព្រឹត្តិបត្រអនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម (ច្បាប់លេខ៤) សរសេរ ថា "ប៉ោម"



www.elibraryofcambodia.org

ហើយ ទើបធ្វើឲ្យព្រះអង្គបានស្គាល់កញ្ញា ម៉ូនិក យ៉ាងច្បាស់តាំងពីនៅកុមារភាពមកម្ល៉េះ ក៏ប៉ុន្តែសេចក្តីស្នេហាបានឆាបឆេះឡើង នៅពេលដែលមានការប្រឡងបវរកញ្ញានៅអនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ដែលទ្រង់បានចូលរួមក្នុងពិធីនោះ។ ពីដំបូង អ្នកស្រី ប៉ុម ពាង ហាក់ដូចជាស្ទាក់ស្ទើរក្នុងការលើកកូនស្រីសំណព្វចិត្តរបស់ខ្លួនធ្វើជាមហេសីរបស់សម្តេច សីហនុ ព្រោះតែអ្នកស្រីបានចាត់ទុកព្រះអង្គមានចិត្តសាវ៉ាពេកក្នុងរឿងស្នេហា ប៉ុន្តែនៅទីបំផុត ព្រះអង្គក៏បានសម្រេចដូចបំណងនៅក្នុងការតាមស្នេហ៍កញ្ញា ម៉ូនិក ហើយក្រោយមកបានរៀបអភិសេកជាមួយគ្នានៅខែមេសា ឆ្នាំ១៩៥២។ នៅឆ្នាំ១៩៩២ ព្រះករុណាសម្តេច នរោត្តម សីហនុ បានប្រទានគោរមងារដល់អ្នកម្នាង ប៉ូល ម៉ូនិក អ៊ីស៊ី ជាសម្តេចព្រះជាយា។ នៅឆ្នាំ១៩៩៣ សម្តេចព្រះជាយា ទ្រង់បានទទួលគោរមងារថា ជាសម្តេចព្រះមហេសី នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា ហើយនៅឆ្នាំ១៩៩៦ ព្រះមហេសីបានទទួលបរមងារជាសម្តេចព្រះរាជអគ្គមហេសី ហើយចុងក្រោយនេះ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ត្រូវបានព្រះរាជបុត្រ សីហមុនី ជាព្រះមហាក្សត្រថ្មីថ្វាយព្រះបរមងារថា ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។



ម៉ូនិក អ៊ីស៊ី



www.elibraryofcambodia.org



*ព្រះមហាក្សត្រសម្ដេចព្រះនរោត្តម សីហនុ និងព្រះអគ្គមហេសី មុនិនាថ សីហនុ (អ៊ុំ មុនិនាថ)។*

*រូបក្នុង* http://4.bp.blogspot.com/-l83Kre1MrU/UlwMj_qXWAI/AAAAAAAABel/gzhhl2WdSws/s1600/LTOsdsihaph 12.jpg

ចំណាងស្នេហ៍ជាមួយអ្នកម្នាង ម៉ូនិក ព្រះអង្គបានទទួលនូវបុត្រា២ព្រះអង្គ៖



*ព្រះអង្គម្ចាស់ សីហមុនី*

១. ព្រះអង្គម្ចាស់ នរោត្តម សីហមុនី។ ព្រះអង្គម្ចាស់ សីហមុនី ត្រូវបានបញ្ជូនឲ្យទៅសិក្សានៅប្រទេសឆេកូស្លូវ៉ាគី និងក្រោយមកបន្តសិក្សានៅប្រទេសកូរ៉េខាងជើង។ ព្រះអង្គម្ចាស់ សីហមុនី ក្រោយមកក៏ត្រូវបានក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបោះឆ្នោតជ្រើសតាំងឲ្យឡើងធ្វើជាព្រះមហាក្សត្រជំនួសព្រះបិតារបស់ព្រះអង្គ ដែលបានដាក់រាជ្យនៅឆ្នាំ២០០៤[157]។

[157] *រូបព្រះរាជកុមារ នរោត្តម សីហមុនី និងនរោត្តម នរិន្ទ្រពង្ស នៅក្នុង៖ https://www.facebook.com/ilovemymonarch?fref=photo*



www.elibraryofcambodia.org

២. ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស[158] ហើយក៏ត្រូវបានបញ្ជូនឲ្យទៅសិក្សានៅសហភាពសូវៀត (រុស្ស៊ី)។ សម្ដេច សីហនុ បានឡាយថា ព្រះអង្គម្ចាស់ នរិន្ទពង្ស ជាបុត្រាមួយអង្គដែលបានធ្វើឲ្យបិតាចុកចាប់ព្រះឱរាជាងគេក្នុងចំណោមបុត្រាបុត្រីទាំង១៤អង្គរបស់ព្រះអង្គ។ សម្ដេច នរោត្តម សីហនុ បានឡាយថា ក្រៅពីនោះ នៅក្នុងដំណើររឿងស្នេហារបស់ព្រះអង្គ ទ្រង់ក៏មានស្នេហាជាមួយអតីតស្នំមួយចំនួនរបស់ព្រះអយ្យកោ ខាងមាតារបស់ទ្រង់គឺព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ដែរ ប៉ុន្តែមានតែនារី៥នាក់ទេដែលមានបុត្រាបុត្រីជាមួយព្រះអង្គ ហើយសព្វថ្ងៃនេះ ក្នុងចំណោមបុត្រទាំង១៤អង្គ នៅមានព្រះជន្មតែ៦អង្គប៉ុណ្ណោះ (គិតត្រឹមឆ្នាំសៀវភៅបោះពុម្ព)។ ព្រះអង្គធ្លាប់បានមានបន្ទូលជាភាសាអង់គ្លេសនៅក្នុងសន្និសីទកាសែតនាទសវត្សរ៍១៩៧០ថា ព្រះអង្គក៏ធ្លាប់ជាផ្លេប៊យ (Playboy)[159] ហើយថា បើទោះបីព្រះអង្គជា Playboy ក៏ដោយ ក៏ព្រះអង្គមិនដែលពាក់ពន្ធ័នឹងនារីវៀតណាមណាម្នាក់ដែរ។ សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រព្រះអង្គបានមាន


ព្រះអង្គម្ចាស់ នរិន្ទពង្ស

[158] ឯកសារខ្លះសរសេរ "នរិន្ទ:ពង្ស" និង "នរិន្ទពង្ស" "នរិន្ទ្រតារាពង្ស" និង "ណារិន្ទពង្ស"។ ពាក្យ "នរិន្ទ" មានន័យថា "អ្នកដែលជាម្ចាស់នៃមនុស្ស ឬធំលើអស់ជន........

[159] https://www.youtube.com/watch?v=yaHVVyj6xjk
(ក្នុងវចនានុក្រម Cambridge គឺ Playboy មានន័យថា a rich man who spends his time and money on expensive things and a life of pleasure ឬបុរសអ្នកមានដែលចំណាយពេលវេលានិងលុយកាក់សម្រាប់របស់របរថ្លៃៗនិងជីវិតសប្បាយរីករាយ)



www.elibraryofcambodia.org

បន្ទូលថា "នៅពេលខ្ញុំធំដឹងក្ដី ឪពុកខ្ញុំបានចោទខ្ញុំថាជាផ្ដេសផ្ដាស តែគាត់ជាផ្ដេសផ្ដាសជាងខ្ញុំទៅទៀត"[160]។

## រាជបល្ល័ង្ក និងរាជកិច្ច

**១៩៤០៖** អាណាចក្រជប៉ុនចាប់ផ្ដើមមានឥទ្ធិពលនៅតំបន់អាស៊ី ពិសេសនៅឥណ្ឌូចិន។ នៅឆ្នាំនោះ ថៃដែលជាអ្នកគាំទ្រជប៉ុនបានគាបសង្កត់បារាំងឲ្យប្រគល់ទឹកដីដែលបារាំងគ្រប់គ្រងមកខ្លួនជាអ្នកកាន់កាប់វិញ តែរដ្ឋបាលបារាំងដែលជាអាណាព្យាបាលកម្ពុជាមិនយល់ព្រម ដែលនាំឲ្យមានសង្គ្រាមថៃ-បារាំងកើតឡើងនៅចន្លោះខែតុលា ឆ្នាំ១៩៤០ និងខែឧសភា ឆ្នាំ ១៩៤១។ កងទ័ពថ្មើរជើង និងទ័ពអាកាសរបស់ថៃបានបំពាក់អាវុធបានល្អជាង និងមានឱកាសប្រយុទ្ធជាមួយបារាំងនៅកម្ពុជា។ ទោះបីជាយ៉ាងនេះក្ដី ក៏កងទ័ពជើងទឹកបារាំងដែលមានសព្វាវុធទំនើបបានវាយដោយជោគជ័យក្នុងសមរភូមិកោះឆាង (Koh Chang)។ ដោយបារម្ភថាការប្រយុទ្ធគ្នារវាងបារាំងនិងថៃអាចប៉ះពាល់ផែនការរបស់ខ្លួននៅតំបន់អាស៊ីអាគ្នេយ៍ ជប៉ុនបានចូលមកអន្តរាគមន៍ ហើយបានធ្វើកិច្ចព្រមព្រៀងបទឈប់បាញ់គ្នាដែលបានប្រកាសនៅថ្ងៃទី២៨ មករា ១៩៤១។ គួរបញ្ជាក់ថាមុនសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) រដ្ឋាភិបាលបារាំងបានយល់ព្រមធ្វើកិច្ចព្រមព្រៀងជាមួយថៃ ដើម្បីរៀបចំផែនទីថ្មីដែលអាចជាការពេញចិត្តសម្រាប់ថៃ ប៉ុន្តែនៅពេលសង្គ្រាមលោកលើកទី២បានផ្ទុះឡើង បារាំងបានជាប់ដៃវាយតតាំងជាមួយពួកឈ្លានពានហ៊ីត្លែរអាល្លឺម៉ង់ ខណៈដែលជប៉ុនមានឥទ្ធិពលនៅឥណ្ឌូចិន ដែលនាំឲ្យកិច្ចព្រមព្រៀងនោះមិន

[160] *សៀវភៅ: Worrior Prince - Norodom Ranariddh, Son of King Sihanouk of Cambodia ទំព័រ២*



www.elibraryofcambodia.org

បានធ្វើឡើង។ ឆ្លៀតឱកាសដែលអាណាចក្រជប៉ុនកំពុងគាំទ្រខ្លួន ហើយបារាំងកំពុងជាប់ដៃជាមួយពួកហ៊ីត្លែរនៅអឺរ៉ុប និងចុះខ្សោយនៅឥណ្ឌូចិន សៀមក៏បានចូលវាយដណ្ដើមកាន់កាប់ខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ ឬ ស៊ីសុផុន របស់ខ្មែរសារជាថ្មីនៅដើមឆ្នាំ១៩៤១។ នៅថ្ងៃទី៩ ឧសភា ឆ្នាំដដែល កិច្ចព្រមព្រៀងសន្តិភាពបានធ្វើនៅទីក្រុងតូក្យូប្រទេសជប៉ុន ហើយជប៉ុនបានបង្ខំឲ្យបារាំងប្រគល់ទឹកដីនោះទៅឲ្យសៀមតាមសំណើរបស់សៀម[161]។ ចាប់ពីថ្ងៃទី ៩ ឧសភា ១៩៤១ ដល់ឆ្នាំ ១៩៤៥ ខណៈដែលអាណាចក្រជប៉ុនគ្រប់គ្រងឥណ្ឌូចិន សៀមមានឱកាសកាន់កាប់ទឹកដីនៅក្នុងខេត្តទាំង៤នោះឡើងវិញ។

**២៥ មេសា ១៩៤១៖** នៅពេលដែលព្រះករុណាព្រះបាទសម្តេចស៊ីសុវត្ថិ មុនីវង្ស ដែលជាព្រះអយ្យកោ [ជីតា] ខាងមាតារបស់ព្រះអង្គម្ចាស់ នរោត្តម សីហនុ បានសោយទិវង្គតនៅថ្ងៃទី ២៤ មេសា ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កក៏បានជ្រើសតាំងនិងថ្វាយព្រះរាជហឋានៈព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**២៨ តុលា ឆ្នាំ ១៩៤១៖** ព្រះអង្គម្ចាស់ នរោត្តម សីហនុ បានគ្រងរាជសម្បត្តិជាផ្លូវការក្នុងកាលៈទេសៈដែលកម្ពុជាគឺជាផ្នែកមួយនៃឥណ្ឌូចិន (កម្ពុជា-វៀតណាម-ឡាវ) ដែលស្ថិតនៅក្រោមអាណានិគមបារាំង។ ព្រះអង្គធ្លាប់បានទូលថា "ព្រះអង្គម្ចាស់វ័យក្មេងនេះ [នរោត្តម សីហនុ] ដែលព្រះអង្គមិនដែលសង្ឃឹមសោះថា ថ្ងៃណាមួយព្រះអង្គនឹងអាចឡើងគ្រងរាជបល្ល័ង្ករបស់ប្រទេសកម្ពុជានោះ នាពេលនោះកំពុងបំពេញការសិក្សាដ៏ល្អប្រសើរនៅទីក្រុងព្រៃនគរ ហើយហៀបនឹងប្រឡងយកមធ្យមសិក្សាបត្រ

[161] *http://en.wikipedia.org/wiki/Cambodian%E2%80%93Thai_border_dispute*



www.elibraryofcambodia.org

ខាងផ្នែកវោហាសាស្ត្រ (Baccalauréat de rhétorique)"[162] ទៀតផង។ ព្រះអង្គបានបន្តថា ការគ្រងព្រះរាជបល្ល័ង្កនេះក៏មានជម្លោះនិងការប្រជែងគ្នារវាងសែខាងព្រះជេដ្ឋា [បង] ព្រះបាទ នរោត្តម និងសែព្រះអនុជ [ប្អូន] ព្រះបាទ ស៊ីសុវត្ថិ ដែរ ហើយថា នៅក្នុងឆ្នាំ១៩០៦ ដោយមានការគាបសង្កត់ពីបារាំង ក៏មានការលម្អៀងទៅរកសែព្រះបាទ ស៊ីសុវត្ថិ ដែលជាព្រះអនុជរបស់ព្រះបាទ នរោត្តម ដែរ ហើយក៏ជ្រើសរើសយកសែព្រះបាទ ស៊ីសុវត្ថិ ឲ្យឡើងសោយរាជ្យនាឆ្នាំនោះទៅ។ ក្រោយពីព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ដែលមានព្រះជន្មាយុជរាបានសោយព្រះសុវណ្ណគតទៅ ហើយដើម្បីបញ្ចប់នូវការប្រជែងគ្នារវាងសែព្រះបាទ ស៊ីសុវត្ថិ និងសែព្រះបាទ នរោត្តម ផង បារាំងនិងក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសរើសព្រះអង្គម្ចាស់វ័យក្មេង សីហនុ ឲ្យឡើងគ្រងរាជ្យបន្ត។ ព្រះអង្គមានសែខាងព្រះជេដ្ឋាព្រះបាទ នរោត្តម ផង និងសែព្រះអនុជ ព្រះបាទ ស៊ីសុវត្ថិ ផង គឺថាខណៈដែលព្រះអង្គជាព្រះរាជនត្តាទួត [ចៅទួត] របស់ព្រះបាទ នរោត្តម សែខាងព្រះបិតានោះ ព្រះអង្គក៏ជាព្រះរាជនត្តាទួតរបស់ព្រះបាទ ស៊ីសុវត្ថិ សែខាងព្រះមាតាដែរ[163]។

---

[162] "រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា" របស់សម្តេចឪ (ទំព័រ ១៨)

[163] សៀវភៅ៖ "រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា" របស់សម្តេចឪ (ទំព័រ ១៧-១៨)



www.elibraryofcambodia.org



*ថ្ងៃឡើងគ្រងរាជបល្ល័ង្កជាផ្លូវការរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ នាថ្ងៃទី ២៨ តុលា ១៩៤១ បន្ទាប់ពីក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសតាំងនិងថ្វាយព្រះរាជឋានៈជូនព្រះអង្គកាលពីថ្ងៃទី ២៥ មេសា ឆ្នាំដដែល (រូបបណ្ណសារដ្ឋានជាតិកម្ពុជា)។*

**១៩៤១ - ១៩៤៥៖** អាណាចក្រជប៉ុនបានចូលមកឥណ្ឌូចិន [កម្ពុជា-វៀតណាម-ឡាវ] ហើយបានធ្វើអាណានិគមជំនួសបារាំង។ ដោយមានការគាបសង្កត់ពីជប៉ុន ព្រះមហាក្សត្រ នរោត្តម សីហនុ បានប្រកាសពីឯករាជភាពរបស់កម្ពុជាពីប្រទេសបារាំង។ ព្រះអង្គមានការប្រុងប្រយ័ត្នចំពោះការសម្របសម្រួលលើកិច្ចការជាច្រើនជាមួយជប៉ុន ហើយបន្ទាប់មក



www.elibraryofcambodia.org

ជប៉ុនក៏បានតែងតាំង សឺង ង៉ុកថាញ់ ជារដ្ឋមន្ត្រីការបរទេស និងជានាយករដ្ឋមន្ត្រី[164] នៅថ្ងៃទី១៤ សីហា ១៩៤៥។

**១៩៤៥៖** នៅចុងឆ្នាំនេះ អាណាចក្រជប៉ុនចាញ់សង្គ្រាមលោកលើកទីពីរ។ ពេលនោះ បារាំងក៏ចាប់ផ្តើមមានអំណាចនៅ កម្ពុជាឡើងវិញ ហើយបន្តធ្វើអាណានិគមលើកម្ពុជាម្តងទៀត។

**តុលា ១៩៤៦៖** សៀមក៏បានប្រគល់ខេត្តខ្មែរដែលខ្លួនកាន់កាប់មកឲ្យខ្មែរវិញ។ ទោះបីជាយ៉ាងនេះក្តី សៀមនៅតែបន្តគ្រប់គ្រងប្រាសាទព្រះវិហារខ្មែរនិងតំបន់ជុំវិញប្រាសាទដដែល ដែលធ្វើឲ្យសម្តេចព្រះ នរោត្តម សីហនុ ដាក់ពាក្យបណ្តឹងទៅតុលាការអន្តរជាតិស្ថិតនៅទីក្រុងឡាអេនៃប្រទេសហូឡង់។ ការដាក់ពាក្យបណ្តឹងនេះក៏មានការជួយជ្រោមជ្រែងពីប្រទេសបារាំងដែរ។ នៅក្នុងខែ**មិថុនា** ឆ្នាំ **១៩៤៧** ព្រះមហាក្សត្រ នរោត្តម សីហនុ បានសាងព្រះផ្នួសមួយព្រះវស្សា (បីខែ)។


មហាក្សត្រ សីហានុបួសនៅវត្តលង្កា

**៤ មិថុនា ១៩៤៩៖** ថ្ងៃនេះបារាំងបានផ្ទេរទឹកដីកម្ពុជាក្រោមចេញពីកម្ពុជា ដោយប្រគល់ឲ្យវៀតណាម កាន់កាប់ជាផ្លូវការ។ ជាការពិត ដែនដីនៃកម្ពុជាក្រោម បើទោះជាកម្ពុជាគិតថាជារបស់ខ្លួនក៏ដោយ ក៏វៀតណាម

[164] *http://webcache.googleusercontent.com/search?q=cache:hlomngQxARAJ:en.wikipedia.org/%20wiki/Norodom_Sihanouk+&cd=1&hl=en&ct=clnk&gl=kh*



www.elibraryofcambodia.org

បានកាន់កាប់ និងមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងរួចទៅហើយ ព្រោះវៀតណាមបានចូលកាន់កាប់តាំងពីឆ្នាំ១៦២៣មក ដែលពេលនោះ ព្រះបាទជ័យជេដ្ឋាទី២កំពុងគ្រងរាជ្យនៅឧដុង្គមានជ័យ ហើយទ្រង់មានមហេសីព្រះនាម ម្ចាស់ក្សត្រិយ៍ ង៉ុក វ៉ាន់ (Ngọc Vạn) ដែលខ្មែរហៅថា ព្រះអង្គចូវ ជាបុត្រីស្តេចយួនព្រះនាម ង្វៀន ហ៊្វុក ង្វៀន (Nguyễn Phúc Nguyên) ឬ វ៉ួង សាយ (Vuong Sai)[165]។

នៅពេលបារាំងកាត់ទឹកដីឲ្យវៀតណាម ព្រះមហាក្សត្រ នរោត្តម សីហនុ បានខ្វាល់យ៉ាងខ្លាំង ហើយបានតវ៉ានឹងបារាំង ដោយព្រះអង្គបានបញ្ជូនគណប្រតិភូខ្មែរទៅចរចានៅប៉ារីស ពីបញ្ហាកម្ពុជាក្រោម។ ប៉ុន្តែខណៈដែលប្រតិភូខ្មែរកំពុងទៅចរចានៅប៉ារីស ស្រាប់តែបារាំងនៅភ្នំពេញបានគំរាមព្រះមហាក្សត្រ នរោត្តម សីហនុ ថា ព្រះអង្គអាចនឹងមានបញ្ហារាជបល្ល័ង្ក ប្រសិនបើបន្តការតវ៉ានោះ។ គួរបញ្ជាក់ថា រាជបល្ល័ង្កនៅពេលនោះ សមាជិករាជវង្សានុវង្សសៃ ស៊ីសុវត្ថិ ក៏នៅតែចង់បានដែរដូចជា ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត និង ស៊ីសុវត្ថិ សិរិមតៈ ជាដើម។ ដោយគ្មានជម្រើសក្រោមគំនាបរបស់បារាំង ព្រះមហាក្សត្រ នរោត្តម សីហនុ បានបញ្ជាឲ្យគណប្រតិភូខ្មែរដែលមានលោកនាយករដ្ឋមន្ត្រី យ៉ែម សំបូរ ជាប្រធានឲ្យវិលមកប្រទេសវិញ ហើយបញ្ឈប់ការចរចា[166]។ ដូចនេះ កូសាំងស៊ីន ឬកម្ពុជាក្រោមជាផ្នែកនៃប្រទេសកម្ពុជាដែលបារាំងបានដាក់អាណានិគមតាំងពីឆ្នាំ១៨៦២នោះ ក៏បានក្លាយជារបស់វៀតណាមចាប់ពីថ្ងៃទី៤ មិថុនា ១៩៤៩ រហូតមក។

កម្ពុជាក្រោមគ្របដណ្តប់តំបន់ ៦៧.៧០០ គីឡូម៉ែត្រការ៉េ ហើយ

---

[165] *សូមអានខ្លឹមសារបន្ថែមស្តីពីការបាត់បង់កម្ពុជាក្រោម នៅក្នុងរាជប្រវត្តិព្រះបាទអង្គឌួង*

[166] *សៀវភៅប្រវត្តិសាស្ត្រកម្ពុជានិងវប្បធម៌ខ្មែរ (ទំព័រ១៧៦-១៧៧)*



www.elibraryofcambodia.org

ពេលនោះមានប្រជាជនប្រមាណ៨លាននាក់ជាខ្មែរក្រោម រស់នៅតាមខេត្តចំនួន ២១ នៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ ដោយប្រជាជនប្រហែល៩៦% កាន់សាសនាព្រះពុទ្ធ[167]។ មុនសង្គ្រាមលោកលើកទី២ នៅកម្ពុជាក្រោមមានវត្តជាង ៧០០ កន្លែង ប៉ុន្តែដោយសារនយោបាយ និងការបំផ្លាញរបស់ចលនាវៀតណាមនិយម មានវត្ត៥៦០ ដែលនៅសល់[168]។ សហព័ន្ធខ្មែរកម្ពុជាក្រោមបានស្នើលោក ឈាន វ៉ម[169] ដែលជាបញ្ញវន្តកម្ពុជាមួយរូបនោះឲ្យសរសេរអត្ថបទមួយទាក់ទិននឹងកម្ពុជាក្រោមទៅតាមការយល់ដឹងរបស់លោក។ នៅក្នុងសំណេរនោះ ឈាន វ៉ម បានលើកឡើងពី "កិច្ចការកូសាំងស៊ីន" (Cochin China Affair) ជាលក្ខខ័ណ្ឌដែលបារាំងបានប្រគល់កម្ពុជាក្រោមឲ្យទៅវៀតណាមកាន់កាប់។ "កិច្ចការកូសាំងស៊ីន" មានលក្ខណៈពិសេសមិនធ្លាប់មានពីមុនមកនៅក្នុងប្រវត្តិសាស្ត្រនៃអាណានិគម ដែលជាករណីលើកដំបូងនៃអ្នកធ្វើអាណានិគមមកលើប្រទេសមួយ បែរជាផ្ទេរប្រទេសក្រោមអាណានិគមនោះទៅឲ្យប្រទេសមួយទៀតធ្វើជាអាណានិគមគ្រប់គ្រងបន្តជំនួសខ្លួនទៅវិញ។

តាមឯកសាររបស់លោក ឈាន វ៉ម "ក្នុងពេលដែលគណប្រតិភូខ្មែរកំពុងចរចានៅប៉ារីស ស្រាប់តែនៅភ្នំពេញ ហ្លួង សីហនុ បានយល់ព្រមជាមួយបារាំងបញ្ឈប់បេសកកម្មគណៈប្រតិភូខ្មែរនៅប៉ារីស"[170]។

*"អតីតទឹកដីកម្ពុជាក្រោមគឺត្រូវបានគ្រប់គ្រងផ្នែករដ្ឋបាលដោយ*

---

[167] *សមាគមខ្មែរកម្ពុជាក្រោម៖ http://www.khmerkrom.org/news-events/human-rights-monitor/146-27mr-chhean-vam-s-testimony-cochin-china-affair*

[168] *សមាគមខ្មែរកម្ពុជាក្រោម៖ http://www.khmerkrom.org/news-events/human-rights-monitor/146-27mr-chhean-vam-s-testimony-cochin-china-affair និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជានិងវប្បធម៌ខ្មែរ (ទំព័រ១៧៦)*

[169] *សូមអានប្រវត្តិ ឈាម វ៉ម ក្នុងសៀវភៅ៖ នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"*

[170] *សៀវភៅប្រវត្តិសាស្ត្រកម្ពុជានិងវប្បធម៌ខ្មែរ (ទំព័រ១៧៦-១៧៧)*



www.elibraryofcambodia.org

*ប្រទេសបារាំង ដោយយកធ្វើជាអាណានិគមកូសាំងស៊ីន (Co-chinchina) នៅចន្លោះឆ្នាំ១៨៦២ និងឆ្នាំ ១៩៤៦ ដែលជាឆ្នាំនៃការទទួលស្គាល់ផ្លូវៀតណាម។ ទឹកដីនោះស្ថិតនៅក្នុងការគ្រប់គ្រងរបស់វៀតណាមតាំងពីសតវត្សទី១៧ នៅពេលដែលអ្នកគ្រប់គ្រងរបស់ប្រទេសនេះបានឆ្លៀតឱកាសពីការមិនឯកភាពផ្ទៃក្នុងនៅក្នុងប្រទេសកម្ពុជា ហើយបានពង្រីកកំណើនអន្តោប្រវេសន៍វៀតណាមចូលមកក្នុងទឹកដីនេះ ហើយក៏ដណ្តើមយក"*[171]។

ចំពោះទឹកដីកម្ពុជាក្រោមនេះ នៅឆ្នាំក្រោយៗមក អ្នកជាតិនិយម និងសមាគមខ្មែរកម្ពុជាក្រោមបានប្រារព្ធពិធីនៃថ្ងៃនេះ ដើម្បីរម្លឹកពីការបាត់បង់កម្ពុជាក្រោមទៅឲ្យវៀតណាម ហើយពួកគេនិងឥស្សរជនខ្លះទៀតដូចជា ខៀវ សំផន នួន ជា និង ប៉ុល ពត ដោយរួមទាំងសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ផង ចង់ទាមទារទឹកដីនោះមកវិញ ខណៈដែលឥស្សរជននយោបាយខ្លះទៀត ដូចជាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងមេដឹកនាំគណបក្សប្រជាជនកម្ពុជារបស់សម្តេចបាននិយាយថា វាពិបាកហើយទៅមិនរួចទេ។ នៅថ្ងៃទី៤ មិថុនា ឆ្នាំ២០១៤ សមាគមខ្មែរកម្ពុជាក្រោមបានប្រារព្ធពិធីនេះដែរនៅឯវត្តសាមគ្គីរង្សី ក្នុងរាជធានីភ្នំពេញ។ នៅក្នុងពិធីថ្ងៃនោះ លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិក៏បានចូលរួមដែរ ដោយលោកបាននិយាយថា បើគណបក្សរបស់លោកបានដឹកនាំប្រទេសនៅពេលខាងមុខ គណបក្សលោកនឹងស្នើឲ្យរដ្ឋសភាបង្កើតច្បាប់អនុញ្ញាតឲ្យខ្មែរកម្ពុជាក្រោមអាចចេញចូលទឹកដីប្រទេសកម្ពុជា ដោយមិនចាំបាច់ប្រើលិខិតឆ្លងដែន ដោយលោកបញ្ជាក់ថា "យើងនឹងស្នើច្បាប់សុំឲ្យបងប្អូនខ្មែរក្រោមគឺជាខ្មែរដូចគ្នាទាំងអស់គឺចេញចូលមកទឹកដីក្រោម មក

[171] *កាសែត The Cambodia Daily ថ្ងៃទី៩ កក្កដា ២០១៤ (ទំព័រ១៥)*

ទឹកដីកណ្តាលនេះគឺមិនមែនឆ្លងប្រទេសទេគឺឆ្លងខេត្ត.......បងប្អូនជាម្ចាស់ដីទាំងអស់គ្នាមិនបាច់ត្រូវការលិខិតឆ្លងដែនអីទេ"[172]។ នៅព្រឹកថ្ងៃទី៨ **ខែកក្កដា ២០១៤** ក្រុមយុវជនប្រមាណ២០០នាក់ ដោយរួមមានទាំងព្រះសង្ឃជាច្រើនអង្គ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិផងបានប្រមូលផ្តុំគ្នា ដើម្បីធ្វើបាតុកម្មតវ៉ាអហិង្សានៅមុខស្ថានទូតវៀតណាមប្រចាំកម្ពុជា។ ការតវ៉ានេះបានធ្វើឡើង បន្ទាប់ពីលោក ទ្រឹង វ៉ាន់ថុង (Tran Van Thong) លេខាទី១ និងជាអ្នកនាំពាក្យនៃស្ថានទូតវៀតណាមបានប្រាប់អ្នកសារព័ត៌មានកាលពីដើមខែមិថុនាកន្លងទៅថា បារាំងមិនបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យវៀតណាមទេ តែព្រៃនគរជាទឹកដីរបស់វៀតណាមតាំងពីយូរយារណាស់មកហើយ ហើយថា ព័ត៌មានបាត់បង់ទឹកដីគ្មានអ្វីជាមូលដ្ឋានទេ គឺគ្មានអ្វីជាភស្តុតាងឡើយ។ បញ្ហានេះបានធ្វើឲ្យអ្នកជាតិនិយមកម្ពុជា ដោយរួមទាំងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិផងនោះបានខឹងសម្បា រហូតកើតមានការតវ៉ាទាមទារឲ្យស្ថានទូតវៀតណាមសុំទោសពលរដ្ឋខ្មែរជាសាធារណៈចំពោះការបំភ្លៃប្រវត្តិសាស្ត្រ តែការតវ៉ាត្រូវបានកងសន្តិសុខខណ្ឌចំការមនពាក់មួកសុវត្ថិភាពពណ៌ខ្មៅប្រដាប់ដោយដំបងឆក់បានវាយបំបែកក្រុមអ្នកតវ៉ានិងសមាជិកជាប់ឆ្នោតគណបក្សសង្គ្រោះជាតិផង ហើយកងសន្តិសុខបានដណ្តើមយកមេក្រូនិងសម្ភារៈតវ៉ាមួយចំនួនពីអ្នកតវ៉ា មុននឹងកម្លាំងនគរបាលបង្ក្រាបបាតុកម្មក្រុងនិងក្រសួងមហាផ្ទៃមកដល់។ ការប៉ះទង្គិចគ្នារវាងកងសន្តិសុខនិងអ្នកតវ៉ាដែលមានដុំថ្ម និងវត្ថុរឹងបានបណ្តាលឲ្យរងរបួសទាំងសង



កឹម សុខា

[172] VOD: http://vodhotnews.com/21916



www.elibraryofcambodia.org

ខាងប្រមាណ១០នាក់។ នៅថ្ងៃដដែលនោះ លោក ទ្រឹង វ៉ានថុង នៅតែប្រកាន់ជំហរចំពោះសម្តីរបស់ខ្លួន ដោយអះអាងថា "ទឹកដីភាគខាងត្បូងរបស់វៀតណាមគឺជាទឹកដីរបស់វៀតណាម វាសមស្របទៅតាមច្បាប់អន្តរជាតិ ហើយត្រូវបានអង្គការសហប្រជាជាតិ និងបណ្តាអង្គការអន្តរជាតិ និងបណ្តាប្រទេសក្នុងអាស៊ានគេទទួលស្គាល់ ហើយវៀតណាមជាប្រទេសមួយមានឯករាជ្យ មានអធិបតេយ្យភាពនិងបូរណភាពទឹកដី។ ហើយចំពោះបងប្អូនណាមួយ ឬអង្គការណាមួយចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាប់ប្រឆាំងនឹងឯកភាពជាតិនិងបូរណភាពទឹកដីរបស់វៀតណាម យើងមិនអនុញ្ញាតឲ្យបងប្អូនណាមួយ ឬអង្គការណាមួយជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់វៀតណាមទេ និងរំលោភទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់វៀតណាមនោះទេ"[173]។ ស្ថានទូតវៀតណាមនៅព្រឹកនោះក៏បានចេញសេចក្តីថ្លែងការណ៍មួយដែរ ដោយថ្កោលទោសនូវទង្វើនៃការដឹកនាំឲ្យមានការតវ៉ានោះ ហើយខ្លឹមសារក៏ប្រហាក់ប្រហែលគ្នានឹងសម្តីលោក ទ្រឹង វ៉ានថុង ដែរ។ បន្ទាប់មកនៅថ្ងៃទី១២ កក្កដា ២០១៤ លោក ឡឺ ហាយ ប៊ិញ (Le Hai Binh) អ្នកនាំពាក្យក្រសួងការបរទេសវៀតណាមត្រូវបានដកស្រង់សម្តីដោយគេហទំព័រព័ត៌មានវៀតណាមមួយដោយនិយាយថា លោកបានស្នើរដ្ឋាភិបាលកម្ពុជាចាត់វិធានការបញ្ចៀសនូវរាល់ការតវ៉ានៅមុខស្ថានទូតវៀតណាមនៅរាជធានីភ្នំពេញទៅថ្ងៃខាងមុខ។ ប៉ុន្តែនៅថ្ងៃទី១៣ ខែកក្កដា ២០១៤ លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃកម្ពុជាបានប្រាប់វិទ្យុសំឡេងប្រជាធិបតេយ្យថា ការស្នើសុំរបស់ជនជាតិវៀតណាមគឺជាសិទ្ធិរបស់មន្ត្រីរូបនោះ ហើយការធ្វើបាតុកម្មរបស់បាតុករខ្មែរប្រឆាំងនឹងវៀតណាដែលមពាក់ព័ន្ធទៅនឹងទឹកដីខ្មែរកម្ពុជាក្រោមជាសិទ្ធិរបស់បាតុករទាំង

---

[173] *កាសែតរស្មីកម្ពុជា ថ្ងៃទី៩ កក្កដា ២០១៤ (ទំព័រមុខ និងទំព័រ ៣ក)*



www.elibraryofcambodia.org

នោះ[174]។ លោក ខៀវ សុភ័គ បញ្ជាក់ថា "តាមប្រវត្តិសាស្ត្រ ដើមឡើយ ទឹកដីខ្មែរកម្ពុជាក្រោមត្រូវបានព្រះបាទជ័យជេដ្ឋាទី២អនុញ្ញាតឲ្យជនជាតិវៀតណាមរស់នៅលើទឹកដីខ្មែរកម្ពុជាក្រោម បន្ទាប់មកបារាំងសេសបានកាត់ទឹកដីនោះឲ្យវៀតណាមនៅថ្ងៃទី៤ មិថុនា ១៩៤៩។ លោកបន្តថា "ហេតុនេះគ្មាននរណាម្នាក់កាឡៃប្រវត្តិសាស្ត្របាននោះទេ"។

សហព័ន្ធនិស្សិតកម្ពុជា និងសមាគមខ្មែរកម្ពុជាក្រោមបានប្រកាសថា ពួកខ្លួននឹងធ្វើបាតុកម្មម្តងទៀតនៅមុខស្ថានទូតវៀតណាមនាថ្ងៃទី២១ កក្កដា ២០១៤ ក្នុងគោលបំណងដដែល ហើយហែក្បួនដើម្បីផ្ញើញត្តិទៅបណ្តាស្ថានទូតសំខាន់ៗដូចជាស្ថានទូតបារាំង អង់គ្លេស អាមេរិក រុស្ស៊ី ចិន និងសហគមន៍អឺរ៉ុប ប៉ុន្តែអាជ្ញាធររាជធានីភ្នំពេញដែលមានលោក ប៉ា សុជាតិវង្ស ជាអភិបាល បានព្រមានថា កម្លាំងសមត្ថកិច្ចរបស់លោកនឹងបង្ក្រាបក្បួនដង្ហែនោះ។ ទន្ទឹមពេលដែលកំពុងមានបញ្ហា វៀតណាមបានប្តូរឯកអគ្គរដ្ឋទូតថ្មីរបស់ខ្លួនចេញគឺលោក ង៉ូ អាញ់យុង (Ngo Anh Dung) ដែលបញ្ចប់អាណត្តិរបស់ខ្លួន ហើយតែងតាំងលោក ថាច់ យូ (Thach Du) អនុរដ្ឋមន្ត្រី [រដ្ឋលេខាធិការ] ក្រសួងការបរទេសមកជំនួសវិញ។ លោកឯកអគ្គរដ្ឋទូតវៀតណាម ថាច់ យូ មានដើមកំណើតជាខ្មែរ[175]។ ក្រោយៗមកការតវ៉ាចេះតែកើតមានជាបន្តបន្ទាប់ ដោយសារតែវៀតណាមមិនព្រមសុំទោស។ ម្យ៉ាងទៀតចាប់តាំងពីអាណត្តិទី២នាឆ្នាំ១៩៩៨ មក (នេះនៅមិនទាន់គិតពីឆ្នាំ១៩៧៩-១៩៩៨ទេ) គឺសមាគមខ្មែរកម្ពុជាក្រោម ដោយរួមទាំងគណបក្សប្រឆាំងផងតែងតែចោទប្រកាន់រាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ទាំងក្នុងរដ្ឋកាលព្រះមហាក្សត្រ

[174] *http://vodhotnews.com/22817*

[175] *AKP: http://www.akp.gov.kh/kh/?p=89169*



www.elibraryofcambodia.org

សម្តេចព្រះ នរោត្តម សីហនុ និងព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ថា ជារដ្ឋាភិបាលក្រោមឥទ្ធិពលអំណាចរបស់វៀតណាម ព្រោះថា រដ្ឋាភិបាលកម្ពុជាមិនដែលការពារផលប្រយោជន៍ខ្មែរនៅកម្ពុជាក្រោមឡើយ ហើយក៏មិនដែលហ៊ាននិយាយពីបញ្ហាជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់ដែលរស់នៅក្នុងប្រទេសកម្ពុជាដែរ។




*ព្រះសង្ឃនិងពលរដ្ឋតវ៉ានៅក្បែរស្ថានទូតវៀតណាមនាថ្ងៃទី២១ កក្កដា ២០១៤ ដើម្បីឲ្យវៀតណាមសុំទោសពីបញ្ហាដីកម្ពុជាក្រោម មុនហែក្បួនយកញត្តិទៅស្ថានទូតសំខាន់ៗនៅភ្នំពេញ។ រូប ហេង ស៊ីនិត្យ*



www.elibraryofcambodia.org




រូបលើ៖ ព្រះសង្ឃនិងពលរដ្ឋតវ៉ានៅក្បែរស្ថានទូតវៀតណាមនាថ្ងៃទី២១ កក្កដា ២០១៤ ដើម្បីឲ្យវៀតណាមសុំទោសពីបញ្ហាដីកម្ពុជាក្រោម ( រូប ហេង ស៊ីនិត្យ )។

រូបក្រោម៖ ក្រុមបាតុករដោយមានទាំងព្រះសង្ឃផងបានកាត់និងដុតទង់ជាតិវៀតណាមនៅក្បែរមុខស្ថានទូតវៀតណាមនាព្រឹកថ្ងៃអាទិត្យទី៥ តុលា ២០១៤ ហើយគំរាមដុតស្ថានទូតនៅពេលក្រោយ ប្រសិនបើមិនមានការសុំទោសនោះ (រូបកាសែត The Cambodia Daily/ Siv Channa ចុះថ្ងៃទី៦ តុលា ២០១៤។





www.elibraryofcambodia.org





ផ្នែកខ្លះនៃខណ្ឌទី១ក្នុងទីក្រុងហូជីមិញ (អតីតក្រុងព្រៃនគរក្នុងដែនដីកម្ពុជាក្រោម) នាព្រឹកថ្ងៃទី ២១ វិច្ឆិកា ឆ្នាំ២០១៤ (រូប ឆាយ សុផល ថតពីលើសណ្ឋាគារ Sofitel Saigon Plaza)។



www.elibraryofcambodia.org









រូបលើឆ្វេង៖ ទិដ្ឋភាពនៃផ្នែកខ្លះក្នុងទីក្រុងហូជីមិញ (អតីតក្រុងព្រៃនគរក្នុងដែនដីកម្ពុជាក្រោម) នាព្រឹកថ្ងៃទី ២១ វិច្ឆិកា ២០១៤។ រូបលើស្តាំ៖ សាលាក្រុងហូជីមិញ ថ្ងៃទី ២០ វិច្ឆិកា ២០១៤។ ទីក្រុងហូជីមិញមានអត្រាអ្នករស់នៅប្រមាណ១០លាននាក់នាឆ្នាំ ២០១៣ ដែលច្រើនជាងរាជធានីភ្នំពេញដល់ទៅប្រមាណ៤ដង។ រូបពីរខាងឆ្វេង៖ ទិដ្ឋភាពនៃផ្នែកខ្លះក្នុងទីក្រុងហូជីមិញ (រូប៖ ឆាយ សុផល)។



www.elibraryofcambodia.org

**ដើមទសវត្សរ៍ ១៩៥០៖** បន្ទាប់ពីសង្គ្រាមលោកលើកទីពីរចប់ ព្រះករុណាសម្ដេចព្រះ នរោត្ដម សីហនុ បានចាប់ផ្ដើមទាមទារឯករាជភាពពីបារាំង ដោយបញ្ចប់អាណានិគមរបស់បារាំងទាំងនៅប្រទេសកម្ពុជា និងនៅប្រទេសក្នុងឥណ្ឌូចិន។ គួររម្លឹកថា បន្ទាប់ពីសង្គ្រាមលោកលើកទីពីរត្រូវបានបញ្ចប់ ក្រុមប្រទេសមហាអំណាចមានអាម៉េរិក បារាំង អង់គ្លេស និងរុស្ស៊ី បានធ្វើការបែងចែកតំបន់ត្រួតត្រារៀងៗខ្លួនទាំងនៅអឺរ៉ុប ទាំងនៅអាស៊ី។ ដំបូងពួកគេបានបែងចែកអំណាចគ្រប់គ្រងនៅអាល្លឺម៉ង់ បន្ទាប់មកនៅក្នុងតំបន់អឺរ៉ុប អាហ្វ្រិក មជ្ឈឹមបូព៌ាមុននឹងមកប្រទេសអាស៊ី[176]។ ចំណែកឯនៅតំបន់អាស៊ីអាគ្នេយ៍វិញ អង់គ្លេសបានកាន់កាប់ប្រទេសច្រើនជាងគេរួមមានឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ប្រ៊ុយណេ និងភូមា ឯអាម៉េរិកគ្រប់គ្រងប្រទេសថៃ និងហ្វីលីពីន ខណៈដែលបារាំងបន្តត្រួតត្រាឥណ្ឌូចិន [កម្ពុជា វៀតណាម និងឡាវ] ដដែល។

**៩ កុម្ភៈ ១៩៥៣៖** ក្នុងនាមជាព្រះមហាក្សត្រ សម្ដេចព្រះ នរោត្ដម សីហនុ បានយាងទៅទីក្រុងប៉ារីស ដើម្បីធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ។ ឆ្លៀតឱកាសនោះ ព្រះមហាក្សត្រក៏បានស្នើឲ្យរដ្ឋាភិបាលបារាំងរំលាយសមាគមនិស្សិតខ្មែរដែលដឹកនាំដោយ លោក ហ៊ូ យន់ ព្រោះសមាគមនេះហាក់ដូចជាប្រឆាំងនឹងព្រះអង្គនិងរាជានិយមនៅកម្ពុជា។ នៅថ្ងៃទី ២៥ មីនា ព្រះអង្គបានជួបជាមួយលោក វ៉ាំងសុង អូរីយ៉ូល ប្រធានាធិបតីបារាំង ដើម្បីលើកពីចំណុចស្ដីពីការទាមទារឯករាជ្យ តែលទ្ធផលមិនទទួលបានគួរជាទីពេញចិត្តឡើយ។

---

[176] *កម្ពុជាក្នុងសង្គ្រាមវៀតណាម (ទំព័រ១៤)*



www.elibraryofcambodia.org

**១៣ មេសា ១៩៥៣៖** ដោយសារលទ្ធផលក្នុងជំនួបជាមួយប្រធានាធិបតីបារាំងមិនបានល្អ ព្រះមហាក្សត្រ នរោត្តម សីហនុ បានបន្តយាងចេញទៅសហរដ្ឋអាម៉េរិក កាណាដា និងជប៉ុនទៀត ដើម្បីស្វែងរកការគាំទ្រដល់ព្រះអង្គក្នុងការស្វែងរកឯករាជ្យ និងបូរណភាពទឹកដីពីអាណានិគមនិយមបារាំង។ នៅសហរដ្ឋអាម៉េរិក សារព័ត៌មានអាម៉េរិក ពិសេសកាសែត ញូវយ៉កថៃមន៍ បានផ្សព្វផ្សាយពីកិច្ចខិតខំប្រឹងប្រែងរបស់ព្រះមហាក្សត្រកម្ពុជាក្នុងការទាមទារឯករាជ្យ ដែលការផ្សាយនេះគឺជាសំឡេងដែលមានឥទ្ធិពលនៅក្នុងពិភពលោក។



*ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ (ឆ្វេង) ត្រូវបានព្រះមហាក្សត្រថៃ អានុលយ៉ាដេត ស្វាគមន៍ នៅស្ថានីយរថភ្លើងក្នុងទីក្រុងបាងកក នាខែតុលា ឆ្នាំ ១៩៥៣។ រូបផ្សាយនៅក្នុងកាសែត Bangkok Post (៤ កក្កដា ១៩៨២)*

**មិថុនា ១៩៥៣៖** ព្រះអង្គបានយាងទៅប្រទេសថៃក្រៅផ្លូវការ ដោយមហាក្សត្រថៃមិនបានដឹងជាមុនទេថា ការយាងនេះគឺមានបំណងចង់និរទេសព្រះកាយ បន្ទាប់ពីមានការគំរាមដល់សង្ខាររបស់ព្រះអង្គពីសំណាក់ពួកបារាំង ហើយថា ព្រះអង្គនឹងមិនយាងមកវិញទេ លុះត្រាតែប្រទេសទទួលបានឯករាជ្យ[177]។ នៅពេលរាត្រីមួយនាខែមិថុនា ព្រះមហាក្សត្រខ្មែរ នរោត្តម

[177] http://webcache.googleusercontent.com/search?q=cache:hlomngQxARAJ:en.wikipedia.org/ wiki/Norodom_Sihanouk+&cd=1&hl=en&ct=clnk&gl=kh



www.elibraryofcambodia.org

សីហនុ បានយាងតាមរថយន្តចូលច្រកព្រំដែនអារញ្ញ ហើយបន្ទាប់មក អាជ្ញាធរតម្រួតថៃនៅទីនោះបានអមដំណើរយាងរបស់ព្រះអង្គទៅទីក្រុងបាងកក។ នៅទីក្រុងបាងកក ព្រះមហាក្សត្រថៃ ភូមិបុល អាឌុលយ៉ាដេត (Bhumibol Adulyadej) បានយាងមកស្វាគមន៍ព្រះមហាក្សត្រខ្មែរនៅឯស្ថានីយរថភ្លើង មុនឲ្យអាជ្ញាធរប៉ូលីសជូនព្រះអង្គយាងទៅសណ្ឋាគារមួយដើម្បីគង់សម្រាកព្រះកាយ[178]។ ក្រោយមកដោយដឹងថា ព្រះមហាក្សត្រខ្មែរបានយាងមកទីក្រុងបាងកកដើម្បីប្រកាសឯករាជ្យពីបារាំង ហើយយកប្រទេសថៃជាមូលដ្ឋាននៃការទាមទារឯករាជ្យនោះ រដ្ឋាភិបាលថៃមិនយល់ព្រមទេ ព្រោះថៃគិតថា ទី១បារាំងជាប្រទេសមហាអំណាចក្នុងពិភពលោក ទី២ មេទ័ពថៃខ្លះក៏បាននិងកំពុងរៀននៅបារាំងដែរ ហើយទី៣ គឺយ៉ាងហោចណាស់ក៏ពីរលើកដែរកន្លងមក ដែលបារាំងព្យាយាមត្រួតត្រាប្រទេសថៃបន្ទាប់ពីឥណ្ឌូចិន។ ដោយសម្រេចថា ខ្លួនមិនចង់ប្រឆាំងបារាំងនោះ រាជរដ្ឋាភិបាលថៃបានស្នើឲ្យព្រះមហាក្សត្រខ្មែរយាងត្រឡប់មកកាន់ប្រទេសវិញ ដែលចាប់ពីពេលនោះមក ទំនាក់ទំនងព្រះមហាក្សត្រខ្មែរ សីហនុ និងព្រះមហាក្សត្រថៃ ភូមិបុល មិនសូវល្អឡើយ។

មានកត្តាមួយទៀតដែលរាជរដ្ឋាភិបាលសៀមមិនព្រមសហការជាមួយព្រះមហាក្សត្រខ្មែរ ក៏ព្រោះសៀមបានគាំទ្រខ្មែរឥស្សរៈរួចទៅហើយនាពេលនោះ ហើយសៀមក៏ងាយគ្រប់គ្រងចលនាខ្មែរឥស្សរៈនេះដែរ តែថៃពិតជាមិនអាចគ្រប់គ្រង នរោត្តម សីហនុ បានទេ ដូចនេះថៃក៏មិនព្រមសហការជាមួយព្រះមហាក្សត្រខ្មែរនាពេលនោះ។ បន្ទាប់ពីថៃមិនស្វាគមន៍ សម្តេច សីហនុ ក៏បានសម្រេចព្រះទ័យបង្កើតស្នាក់ការស្វយ័តមួយនៅក្នុងខេត្តសៀមរាប ហើយបង្កើតកងជីវពល ដើម្បីប្រឆាំងបារាំង។

---

178 កាសែត Bangkok Post ថ្ងៃអាទិត្យទី ៤ កក្កដា ១៩៨២ ទំព័រ ១៩



www.elibraryofcambodia.org

៩ វិច្ឆិកា ១៩៥៣៖ ក្រោយពីមានការខិតខំប្រឹងប្រែងជាមួយមហាមន្ត្រីនិងមន្ត្រីជាច្រើនរបស់ព្រះអង្គកន្លងមក សម្តេច សីហនុ បានទទួលជោគជ័យ ដោយសារបារាំងប្រគល់ឯករាជ្យទាំងស្រុងមកឲ្យព្រះរាជាណាចក្រកម្ពុជា។


រូប៖ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ (ទីពីរស្តាំ) និងមន្ត្រីបារាំងនាថ្ងៃទទួលឯករាជ្យជាតិ។ រូបបណ្ណាល័យជាតិកម្ពុជា

៣ មីនា ១៩៥៥៖ ក្រោយពីប្រទេសបានទទួលឯករាជ្យពីបារាំង សម្តេច សីហនុ នាថ្ងៃនោះបានដាក់រាជ្យ ហើយថ្វាយរាជបល្ល័ង្កជូនព្រះបិតានិងព្រះមាតារបស់ទ្រង់គឺព្រះអង្គម្ចាស់ នរោត្តម សុរាម្រិត និងម្ចាស់ក្សត្រី ស៊ីសុវត្ថិ កុសមៈ[179]។ បន្ទាប់មក ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយម ដែលក្រោយមកក្លាយជាគណបក្សសង្គមរាស្ត្រនិយម ដោយធ្វើនយោបាយចូលរួមប្រកួតប្រជែងបោះឆ្នោតសភាជាមួយគណបក្សផ្សេងៗទៀត ហើយគណបក្សនេះក៏បានឈ្នះដល់ទៅ៨២%នៃការបោះឆ្នោតសភាដ៏ពេញនិយម[180]។ បន្ទាប់មកព្រះអង្គក៏បានក្លាយជាព្រះប្រមុខដឹកនាំនៃរដ្ឋាភិបាល ឬរបបសង្គមរាស្ត្រនិយមរហូតដល់ថ្ងៃទី ១៨ មីនា ឆ្នាំ១៩៧០។ គួរបញ្ជាក់ថា លោក ឆាល មៃយ័រ (Charles Meyer: ១៩២៣ - ២០០៤) ជនជាតិបារាំងដែលបានមករស់នៅក្នុងប្រទេសកម្ពុជានិងវៀតណាមចាប់ពីឆ្នាំ


(ឆាល មៃយ័រ / បណ្ណាល័យជាតិកម្ពុជា)

[179] គេហទំព័រ http://norodomsihanouk.info/family/id_01.html សរសេរថា ព្រះអង្គដាក់រាជនៅខែមេសា១៩៥៥

[180] គេហទំព័រ http://norodomsihanouk.info/family/id_01.html



www.elibraryofcambodia.org

១៩៤៥ បានក្លាយជាជំនួយការ និងជាទីកប្រឹក្សារបស់សម្ដេច សីហនុ ដោយលោកបានជួយបង្កើតចលនាសង្គមរាស្ត្រនិយមនេះ[181]។ នៅពេលនោះ លោក ឆាល ក៏បានជួយកិច្ចការងារព័ត៌មាន និងកិច្ចការសាធារណៈ ហើយជួយសរសេរទស្សនាវដ្ដី និងរាល់ការចេញផ្សាយជាផ្លូវការជាច្រើនរបស់រដ្ឋាភិបាលកម្ពុជាដែរ។

**៥ មករា ១៩៥៦៖** នៅថ្ងៃនេះ សម្ដេចព្រះ នរោត្តម សីហនុ បានលាចេញពីតំណែងនាយករដ្ឋមន្ត្រីនៃរបបសង្គមរាស្ត្រនិយម ដោយប្រគល់តំណែងនេះទៅលោក អ៊ុម ឈាងស៊ុន ដែលលោកកំពុងកាន់តំណែងជារដ្ឋមន្ត្រីមហាផ្ទៃនិងបោសសម្អាតទូទៅ។ ការលាឈប់នេះក៏ដោយសារតែព្រះអង្គមិនសព្វព្រះទ័យនឹងការរិះគន់បែបវាយប្រហារពីសំណាក់សារព័ត៌មានលោកខាងលិច ពិសេសកាសែតអាម៉េរិកដែលបានដាក់ងារព្រះអង្គថា "ស្ដេចក្រហម"។ ការដាក់ងារជា "ស្ដេចក្រហម" នេះ ក៏ដោយសារពួកគេមិនពេញចិត្តនឹងនយោបាយរបស់ព្រះអង្គដែលប្រកាន់យកនយោបាយអព្យាក្រឹត្រ។ កាលពីចុងឆ្នាំ ១៩៥៥ ព្រះអង្គបានយាងទៅបំពេញទស្សនកិច្ចនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដែលនៅទីនោះ ពួកមេដឹកនាំប្រទេសនេះបានខិតខំបញ្ចុះបញ្ចូលព្រះអង្គឲ្យបោះបង់នយោបាយ "អព្យាក្រឹត" របស់ព្រះអង្គចោលទៅ ហើយងាកមករកអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ហៅកាត់ថា សេអាតូ (SEATO)[182] ដែលជាប្លុកសេរីវិញ។ ព្រះអង្គមិនយល់ព្រមព្រោះព្រះអង្គយល់ថា មនុស្សក្នុងប្លុកសេរីជាពួកសាធារណរដ្ឋដែលមានអាម៉េរិកជាបងធំ ហើយពួកសាធារណរដ្ឋនេះមិនត្រូវគ្នានឹងរាជានិយមឡើយ។ ជាងនេះទៅទៀត ព្រះអង្គត្រូវតែមានការប្រុងប្រយ័ត្នបំផុត ព្រោះថា ពួក

---

[181] *បណ្ណសារដ្ឋានជាតិកម្ពុជា*

[182] *SEATO = Southeast Asia Treaty Organization*



www.elibraryofcambodia.org

កុម្មុយនិស្តមានចិននិងវៀតណាមក៏បានព្យាយាមអន្ទងកម្ពុជាឲ្យចូលក្នុងបន្ទាត់នយោបាយរបស់ពួកគេដែរ ហើយពួកនេះក៏បានជួយជ្រោមជ្រែងក្រុមចលនាតស៊ូខ្មែរក្រហមទៀត ដែលបញ្ហានេះគឺជាគ្រោះអាសន្ននៃអំណាចរាជបល្ល័ង្ក និងរាជានិយមរបស់ព្រះអង្គ។ ចរន្តនយោបាយប្រទាក់ក្រឡានិងចាក់ស្រែះនេះហើយ ដែលធ្វើឲ្យព្រះអង្គពិបាកបោះបង់ចោលនយោបាយ "អព្យាក្រឹត" ក្នុងការចាប់យកក្រុម "សេរីអាត្ម" នោះ។ បើព្រះអង្គហ៊ានធ្វេសតែបន្តិចនាពេលនោះ ព្រះអង្គអាចបាត់បង់អំណាចភ្លាមៗដោយសារតែពួកខ្មែរក្រហមដែលមានចិន និងវៀតណាមកុម្មុយនិស្តនៅពីក្រោយ ឬក៏ដោយពួកសាធារណរដ្ឋដែលមាន សឺង ង៉ុកថាញ់ និង សម សារី[183] ជាដើម។ ដូចនេះ ព្រះអង្គបានបណ្ដោយឲ្យកម្ពុជាវេរាំក្នុងល្បែងអព្យាក្រឹតរវាងពួក "ក្រហម" និងពួក "សេរីអាត្ម"។

**១៣ - ២១ កុម្ភៈ ១៩៥៦៖** ព្រះអង្គក៏បានយាងទៅប្រទេសដែលជាប្លុកកុម្មុយនិស្ត គឺចិន សហភាពសូវៀត (រុស្ស៊ី) និងឆេកូស្លូវ៉ាគី។ នៅក្នុងទីក្រុងប៉េកាំង ព្រះអង្គបានចេញសេចក្ដីថ្លែងការណ៍មួយស្ដីពីមិត្តភាពកម្ពុជា-ចិន ដែលក្នុងនោះកម្ពុជាសុខចិត្តព្រមទទួលយកជំនួយពីមិត្តចិន ហើយសេចក្ដីប្រកាសនេះត្រូវបានសារព័ត៌មានលោកខាងលិចចោទព្រះអង្គថា គឺពិតជា "ស្ដេចក្រហម" មែន។

**មេសា ១៩៦០៖** បន្ទាប់ពីព្រះបិតាព្រះបាទសម្ដេច នរោត្តម សុរាម្រិត ស្ដេចសោយព្រះទិវង្គតនាថ្ងៃ៣ មេសា នាឆ្នាំនោះ សមាជិកសភាបានឯកភាពជាឯកច្ឆន្ទដោយថ្វាយព្រះរាជតំណែងជាព្រះប្រមុខរដ្ឋនៃប្រទេស

---

*[183] អានប្រវត្តិ សឺង ង៉ុកថាញ់ និង សម សារី នៅក្នុងសៀវភៅ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"*



www.elibraryofcambodia.org

កម្ពុជាជូនសម្ដេចព្រះ នរោត្តម សីហនុ ដើម្បីឲ្យព្រះអង្គបានដឹកនាំកសាងជាតិ។ នៅឆ្នាំបន្ទាប់ (១៩៦១) ព្រះអង្គក៏បានយាងចូលរួមក្នុងកិច្ចប្រជុំកំពូលលើកដំបូងនៃសន្និសីទរបស់បណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធនាទីក្រុងប៊ែលហ្គ្រាត (Belgrade) ប្រទេសយូហ្គោស្លាវី។

**១៥ មិថុនា ១៩៦២៖** ក្រោមរាជកិច្ចដឹកនាំនៃសម្ដេច សីហនុ ប្រទេសកម្ពុជាបានឈ្នះក្ដីលើករណីប្រាសាទព្រះវិហារ ដែលសាងសង់ក្នុងសតវត្សទី៩-១១ពីប្រទេសថៃនៅឯតុលាការអន្តរជាតិនាទីក្រុងឡាអេ។ មុនកាត់ក្ដីនេះ ថៃបានចាត់ទុកប្រាសាទព្រះវិហារខ្មែរថាជារបស់ខ្លួន ដោយបានបញ្ជូនកងទ័ពមកកាន់តំបន់ជុំវិញប្រាសាទនេះ។ កម្ពុជាដែលកាលពីឆ្នាំនោះមានសម្ដេច នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋបានប្ដឹងទៅតុលាការអន្តរជាតិមួយនេះ។ បើទោះជាថៃដែលកាលពីពេលនោះចាញ់ក្ដីមិនហ៊ានតវ៉ាក៏ដោយ ក៏ថៃនៅតែចិញ្ចឹមចិត្តថា ប្រាសាទព្រះវិហារជារបស់ខ្លួន ហើយមានបំណងចង់បានជាដរាបមក។ អស់ជាច្រើនឆ្នាំក្រោយមក ជម្លោះនៃប្រាសាទវិហារនៅតែបន្តមាន ដោយសារថៃចេះតែចង់បាន។ គួរបញ្ជាក់ថា នៅក្នុងតំបន់ទេសចរណ៍មួយនាខេត្តសមុទ្រប្រាកាន ប្រទេសថៃ ថៃក៏បានសាងសង់ប្រាសាទព្រះវិហារជានិមិត្តរូបដែរ ដើម្បីទាក់ទាញភ្ញៀវទេសចរទាំងក្នុងស្រុក និងបរទេស។ នៅពេលខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅទីនោះនាឆ្នាំ ២០០៥ ហើយស្ដាប់ឮមគ្គុទេសក៍ទេសចរណ៍ថៃរៀបរាប់ថា ប្រាសាទនេះជាអតីតប្រាសាទរបស់ថៃ គឺខ្ញុំមិនហ៊ានតវ៉ា ឬបញ្ចេញយោបល់នោះទេ ព្រោះខ្ញុំខ្លាចមានបញ្ហានៅទីនោះ។ ដូចគ្នានឹងនៅក្នុងរាជវាំងនាទីក្រុងបាងកកដែរ គឺខ្ញុំគ្រាន់តែស្ដាប់ ហើយងក់ក្បាល នៅពេលមគ្គុទេសក៍ទេសចរណ៍ថៃពន្យល់ថា ប្រាសាទអង្គរវត្តជាអតីតៈរបស់ថៃ។



www.elibraryofcambodia.org



*ប្រាសាទព្រះវិហារជានិមិត្តរូបដែលបានសាងសង់នៅក្នុងតំបន់ទេសចរណ៍មួយនាខេត្តសមុទ្រប្រាការ ប្រទេសថៃ ដើម្បីទាក់ទាញភ្ញៀវទេសចរទាំងក្នុងស្រុកនិងបរទេស។ មគ្គុទេសក៍ទេសចរណ៍ថៃរៀបរាប់ថា ប្រាសាទព្រះវិហារជាអតីតប្រាសាទរបស់ថៃ។ រូប ឆាយ សុផល នៅថ្ងៃទី ៣ សីហា ឆ្នាំ ២០០៥៦*

សូមរម្លឹកបន្តិចថា ជាច្រើនឆ្នាំក្រោយមក ថៃនៅតែមិនអស់ចិត្តពីប្រាសាទព្រះវិហាររបស់ខ្មែរនេះ ដោយកងទ័ពរបស់ថៃបានបង្កបញ្ហាជាបន្តបន្ទាប់នៅតំបន់នោះ។ នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលថៃក្នុងអាណត្តិលោកនាយករដ្ឋមន្ត្រី អាប់ភិស៊ីត វីចាជីវ៉ា (Abhisit Vejajiva) មានបញ្ហានយោបាយផ្ទៃក្នុង ហើយលោក អាប់ភិស៊ីត តែងតែបានបង្វិលបញ្ហានោះឲ្យជាប់ពាក់ព័ន្ធនឹងបញ្ហាព្រំដែនរវាងកម្ពុជា-ថៃទៅវិញ ពិសេសពីប្រាសាទព្រះវិហារខ្មែរ។ នៅពេលនោះ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរបានខិតខំតស៊ូខ្នះខ្នែងទាំងផ្លូវច្បាប់អន្តរជាតិផង និងកងកម្លាំងយោធាផងក៏បានទទួលជោគជ័យជាប្រវត្តិសាស្ត្រម្តងទៀត។ នៅក្នុងឆ្នាំនោះ បញ្ហានេះបានធ្វើឲ្យចំណងការទូតរបស់ប្រទេសទាំងពីរកាន់តែធ្លាក់ចុះ រហូតដល់មានការដកឯកអគ្គរាជទូតចេញពីប្រទេសរៀងៗខ្លួន ដែលការដកនេះ ថៃជាអ្នកធ្វើ



www.elibraryofcambodia.org

មុន។ ក្រោយមក ថៃក៏បានបញ្ជូនឯកអគ្គរាជទូតរបស់ខ្លួនមកកាន់ប្រទេសកម្ពុជាវិញ ហើយកម្ពុជាក៏ធ្វើតាមក្រោយ។ នៅថ្ងៃទី៧ ខែ កក្កដា ឆ្នាំ ២០០៨ នាទីក្រុងកេបិចប្រទេសកាណាដា បេសកកម្មរបស់គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយលោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានទទួលជោគជ័យជាប្រវត្តិសាស្ត្រ ដោយអង្គការយូណេស្កូបានដាក់បញ្ចូលប្រាសាទព្រះវិហារខ្មែរទៅជាបេតិកភណ្ឌពិភពលោក ដើម្បីអភិរក្សឲ្យបានប្រសើរដល់ប្រាសាទនេះ។

កាលពីថ្ងៃទី១៥ កក្កដា ឆ្នាំ២០០៨ ដោយមិនសុខចិត្តចំពោះការបញ្ចូលប្រាសាទព្រះវិហារខ្មែរដាក់ជាបេតិកភណ្ឌពិភពលោក ព្រះសង្ឃមួយអង្គ និងតាជីពីរនាក់របស់ថៃ បានចូលមកអង្គុយនៅមុខជណ្តើរឡើងប្រាសាទព្រះវិហារក្នុងទឹកដីខ្មែរ ដោយបានឆ្លងចូលដោយខុសច្បាប់។ អ្នកទាំងបីមកធ្វើសមាធិ (តាំងអារម្មណ៍) ដោយចាត់ទុកថា ប្រាសាទព្រះវិហារជារបស់ថៃ ប៉ុន្តែពួកគេត្រូវបានកម្លាំងនគរបាលកម្ពុជាចាប់បញ្ជូនឲ្យត្រឡប់ចូលទៅក្នុងទឹកដីថៃវិញ។ នៅថ្ងៃទី១៦ កក្កដា ឆ្នាំ ២០០៨ ថៃបានបញ្ជូនកងទ័ពរបស់ខ្លួនចូលមកក្នុងដែនដីរបស់កម្ពុជានៅក្នុងបរិវេណវត្តកែវសិក្ខាគិរីស្វារៈ ក្បែរប្រាសាទព្រះវិហារ។ កងកម្លាំងរបស់ព្រះរាជាណាចក្រកម្ពុជាបន្ទាប់មកក៏បានបញ្ជូនទៅទីនោះដែរ ដោយសម្តេចតេជោ ហ៊ុន សែន និងរាជរដ្ឋាភិបាលរបស់លោកបានស្រែកប្រាប់ពិភពលោកថា ថៃកំពុងតែឈ្លានពានចូលដែនដីកម្ពុជាហើយ ហើយទាមទារឲ្យពួកនេះដកចេញពីទឹកដីកម្ពុជាជាបន្ទាន់។ ទោះជាកម្ពុជាប្រកាសឲ្យពួកគេដកទ័ពចេញក៏ដោយ ក៏ថៃនៅតែគឃ្លើនមិនព្រមដកថយដែរ ហើយក៏បានបញ្ជូនកម្លាំងរបស់ខ្លួនបន្ថែមមកដោះមីននៅក្នុងទឹកដីខ្មែរថែមទៀត។ នេះក៏ដោយសារតែថៃគិត



www.elibraryofcambodia.org

ថា ប្រទេសកម្ពុជាតូច និងមានកម្លាំងទ័ពតិចជាងខ្លួន។ ជនជាតិថៃមួយចំនួនបានចាត់ទុកកម្ពុជាជាប្រទេសតូច និងក្រីក្រ ដែលពិតជាមិនហ៊ានតបតជាមួយពួកគេឡើយ ហើយក៏បានបញ្ជូនទ័ពមកកាន់តែច្រើននៅតាមតំបន់ព្រំដែន។ ប៉ុន្តែការគិតរបស់ពួកគេពិតជាខុស ព្រោះកងកម្លាំងដែលឯកភាពតែមួយក្រោមបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជាគឺមិនខ្លបខ្លាចចំពោះកម្លាំងឈ្លានពានរបស់ថៃឡើយ។ នៅថ្ងៃទី២១ កក្កដា ឆ្នាំ ២០០៨ ស្ថានភាពយោធាកាន់តែតានតឹង ហើយមេទ័ពនៃប្រទេសទាំងពីរបានចរចាគ្នាដើម្បីដោះស្រាយបញ្ហា ប៉ុន្តែការដោះស្រាយនៅតែមិនអាចធ្វើបាន។ ថៃចាត់ទុកវត្តកែវសិក្ខាគិរីស្វារៈ ស្ថិតនៅក្នុងតំបន់ស ហើយតំបន់នៅក្បែរប្រាសាទព្រះវិហារដែលថៃគិតថាមានទំហំ ៤,៦ គីឡូម៉ែត្រការ៉េនោះ ចាត់ទុកថាជារបស់ថៃ ប៉ុន្តែកម្ពុជាមិនទទួលស្គាល់ឡើយ។ ចាប់តាំងពីពេលនោះមក កងទ័ពថៃបានបាញ់ផ្លោងគ្រាប់តូចធំជាញឹកញាប់ចូលមកក្នុងទឹកដីកម្ពុជា បង្កការខូចខាតដល់ប្រាសាទព្រះវិហារ វត្តកែវសិក្ខាគិរីស្វារៈ និងផ្ទះសម្បែងអ្នកភូមិនៅតំបន់ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ មិនតែប៉ុណ្ណោះបានធ្វើឲ្យប្រជាជន និងកងទ័ពខ្មែរស្លាប់ និងរបួសជាច្រើននាក់ ហើយជនស៊ីវិលបានរត់មកជ្រកកោននៅក្នុងជំរំជនភៀសខ្លួនឆ្ងាយពីតំបន់ព្រំដែន។ ជាការឆ្លើយតប កងទ័ពកម្ពុជាក្រោមការគ្រប់គ្រងរបស់សម្តេច ហ៊ុន សែន បានប្តេជ្ញាមិនចុះញ៉ម ហើយបានវាយតបទៅពួកសត្រូវវិញ ដោយពួកទាំងនោះក៏ទទួលការខូចខាត មានស្លាប់ និងរបួសផងដែរ។ ទោះជាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឲ្យសមាគមអាស៊ាន ពិសេសប្រទេសឥណ្ឌូណេស៊ីដែលជាប្រធានអាស៊ានមកធ្វើអន្តរាគមន៍ដោយដាក់អ្នកអង្កេតការណ៍ក៏ដោយ ក៏ថៃមិនព្រមអនុញ្ញាតដែរ ដោយថៃនិយាយថា ទុកឲ្យខ្លួន និងកម្ពុជាដោះស្រាយទ្វេភាគី។ ថៃគិតថា ការដោះស្រាយទ្វេភាគី គឺថៃអាចមានប្រៀប



www.elibraryofcambodia.org

លើកម្ពុជាខាងឈ្មោះ។ បន្ទាប់មក កម្ពុជាក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិពីការដែលកងទ័ពថៃបានចូលឈ្លានពានកម្ពុជាចំនួន៣លើកធំៗ គឺលើកទី១នៅថ្ងៃទី ១៥ កក្កដា ឆ្នាំ ២០០៨ លើកទី២នៅថ្ងៃទី ៤-៧ កុម្ភៈ ឆ្នាំ ២០១១ និងលើកទី៣នៅថ្ងៃទី ២២ មេសា ដល់ថ្ងៃទី ៤ ឧសភា ឆ្នាំ ២០១១ នៅតំបន់ប្រាសាទព្រះវិហារ ប្រាសាទតាមាន់ និងប្រាសាទតាក្របីក្នុងខេត្តឧត្តរមានជ័យ។ នៅថ្ងៃទី ២៦ មិថុនា ឆ្នាំ ២០១១ នៅឯកិច្ចប្រជុំលើកទី ៣៥ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនាទីក្រុងប៉ារីស ប្រទេសបារាំង គណៈកម្មាធិការនេះបានទទួលយករបៀបវារៈរបស់កម្ពុជាស្ដីពីបញ្ហាជួសជុលប្រាសាទព្រះវិហារ។ របៀបវារៈនេះត្រូវបានប្រទេសថៃជំទាស់យ៉ាងខ្លាំង ប៉ុន្តែទីបំផុត សំណើកម្ពុជាត្រូវបានទទួលយក ហើយគណៈកម្មាធិការនេះក៏បានសម្រេចបញ្ជូនអ្នកជំនាញឲ្យមកពិនិត្យ និងជួសជុលការខូចខាតប្រាសាទព្រះវិហារជាបន្ទាន់។ ការសម្រេចនេះគឺជាជោគជ័យជាថ្មី និងជាប្រវត្តិសាស្ត្ររបស់គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងរបស់ថៃនៅពេលនោះគឺរារាំងផែនការគ្រប់គ្រងប្រាសាទព្រះវិហារខ្មែរ ដោយមិនចង់ឲ្យបញ្ជូនអ្នកជំនាញការបរទេសមកពិនិត្យ និងជួសជុលប្រាសាទនេះឡើយ។ ដោយមិនសុខចិត្តក្រុមប្រតិភូថៃដែលទៅចូលរួមក្នុងពិធីនោះដែរបានតវ៉ា ហើយបានដើរចេញពីកិច្ចប្រជុំពាក់កណ្ដាលទី ដោយប្រកាសថា ថៃនឹងដកខ្លួនចេញពីសមាជិកភាពនៃអនុសញ្ញាឆ្នាំ ១៩៧២ របស់គណៈកម្មាធិការមួយនេះ។ ចំពោះឥរិយាបថរបស់ប្រតិភូនៃរដ្ឋាភិបាលថៃនេះ សម្ដេច ហ៊ុន សែន នៅថ្ងៃទី ២៧ មិថុនា ឆ្នាំ ២០១១ ក្នុងពិធីប្រគេនសញ្ញាបត្រ និងវិញ្ញាបនបត្រដល់សមណនិស្សិត និងគរុនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនាសាលសន្និសីទចតុមុខ បានហៅរដ្ឋាភិបាលថៃរបស់លោក អាភីស៊ីត វីចាជីវ៉ា ថា



www.elibraryofcambodia.org

ជារដ្ឋាភិបាលដែលប្រើឥរិយាបថជា "បងធំ" ដែលច្រឡើសបើស និង "ប្រើឥរិយាបថច្រងេងច្រងាង" នៅឯកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី ៣៥ នៅប្រទេសបារាំង។ ចាប់តាំងពីលោក អាប់ភីស៊ិត បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីថៃមក លោក អាប់ភីស៊ិត និងរដ្ឋាភិបាលរបស់លោកតែងតែភ្ជាប់បញ្ហានយោបាយផ្ទៃក្នុងរបស់ខ្លួនមកជាមួយបញ្ហាព្រំដែនកម្ពុជា។ ប៉ុន្តែ អាប់ ភីស៊ិត ត្រូវទទួលបរាជ័យយ៉ាងអាម៉ាស់ក្នុងការបោះឆ្នោតជាតិថៃនាថ្ងៃទី ៣ កក្កដា ឆ្នាំ២០១១ ដោយគណបក្សភឿថៃរបស់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ត្រា បានទទួលជោគជ័យដ៏សម្បើម។ នៅព្រឹកថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១ ថ្លែងនៅក្នុងពិធីសម្ភោធការដ្ឋានសាងសង់ស្ពានតាខ្មៅសម្តេច ហ៊ុន សែន បានផ្ញើសារជូនពរដល់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា ដែលកំពុងត្រៀមខ្លួនធ្វើជានាយករដ្ឋមន្ត្រីថៃ ដោយសម្តេចសង្ឃឹមថា រដ្ឋាភិបាលថ្មីរបស់ថៃនឹងដោះស្រាយបញ្ហាគ្រប់យ៉ាងជាមួយកម្ពុជាដោយសន្តិវិធីកាន់តែល្អប្រសើរនៅក្នុងនាមជាដៃគូក្នុងក្របខ័ណ្ឌអាស៊ានក៏ដូចជាក្នុងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ។ លោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា គឺជាប្អូនស្រីបង្កើតរបស់លោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា អតីតនាយករដ្ឋមន្ត្រីថៃ ដែលលោក អាភីស៊ិត បានឡើងធ្វើជានាយករដ្ឋមន្ត្រីថៃ ក្រោយពីមានរដ្ឋប្រហារយោធា។ លោក ថាក់ស៊ីន ដែលជាអ្នកជំនួញដ៏ធំរបស់ថៃដែរនោះគឺជាមេដឹកនាំថៃដែលពិភពលោកមើលឃើញថាជាសម្ព័ន្ធមិត្តដ៏ល្អជាមួយនិងប្រទេសកម្ពុជា ពិសេសជាមួយសម្តេច ហ៊ុន សែន។ នៅថ្ងៃទី ១៨ កក្កដា ឆ្នាំ ២០១១ តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ក៏បានសម្រេចដាក់ចេញវិធានការបណ្តោះអាសន្នជាបន្ទាន់ ដោយតម្រូវឲ្យបង្កើតតំបន់សុវត្ថិភាពគ្មានយោធា។ តុលាការនេះបានបង្គាប់ឲ្យទាំងកម្ពុជានិងថៃដកកងទ័ពចេញពីតំបន់ព្រំដែនប្រាសាទព្រះវិហារ ដើម្បី



www.elibraryofcambodia.org

ឲ្យមានបទឈប់បាញ់ជាអចិន្ត្រៃយ៍ និងតម្រូវឲ្យភាគីទាំងពីរទទួលយកអ្នកសង្កេតការណ៍អាស៊ានចុះមកកាន់តំបន់ជម្លោះ។ កាលពីពេលនោះ គណៈប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំដោយលោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រោមការណែនាំពីសម្តេច ហ៊ុន សែន។ ការសម្រេចនេះត្រូវបានប្រទេសកម្ពុជាចាត់ទុកថា គឺជាជោគជ័យដ៏ធំធេង ហើយក៏បានចេញសេចក្តីថ្លែងការណ៍គាំទ្រនិងសាទរចំពោះសេចក្តីសម្រេចនេះ។ នៅថ្ងៃទី២១ កក្កដា ឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងមួយស្តីពីការអនុវត្តដីការបង្គាប់របស់តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេឲ្យប្រទេសថៃ ប្រទេសឥណ្ឌូណេស៊ី និងតុលាការយុត្តិធម៌អន្តរជាតិ ព្រមទាំងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាផ្លូវការ។ នៅព្រឹកថ្ងៃទី២២ កក្កដា ឆ្នាំ ២០១១ ថ្លែងនៅក្នុងសន្និសីទកាសែតដ៏កម្រមួយស្តីពីបញ្ហាព្រំដែនកម្ពុជា-ថៃនៅឯវិមានសន្តិភាព សម្តេច ហ៊ុន សែន បានបង្ហាញពីឆន្ទៈរបស់កម្ពុជាក្នុងការគោរពនូវសេចក្តីបង្គាប់របស់តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ហើយបានរិះគន់លោក អាភីស៊ិត វីចាជីវ៉ា នាយករដ្ឋមន្ត្រីចាំផ្ទះ (ជិតចប់អាណត្តិ) ថៃថា ជាមនុស្សនិយាយបែប "កូនក្មេង"។ ការលើកឡើងរបស់សម្តេច ហ៊ុន សែន បានធ្វើឡើងបន្ទាប់ពី អាភីស៊ិត បាននិយាយនៅថ្ងៃទី ២១ កក្កដា ថា ប្រទេសឥណ្ឌូណេស៊ី មិនអាចបញ្ជូនអ្នកអង្កេតការណ៍មកកាន់តំបន់ជម្លោះបានទេ លុះត្រាតែប្រទេសកម្ពុជាដកកងទ័ពចេញពីតំបន់នោះមុនសិន។ ចំណែកខាងកម្ពុជាវិញ សម្តេច ហ៊ុន សែន បានអះអាងថា ការដកកងទ័ពត្រូវតែធ្វើឡើងដំណាលគ្នា មិនអាចមុនក្រោយបានឡើយ ហើយថា អាភីស៊ិត ជាមនុស្សមិនស្មោះត្រង់ ព្រោះ "ស៊ីញៀនឹងដៃ លុបនឹងជើង"។ ទាក់ទិននឹងការវាយប្រយុទ្ធគ្នានោះ ការខូចខាត



www.elibraryofcambodia.org

ធ្ងន់ធ្ងរជាងគេគឺនៅថ្ងៃទី ៤ ដល់ថ្ងៃទី ៧ កុម្ភៈ ឆ្នាំ២០១១ ដោយទាហានថៃបានវាយប្រហារយ៉ាងខ្លាំងចូលមកប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទ។ ពួកគេបានផ្លោងចូលប្រាសាទប្រមាណ៤១៤គ្រាប់ ក្នុងនោះគ្រាប់កាំភ្លើងធំដែលធ្លាក់ដោយមិនបានផ្ទុះមានរហូតដល់៩៣គ្រាប់។ ដោយឡែក គ្រាប់ផ្លោងបានធ្លាក់ចូលវត្តកែវសិក្ខាគិរីស្វារៈ ដែលធ្វើឲ្យខូចខាតវត្ត និងព្រះបដិមា។ នៅថ្ងៃទី ២១ មិថុនា ឆ្នាំ ២០១១ ថ្លែងនៅឯទិវាអតីតយុទ្ធជនក្នុងទីក្រុងភ្នំពេញ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានថ្លែងថា កងទ័ពកម្ពុជាបានស្លាប់ចំនួន ១៣ នាក់ ដោយគ្រាប់កាំភ្លើងកងទ័ពថៃក្នុងការវាយប្រយុទ្ធក្នុងរយៈពេល ១២ ថ្ងៃ ដែលចាប់ផ្តើមពីថ្ងៃទី២២ មេសា ២០១១ នៅតាមតំបន់ព្រំដែនជម្លោះក្នុងខេត្តឧត្តរមានជ័យ។ សម្តេច ហ៊ុន សែន បានចោទប្រកាន់ថា ការវាយប្រហារនេះប្រៀបដូចជា "អំពើភេរវកម្ម" គឺមិនមែនជាសង្គ្រាមទេ ព្រោះកងទ័ពថៃបានប្រើកាំភ្លើងស្នាយភឺ (Sniper) ដែលជាកាំភ្លើងមានពន្លឺពិសេសអាចមើលឃើញនៅពេលយប់ងងឹតបាន។ សម្តេចបានបញ្ជាក់ថា "ខ្ញុំគិតថា ការប្រយុទ្ធគ្នាដោយការប្រើប្រាស់ស្នាយភឺគឺមិនមែនជាសង្គ្រាមទេ ជាភេរវកម្ម។ បើថ្ងៃក្រោយវាយគ្នា វាយឲ្យចំ [ទល់មុខគ្នា] កុំលួចបាញ់។ នេះជាអំពើឃោរឃៅ"។ ចំណែកភាគីថៃវិញក៏បានប្រកាសដែរថា មានទាហានរបស់ខ្លួនចំនួន៨ នាក់ និងជនស៊ីវិលម្នាក់បានស្លាប់ក្នុងការប្រយុទ្ធនេះ។ ជាងនេះទៅទៀត ក្នុងការប្រយុទ្ធគ្នានៅតំបន់ប្រាសាទព្រះវិហារ កងទ័ពថៃបានប្រើគ្រាប់បែកចង្កោម ដែលអង្គការសហប្រជាជាតិបានហាមឃាត់ដាច់ខាតមិនឲ្យប្រើនៅក្នុងពិភពលោកទៀតផង។ សហគមន៍អន្តរជាតិបានថ្កោលទោសថៃពីទង្វើនេះ និងស្រែកឲ្យបញ្ឈប់ការប្រើប្រាស់គ្រាប់បែកប្រភេទនេះជាបន្ទាន់។



www.elibraryofcambodia.org

**៣ ឧសភា ១៩៦៥៖** សម្ដេច នរោត្ដម សីហនុ បានផ្ដាច់ចំណង ការទូតជាមួយសហរដ្ឋអាម៉េរិក បន្ទាប់ពីយន្ដហោះអាម៉េរិកបានទម្លាក់គ្រាប់បែកជាលើកដំបូងលើបណ្ដាភូមិមួយចំនួនរបស់ប្រទេសកម្ពុជានាថ្ងៃទី១ ឧសភា នៅតំបន់ចំពុះសេក ឬចំពុះទា ក្នុងទឹកដីខេត្តស្វាយរៀងជាប់ព្រំដែនវៀតណាមខាងត្បូង[184]។ លោក ហិនរី ឃីស៊ីងហ្គ័ (Henry Kissinger) រដ្ឋមន្ត្រីការបរទេសអាម៉េរិកនៅឆ្នាំ ១៩៧៣ បានអះអាងថា "មិនមែនជាការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាទេ ប៉ុន្ដែនោះជាការទម្លាក់គ្រាប់បែកមកលើវៀតណាមខាងជើងនៅក្នុងប្រទេសកម្ពុជា"[185]។

**មេសា ១៩៦៧៖** លោក លី គ្វាន់យូ (Lee Kuan Yew) នាយករដ្ឋមន្ត្រីប្រទេសសិង្ហបុរីដំបូងគេក្នុងចន្លោះឆ្នាំ១៩៥៩-១៩៩០ បានមកទស្សនកិច្ចនៅប្រទេសកម្ពុជាជាលើកដំបូងនាខែមេសា ឆ្នាំ១៩៦៧ បន្ទាប់ពីមានការអញ្ជើញពីសម្ដេចព្រះ នរោត្ដម សីហនុ ព្រះប្រមុខរដ្ឋខ្មែរ ហើយក្រោយមក លោក លី គ្វាន់យូ ក៏បានមកទស្សនាប្រាសាទអង្គរវត្តចំនួនពីរលើកទៀត។ នៅក្នុងដំណើរទស្សនកិច្ចនៅរាជធានីភ្នំពេញ ព្រះប្រមុខរដ្ឋខ្មែរបាននាំលោក លី គ្វាន់យូ ដើរលំហែរតាមមហាវិថីនានាដោយរថយន្ត មែកសីដែស។ នៅពេលនោះ លោក លី គ្វាន់យូ មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះស្ថាបត្យកម្មនៃអគាររបស់ខ្មែរនៅក្នុងរាជធានីភ្នំពេញ ហើយលោកមានបំណងចង់ឲ្យប្រទេសសិង្ហបុរីបានអភិវឌ្ឍដោយយកលំនាំបែបនេះ។ លោក លី គ្វាន់យូ បានងាកមករកសម្ដេចព្រះប្រមុខរដ្ឋខ្មែរដោយនិយាយថា "ខ្ញុំសង្ឃឹមថា នៅថ្ងៃណាមួយ ទីក្រុងរបស់ខ្ញុំនឹងមើលទៅដូចជាទីក្រុង ភ្នំ

184 *សៀវភៅ MY WAR WITH THE C.I.A ទំព័រ២៦៨*

185 *សៀវភៅ Sideshow ទំព័រ២៨*



www.elibraryofcambodia.org

ពេញ] នេះដែរ"[186]។ នៅឆ្នាំនោះ ស្ថាបត្យកម្មនៅក្នុងរាជធានីភ្នំពេញត្រូវបានបរទេសប្រសិទ្ធិនាមថាជា "គុជនៃទិសបូព៌ា" (Pearl of the East)[187] ហើយឯកសារខ្លះបានរៀបរាប់ថា "នៅចុងទសវត្ស៍១៩៦០ ប្រទេសកម្ពុជាគឺជាតារាដ៏ភ្លឺចិញ្ចាចនៃឥណ្ឌូចិន ដោយមានបញ្ញវន្ត អ្នកជំនួញ សិល្បៈករ និងស្ថាបត្យករដ៏ប៉ិនប្រសព្វ ដែលបានរស់នៅ ប្រកបរបបរកស៊ី និងធ្វើការនៅទីនោះ"[188]។ ដោយសារតែពាក្យលោក លី គ្វាន់យូ នេះហើយ ទើបប្រជាជនខ្មែរមួយចំនួនបានសន្មត់ថា សិង្ហបុរីបានកសាងទីក្រុងរបស់ខ្លួនដោយយកគំរូតាមរាជធានីភ្នំពេញ។ ទាក់ទិននឹងបញ្ហានេះ ខ្ញុំ [អ្នកចងក្រងសៀវភៅ] បានទៅប្រទេសសិង្ហបុរីជាច្រើនលើក ដើម្បីស្វែងរកការបញ្ជាក់ពីបញ្ហានេះ តែមិនមានប្រភពមនុស្សនិងប្រភពឯកសារណាមួយបង្ហាញថា លោក លី គ្វាន់យូ បានធ្វើរបៀបនេះឡើង។ ជាការពិតមានអគារខ្លះនៅតំបន់ទីក្រុងចិន (China town) ក្នុងប្រទេសសិង្ហបុរីមើលទៅស្រដៀងគ្នានឹងអគារនៅភ្នំពេញដែលបារាំងបានសង់ឲ្យដែរ តែថា អគារនៅប្រទេសសិង្ហបុរីគឺយកលំនាំតាមប្រទេសអង់គ្លេសទេ ព្រោះប្រទេសសិង្ហបុរីធ្លាប់នៅក្រោមអាណានិគមប្រទេសអង់



*ខ្ញុំ ឆាយ សុផល (ស្តាំ) និងប្រធានាធិបតីសិង្ហបុរី លោក Sellapan Ramanathan Nathan នៅវិមានប្រធានាធិបតីសិង្ហបុរី ឆ្នាំ២០០១។*

[186] https://goingphnomandon.wordpress.com/tag/lee-kuan-yew/

[187] http://en.wikipedia.org/wiki/New_Khmer_Architecture

[188] http://phoumirak.blogspot.sg/2008/12/lee-kuan-yews-quote-about-cambodia-in.html



www.elibraryofcambodia.org

ត្រួស។ នៅថ្ងៃទី៩ មេសា ឆ្នាំ ២០១៥ លោក Ivan Lim មិត្តខ្ញុំម្នាក់ជាអ្នកសារព័ត៌មានជនជាតិសិង្ហបុរីបានបើករថយន្តជូនខ្ញុំមើលជុំវិញទីក្រុងសិង្ហបុរី ពិសេសនៅតាមតំបន់ដែលមានអគារចាស់ៗក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ជាកន្លែងដែលរដ្ឋាភិបាលសិង្ហបុរីធ្វើការអភិរក្ស ដោយទុកអគារទាំងនោះជាអគារប្រវត្តិសាស្ត្រ។ Ivan Lim ក៏ធ្លាប់បានមកលេងទីក្រុងភ្នំពេញដែរ ហើយទាំងលោកនិងខ្ញុំបានសង្កេតឃើញដូចគ្នាថា នៅតាមវិថីនៅសិង្ហបុរីគឺមានដាំដើមឈើនៅតាមសងខាងផ្លូវ ដែលដូចគ្នានឹងមហាវិថីធំៗនៅរាជធានីភ្នំពេញនាសម័យសង្គមរាស្ត្រនិយមដែរ។



*ពីឆ្វេងទី១៖ ខ្ញុំ ឆាយ សុផល ទី២៖ អ្នកកាសែតបង់ក្លាដែសមិនចាំឈ្មោះ ទី៣៖ លោក Werner Vom Busch ប្រធានតំណាងមូលនិធិ Konrad Adenauer Stiftung នៃប្រទេសអាល្លឺម៉ង់ប្រចាំប្រទេសសិង្ហបុរី និងទី៤៖ លោក Lee Hsien Loong នាយករដ្ឋមន្ត្រីប្រទេសសិង្ហបុរី នៅឯសន្និសីទអន្តរជាតិក្នុងប្រទេសសិង្ហបុរីនាឆ្នាំ២០០៦។ Lee Hsien Loong ជាកូនប្រុសច្បងរបស់លោក លី គាន់យូ។*

**១១ មិថុនា ១៩៦៩៖** សម្តេច នរោត្តម សីហនុ បានផ្សះផ្សាចំណង ការទូតជាមួយសហរដ្ឋអាមេរិកឡើងវិញ បន្ទាប់ពីសហរដ្ឋអាមេរិក



www.elibraryofcambodia.org

បានសន្យាថា នឹងគោរពឯករាជភាពនិងបូរណភាពដែនដីកម្ពុជានៅតាមព្រំដែន ប៉ុន្តែនៅថ្ងៃទី៣០ មេសា ១៩៧០ លោកប្រធានាធិបតីអាម៉េរិក រិចឆាត និកសុន (Richard Nixon) បានប្រកាសតាមទូរទស្សន៍ថា ទ័ពអាម៉េរិកនិងវៀតណាមខាងត្បូងបានចូលក្នុងដីកម្ពុជាហើយ[189]។ ទោះបីជាយ៉ាងនេះក្តី កាសែតអាម៉េរិក ឌឹ ញូយ៉កថាមស៍ (The New York Times) បានរាយការណ៍ថា នៅពេលសង្គ្រាមវៀតណាមបានចាប់ផ្តើមគំរាមកំហែងដល់ប្រទេសកម្ពុជា ដោយវៀតណាមបានប្រើប្រាស់កំពង់ផែព្រះសីហនុ និងតំបន់ភាគខាងកើតប្រទេសកម្ពុជាសម្រាប់ដឹកសម្ភារៈផ្គត់ផ្គង់យោធា ព្រះអង្គបានងាករកការស្តារទំនាក់ទំនងជាមួយអាម៉េរិកឡើងវិញ[190]។ កាសែតបានបន្តថា ដោយសារទំនាក់ទំនងឡើងវិញនេះ ព្រះអង្គបានធ្វើជាមិនដឹងមិនឮពីរឿងដែលរដ្ឋបាលលោកប្រធានាធិបតី និកសុន បានបើកយុទ្ធនាការសម្ងាត់មួយក្នុងការទម្លាក់គ្រាប់បែកមកនៅលើតំបន់នៃព្រំដែនកម្ពុជានាឆ្នាំ ១៩៦៩ ប៉ុន្តែទំនាក់ទំនងនេះនៅមិនបានយូរឡើយ ព្រោះព្រះអង្គត្រូវបានគេទម្លាក់ចេញពីព្រះប្រមុខរដ្ឋនៅមួយឆ្នាំក្រោយមក។

**៣ កញ្ញា ១៩៦៩៖** សម្តេច សីហនុ បានយាងទៅទីក្រុងហាណូយ ដើម្បីចូលរួមបុណ្យសពលោក ង្វៀង អៃកុក ហៅ ហូជីមិញ ដែលបានទទួលមរណភាពនៅថ្ងៃដដែលនោះ ហើយសម្តេច សីហនុ គឺជាប្រមុខរដ្ឋនៃប្រទេសតែមួយគត់ដែលបានចូលរួមបុណ្យសពនេះ[191]។ សម្តេច សីហនុ បានកោតសរសើរលោក ហូជីមិញ យ៉ាងជ្រាលជ្រៅ ដោយព្រះអង្គឡាយថា

[189] *The New York Times: http://www.nytimes.com/2012/10/15/world/asia/norodom-sihanouk-cambodian-leader-through-shifting-allegiances-dies-at-89.html?_r=0*

[190] *សៀវភៅ "ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ ឆ្នាំ" (ទំព័រ១០)*



www.elibraryofcambodia.org

"លោក [ហូជីមិញ] មិនមែនគ្រាន់តែជារបស់វៀតណាមប៉ុណ្ណោះនោះទេ តែលោកជារបស់ឥណ្ឌូចិន ឆ្ពោះទៅអាស៊ី និងពិភពលោក...ចំពោះខ្ញុំដែលជាជនជាតិអាស៊ីម្នាក់ លោកមានលំដាប់ខ្ពស់ជាងគេក្នុងចំណោមឥស្សរជនអាស៊ី"។ គួររម្លឹកថា បន្ទាប់ពីសង្គ្រាមត្រជាក់ដែលកើតមានតាំងពីឆ្នាំ ១៩៤៧ រវាងប្លុកកុម្មុយនិស្តដែលមានសហភាពសូវៀត (រុស្ស៊ី) ជាបងធំ និងពួកប្លុកសេរីដែលមានអាម៉េរិកជាបងធំមក សង្គ្រាមនេះក៏បានជះឥទ្ធិពលមកលើប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍។ សង្គ្រាមត្រជាក់បានកើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ដោយសារទំនាស់នយោបាយភូមិសាស្ត្រ ផលប្រយោជន៍សេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងមនោគមន៍វិជ្ជារវាងមហាអំណាចសហភាពសូវៀតនិងអាម៉េរិក ហើយឥទ្ធិពលនៃសង្គ្រាមត្រជាក់[192] នេះបានធ្វើឲ្យប្រទេស៤នៅតំបន់អាស៊ីអាគ្នេយ៍ក្នុងនោះមានឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងថៃ នាំគ្នាបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ជាផ្លូវការនៅថ្ងៃទី៨ សីហា ១៩៦៧ ដោយការបង្កើតនេះមានការគាំទ្រពីពួកប្លុកសេរី ដើម្បីទប់ទល់នឹងពួកបក្សកុម្មុយនិស្តឥណ្ឌូចិន (វៀតណាម-កម្ពុជា-ឡាវ) ដែលបក្សកុម្មុយនិស្តឥណ្ឌូចិននេះមានការគាំទ្រពីសហភាពសូវៀត និងចិនកុម្មុយនិស្ត។

**មុនថ្ងៃរដ្ឋប្រហារ ១៨ មីនា ១៩៧០៖** នៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧០ បន្ទាប់បានពីសម្រាកក្នុងមន្ទីរពេទ្យមួយនៅរាជធានីភ្នំពេញរួចមក សម្តេច នរោត្តម សីហនុ បានយាងចេញពីប្រទេសកម្ពុជា ដើម្បីទៅពិនិត្យនិងព្យាបាលព្រះរោគនៅឯគ្លីនិក Pathé ក្នុងទីក្រុង Grasse ប្រទេសបារាំង ដែលព្រះអង្គត្រូវយាងទៅជាទៀងទាត់រាល់ពីរឆ្នាំម្តង។ ព្រះអង្គបានឡាយ

[192] *សង្គ្រាមត្រជាក់បានរលត់ទៅវិញនៅថ្ងៃ២៦ ធ្នូ ឆ្នាំ ១៩៩១ នៅពេលសហភាពសូវៀតបានដួលរលំ។*



www.elibraryofcambodia.org

ថា ព្រះអង្គបានយាងចេញជាមួយអគ្គមហេសី មុនិនាថ ជាមួយនិងវ៉ាលីតូច មួយ អមដំណើរដោយសម្តេច ប៉ែន នុត ហើយថា "ខ្ញុំត្រូវការសម្រាកទាំងស្រុង និងត្រូវការព្យាបាលជំងឺពុំរ៉ែមួយចំនួន ហើយខ្ញុំបានគិតថា វានឹងជាមេរៀន ដែលជាបទពិសោធន៍មិនល្អសម្រាប់ សិរិមតៈ និងអ្នកគាំទ្ររបស់ទ្រង់" ដើម្បីមានអ្វីៗទាំងអស់នៅក្នុងដៃ ហើយទុកឲ្យពួកគេដឹងថា តើពួកគេអាចដោះស្រាយភាពទ្រុឌទ្រោមសេដ្ឋកិច្ចរបស់ប្រទេសដោយវិធីណា នៅពេលដែលពួកគេបានបោះបង់គោលនយោបាយរបស់សីហនុនោះ[193]។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ត្រូវជាបងជីទួតមួយរបស់សម្តេច សីហនុ។ សម្តេច សីហនុ បានឡាយថា "ខ្ញុំបានដឹងថា សិរិមតៈ បានទាក់ទងយ៉ាងជិតស្និទ្ធជាមួយស្ថានទូតអាម៉េរិកនៅក្នុងខែ មិថុនា ឆ្នាំ១៩៦៩ ហើយខ្ញុំបានធ្វើការប្រមើលមើលនៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំជាមួយទូរទស្សន៍បារាំងថា អនាគតនឹងអន្ធការបំផុត ប្រសិនបើខ្ញុំត្រូវបានគេផ្តួលនោះ"។ ព្រះអង្គបានបន្តថា ក្រោយពីព្យាបាលរួចមក ព្រះអង្គបានបន្តយាងទៅទីក្រុងប៉ារីស ទីក្រុងមូស្គូ និងទីក្រុងប៉េកាំង ក្នុងដំណើរទស្សនកិច្ចនយោបាយ ដើម្បីស្វែងរកជំនួយយោធា សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនឹងវិលត្រឡប់មកកាន់កម្ពុជា ដោយពង្រឹងនិងរៀបចំសេដ្ឋកិច្ចជាតិឡើងវិញ តាមមធ្យោបាយខ្លួនឯង និងការជួយពីមិត្តពិតប្រាកដ។ ព្រះអង្គបានបញ្ជាក់ថា ដំណើរទស្សនកិច្ចនេះបានធ្វើឡើងស្របពេលដែលពួកវៀតណាមទាំងខាងត្បូងនិងខាងជើង បានចូលមកក្នុងទឹកដីកម្ពុជាដោយខុសច្បាប់ ខណៈដែល លន់ នល់ កំពុងតែកាន់ទុក្ខកិរិយារបស់ខ្លួន ដែលទើបតែទទួលមរណភាព។

នៅក្នុងទីក្រុងប៉ារីស សម្តេច សីហនុ បានសម្ភាសជាមួយទូរទស្សន៍បារាំងនាថ្ងៃទី ១០ មីនា ឆ្នាំ ១៩៧០ ដោយមានបន្ទូលថា ពួកស្តាំនិយមនៅ

---

[193] *សៀវភៅ "ហ៊ិន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ឆ្នាំ" (ទំព័រ៥-៦)*



www.elibraryofcambodia.org

ក្នុងរាជធានីភ្នំពេញបានទាក់ទងជាមួយស៊ីអាយអេ (C.I.A)[194] "បានចក់ឱកាសនៃការអវត្តមានដ៏យូររបស់ខ្ញុំ ដើម្បីព្យាយាម និងផ្លាស់ប្តូរទិសដៅនយោបាយកម្ពុជា។ ពួកគេចង់ឲ្យពួកយើងចូលក្នុងជំរំអាមេរិក" ហើយព្រះអង្គបានព្រមានជាថ្មីអំពីគ្រោះថ្នាក់នៃរដ្ឋប្រហារ ហើយថា "អ្វីៗទាំងអស់គឺអាស្រ័យលើកងទ័ព"។ នៅប្រទេសបារាំងនាព្រឹកថ្ងៃសុក្រទី ១៣ មីនា ឆ្នាំ១៩៧០ ខណៈដែលសម្តេច នរោត្តម សីហនុ កំពុងជិះរថយន្តឆ្ពោះទៅកាន់អាកាសយានដ្ឋានទីក្រុងប៉ារីស ដើម្បីយាងទៅទីក្រុងម៉ូស្គូ សហភាពសូវៀតនោះ ស្រាប់តែទីប្រឹក្សាម្នាក់របស់ព្រះអង្គបាននិយាយបែបលេងថា "សម្តេច! ព្រះអង្គមិនត្រូវយាងទៅទេ។ នេះជាថ្ងៃសុក្រទី១៣" ។ សម្តេចសីហនុ មានបន្ទូលថា ព្រះអង្គមិនមានជំនឿ [ថ្ងៃសុក្រ ទី ១៣] [195] នោះទេ រួចក៏បានសើច ហើយ ៥ ថ្ងៃក្រោយមក ព្រះអង្គត្រូវបានគេទម្លាក់ចេញពីព្រះតំណែង។

**១៨ មីនា ១៩៧០៖** សម្តេច សីហនុ ត្រូវបានទម្លាក់ចេញពីព្រះប្រមុខរដ្ឋដោយក្រុម លន់ នល់ និង សិរិមតៈ ខណៈដែលព្រះអង្គកំពុងយាងដំណើរ "ទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត [រុស្ស៊ី][196]"។ រូបត្តុករបស់សម្តេចត្រូវបានគេគូរដោយដាក់សញ្ញាខ្វែងនៅលើព្រះភ័ក្ត្រដាក់បង្ហាញ

---

*[194] Central Intelligence Agency*

*[194] សៀវភៅ MY WAR WITH THE C.I.A ទំព័រ២១*

*ថ្ងៃសុក្រទី ១៣ ក្រុមគ្រីស្តសាសនិកជាច្រើនមានជំនឿថា ជាថ្ងៃមិនសូវមានលាភសំណាង*

*[194] គេហទំព័រ http://norodomsihanouk.info/family/id_01.html*

*[195] សៀវភៅ MY WAR WITH THE C.I.A ទំព័រ២១*

*ថ្ងៃសុក្រទី ១៣ ក្រុមគ្រីស្តសាសនិកជាច្រើនមានជំនឿថា ជាថ្ងៃមិនសូវមានលាភសំណាង*

*[196] គេហទំព័រ http://norodomsihanouk.info/family/id_01.html*



www.elibraryofcambodia.org

ពាសពេញទីក្រុងភ្នំពេញ ពិសេសការបាចពីលើយន្តហោះ។ សម្តេច សីហនុ បានបន្ទោសលោក រិចឆាត និកសុន ប្រធានាធិបតីអាម៉េរិកថា "នោះគឺជានិកសុន ដែលបានផ្តល់ការប្រឈមឲ្យប្រជាជនយើងទាំងបី [កម្ពុជា-វៀតណាម-ឡាវ]។ នោះគឺជាគាត់ដែលបានសម្រេចចិត្តសាកល្បងកម្លាំង ហើយទុកឲ្យពួកយើងគ្មានជម្រើស ប៉ុន្តែ [យើង] ត្រូវតែទទួលយកការប្រឈមនោះ។ យើងបានសម្រេចចិត្តប្រើកម្លាំងរួមគ្នាប្រឆាំងនឹងគាត់ ឬក៏នរណាក៏ដោយ ដែលមកជំនួសគាត់ធ្វើជាប្រធានាធិបតីសហរដ្ឋអាម៉េរិក ប្រសិនបើគាត់នោះប្រកាន់យកគោលនយោបាយដូចគ្នានេះ លុះត្រាទទួលបានជោគជ័យជាស្ថាពរ"។

**២៣ មីនា ១៩៧០៖** នៅក្នុងទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ បានបង្កើតចលនាមួយជាផ្លូវការប្រឆាំងនឹងរបប លន់ នល់ ដែលចលនានោះមានឈ្មោះថា "រណសិរ្សរួបរួមជាតិ" (FUNC ឬ FUNK[197]) ដោយមានការចូលរួមរវាងពួកសីហនុនិយមនិងពួកខ្មែរក្រហម។ ក្រោយមកដោយមានសត្រូវរួមគ្នាគឺពួក លន់ នល់ សិរិមតៈ និងចក្រពត្តិអាម៉េរិក សម្តេច នរោត្តម សីហនុ និងមេខ្មែរក្រហម ខៀវ សំផន ប៉ុល ពត ក៏បានបង្កើត "រដ្ឋាភិបាលរួបរួមជាតិ" (GRUNK[198]) ដើម្បីវាយរំដោះប្រទេសចេញពី "កងកម្លាំងប្រដាប់អាវុធជាតិខ្មែរ" (FANK[199]) នៃរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់។

---

*[151] FUNC = Front Uni National du Cambodge) ហើយ FUNK = Front Uni National du Kampuchea*

*[198] GRUNK (Gouvernement Royal d'Union Nationale du Kampuchea ឬ Royal Government of National Union of Kampuchea) បង្កើតថ្ងៃទី ៥ ឧសភា ១៩៧០*

*[199] FANK (Forces Armées Nationales Khmères ឬ Khmer National Armed Forces)*



www.elibraryofcambodia.org

**កុម្ភៈ - មីនា ១៩៧៣៖** សម្តេច សីហនុ បានយាងឆ្លងកាត់ទីក្រុងហាណូយប្រទេសវៀតណាម ចូលមកតំបន់រំដោះក្នុងទឹកដីកម្ពុជា ដែលដំណើរនេះ ព្រះអង្គបានចាត់ទុកថា ជាដំណើរប្រវត្តិសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីបង្ហាញពីជំហរព្រះអង្គចំពោះអំពើរបស់ចក្រពត្តិអាម៉េរិក និង "ពួកកញ្ជះ" ទាំងនៅក្នុងប្រទេស និងនៅបរទេស។ ព្រះអង្គបានបញ្ជាក់ថា វាជាឱកាសមួយដ៏ល្អសម្រាប់ព្រះអង្គដែលចំណាយមួយខែក្នុងខែ មីនា ជាមួយប្រជារាស្ត្ររបស់ព្រះអង្គ និងរស់នៅជាមួយវរជន និងវរនារីនៃកម្លាំងចលនាតស៊ូរំដោះជាតិ ពិសេសនៅក្នុងខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តសៀមរាប[200]។ ក្នុងរយៈពេល៨ថ្ងៃក្នុងទឹកដីវៀតណាម អ្នកហែហមវៀតណាមចំនួន ១៥០ នាក់ ដោយរួមទាំងគ្រូពេទ្យផ្នែកវះកាត់ចល័តផងបានអមដំណើរសម្តេច សីហនុ និងអគ្គមហេសី ដោយជិះរថយន្តម៉ាកហ្ស៊ីប (Jeeps) របស់សូវៀត តាមផ្លូវលំហូជីមិញហើយមួយយប់ៗ ព្រះអង្គគង់នៅក្នុងផ្ទះឈើដ៏ស្អាតបំផុត និងសោយអាហារបារាំងជារៀងរាល់ថ្ងៃ[201]។

**ចុងខែ ធ្នូ ១៩៧៥៖** សម្តេច នរោត្តម សីហនុ បានយាងមកពីប៉េកាំងប្រទេសចិនមកធ្វើជាប្រមុខរដ្ឋខ្មែរក្រហម បន្ទាប់ពីទ័ពរបស់ខ្មែរក្រហមបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ និង សិរិមតៈ នាថ្ងៃទី ១៧ មេសា ១៩៧៥។

[200] *សៀវភៅ "Shadow Over Angkor" ( ទំព័រទី ១៧៨)*

[201] *The Tragedy of Cambodia History ( ទំព័រ២២៨)*



www.elibraryofcambodia.org



*សម្តេច នរោត្តម សីហនុ យាងទស្សនកិច្ចទីក្រុងហាណូយ វៀតណាម នាថ្ងៃទី២៥ ឧសភា ឆ្នាំ ១៩៧០ (មួយខែបន្ទាប់ពីត្រូវបានគេទម្លាក់ចេញពីព្រះប្រមុខរដ្ឋ) ដោយទទួលបានបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅពីលោកប្រធានាធិបតីវៀតណាម Pham Van Dong (រូបរបស់ Bettmann/CORBIS)។*

**៥ មករា ១៩៧៦៖** ព្រះអង្គបានប្រកាសឲ្យប្រើប្រាស់រដ្ឋធម្មនុញ្ញថ្មី ហើយក្រោយមក ខ្មែរក្រហមក៏បង្កើតរដ្ឋាភិបាលថ្មីមួយ ដែលមាន ប៉ុល ពត ជានាយករដ្ឋមន្ត្រី។



*សម្តេច នរោត្តម សីហនុ (ស្តាំ) អានសេចក្តីប្រកាសស្តីពីការលាលែងចេញពីប្រមុខរដ្ឋនាថ្ងៃទី១១ មីនា ១៩៧៦។ ឈន ហៃ មន្ត្រីខ្មែរក្រហមទទួលបន្ទុកការងារថតជាអ្នកថតសំឡេងព្រះអង្គ។*

**១១ មីនា ៧៦៖** សម្តេច នរោត្តម សីហនុ បានសុំលាលែងពីប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីព្រះអង្គបានស្ថិតនៅក្នុងមុខតំណែងតាំងពីព្រះអង្គបានយាងចូលមកក្នុងប្រទេសវិញនាខែធ្នូ ឆ្នាំ



www.elibraryofcambodia.org

១៩៧៥។ នៅពាក់កណ្តាលឆ្នាំ ១៩៧៦៖ ព្រះអង្គបានសុំ ប៉ុល ពត យាងទៅកាន់ប្រទេសចិន ដើម្បីចូលរួមបុណ្យសពលោក ជូ អិនឡាយ នាយករដ្ឋមន្ត្រីចិន ដែលបានស្លាប់ដោយរោគាពាធ ប៉ុន្តែ ប៉ុល ពត មិនឲ្យព្រះអង្គយាងទៅឡើយ ព្រោះ ប៉ុល ពត និងមន្ត្រីរបស់ខ្លួនខ្លាចព្រះអង្គមិនយាងត្រឡប់មកវិញ ដែលប្រការនេះបានធ្វើឲ្យព្រះអង្គមិនសព្វហឫទ័យ ហើយខ្ទាល់នឹង ប៉ុល ពត ទើបព្រះអង្គបានសម្រេចព្រះទ័យលាចេញពីប្រមុខរដ្ឋខ្មែរក្រហម[203]។ ចាប់តាំងពីថ្ងៃនោះមក ព្រះអង្គ និងព្រះមហេសី មុនិនាថ ព្រមទាំងសមាជិករាជវង្សភាគច្រើនត្រូវបានឃុំព្រះកាយក្នុងដំណាក់។

**រសៀលថ្ងៃទី ៦ មករា ១៩៧៩៖** សម្តេច សីហនុ បានយាងចេញពីភ្នំពេញជាមួយមហេសី មុនិនាថ សីហនុ និងមន្ត្រីស្ថានទូតចិន និងស្ថានទូតផ្សេងៗតាមយន្តហោះចិន Boeing 707 ដែលបានចុះចតនៅអាកាសយានដ្ឋានពោធិចិនតុង (អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ)[204]។

**៧ មករា ១៩៧៩៖** កងទ័ពវៀតណាមបានចូលកាន់កាប់ទីក្រុងភ្នំពេញ ដោយបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមប៉ុល ពត។ សម្តេច សីហនុ និងពួកមេខ្មែរក្រហម ប៉ុល ពត នួន ជា អៀងសារី ខៀវ សំផន និងពួកសម្ព័ន្ធមិត្ត ព្រមទាំងជនជាតិខ្មែរមួយចំនួនទៀតដែលរស់នៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ និងនៅបរទេសខ្លះទៀត ដោយរួមទាំងប្រទេសមហាអំណាចមួយចំនួនផងបានចាត់ទុកថា ៧ មករា ១៩៧៩ ជាថ្ងៃឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជា ហើយបានដាក់ប្រទេស

---

*[203] សៀវភៅ៖ ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ (ទំព័រ៣០)*

*[204] Brother Enemy ទំព័រ៣១៦*

*[205] សៀវភៅ៖ ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ (ទំព័រ៥៩)*



www.elibraryofcambodia.org

កម្ពុជាឲ្យស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ខ្លួន[206]។ ទោះបីជាយ៉ាងនេះក្តី ក៏ ហេង សំរិន ជា ស៊ីម និង ហ៊ុន សែន ព្រមទាំងប្រជាជនខ្មែររាប់លាននាក់ដែលបានរួចពីការកាប់សម្លាប់របស់ពួកប៉ុលពតបានចាត់ទុកថា គឺជាថ្ងៃរំដោះជីវិតរបស់ខ្លួនឲ្យចេញពីសេចក្តីស្លាប់ ឬជាថ្ងៃកំណើតទីពីររបស់ខ្លួន។

**ពាក់កណ្តាលខែមករា ១៩៧៩៖** សម្តេច នរោត្តម សីហនុ បានស្នើសុំសហរដ្ឋអាមេរិកឲ្យផ្តល់សិទ្ធិជ្រកកោននយោបាយដល់ព្រះអង្គ ប៉ុន្តែអាមេរិកមិនបានផ្តល់ឲ្យឡើយ ខណៈដែលប្រទេសបារាំងក៏បានផ្តល់លក្ខខ័ណ្ឌដែលមិនអាចទទួលយកបានសម្រាប់ព្រះអង្គ ហើយបន្ទាប់ពីការជួបប្រទះភាពមិនសព្វព្រះទ័យទាំងនេះ លោក តេង ហ្សាវពីង (Deng Xiaoping) បុរសខ្លាំងរបស់ប្រទេសចិនបានអញ្ជើញព្រះអង្គជាផ្លូវការឲ្យយាងទៅគង់នៅប្រទេសចិន ហើយព្រះអង្គក៏សព្វព្រះទ័យ ដោយសម្តែងការអរគុណដល់ការអញ្ជើញរបស់លោក តេង ហ្សាវពីង ក្នុងនាមប្រជាជន និងរដ្ឋាភិបាលប្រទេសចិន[207]។

**៥ មីនា ១៩៧៩៖** បើទោះជាមេខ្មែរក្រហមជាសត្រូវរបស់ទ្រង់ក៏ដោយ ក៏សម្តេច សីហនុ បានចរចាជាមួយ ខៀវ សំផន ប្រមុខរដ្ឋខ្មែរក្រហម ដោយទ្រង់បានស្នើឲ្យមានការរួបរួមគ្នា ដើម្បីប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម[208]។ នៅឆ្នាំនោះ អង្គការសហប្រជាជាតិក៏បានព្យួរអាសនៈកម្ពុជាដែរ ដោយសារតែកម្ពុជាមានភាគីជម្លោះនយោបាយនិងប្រដាប់អាវុធ

---

[206] *សៀវភៅ៖ ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ ( ទំព័រ៥៩ )*

[207] *សៀវភៅ Shadow of over Angkor ទំព័រ ១៩៧*

[208] *សៀវភៅ៖ ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តសាស្ត្រខ្មែរជាង៤០ ( ទំព័រ៧៩ )*



www.elibraryofcambodia.org

ច្រើនពេក គឺមិនដឹងថា តើភាគីណាតំណាងឲ្យប្រជាជនកម្ពុជាពិតប្រាកដ។ នៅមុននេះ អាសនៈជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមប៉ុលពត។

**ឧសភា ១៩៨១៖** បន្ទាប់ពីមានសំណើនិងការទទូចពីក្រុមចលនាតស៊ូតូចៗនានា ពិសេសពីលោក អ៊ិន តាំ ដែលជាអតីតនាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ និងជាគូសត្រូវរបស់សម្តេច សីហនុ នោះ ស្រាប់តែសម្តេចបានយល់ព្រមបង្កើតចលនាតស៊ូថ្មីមួយទៀតដែលគាំទ្រព្រះអង្គ។ ចលនានោះមានឈ្មោះថា អេអិនអេស (ANS ឬ Armee Nationale Sihanoukienne ឬ National Sihanoukist Army ឬ កងទ័ពជាតិសីហនុ)[209]។ លោក អ៊ិន តាំ ក៏បានទទួលតំណែងជាអគ្គមេបញ្ជាការកងទ័ពរបស់ចលនាអេអិនអេស នេះ ដែលត្រូវបានគេស្គាល់ថា ជាចលនាពួកសីហនុនិយម (Sihanouk-ists)។ "បើតាមសម្តេច សីហនុ បានឲ្យដឹងថា អេអិនអេស បច្ចុប្បន្ននេះ [ឆ្នាំ១៩៨១] មានមនុស្សចំនួន ៥.០០០នាក់ បំពាក់ដោយអាវុធ ជាមួយនិងមនុស្ស ៥.០០០នាក់ផ្សេងទៀតកំពុងហ្វឹកហ្វឺន ហើយរង់ចាំការបំពាក់អាវុធ" ហើយកងទ័ពនេះត្រូវបានបង្វឹកដោយប្រទេសពីរនៅក្នុងសមាគមអាស៊ាន រីឯឯកសណ្ឋានថ្មីៗត្រូវបានទិញជាមួយនឹងលុយកាក់ដែលប្រទេសចិនបានថ្វាយជូនសម្តេច សីហនុ[210]។

---

[209] *កាសែត Bangkok Post (៥ មិថុនា ១៩៨៣) ដោយ Jacques Bekaert*

[210] *Front Uni National pour un Cambodge Indépendant, Neutre, Pacifique, et Coopératif or National United Front for an Independent, Neutral, Peaceful and Cooperative Cambodia*



www.elibraryofcambodia.org

**កុម្ភៈ ១៩៨១៖** បន្ទាប់មក ដោយមានការលើកទឹកចិត្តពីបណ្ដាប្រទេសនៅក្នុងសមាគមអាស៊ាន សម្ដេច សីហនុ ក៏បានបង្កើតចលនាថ្មីមួយទៀតដែលមានឈ្មោះថា ចលនាហ្វ៊ុនស៊ីនប៉ិច (FUNCINPEC)[211]។ ការបង្កើតចលនានេះបានធ្វើឡើងជាផ្លូវការនៅថ្ងៃទី២១ មីនា ឆ្នាំដដែលនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង ដោយមានសមាជិកដែលនិរទេសព្រះកាយនិងខ្លួនចំនួនប្រមាណជា១០០នាក់។

**មិថុនា ១៩៨២៖** សម្ដេច សីហនុ ធ្វើជាប្រធានរដ្ឋាភិបាលចម្រុះត្រីភាគី ដោយរដ្ឋាភិបាលនោះបានយកឈ្មោះរបស់របបខ្មែរក្រហមមកដាក់គឺ "រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ"។ ការបង្កើតរដ្ឋាភិបាលចម្រុះនេះបានធ្វើឡើងជាផ្លូវការនាទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២២ មីនា ឆ្នាំនោះ ដោយរដ្ឋាភិបាលនេះមានបីក្រុមរួមគ្នាគឺទីមួយ កម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត អៀង សារី ខៀវ សំផន និង នួន ជា ទីពីរ ក្រុម ខេភីអិនអិលអេហ្វ [KPNLF][212] ដឹកនាំដោយលោក សឺន សាន និងទីបីក្រុមហ្វ៊ុនស៊ីនប៉ិច ដែលដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ក្រោមការគ្រប់គ្រងដោយផ្ទាល់ពីបិតារបស់ទ្រង់គឺសម្ដេច សីហនុ។ បន្ទាប់ពីបានបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីនេះរួចភ្លាម អង្គការសហប្រជាជាតិក៏បានទទួលស្គាល់រដ្ឋាភិបាលនេះ ហើយក៏ប្រគល់អាសនៈរបស់ប្រទេសកម្ពុជាប្រចាំអង្គការសហប្រជាជាតិទៅឲ្យរដ្ឋាភិបាលចម្រុះនេះតែម្ដង។ ប៉ុន្តែទោះបីជាយ៉ាងនេះក្ដី ក៏អ្នកតំណាងរដ្ឋាភិបាលចម្រុះនេះនៅឯ

---

[212] *KPNLF = Khmer People's National Liberation Front (រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ)*



www.elibraryofcambodia.org

អង្គការសហប្រជាជាតិនោះ គឺជាមន្ត្រីរបស់ខ្មែរក្រហមដដែល។

នៅដើមឆ្នាំ ១៩៨២ បន្ទាប់ពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីរួចមក កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា រួមជាមួយកងទ័ពវៀតណាមបានវាយចូលក្នុងជំរំរបស់ក្រុមចលនាតស៊ូ ខេភីអិនអិលអេហ្វរបស់លោក សឺន សាន នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ។ ការវាយប្រហារនោះក៏បានបណ្ដាលឲ្យទាំងកងទ័ព និងជនស៊ីវិលជាច្រើនបានស្លាប់ និងរងរបួសផងដែរ។

**១៤ មិថុនា ១៩៨៣៖** សម្ដេច សីហនុ បានចោទប្រកាន់កម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមដែលជាដៃគូតស៊ូនោះថា កំពុងតែនាំរដ្ឋាភិបាលចម្រុះត្រីភាគីឲ្យឈានទៅរកភាពរលត់រលាយ។ ក្រោយពីជួបលោក ក្លូត ជេស្សុន (Claude Cheysson) រដ្ឋមន្ត្រីការបរទេសបារាំងក្នុងទីក្រុងប៉ារីសនាថ្ងៃនោះ សម្ដេច សីហនុ បានមានបន្ទូលថា ព្រះអង្គកំពុងរង់ចាំចម្លើយពីភាគីកម្ពុជាប្រជាធិបតេយ្យ ពីសំណើរបស់ព្រះអង្គដើម្បីសុំលាឈប់ពីប្រធានរដ្ឋាភិបាលចម្រុះត្រីភាគី។ ការសុំលាឈប់របស់ព្រះអង្គនេះ គឺដោយសារតែភាគីកម្ពុជាប្រជាធិបតេយ្យបានជំទាស់នឹងសំណើរបស់ព្រះអង្គ ពីផែនការបង្រួបបង្រួមជាតិ តាមរយៈការរៀបចំការបោះឆ្នោតជាទូទៅមួយ ដោយមានភាគីទំនាស់ខ្មែរទាំងអស់ចូលរួម[213]។ ប៉ុន្តែភាគីកម្ពុជាប្រជាធិបតេយ្យមិនយល់ព្រម ព្រោះពួកគេគិតថា ភាគីសាធារណរដ្ឋប្រជាមានិតកម្ពុជារបស់ ហេង សំរិន ជា ស៊ីម និង ហ៊ុន សែន....ជាជនក្បត់ជាតិ[214]។ ទាំងសម្ដេច

---

[213] *សៀវភៅ៖ ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ (ទំព័រ៨៥)*

[214] *AFP ផ្សាយនៅកាសែត Bangkok Post ថ្ងៃទី ១៨ មិថុនា ឆ្នាំ ១៩៨៣*



www.elibraryofcambodia.org

សីហនុ និងមេដឹកនាំភាគីកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមពិតជាត្រូវការគ្នា នៅក្នុងកាលៈទេសៈដ៏លំបាកនេះ មានន័យថា សម្តេច សីហនុ ត្រូវការកម្លាំងទ័ពដែលមានចំនួនច្រើនរបស់ខ្មែរក្រហម ដើម្បីប្រយុទ្ធជាមួយសត្រូវរួម ខណៈដែលខ្មែរក្រហមក៏ត្រូវការសម្តេច សីហនុ ដើម្បីផលប្រយោជន៍នយោបាយការទូតទាំងក្នុងប្រទេស ក្នុងតំបន់ និងនៅលើឆាកអន្តរជាតិដែរ ពោលគឺ សន្លឹកបៀមានប្រយោជន៍ទាំងសងខាង។ នៅក្នុងដំណាក់កាលនោះ បើទោះជាស្ថិតនៅក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយគ្នា និងមានបំណងវាយផ្តួលរំលំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដូចគ្នាក៏ដោយ ក៏ពួកគេតែងតែវាយប្រហារគ្នាឯងដែរ ពិសេសការវាយប្រហារពីពួកកងទ័ពកម្ពុជាប្រជាធិបតេយ្យនៃខ្មែរក្រហម ដែលមានចំនួនច្រើនជាង។ ការវាយប្រហារមកលើគ្នាឯងនេះ គឺក្នុងគោលបំណងដណ្តើមតំបន់កាន់កាប់ឲ្យបានច្រើន និងយកឥទ្ធិពលលើដៃគូ ព្រមទាំងទាក់ទាញចំណាប់អារម្មណ៍និងជំនួយពីសហគមន៍អន្តរជាតិ។

**៧ ឧសភា ១៩៨៧៖** ដោយនយោបាយកម្ពុជាបានវិវឌ្ឍជាមួយនិងការជួយពីសហគមន៍អន្តរជាតិដើម្បីស្វែងរកសន្តិភាព សម្តេច សីហនុ នៅថ្ងៃនោះបានប្រកាសលាលែងពីព្រះប្រធានរដ្ឋាភិបាលត្រីភាគី និងឈប់ទាក់ទិននឹងចលនាហ៊្វុនស៊ីនប៉ិច ឬក៏ក្រុមនយោបាយណាមួយ ដើម្បីព្រះអង្គបានគង់នៅអព្យាក្រឹតជាតំណាងឲ្យប្រទេសកម្ពុជា ឬជាប្រមុខរដ្ឋបណ្តោះអាសន្នមុនការបោះឆ្នោតជាសកលមកដល់។

**២ ធ្នូ ១៩៨៧៖** សម្តេច នរោត្តម សីហនុ បានជួបចរចាជាលើកដំបូងនៅក្នុងទីក្រុង ហ្វែរអង់តាដឺណ័រ (Fair Anta denor) ប្រទេសបារាំងជាមួយ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា



www.elibraryofcambodia.org

តែការចរចានេះមិនទទួលបានលទ្ធផលល្អទេ ហើយសង្គ្រាមពាក្យសំដីរវាងសម្តេច សីហនុ និងលោក ហ៊ុន សែន មានជាហូរហែ។ ទោះជាយ៉ាងនេះក្តី ក៏ជំនួបចរចារវាងឥស្សរជនទាំងពីរនៅតែធ្វើជាបន្តបន្ទាប់ដែរនៅឯក្រៅប្រទេស។



*សម្តេច សីហនុ (ឆ្វេង) និង ហ៊ុន សែន (ស្តាំ) ជាមួយអតីតរដ្ឋមន្ត្រីការបរទេសបារាំង Roland Dumas ក្នុងពេលចរចាសន្តិភាពនៅបារាំង។ រូបបណ្ណសារនៅគេហទំព័រវិទ្យុ RFI*

**១៧ កក្កដា ១៩៩១៖** សម្តេច នរោត្តម សីហនុ បានយាងចាកចេញពីគណៈប្រធាននៃរបបកម្ពុជាប្រជាធិបតេយ្យ និងប្រធានចលនាតស៊ូកម្ពុជា (Résistance Nationale du Cambodge)។ បន្ទាប់មក ព្រះអង្គត្រូវបានជាប់ឆ្នោតជាឯកច្ឆ័ន្ទដោយទទួលតំណែងជាព្រះប្រធានអព្យាក្រឹតនៃឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា មានសមាជិកជាគូជម្លោះមកពីបួនភាគី គឺ៖

- រដ្ឋកម្ពុជាដឹកនាំដោយលោក ហ៊ុន សែន
- ហ៊្វុនស៊ីនប៉ិច ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ
- រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដឹកនាំដោយលោក សឺន សាន
- កម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ដឹកនាំដោយ ខៀវ សំផន

**២៣ តុលា ឆ្នាំ ១៩៩១៖** ក្រោយពីមានការជំរុញពីសហគមន៍អន្តរជាតិ ដោយរួមទាំងឆន្ទៈរបស់ភាគីជម្លោះកម្ពុជាផង ភាគីទាំងអស់ក៏បានឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំងនាថ្ងៃនោះ។ ក្នុងកិច្ចព្រមព្រៀងនោះរួមមាន១៨ប្រទេសជាហត្ថលេខី។ អង្គការសហប្រជាជាតិក៏បានបង្កើតអាជ្ញាធរមួយ



www.elibraryofcambodia.org

ឈ្មោះថា "អ៊ុនតាក់"[216] ហើយបានបញ្ជូនមន្ត្រីការងារទាំងយោធានិងស៊ីវិល ប្រមាណ២០.០០០ នាក់មកពីចម្រុះជាតិសាសន៍នៃប្រទេសទាំង ១៨ជាហត្ថលេខីនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនោះ ដោយបានចំណាយទឹកប្រាក់អស់ចំនួនជាង២,៨ពាន់លានដុល្លារ សម្រាប់កិច្ចការបោះឆ្នោត។ មុនអាជ្ញាធរអ៊ុនតាក់ចូលមកក្នុងទឹកដីកម្ពុជា គឺមានក្រុមបេសកកម្មមួយផ្សេងទៀតបានមកដល់មុន ដែលក្រុមនោះមានឈ្មោះថា "យូណាមិក"[217]។ ក្រុមយូណាមិកនេះបានមកកម្ពុជាដើម្បីស្វែងរកការពិតមួយចំនួនសម្រាប់រក្សាសន្តិសុខ សុវត្ថិភាពបុគ្គលិករបស់អាជ្ញាធរអ៊ុនតាក់ ក៏ដូចជាសមាជិក អេសអិនស៊ី[218]។ សម្តេច សីហនុ ជាព្រះប្រធានអេសអិនស៊ី ដែលមានសមាជិកជាភាគីជម្លោះទាំងបួនខាងលើ។

**១៤ វិច្ឆិកា ១៩៩១៖** សម្តេច សីហនុ បានយាងមកកាន់ទីក្រុងភ្នំពេញ បន្ទាប់ពីព្រះអង្គបានយាងចេញកាលពីមួយថ្ងៃមុនកងទ័ពវៀតណាមចូលកាន់កាប់ទីក្រុងភ្នំពេញនាថ្ងៃទី៧ មករា ១៩៧៩។ នៅថ្ងៃយាងត្រឡប់មកនោះ ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលរដ្ឋកម្ពុជាបានរៀបចំបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅទទួលសម្តេច សីហនុ និងម្ចាស់ក្សត្រិយ៍ មុនិនាថ។ នៅតាមដងផ្លូវចាប់ពីអាកាសយានដ្ឋានរហូតមកព្រះបរមរាជវាំង សិស្ស និស្សិត និងប្រជាពលរដ្ឋក្មេងចាស់ ប្រុសស្រី បានឈរតម្រៀបគ្នាជាជួរទាំងសងខាងផ្លូវ។ ហ៊ុន សែន និងសម្តេច សីហនុ បានជិះលើរថយន្តតែមួយឈរទន្ទឹមគ្នា

---

*216 UNTAC ( United Nations Transitional Authority in Cambodia ) ឬ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា*

*217 UNAMIC ( United Nations Advanced Mission in Cambodia ) ឬអាជ្ញាធរបេសកកម្មឈានមុខរបស់អង្គការសហប្រជាជាតិ*

*218 SNC ( Supreme National Council ) ឬ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឬឧត្តមក្រុមប្រឹក្សាជាតិ*



www.elibraryofcambodia.org

លើកដៃស្វាគមន៍ដោយរីករាយ និងត្រេកត្រអាលដល់ប្រជាពលរដ្ឋដែលកំពុងឈរស្រែកហ៊ោរនៅតាមដងផ្លូវ។ ប្រជាពលរដ្ឋគិតថា កម្ពុជាគឺពិតជាទទួលបានសន្តិភាពពេញលេញ ដោយនគរខ្មែរមានស្ដេចសោយរាជ្យឡើងវិញហើយ ដែលជាសញ្ញាបញ្ជាក់ថា មានសន្តិសុខ និងការរីកចម្រើនរុងរឿង។ នៅមុនការយាងត្រឡប់ លោក ហ៊ុន សែន បានស្នើឲ្យក្រសួងហិរញ្ញវត្ថុនៃរដ្ឋកម្ពុជាបានបញ្ចេញខ្ទង់ចំណាយរាប់ម៉ឺនដុល្លារ ដើម្បីជួសជុលព្រះរាជដំណាក់នៅក្នុងព្រះបរមរាជវាំងឲ្យបានល្អស័ក្តិសមទៅនឹងតួនាទីរបស់ព្រះអង្គក្នុងនាមជាព្រះប្រធានអព្យាក្រឹតរបស់គូជម្លោះ។



www.elibraryofcambodia.org



សម្តេច នរោត្តម សីហនុ (ឆ្វេង) និង ហ៊ុន សែន នាថ្ងៃយាងត្រឡប់មកប្រទេសវិញនាថ្ងៃទី១៤ វិច្ឆិកា ១៩៩១។ រូបក្រោម៖ ទិដ្ឋភាពនាថ្ងៃយាងត្រឡប់មកវិញរបស់សម្តេច នរោត្តម សីហនុ នៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ពីឆ្វេងលើវេទិកា៖ ហ៊ុន សែន ហេង សំរិន សម្តេច សីហនុ និង ជា ស៊ីម។ (រូបថតទាំងពីរសន្លឹកនេះ ខ្ញុំ (ឆាយ សុផល) បានថតចេញពីរូបដែលព្យួរនៅលើជញ្ជាំងក្នុងសាលពិព័រណ៍នៃព្រះបរមរាជវាំងនារសៀលថ្ងៃទី៥ វិច្ឆិកា ២០១៤)





www.elibraryofcambodia.org

**២៤ កញ្ញា ១៩៩៣៖** ដោយមានការឯកភាពគ្នា បន្ទាប់ពីការបោះឆ្នោតជ្រើសរើសរដ្ឋសភា នីតិកាលទីមួយនាថ្ងៃទី២៣ ឧសភា កន្លងមក សភាក៏បានកោះប្រជុំជាលើកដំបូងក្រោមអធិបតីភាពនៃសម្តេច សីហនុ ហើយប្រទេសក៏ត្រូវបានដាក់ឈ្មោះថា "ព្រះរាជាណាចក្រកម្ពុជា"។ កិច្ចប្រជុំនោះបានសម្រេចថ្វាយព្រះរាជតំណែងជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ និងជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាជូន សម្តេច នរោត្តម សីហនុ ដែលជាការឡើងគ្រងរាជបល្ល័ង្កជាលើកទីពីរ ដែលកាលពីលើកទីមួយគឺនៅថ្ងៃទី២៥ មេសា ១៩៤១ - ៣ មីនា ឆ្នាំ ១៩៥៥។ រដ្ឋធម្មនុញ្ញថ្មីនេះមិនមានមាត្រាចែងពីទោសប្រហារជីវិតដូចកាលពីសម័យសង្គមរាស្ត្រនិយមមុនឆ្នាំ១៩៧០ ទៀតទេ ព្រោះខ្លាចខ្មែរយកមាត្រានេះចងអាឃាតនឹងគ្នា បន្ទាប់ពីសង្គ្រាមមក។



*សម្តេចឪ នរោត្តម សីហនុ ឡើងគ្រងរាជសម្បត្តិជាថ្មីនៅឆ្នាំ១៩៩៣។ រូប VOA*

**៥ មេសា ១៩៩៦៖** នៅក្រុងកំពង់ចាម អង្គរក្សម្នាក់ក្នុងចំណោមអង្គរក្សជាជនជាតិកូរ៉េខាងជើងរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ បានរត់បុក សម្តេច ហ៊ុន សែន ដែលកំពុងដើរនៅក្បែរនោះដែរ ដោយកាំភ្លើងរបស់អង្គរក្សនោះដែលគេទុកសម្រាប់ការពារព្រះមហាក្សត្របានទៅប៉ះកែងដៃឆ្វេងសម្តេច ហ៊ុន សែន មួយទំហឹង។ ឧបទ្ទវហេតុនេះបានធ្វើឲ្យទាំងព្រះមហាក្សត្រ និងប្រធានក្រុមអង្គរក្សជនជាតិកូរ៉េខាងជើងសូមទោសសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។



www.elibraryofcambodia.org

**១៤ កញ្ញា ១៩៩៦៖** ព្រះមហាក្សត្រ សីហនុ បានឡាយព្រះហស្ថលេខាលើកលែងទោសឲ្យ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសរបស់ខ្មែរក្រហម។ ការប្រទានការលើកលែងទោសនេះបានធ្វើឡើងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ដែលជាថ្នូរនឹងការផ្តាច់ខ្លួនរបស់ អៀង សារី ចេញពីពួកប៉ុលពត នួន ជា សុន សេន ខៀវ សំផន និង តា ម៉ុក ហើយចូលរួមជាមួយរាជរដ្ឋាភិបាលចម្រុះស្របច្បាប់។ អៀងសារីនៅពេលនោះជាបងធំប្រចាំនៅតំបន់ប៉ៃលិន និងម៉ាឡៃដែលមានកងទ័ពនិងជនស៊ីវិលរាប់ពាន់នាក់។ បន្ទាប់ពីការលើកលែងទោសមក ខ្ញុំក៏បានធ្វើដំណើរទៅយកព័ត៌មាននៅទីតំបន់ទាំងពីនោះ។



*រូបឆ្វេង៖ ខ្ញុំ ឆាយ សុផល (ឆ្វេង) ថតរូបជាមួយកងទ័ពខ្មែរក្រហមនៅខែ កញ្ញា ឆ្នាំ១៩៩៦ នៅម៉ាឡៃ ដែលជាតំបន់ខ្មែរក្រហមក្រោមបញ្ជារបស់ អៀង សារី ជាប់នឹងព្រំដែនថៃ (រូប Darren Whiteside)។ រូបស្តាំ៖ អៀង សារី ធ្វើសន្និសីទកាសែតនៅម៉ាឡៃនៅខែ កញ្ញា ១៩៩៦ (រូប ឆាយ សុផល)។*



www.elibraryofcambodia.org






រូបលើឆ្វេង៖ ខ្ញុំ ឆាយ សុផល នាពាក់កណ្ដាលឆ្នាំ ១៩៩៨ និងរថក្រោះ ដែលធេះខូចខាតនៅលើផ្លូវចន្លោះប៉ៃលិន និងម៉ាឡៃ (រូប Robbert Birshel)។ រូបលើស្ដាំ៖ ខ្ញុំ ឆាយ សុផល នាថ្ងៃ១៧ មេសា ២០១៣ មកដល់ជិតទីតាំងដែលរថក្រោះឆេះ (រូប ស្រីនិក)។ ទីតាំងដែលរថក្រោះឆេះនោះមើលមិនស្គាល់ទេ នាឆ្នាំ២០១៣ ព្រោះថា មានការអភិវឌ្ឍ ដោយផ្លូវត្រូវបានចាក់បេតុង និងមានផ្ទះអ្នកភូមិនៅជាប់ជាជើក ដែលខុសពីឆ្នាំ១៩៩៨ មានភាពស្ងាត់ជ្រងំ ហើយផ្លូវជាផ្លូវលំ។



រូបឆ្វេង៖ ខ្ញុំ ឆាយ សុផល និងកាំភ្លើងធ្លោង របស់ខ្មែរក្រហមដែលខូចខាតនៅតាំងប៉ៃលិន នាឆ្នាំ១៩៩៨ (រូប Robbert Birshel)។

រូបស្ដាំ៖ ខ្ញុំ ឆាយ សុផល និងកាំភ្លើងធំប្រភេទកាំជ្រួចហ្វុងផលិតនៅស៊ុយបស់រាជរដ្ឋាភិបាលកម្ពុជានាពាក់កណ្ដាលឆ្នាំ១៩៩៦ នៅលើភ្នំសំពៅ ខេត្តបាត់ដំបង (រូប Leo Dobbs)។



www.elibraryofcambodia.org

**ចុងឆ្នាំ ១៩៩៦ - ដើមឆ្នាំ១៩៩៧៖** ព្រះមហាក្សត្រ សីហនុ មិនសូវសព្វព្រះរាជហឫទ័យនឹងលោកនាយករដ្ឋមន្ត្រីទី២ ហ៊ុន សែន ហើយខ្វាល់នឹងមន្ត្រីមួយចំនួនរបស់សម្ដេច ហ៊ុន សែន ដែលព្រះអង្គចោទថា ពួកគេបានប្រមាថព្រះអង្គនិងរាជានិយម។ នៅដើមឆ្នាំ ១៩៩៧ ដោយសំអាងលើការព្យាបាលព្រះរោគ ព្រះអង្គបានយាងទៅទីក្រុងប៉េកាំង។ ព្រះអង្គធ្លាប់មានរាជបន្ទូលថា នៅក្នុងព្រះបរមរាជវាំង សម្បូរដោយចារបុរសនិងចារនារី។ នាពេលនោះ លោក គង់ សំអុល ដែលជាសមាជិកជាន់ខ្ពស់នៃគណបក្សប្រជាជនកម្ពុជារបស់លោកនាយករដ្ឋមន្ត្រីទី២ ហ៊ុន សែន គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រះបរមរាជវាំង (រដ្ឋមន្ត្រីវាំង ឬ ចៅហ្វាវាំង)។ នៅដើមឆ្នាំ ១៩៩៧ ជម្លោះទាំងនយោបាយនិងយោធារវាងព្រះបុត្រារបស់ព្រះអង្គ គឺសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ មានសភាពកាន់តែតានតឹង។ នៅឆ្នាំនោះ ហ៊ុន សែន បានស្នើឲ្យព្រះអង្គយាងចូលមកប្រទេសវិញ ដើម្បីជួយបន្ធូរបន្ថយភាពតានតឹងនោះ ប៉ុន្តែព្រះអង្គមិនយាងមកឡើយ។ ដោយសារការមិនយាងមករបស់ព្រះមហាក្សត្រ សីហនុ នេះហើយ បានធ្វើឲ្យសម្ដេច ហ៊ុន សែន ព្រមានថាតើប្រទេសគួរប្រកាន់យករបបរាជានិយម ឬក៏សាធារណរដ្ឋ។ ទីបំផុត រាជរដ្ឋាភិបាលចម្រុះរបស់សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ត្រូវបានបែកបាក់ទាំងស្រុង ហើយបានប្រយុទ្ធបង្ហូរឈាមគ្នានៅថ្ងៃទី ៥-៦ កក្កដា ឆ្នាំ ១៩៩៧ នៅកណ្ដាលរាជធានីភ្នំពេញ ខណៈដែលព្រះមហាក្សត្រ សីហនុ គង់នៅប៉េកាំង។ កម្លាំងប្រដាប់អាវុធទាំងយោធានិងនគរបាលដែលស្មោះត្រង់នឹងសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ បានរត់បោលសមរភូមិ ហើយភៀសខ្លួនទៅព្រំដែនខ្មែរ-ថៃក្នុងតំបន់អូរស្មាច់ខេត្តឧត្ដរមាន



www.elibraryofcambodia.org

ជ័យ។ បន្ទាប់មក ប្រទេសក៏ចាប់ផ្តើមមានសង្គ្រាមផ្ទៃក្នុងម្តងទៀត ហើយព្រះមហាក្សត្រ នរោត្តម សីហនុ មិនមានបន្ទូលអ្វីទាល់តែសោះទាក់ទិននឹងការបង្ហូរឈាមគ្នានេះ ខណៈដែលព្រះរាជបុត្រារបស់ព្រះអង្គគឺសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ កំពុង និរទេសព្រះកាយនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង[219]។

**៣១ សីហា ១៩៩៧៖** នៅចុងខែសីហាឆ្នាំនេះ ព្រះមហាក្សត្រ នរោត្តម សីហនុ បានយាងមកគង់នៅរាជដំណាក់ក្នុងក្រុងសៀមរាប បន្ទាប់ពីមានការវាយប្រហារបង្ហូរឈាមគ្នាកាលពីថ្ងៃទី៥-៦កក្កដាមុននេះ។ ការយាងមកនេះក្នុងបំណងសម្រួលស្ថានការណ៍ នយោបាយដែលកំពុងតានតឹងទាំងក្នុងប្រទេសនិងនៅលើឆាកអន្តរជាតិ ព្រមទាំងបន្ធូរបន្ថយការប្រយុទ្ធគ្នាខាងយោធានៅតាមព្រំដែនកម្ពុជា-ថៃ ពិសេសនៅតំបន់អូរស្មាច់ រវាងកម្លាំងប្រដាប់អាវុធដែលគាំទ្រសម្តេចក្រុមព្រះ រណឫទ្ធិ និងសម្តេច ហ៊ុន សែន។ សូមរម្លឹកថា នៅរសៀលថ្ងៃទី១៤ សីហា មុននេះ ហ៊ុន សែន បានវិលត្រឡប់មកពីប៉េកាំងវិញជាមួយ អ៊ឹង ហួត ដោយប្រកាសថា ព្រះមហាក្សត្រ សីហនុ



*ខ្ញុំ (អ្នកចងក្រងសៀវភៅ) (ស្តាំ) ទទួលរាជអំណោយជាមុងនិងភួយពីព្រះមហាក្សត្រ សីហនុ នៅមុខព្រះរាជដំណាក់ក្នុងក្រុងសៀមរាប ក្រោយពីសន្និសីទសារព័ត៌មាននាព្រឹកថ្ងៃទី៣១សីហា១៩៩៧។ រូប Daren Whiteside*

---

[219] *សូមអានពីបញ្ហាជម្លោះនេះនៅក្នុងសៀវភៅ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣១រូបជានរណា?"*



www.elibraryofcambodia.org

បានឯកភាពចំពោះរដ្ឋាភិបាលចម្រុះថ្មីហើយដែលមាន អ៊ឹង ហួត ជានាយករដ្ឋមន្ត្រីទី១ ជំនួសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ហើយសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ដដែល។

នៅក្រុងសៀមរាបនាថ្ងៃទី៣១ សីហា ព្រះអង្គបានធ្វើបុណ្យព្រះពុទ្ធសាសនានៅទីសក្ការៈព្រះអង្គចេកព្រះអង្គចមដោយដោះលែងអណ្តើកនិងសត្វចាបជាច្រើន ហើយបួងសួងឲ្យប្រទេសនិងប្រជារាស្ត្ររបស់ព្រះអង្គទទួលបានសុខសន្តិភាពជាថ្មី។ នៅព្រឹកថ្ងៃទី៣១ សីហា ព្រះមហាក្សត្របានធ្វើសន្និសីទសារព័ត៌មានមួយស្តីពីដំណោះស្រាយនយោបាយ ដោយព្រះអង្គបានស្នើសុំឲ្យភាគីទាំងសងខាងបង្រួបបង្រួមគ្នា ដោយយកជាតិនិងប្រជាជនជាធំ។ នៅពេលរាត្រីមុនធ្វើសន្និសីទសារព័ត៌មាន ម្ចាស់ក្សត្រិយ៍ដាយអាណា (Diana) របស់ចក្រភពអង់គ្លេសបានសោយទិវង្គតដោយសារតែគ្រោះថ្នាក់ចរាចរណ៍នៅទីក្រុងប៉ារីស ប្រទេសបារាំង ហើយនៅក្នុងសន្និសីទសារព័ត៌មាននាពេលព្រឹក ព្រះមហាក្សត្រខ្មែរក៏បានសម្តែងមរណទុក្ខជូនដល់រាជវង្សនៃចក្រភពអង់គ្លេសដែរនាថ្ងៃនោះ។



*ទិដ្ឋភាពបរិវេណខាងក្នុងព្រះរាជដំណាក់នៅក្រុងសៀមរាប (រូប៖ ឆាយ សុផល)*



www.elibraryofcambodia.org













ទិដ្ឋភាពខាងក្រៅនិងខាងក្នុងព្រះរាជដំណាក់
នៅក្រុងសៀមរាប (រូបៈ ឆាយ សុផល)



www.elibraryofcambodia.org

**៣ កញ្ញា ១៩៩៧៖** ខណៈដែលព្រះមហាក្សត្រ នរោត្តម សីហនុ កំពុងគង់នៅរាជដំណាក់ក្នុងក្រុងសៀមរាប ស្រាប់តែនៅរសៀលថ្ងៃនោះ យន្តហោះរបស់ក្រុមហ៊ុនវៀតណាមមួយគ្រឿងម៉ាក Tupelov 134 ផលិតនៅប្រទេសរុស្ស៊ី ដែលហោះចេញពីទីក្រុងហូជីមិញប្រទេសវៀតណាមបានធ្លាក់នៅប្រមាណ៣០០ម៉ែត្រពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បណ្តាលឲ្យមនុស្សនៅលើយន្តហោះទាំងអស់៦៥នាក់បានស្លាប់ លើកលែងតែក្មេងពីរនាក់ ម្នាក់អាយុមួយខួបនិងម្នាក់ទៀតអាយុបួនឆ្នាំបានរស់រានមានជីវិត។ ការធ្លាក់នោះគឺដោយសារតែនៅរសៀលថ្ងៃនោះ អាកាសធាតុនៅភ្នំពេញពិសេសនៅអាកាសយានដ្ឋានអន្តរជាតិមានភ្លៀងធ្លាក់ខ្លាំង ដែលធ្វើឲ្យអាកាសយានិកមិនអាចមើលផ្លូវឃើញ ហើយយន្តហោះក៏ប៉ះនឹងដើមអំពិលបារាំងរួចក៏បុកធ្លាក់ដីនៅក្បែរអាកាសយានដ្ឋានតែម្តង។ អ្នកដំណើរភាគច្រើនគឺជាជនជាតិកូរ៉េ បន្ទាប់មកវៀតណាម និងកម្ពុជា។

**កញ្ញា ១៩៩៨៖** ព្រះមហាក្សត្រ នរោត្តម សីហនុ បានយាងមករាជធានីវិញ។ នៅឆ្នាំនោះជាថ្មីម្តងទៀត ដោយមានការជួយជ្រោមជ្រែងពីសហគមន៍អន្តរជាតិ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាតិអាណត្តិទី២ ហើយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានយាងចូលមកប្រទេសវិញដើម្បីចូលរួមបោះឆ្នោតនាថ្ងៃទី ២៦ កក្កដា ឆ្នាំ ១៩៩៨ បន្ទាប់ពីទទួលបានការលើកលែងទោសពីព្រះបិតាព្រះមហាក្សត្រ នរោត្តម សីហនុ។

**១ សីហា ២០០០៖** ដំណើរយាងរបស់ព្រះមហាក្សត្រ សីហនុ ទៅទីក្រុងប៉េកាំងប្រទេសចិន ដើម្បីពិនិត្យនិងព្យាបាលព្រះរោគត្រូវបានអាក់ខានដោយយន្តហោះរបស់អាកាសចរ Royal Air Cambodge ដែលដឹកសម្តេចឪសម្តេចម៉ែនោះបានហូរប្រេងចេញពីស្លាបខាងឆ្វេងបាចសាចពេញ



www.elibraryofcambodia.org

ផ្ទៃពីស [បរិវេណ]។ ដោយគ្មានជម្រើស សម្ដេច ហ៊ុន សែន បានស្នើឲ្យសម្ដេចឪសម្ដេចម៉ែយាងត្រឡប់ទៅព្រះបរមរាជវាំងវិញ ដោយពន្យារពេលការយាងទៅប៉េកាំង។ នៅព្រឹកនោះ សម្ដេច ហ៊ុន សែន ប្រាប់ទៅលោកប្រធានគ្រប់គ្រងអាកាសចរ Royal Air Cambodge ដោយម៉ឺងម៉ាត់ថាលោកត្រូវតែជ្រើសរើសយកការលាលែងឬក៏ត្រូវបណ្ដេញចេញពីតំណែងជាប្រធានគ្រប់គ្រងអាកាសចរ Royal Air Cambodge នេះ។ សម្ដេច ហ៊ុន សែន មានការខឹងសម្បាយ៉ាងខ្លាំងចំពោះការធ្វេសប្រហែសផ្នែកបច្ចេកទេសរបស់អ្នកគ្រប់គ្រងអាកាសចរ Royal Air Cambodge ព្រោះការធ្វេសប្រហែសនេះអាចមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ថ្នាក់ដឹកនាំប្រទេស។



*សម្ដេច ហ៊ុន សែន (ស្ដាំ) មានប្រតិកម្មខ្លាំងៗពីរឿងយន្តហោះដឹកព្រះមហាក្សត្រលេចប្រេងតាមស្លាបសាចពេញពីស មុនពេលហោះ (រូបផ្សាយនៅកាសែត Phnom Penh Post)*

**៧ តុលា ២០០៤៖** បន្ទាប់ពីបានប្រាប់ឲ្យដឹងជាច្រើនលើកស្ដីពីការចង់ដាក់រាជ្យចាប់តាំងពីឆ្នាំ១៩៩៥មក ហើយដោយសំអាងថា ព្រះ



www.elibraryofcambodia.org

អង្គកាន់តែជរាពាធនិងមានបញ្ហាព្រះសុខភាពផងនោះ ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះជន្ម៨១ព្រះវស្សាក៏បានសម្រេចព្រះទ័យដាក់រាជ្យនៅថ្ងៃនោះតែម្តង។ ក្រុមប្រឹក្សារាជសម្បត្តិបន្ទាប់មកក៏ជ្រើសរើសព្រះអង្គម្ចាស់ នរោត្តម សីហមុនី ព្រះជន្ម៥១ព្រះវស្សា ឲ្យឡើងគ្រងរាជ្យជំនួសព្រះបិតាជាផ្លូវការនៅថ្ងៃសុក្រ ទី២៩ តុលា ឆ្នាំដដែល។ ក្រោយពីដាក់រាជ្យ រដ្ឋសភាជាតិបានថ្វាយព្រះបរមងារដល់ព្រះអង្គថាជា "ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ" ដែលមានព្រះសិទ្ធិដូចគ្នានឹងអភ័យឯកសិទ្ធិរបស់ព្រះមហាក្សត្រថ្មីដែរ។ ចាប់តាំងពីពេលនោះមក ព្រះអង្គភាគច្រើនគង់នៅក្នុងព្រះបរមរាជវាំងនិងចែកអំណោយមនុស្សធម៌ជូនដល់កូនចៅ ចៅទួតដែលជាជនរួមជាតិរបស់ព្រះអង្គ ដោយពិធីមនុស្សធម៌ទាំងនោះធ្វើឡើងនៅក្នុងព្រះបរមរាជវាំង។

**១៥ តុលា ២០១២៖** សម្តេចព្រះ នរោត្តម សីហនុ បានសោយព្រះទិវង្គតនៅប្រមាណ១៦ថ្ងៃមុនពីជីចម្រើនព្រះជន្ម៩០ព្រះវស្សា។ មុននេះ ព្រះអង្គបានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រទំនើបនៅក្នុងទីក្រុងប៉េកាំងចាប់តាំងពីខែមករា ឆ្នាំ ២០១២ នូវព្រះរោគមួយចំនួន ដោយរួមទាំងមហារីកតម្រងនោម ទឹកនោមផ្អែម និងជំងឺលើសឈាម។ រាជរដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា ថ្ងៃទី១៥ តុលា នឹងក្លាយជាថ្ងៃសម្រាកជាផ្លូវការរបស់ជាតិ ដែលជាថ្ងៃកាន់ព្រះរាជមរណទុក្ខដល់សម្តេចឪ។ ព្រះមហាក្សត្រ នរោត្តម សីហមុនី និងសម្តេច ហ៊ុន សែនបានយាងនិងទៅប៉េកាំង ដើម្បីយាងព្រះបរមសពរបស់ព្រះអង្គមកប្រទេស។ នៅថ្ងៃនោះ ខ្ញុំ [អ្នកចងក្រងសៀវភៅ] កំពុង



www.elibraryofcambodia.org

នៅប្រទេស គុយវ៉ែត នៅតំបន់មជ្ឈិមបូព៌ាក្នុងបេសកកម្មយកព័ត៌មានពីសន្និសីទអន្តរជាតិ ដោយមានការអញ្ជើញពីរដ្ឋាភិបាលគុយវ៉ែតតាមរយៈក្រសួងការបរទេសនិងក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ នៅទីនោះ ខ្ញុំនិងអ្នកសារព័ត៌មានកម្ពុជាបួនរូបទៀតបានទៅស្ថានទូតខ្មែរដើម្បីគោរពព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គផង និងយកព័ត៌មានស្តីពីមន្ត្រីបរទេសនានាមកចូលរួមគោរពព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គផង។

ព្រះបរមសពក៏ត្រូវបានយាងមកកាន់ប្រទេសកម្ពុជាវិញពីទីក្រុងប៉េកាំងនាថ្ងៃទី១៧ តុលា ២០១២ តាមជើងយន្តហោះនៃអាកាសចរអ៊ែរ ឆាយណា (Air China) ដោយមានមនុស្សរាប់ម៉ឺននាក់បានឈរសម្រក់ទឹកភ្នែកនៅតាមដងផ្លូវពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមកព្រះបរមរាជវាំង។



*សម្តេចឪ នរោត្តម សីហនុ (កណ្តាល) មានបន្ទូលនាបុណ្យខួបព្រះជន្មរបស់ព្រះអង្គនៅមុខវាំងនាថ្ងៃទី១១ តុលា ឆ្នាំ២០១១។ នេះជាបន្ទូលចុងក្រោយនៅចំពោះមុខសាធារណៈមុនព្រះអង្គសោយព្រះទិវង្គតនាថ្ងៃទី១៥ សីហា ឆ្នាំ២០១២។ (ខាងស្តាំ) សម្តេចម៉ែ មុនិនាថ និងខាងស្តាំ ព្រះមហាក្សត្រ នរោត្តម សីហមុនី (រូប Siv Channa/The Cambodia Daily)។ នៅក្នុងព្រះរាជបន្ទូលនោះ ព្រះអង្គបានសន្យាថានឹងមិនយាងចាកចេញពីប្រទេសទេ តែគង់នៅជាមួយកូនចៅចៅទួតជាទីស្រឡាញ់ជារៀងរហូត។ ទោះបីជាយ៉ាងនេះក្តី ព្រះអង្គត្រូវយាងទៅប៉េកាំងព្យាបាលព្រះរោគ រហូតដល់ព្រះអង្គបានសោយព្រះទិវង្គតនៅទីនោះ។*

www.elibraryofcambodia.org




*ព្រះបរមសពសម្តេចឪនៅក្នុងមន្ទីរពេទ្យមួយនាទីក្រុងប៉េកាំងនាថ្ងៃទី១៧ តុលា ២០១២។ ខាងឆ្វេងក្បែរព្រះបរមសព គឺព្រះមហាក្សត្រ សីហមុនី និងសម្តេចម៉ែ។ រូប Associated Press*



*ខ្ញុំ (ឆាយ សុផល អ្នកចងក្រងសៀវភៅ) ចូលលំឱនកាយគោរពព្រះវិញ្ញាណក្ខន្ធព្រះបាទសម្តេចព្រះនរោត្តម សីហនុ នៅមុខព្រះឆាយាល័ក្ខណ៍របស់ព្រះអង្គក្នុងស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំផ្ទៃស្ទុយយ៉ក នាថ្ងៃទី១៦ តុលា ឆ្នាំ២០១២ គឺមួយថ្ងៃក្រោយពីព្រះអង្គបានសោយទិវង្គតនាទីក្រុងប៉េកាំង (រូប សុខ សាពយ)*



www.elibraryofcambodia.org



រូបឆ្វេង៖ សម្តេចម៉ែ មុនីនាថ សីហនុ ទតព្រះភក្ត្រព្រះបរមសពអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ជាព្រះរាជអគ្គស្វាមីជាចុងក្រោយមុនបិទគម្របព្រះបរមមឈូស (រូបទូរទស្សន៍ជាតិកម្ពុជា)។

រូបក្រោម៖ ព្រះមហាក្សត្រព្រះបរមនាថ នរោត្តម សីហមុនី ទតព្រះភក្ត្រព្រះបរមសពព្រះរាជបិតា អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ជាចុងក្រោយក្រោយមុនបិទគម្របព្រះបរមមឈូស (រូបទូរទស្សន៍ជាតិកម្ពុជា)។

មុនសោយព្រះទិវង្គត ទ្រង់ធ្លាប់មានរាជបណ្តាំថា ព្រះសពទ្រង់ត្រូវដាក់ក្នុងបរមមឈូសផ្តេក គឺមិនមែនព្រះកោដ្ឋបញ្ឈរដូចដាក់ព្រះសពស្តេចអង្គមុនៗនោះទេ។





www.elibraryofcambodia.org

**២៨ វិច្ឆិកា ២០១២៖** ព្រះបរមសពរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះរាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ត្រូវបានព្រះមហាក្សត្រ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានថ្វាយ ព្រះបរមបច្ឆាមរណនាមជាផ្លូវការថា "ព្រះបរមរតនកោដ្ឋ"។

**១ កុម្ភៈ ២០១៣៖** នៅម៉ោង ៨:៣០ ព្រឹក ព្រះរាជពិធីដង្ហែព្រះបរមសពនៃព្រះករុណា ព្រះបរមរតនកោដ្ឋបាន ចាប់ផ្តើមដោយអមជាមួយនឹងការថ្វាយស័ង្ខ របស់ក្រុមបារគូ និងការបាញ់កាំភ្លើងធំ១០១ ណាត់។ ព្រះរាជពិធី



ព្រះរាជពិធីដង្ហែព្រះបរមសព

វិកិលព្រះបរមសពចុះពីព្រះទីនាំងបុស្បុកឃាងទៅតម្កល់លើព្រះទីនាំងក្នុងព្រះមេរុ បានប្រព្រឹត្តទៅនៅក្រោយម៉ោង១១ព្រឹក។ នៅពេលវិកិលព្រះបរមសព ដាក់លើព្រះទីនាំងក្នុងព្រះមេរុក៏មានការបាញ់កាំភ្លើងធំម្តងទៀត។

**៤ កុម្ភៈ ២០១៣៖** ព្រះរាជពិធីថ្វាយព្រះភ្លើងបានប្រារព្ធធ្វើនៅម៉ោង៦ល្ងាច ដោយមានការចូលរួមពីប្រជាពលរដ្ឋជាងមួយលាននាក់នៅតាមដងផ្លូវ។ ព្រះរាជពិធីបុណ្យព្រះសពនេះមានការចូលរួមពីសំណាក់មេដឹកនាំបរទេសជាច្រើន ដោយរួមទាំងលោក Jean-Marc Ayrault នាយករដ្ឋមន្ត្រីបារាំង ព្រះអង្គម្ចាស់ Akishino នៃប្រទេសជប៉ុន លោក Jia Qinglin ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន លោក Nguyen Tan



www.elibraryofcambodia.org

Dung នាយករដ្ឋមន្ត្រីវៀតណាម លោកស្រី Yingluck Shinawatra នាយករដ្ឋមន្ត្រីថៃ និងលោក William E. Todd ឯកអគ្គរដ្ឋទូតអាម៉េរិកប្រចាំកម្ពុជា។ ព្រះមហាក្សត្រ នរោត្តម សីហមុនី និងសម្តេចម៉ែ មុនិនាថ នៅពេលនោះទ្រង់សព្វព្រះរាជហឫទ័យព្រះរាជទានដោះលែងអ្នកទោសជាង ៤០០នាក់។



ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព

ព្រះរាជពិធីថ្វាយព្រះភ្លើងនៅម៉ោង៦ល្ងាច ៤ កុម្ភៈ ២០១៣។

**៥ កុម្ភៈ ២០១៣៖** នាពេលព្រឹក ផ្នែកខ្លះនៃព្រះអដ្ឋិ [ធាតុ] របស់ព្រះបរមរតនកោដ្ឋត្រូវបានយកទៅបំប្លែង [បាច] ក្នុងជងទន្លេចតុមុខនៅទល់មុខព្រះបរមរាជវាំង ក្រោមព្រះរាជអធិបតីព្រះករុណាព្រះមហាក្សត្រ ព្រះបរមនាថ នរោត្តម សីហមុនី និងសម្តេចម៉ែ។ ព្រះរាជពិធីនេះធ្វើតាមជំនឿសាសនា និងរាជប្បវេណីខ្មែរ ដើម្បីភាពត្រជាក់ត្រជុំ និងភាពសុខសាន្តក្នុងព្រះនគរ និងដល់ប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់វណ្ណៈ។



ព្រះរាជពិធីយកព្រះអដ្ឋិរបស់ព្រះបរមរតនកោដ្ឋត្រូវបានយាងយកទៅបំប្លែងក្នុងទន្លេចតុមុខនៅទល់មុខវាំង។



www.elibraryofcambodia.org

**១១ តុលា ២០១៣៖** ក្រោយពីបានសាងសង់អស់រយៈពេលប្រមាណ៨ខែ ដោយក្រុមសិលានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានសិល្បករ វិចិត្រករស្មូនរូប និងអ្នកជំនាញខាងស្ថាបត្យកម្មសរុប១១៧នាក់ និងចំណាយថវិកាសរុប ១.៨២០.២២៩ ដុល្លារអាមេរិកមក ព្រះបរមបដិមាព្រះបរមរតនកោដ្ឋត្រូវបានសម្ពោធជាផ្លូវការនៅក្បែរវិមានឯករាជ្យដោយព្រះមហាក្សត្រ នរោត្តម សីហមុនី សម្តេចម៉ែ មុនីនាថ សីហនុ និងសម្តេច ហ៊ុន សែន ព្រមទាំងមេដឹកនាំជាន់ខ្ពស់របស់ប្រទេស និងមន្ត្រីការទូតបរទេសផង។ ព្រះបរមបដិមានេះគឺធ្វើឡើងដើម្បីទុកឲ្យកូនខ្មែរជំនាន់ក្រោយនឹករឭកដល់ព្រះគុណសម្តេចឪនិងវីរភាពដ៏អង់អាចក្លាហានរបស់ព្រះអង្គក្នុងព្រះរាជបូជនិយកិច្ចបម្រើជាតិមាតុភូមិរបស់ព្រះអង្គ។ ព្រះនាមសម្តេច សីហនុ កាលពីមុនមកក៏ត្រូវបានគេយកមកដាក់ឈ្មោះផ្លូវនៅក្នុងរាជធានីភ្នំពេញ គឺ "មហាវិថីព្រះសីហនុ" ហើយប្រជាជនទូទៅហៅ "ផ្លូវសីហនុ" ជាផ្លូវលេខ២៧៤ ចាប់ផ្តើមចេញពីចំណុចភ្លើងស្តុបអាងទឹកពហុកីឡដ្ឋានអូឡាំពិករហូតដល់ហួសវិមានឯករាជ្យមកដល់មហាវិថីសុធារស។



*ព្រះបរមបដិមាព្រះបរមរតនកោដ្ឋត្រូវបានសម្ពោធនាថ្ងៃទី ១១ តុលា ២០១៣។ អាវសសម្តេចម៉ែ មុនិនាថ និងខាងឆ្វេងដៃព្រះអង្គគឺព្រះមហាក្សត្រ សីហមុនី។*

**១០ - ១២ កក្កដា ២០១៤៖** ព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិយាងទៅតម្កល់នៅឯព្រះចេតិយស្ថិតក្នុងបរិវេណព្រះវិហារព្រះកែវមរកតទៅតាមព្រះរាជប្បវេណីជាតិ និងពិធីសាសនាដែលមានរយៈពេលបីថ្ងៃ។ ថ្ងៃទី១០



www.elibraryofcambodia.org

កក្កដា គឺរៀបចំព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធ ពិធីបង្សុកូល និងរាប់បាត្រនៅមុខព្រះបរមរាជវាំង ដោយមានព្រះសង្ឃចំនួន១.៦០០អង្គ និងមានការចូលរួមពីសំណាក់មន្ត្រីរាជរដ្ឋាភិបាលនិងព្រះបរមរាជវាំង។ នៅក្នុងកិច្ចប្រជុំជាមួយស្ថានីយវិទ្យុនិងទូរស្សន៍កាលពីថ្ងៃទី៧ កក្កដា មុននេះ ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានលើកឡើងថា ព្រះរាជពិធីនេះបញ្ជាក់ពីអត្តសញ្ញាណនិងវប្បធម៌របស់ប្រទេសជាតិ ហើយការរៀបចំព្រះរាជពិធីនាពេលនោះគឺដើម្បីចងក្រងជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយបានយល់ដឹង។

នៅព្រឹកថ្ងៃទី១១ កក្កដា នៅវត្តអារាមនានាទូទាំងប្រទេសមានការទូងស្គរ មុននឹងព្រះរាជពិធីដង្ហែព្រះបរមរតនកោដ្ឋ ព្រះបរមអដ្ឋិ ចេញពីខ្លោងទ្វារមុខព្រះបរមរាជវាំងទៅទិសខាងជើង ហើយបត់ឆ្វេងតាមផ្លូវជាប់រាជវាំងឆ្ពោះទៅមហាវិថីព្រះនរោត្តម ហើយបត់ឆ្វេងសំដៅទៅវិមានឯករាជ្យ។ បន្ទាប់មក ក្បួនដង្ហែក៏បានបត់ឆ្វេងតាមមហាវិថីព្រះសីហនុ និងបត់ឆ្វេងតាមមហាវិថីសម្តេចសុធារសឆ្ពោះមកកាន់ព្រះបរមរាជវាំងវិញ។ នៅពេញមួយថ្ងៃទី ១១ កក្កដា នោះ មានកម្មវិធីសាសនា កម្មវិធីគោរពព្រះវិញ្ញាណក្ខន្ធ កម្មវិធីបាញ់កាំជ្រួច ព្រមទាំងបាញ់កាំភ្លើងធំចំនួន១០១ណាត់នៅពេលកំពុងដង្ហែនិងតម្កល់ព្រះបរមអដ្ឋិ។ ថ្ងៃទី១២ កក្កដា វេលាម៉ោង ៦ ព្រឹក គឺជាព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិក្នុងព្រះចេតិយ កម្មវិធីសាសនា និងតាមការសព្វព្រះរាជហឫទ័យរបស់ព្រះករុណាសម្តេច នរោត្តម សីហមុនី និងសម្តេចព្រះមហាក្សត្រិយ៍ព្រះវររាជមាតាជាតិខ្មែរ មុនិនាថ សីហនុ។



www.elibraryofcambodia.org



ទិដ្ឋភាពនៃក្បួនដង្ហែព្រះបរមសពនៃព្រះករុណាព្រះបរមរតនកោដ្ឋនាព្រឹកថ្ងៃទី១ ខែ កុម្ភៈ ឆ្នាំ ២០១៣។



ព្រះសង្ឃជាង១.០០០អង្គសូត្រធម៌នៅមុខកំពង់បូជាសួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ នរោត្តម សីហនុ។



www.elibraryofcambodia.org



ព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិយាងទៅតម្កល់នៅឯព្រះចេតិយស្ថិតក្នុងបរិវេណព្រះវិហារព្រះកែវមរកតទៅតាមព្រះរាជប្រពៃណីជាតិ និងពិធីសាសនាដែលមានរយៈពេលបីថ្ងៃទី១០-១២ កក្កដា ២០១៤។ រូប AKP





www.elibraryofcambodia.org



ព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិយាងទៅតម្កល់
នៅឯព្រះចេតិយស្ថិតក្នុងបរិវេណព្រះវិហារ
ព្រះកែវមរកតទៅតាមព្រះរាជប្បវេណីជាតិ
និងពិធីសាសនាដែលមានរយៈពេលបីថ្ងៃ
១០ - ១២ កក្កដា ២០១៥។ រូប AKP



រូប ម៉េង គុឹ



រូប ហេង ចិន



ការបាញ់កាំភ្លើងណាក់ រូប AKP



ព្រះចេតិយព្រះបរមអដ្ឋិ រូប AKP



ខ្ញុំ ឆាយ សុផល (ឆ្វេង) និងក្រុមការងារព័ត៌មានថតរូបជាមួយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នៅដំណាក់របស់ព្រះអង្គ បន្ទាប់ពីកិច្ចសម្ភាសន៍នៅថ្ងៃទី៣ កុម្ភៈ ២០១៣ ស្តីពីប្រវត្តិរូបរបស់ព្រះបិតា ក្រុម សីហនុ។ កិច្ចសម្ភាសន៍នេះគឺធ្វើមុនមួយថ្ងៃនៃព្រះរាជពិធីថ្វាយព្រះភ្លើងព្រះសពសម្តេចព្រះ នរោត្តម សីហនុ (រូប ប៉ែន សង្ហា)

www.elibraryofcambodia.org

ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជាទីសក្ការជាព្រះមហាវីរក្សត្រដែលតែងតែប្រកាន់ខ្ជាប់នូវព្រះរាជកិច្ចប្រកបដោយព្រហ្មវិហារធម៌ចំពោះប្រជានុរាស្ត្រនៅទូទាំងនគរ។ ព្រះអង្គតែងតែបំពេញព្រះរាជសកម្មភាពសង្គមកិច្ចដូចជាកសាងព្រះវិហារ កុដិ សាលាបុណ្យ សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង ផ្លូវថ្នល់ ទំនប់ ប្រឡាយ អណ្តូងទឹក ស្រះទឹកសម្រាប់ប្រគេនព្រះសង្ឃ និងជូនប្រជានុរាស្ត្រ។ ព្រះអង្គបានប្រោសព្រះរាជទាន និងបន្តនូវព្រះរាជសកម្មភាពទាំងនេះជារៀងរាល់សប្តាហ៍ ដោយព្រះប្រទានអំណោយជូនប្រជានុរាស្ត្រក្រីក្រ។ ជាងនេះទៅទៀត ប្រជារាស្ត្រខ្មែរទាំងអស់មកពីគ្រប់គណបក្សនិងនិន្នាការនយោបាយតែងតែចាត់ទុកព្រះអង្គជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងជាព្រះបិតាឯករាជ្យជាតិខ្មែរជាប់ជានិច្ច។ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៥៤ ក្នុងរជ្ជកាលរបស់ព្រះអង្គ សាលារៀនជាន់ខ្ពស់ផ្នែកព្រះពុទ្ធសាសនាក៏ត្រូវបានបង្កើតឡើង ដោយរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជាបានអនុម័តដាក់ឈ្មោះថា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ"។ កាលពីឆ្នាំ១៩៥៣ គឺមុនបង្កើតមហាវិទ្យាល័យនេះមួយឆ្នាំ ព្រះអង្គបានគាំទ្រនិងលើកទឹកចិត្តមន្ត្រីសង្ឃដែលចង់និមន្តទៅសិក្សានិងស្រាវជ្រាវនៅក្នុងប្រទេសឥណ្ឌា ស្រីលង្កា និងសៀម ដើម្បីទទួលពុទ្ធិបន្ថែមពីព្រះពុទ្ធសាសនា ដែលអាចមានលទ្ធភាពមកបង្កើតមហាវិទ្យាល័យនេះបាននៅក្នុងប្រទេស[220]។

ព្រះនាមរបស់ព្រះអង្គត្រូវបានស្ថាប័នកំណត់ត្រាប្លែកៗ Guinness World Records របស់ពិភពលោកបានកត់ត្រានៅថ្ងៃទី១ ខែ មករា ឆ្នាំ ១៩៩៣ ថា ជាមេដឹកនាំមួយអង្គដ៏ឆ្នើមក្នុងរជ្ជកាលរាជានិយមនាសម័យកាលទំនើប៕

---

[220] *សៀវភៅ៖ ប្រវត្តិពុទ្ធិកសិក្សា (ទំព័រ៨១-៨២)*



www.elibraryofcambodia.org

# មហាក្សត្រ (៣ មីនា ១៩៥៥ -១៨ មីនា ១៩៧០)



ព្រះបរមឆាយាល័ក្ខណ៍ ព្រះបាទ សម្ដេចព្រះ នរោត្តម សុរាម្រិត និងម្ចាស់ក្សត្រិយានី ស៊ីសុវត្ថិ កុសមៈ នារីរ័ត្ន សិរីវឌ្ឍនា

www.elibraryofcambodia.org

# ព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត



ព្រះបរមឆាយាល័ក្ខណ៍ព្រះបាទ សម្ដេចព្រះ នរោត្តម សុរាម្រិត



www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត** បានគ្រងរាជបល្ល័ង្ក ប្រមាណ៦ព្រះវស្សា៖ **៣ មីនា ១៩៥៥ - ៣ មេសា ១៩៦០**

**ព្រះបិតា៖ នរោត្តម សុធារស** (១៨៧២ - ១៩៤៥) **ព្រះមាតា៖ នរោត្តម ផង៉ាង៉ាម** (១៨៧៤ - ១៩៤៤)





**ប្រសូត៖** ៦ មីនា ១៨៩៦ នៅប្រាសាទខេមរិន្ទ្រ ព្រះបរមរាជវាំង រាជធានីភ្នំពេញ

**សោយព្រះសុវណ្ណគត៖** ៣ មេសា ១៩៦០ នៅរាជធានីភ្នំពេញ ក្នុងព្រះជន្ម៦៤ព្រះវស្សា។ ព្រះបរមបច្ឆាមរណនាមនៃព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត គឺព្រះករុណាព្រះបាទសម្តេច **នរោត្តម សុរាម្រិត "ព្រះមហាកញ្ញានកោដ្ឋ"**។



www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ត្រូវជាក្មួយប្រុសរបស់ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស តែក្រោយមក ទ្រង់បានក្លាយជាបុត្រប្រសាទៀត បន្ទាប់ពីទ្រង់បានរៀបអភិសេកជាមួយបុត្រីរបស់ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស គឺម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន។



S.A.R. le Prince Norodom Suramarit, petit-fils de S.M. Norodom, à 18 ans.

ក្រៅពីមានស្នំជាច្រើននាក់ ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត មានព្រះមហេសី៣អង្គ ព្រះបុត្រា៣អង្គ និងព្រះបុត្រី១អង្គដែលក្នុងនោះរួមមាន៖

**ព្រះអគ្គមហេសីទី១៖** ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (ប្រសូតនាថ្ងៃទី៩ មេសា ១៩០៤ នៅរាជធានីភ្នំពេញ និងសោយព្រះទិវង្គតនៅថ្ងៃទី ២៧ មេសា ១៩៧៥ នៅទីក្រុងប៉េកាំង ប្រទេសចិន)។ ព្រះមហាក្សត្រីយានី កុសុមៈ ត្រូវជាបងប្អូនជីដូនមួយនឹងព្រះស្វាមី នរោត្តម សុរាម្រិត ដែលបានរៀបអភិសេកនៅក្នុងប្រាសាទខេមរិន្ទ្រនាឆ្នាំ ១៩២០។ ព្រះអង្គទាំងពីរមានបុត្រាតែមួយអង្គគត់គឺ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ។



www.elibraryofcambodia.org



ពីឆ្វេង៖ ព្រះឆាយាល័ក្ខណ៍ ព្រះករុណា ព្រះបាទ នរោត្តម សុរាម្រិត ព្រះករុណា ព្រះបាទ នរោត្តម សីហនុ និងមហាក្សត្រីយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា។ ព្រះអង្គទាំងបីបានសោយព្រះទិវង្គតទៅអស់ហើយ។ (រូបបណ្ណាល័យជាតិ)



www.elibraryofcambodia.org

**ព្រះមហេសីទី២៖** អ្នកអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ដួង ម៉ាធូរ៉េត (Duong Mathuret) (ប្រសូតឆ្នាំ១៨៩៦) ដែលជាបុត្រីពៅរបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ដួង ម៉ាធូរ៉ា (Duong Mathura)។ ព្រះអង្គទាំងពីរទ្រង់មិនមានបុត្រទេ។

**មហេសីទី៣៖** អ្នកម្នាង យុនទេព កញ្ញាសោភា គឹមអានយៀប



ញ្ញាសោភា គឹមអានយៀប យុនទេព កញ្ញាសោភា គឹមអានយៀប

ប្រសូតថ្ងៃទី ២៥ ឧសភា ១៩២៥ ហើយទទួលអនិច្ចកម្មនៅថ្ងៃទី១៨ ឧសភា ឆ្នាំ១៩៩៥ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ អ្នកម្នាងជាកូនស្រីពៅរបស់លោក គឹម អាន និងអ្នកអង្គម្ចាស់ក្សត្រិយ៍ នរោត្តម ទូជី (Tuji) ដែលជាបុត្រីពៅរបស់ព្រះអង្គម្ចាស់ នរោត្តម រ៉ាយ៉ា (Raya)។ ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត និងអ្នកម្នាង យុនទេព កញ្ញាសោភា គឹមអានយៀប មានបុត្រីច្បង១អង្គនិងបុត្រា២អង្គ៖

- អ្នកអង្គម្ចាស់ក្សត្រិយ៍ នរោត្តម វង្ស៉ា (ប្រសូត៖ ១៧ សីហា ១៩៤៦ នៅរាជធានីភ្នំពេញ និងសោយទិវង្គតនៅយប់ថ្ងៃទី២៨ កក្កដា ឆ្នាំ ២០១៣ ក្នុងព្រះជន្ម៦៧ព្រះវស្សា ដោយសារព្រះរោគនៅទីក្រុងប៉ារីស)។ ព្រះអង្គជាឥស្សរជននយោបាយហើយជាអ្នកតំណាងរាស្ត្ររបស់គណបក្សហ៊្វុនស៊ិនប៉ិចប្រចាំនៅមណ្ឌលសៀមរាបនៅក្នុងអាណត្តិទី២ឆ្នាំ



នរោត្តម វង្ស៉ា



www.elibraryofcambodia.org

១៩៩៨ និងប្រចាំមណ្ឌលភ្នំពេញនៅអាណត្តិទី៣ឆ្នាំ២០០៣។ អ្នកអង្គម្ចាស់ក្សត្រិយ៍ក៏ធ្លាប់បានទទួលតំណែងជាប្រធានគណកម្មាធិការកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋសភាចាប់ពីឆ្នាំ១៩៩៨ដែរ។

- ព្រះអង្គម្ចាស់ នរោត្តម សិរិវុឌ្ឍ (ប្រសូត៖ ៨ មិថុនា ១៩៥១ នៅរាជធានីភ្នំពេញ)។ ព្រះអង្គធ្លាប់ជាតំណាងរាស្ត្រ ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសក្នុងឆ្នាំ ១៩៩៣-១៩៩៥ ហើយជាសមាជិកព្រឹទ្ធសភានាឆ្នាំ ២០០១។ នៅខែវិច្ឆិកា ឆ្នាំ១៩៩៥ ព្រះអង្គបានធ្វើឲ្យពិភពលោកភ្ញាក់ផ្អើល ដោយសារទ្រង់មានបន្ទូលថាទ្រង់ចង់សម្លាប់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ដើម្បីផ្លាស់ប្តូរប្រវត្តិសាស្ត្រ។ ដោយសារបន្ទូលនេះ ទើបទ្រង់ត្រូវបានគេចាប់ព្រះកាយនៅថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំនោះ ហើយនិរទេសទៅបារាំងមុននឹងកាត់ទោសកំបាំងមុខ តែក្រោយមកត្រូវបានព្រះមហាក្សត្រ នរោត្តម សីហនុ ដែលត្រូវជាព្រះជេដ្ឋា [បង] ផ្តល់ព្រះរាជទានលើកលែងទោសឲ្យដែលជាការបើកផ្លូវឲ្យទ្រង់បានយាងមកប្រទេស និងធ្វើនយោបាយវិញ។ ព្រះអង្គក៏ចេះលេងហ្គីតា អ័ក និងច្រៀងផងដែរ។


នរោត្តម សិរិវុឌ្ឍ

- ព្រះអង្គម្ចាស់ នរោត្តម ប្រិយ៍សោភ័ណ (Preyasophon) (ប្រសូត៖ ១៨ វិច្ឆិកា ១៩៥៤)។



www.elibraryofcambodia.org






www.elibraryofcambodia.org

## ការសិក្សា

ព្រះអង្គបានចូលសិក្សាអក្សរសាស្ត្រខ្មែរនៅទីសំណាក់ នួនមុនីរាម សាលាបារាំង François Garnier អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក្នុងរាជធានីភ្នំពេញ និងនៅសាលា Lycée Chasseloup-Laubat នៅឯព្រៃនគរ។

## រាជបល្ល័ង្ក និងរាជកិច្ច

**១៩១៨-១៩២៥៖** ជាទីប្រឹក្សានិងលេខាផ្ទាល់របស់ព្រះមហាក្សត្រព្រះបាទ ស៊ីសុវត្ថិ។

**១៩២៧-១៩២៩៖** ប្រធានស្ថានទូតនៃព្រះបរមរាជវាំង

**១៩២៩-១៩៤១៖** ព្រះអង្គបានធ្វើជារដ្ឋមន្ត្រីកងម៉ារីនក្រឡាហោម ( Kralahama ) ទទួលបន្ទុកការងារពាណិជ្ជកម្ម និងកសិកម្ម។

**១២ សីហា ១៩៣១៖** ទទួលបានបរមងារស្ដេចក្រុមឃុន វិសុទ្ធខត្តិយវង្ស។

**១៩៣៩៖** ធ្វើជាប្រេសិតពិសេសរបស់ប្រធានាធិបតីនិងរដ្ឋាភិបាលបារាំង។

**២៥ មេសា ១៩៤១៖** ព្រះអង្គបានធ្វើជាប្រធានក្រុមប្រឹក្សាការពាររាជបល្ល័ង្ក ដោយទទួលបានឋានៈនិងបរមងារជាសម្ដេច "អ្នកការពារដ៏កំពូលរបស់ព្រះរាជា"។



www.elibraryofcambodia.org

**មុនឆ្នាំ១៩៥៥៖** ព្រះអង្គបានធ្វើជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ និងជាប្រធានព្រះរាជានុសិទ្ធិ។

**៣ មីនា ១៩៥៥៖** ព្រះអង្គបានឡើងសោយរាជ្យគ្រប់គ្រងរាជសម្បត្តិ បន្ទាប់ពីព្រះរាជបុត្រា គឺព្រះមហាក្សត្រ នរោត្តម សីហនុ បានដាក់រាជ្យ ហើយស្ម័គ្រព្រះទ័យថ្វាយរាជបល្ល័ង្ក ជូនព្រះអង្គជាព្រះបិតា និង ព្រះមាតា។ ពិធីឡើងសោយរាជ្យនេះបានធ្វើឡើងនៅព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំងនៅថ្ងៃទី **៥ មីនា ១៩៥៥**។ បន្ទាប់មក ព្រះអង្គទទួលបានព្រះបរមងារថា



ព្រះបាទ សុរាម្រិត និងព្រះរាជបុត្រា សីហនុ (ស្តាំ) ។ រូប *Le Palais Du Roi Du Cambodge*

"ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋហរិវង្ស គុណាទិរេក ធម្មចរិយោត្តម បរមបពិត ព្រះចៅក្រុងកម្ពុជា"។ នៅក្នុងព្រះរាជតំណែងជាព្រះរាជា គឺប្រទេសបានទទួលឯករាជ្យទាំងស្រុងពីបារាំង។ បើទោះជានគរនាពេលនោះ មានជម្លោះនយោបាយផ្ទៃក្នុងខ្លះតាមរយៈគណបក្សនយោបាយនៅក្នុងសភា និងមានក្រុមប្រឆាំងនឹងរាជានិយមខ្លះក៏ដោយ ក៏ព្រះរាជបុត្រដ៏ឆ្នើមរបស់ព្រះអង្គបានចាត់ចែងកិច្ចការរដ្ឋបានយ៉ាងប្រសើរដែរនៅក្នុងរបបសង្គមរាស្ត្រនិយម។



www.elibraryofcambodia.org



ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (រូបបណ្ណាល័យជាតិ)

www.elibraryofcambodia.org



ព្រះរាជពិធីឡើងគ្រងរាជសម្បត្តិរបស់ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា។ រូបផ្សាយនៅគេហទំព័រ http://www.corbisimages.com/stock-photo/rights-managed/SF38129/king-norodom-suramarit-and-queen-sisowath-kossouan





ព្រះរាជពិធីឡើងគ្រងរាជសម្បត្តិរបស់ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ។ រូបឆ្វេងផ្សាយនៅគេហទំព័រ http://www.corbisimages.com/stock-photo/rights-managed/U1103724/king-norodom-suramarit-sitting-next-to-queen រូបស្តាំផ្សាយនៅគេហទំព័រ http://s39.photobucket.com/user/nguyen77/media/05a6c909.jpg.html

www.elibraryofcambodia.org



រូបលើ៖ ព្រះរាជពិធីសោយទឹកសម្បថមុនឡើងគ្រងរាជសម្បត្តិរបស់ព្រះបាទសម្តេច ព្រះ នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈ នារីរ័ត្ន សិរីវឌ្ឍនា (រូបបណ្ណាល័យជាតិកម្ពុជា)។





រូបលើ និងរូបឆ្វេង៖ ក្បួនដង្ហែក្នុងព្រះរាជពិធីឡើងគ្រងរាជសម្បត្តិរបស់ព្រះបាទសម្តេច នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (រូបបណ្ណាល័យជាតិកម្ពុជា)។



www.elibraryofcambodia.org

**៣ មេសា ១៩៦០៖** ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត បានសោយព្រះទិវង្គត ដោយព្រះរោគាពាធក្នុងព្រះជន្ម៦៤ព្រះវស្សា។ ព្រះអង្គបានទទួលព្រះបរមបច្ឆាមរណនាមថា "ព្រះមហាកញ្ចនកោដ្ឋ"។ ព្រះរាជពិធីព្រះបរមសពព្រះអង្គត្រូវបានធ្វើឡើងតាមគន្លងរាជបវេណី បុរាណរៀងមក ស័ក្តិសមព្រះកិត្តិយសជាស្តេចផែនដី ដោយមានពិធីដង្ហែព្រះកោដ្ឋព្រះបរមសពទៅដាក់នៅទីព្រះមេរុ ដើម្បីធ្វើពិធីថ្វាយព្រះភ្លើង[221]។

បន្ទាប់ពីសោយព្រះទិវង្គតទៅ ព្រះរាជបុត្រាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានថ្វាយតំណែងជាព្រះប្រមុខរដ្ឋ ហើយទ្រង់មិនបានឡើងសោយរាជ្យជាព្រះមហាក្សត្រទេ ប៉ុន្តែរាជបល្ល័ង្កត្រូវបានថ្វាយជូនព្រះមាតា ស៊ីសុវត្ថិ កុសុមៈ។ ក្រោយពីបានគ្រងរាជ្យ ព្រះមាតាក៏បានទទួលព្រះបរមងារថា ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ។ ទោះបីជាយ៉ាងនេះក្តី ព្រះរាជតំណែងនេះត្រូវបានគេមើលឃើញថាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ដោយហេតុថា អំណាចរាជបល្ល័ង្ក និងរាជកិច្ចគឺស្ថិតនៅលើព្រះបុត្រា នរោត្តម សីហនុ ទាំងអស់។ ព្រះចេតិយរបស់ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ស្ថិតនៅក្នុងព្រះបរមរាជវាំង។

[221] http://whoincam.wordpress.com/2009/07/09/norodom-suramarit/



www.elibraryofcambodia.org



ក្បួនដំរីដង្ហែព្រះបរមសព ព្រះបាទ នរោត្តម សុរាម្រិត ។ រូប Milton Osborne ផ្សាយនៅ៖ http://asiapacific.anu.edu.au/newmandala/2013/02/03/sihanouks-revenge/



ព្រះទីនាំងដឹកព្រះបរមសព ព្រះបាទ នរោត្តម សុរាម្រិត ។ រូបនៅ៖ http://minus.com/ljLvKRcZFLMs6



www.elibraryofcambodia.org

ព្រះរាជបុត្រា នរោត្តម សីហនុ កាន់ព្រះកោដ្ឋដាក់ព្រះអដ្ឋិព្រះបិតា នរោត្តម សុរាម្រិត នៅក្នុងព្រះបរមរាជវាំង។







រាជពិធីដង្ហែក្បួនព្រះបរមសព ព្រះបាទ នរោត្តម សុរាម្រិត។ រូបនេះ
www.thecambodiaherald.com/cambodia/cambodia-braces-for-biggest-royal-funeral-in-half-a-century-2491



www.elibraryofcambodia.org



ព្រះកោដ្ឋនេះដែលដើមឡើយធ្វើពីឈើស្រោបមាសនិងដែក ប្រើក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះបាទ នរោត្តម។ ក្រោយមកត្រូវបានផ្លាស់ប្តូរស្រោបប្រាក់ឡើងវិញនៅពេលថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្របន្តបន្ទាប់ដូចជា ព្រះបាទ ស៊ីសុវត្ថិ ឆ្នាំ១៩២៨ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ឆ្នាំ ១៩៤១ និងព្រះបាទ នរោត្តម សុរាម្រិត ឆ្នាំ១៩៦០។ ព្រះកោដ្ឋនេះបានតាំងនៅសារមន្ទីរជាតិមកដល់សព្វថ្ងៃ ហើយរូបនេះ ខ្ញុំ ឆាយ សុផល បានថតនៅថ្ងៃទី ២៨ មីនា ឆ្នាំ ២០១៥ នៅឯសារមន្ទីរជាតិ។



www.elibraryofcambodia.org





ឆ្វេង៖ រាជពិធីបុណ្យព្រះបរមសព ព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រិត (រូបបណ្ណាល័យជាតិ)។

ស្ដាំ៖ ព្រះមហាចេតិយព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត និងព្រះរាជអគ្គមហេសីព្រះបាទក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា នៅក្នុងព្រះរាជវាំង (រូបថតដោយ ឆាយ សុផល ៖ ៥ ធ្នូ ២០១៤)។



www.elibraryofcambodia.org




*ព្រះឆាយាល័ក្ខណ៍ ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សុរាម្រិត ដាក់តាំងនៅមុខប្រាសាទចន្ទឆាយា ។ រូបថតដោយ ឆាយ សុផល ថ្ងៃទី១ មេសា ២០១៥*



www.elibraryofcambodia.org

ព្រះនាមរបស់ព្រះអង្គត្រូវបានគេយកទៅដាក់ឈ្មោះផ្លូវគឺ "មហាវិថីព្រះសុរាម្រិត" ឬផ្លូវ២៦៨ ចាប់ផ្តើមចេញពីចំណុចកែងមហាវិថីសុទ្ធារស (ជីតារបស់សម្តេច សីហនុ) ចាប់ពីសួនច្បារវិមានឯករាជ្យរហូតទៅដល់វិថីប៉ាស្ទ័រ។ ព្រះនាមរបស់ព្រះអង្គក៏ត្រូវបានគេយកទៅដាក់ឈ្មោះសាលារៀនដែរនៅតាមបណ្តាខេត្តនានា។ បន្ថែមពីនេះ ទីរមណីយដ្ឋានមួយក៏មានព្រះនាមព្រះអង្គនិងអគ្គមហេសី កុសុមៈ ដែរ ដោយរមណីយដ្ឋាននោះនៅឧទ្យានជាតិគិរីរម្យមានឈ្មោះថា "រមណីយដ្ឋានគិរីរម្យព្រះសុរាម្រិតកុសមៈ" មានទីតាំងនៅភូមិដំរីភ្លើ ឃុំគិរីរម្យ និងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានចម្ងាយប្រមាណ១១៧គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ រមណីយដ្ឋានគិរីរម្យ (អតីតក្រុងព្រះកុសុមៈ) គឺជារមណីយដ្ឋានធម្មជាតិ ដែលមានភ្នំកម្ពស់៧០០ម៉ែត្រ និងលក្ខណៈពិសេសជាច្រើនសម្រាប់ភ្ញៀវទេសចរដូចជា៖ ព្រៃមនោរម្យពេញដោយដើមស្រល់ជាមួយនឹងផ្កាអ័រគីដេ និងមានខ្យល់ត្រជាក់ប្រកបដោយលក្ខណៈបរិសុទ្ធ[222]។

## គ្រឿងឥស្សរិយយស

- គ្រឿងរាជឥស្សរិយយសនៃព្រះរាជអាណាចក្រកម្ពុជា ១៩៤១
- មេដាយនានានៃរជ្ជកាលព្រះករុណាព្រះ ស៊ីសុវត្ថិ និងព្រះស៊ីសុវត្ថិ មុនីវង្ស ថ្នាក់ទី១
- គ្រឿងរាជឥស្សរិយយសរាជវង្សចក្រី នៃរាជអាណាចក្រសៀម
- គ្រឿងរាជឥស្សរិយយសដំរីរាប់លាន និងដំរីសនៃព្រះរាជាណាចក្រលាវ
- គ្រឿងរាជឥស្សរិយយសនៃប្រទេសអណ្ណាម (យួន/វៀតណាម)
- គ្រឿងឥស្សរិយយសអគ្គមហាធិរិជោមា នៃប្រទេសភូមា
- គ្រឿងឥស្សរិយយសនៃប្រទេសវៀតណាម
- គ្រឿងឥស្សរិយយស Legion of Honour នៃប្រទេសបារាំង ១៩៣៩។

---

[222] *ក្រសួងទេសចរណ៍*



www.elibraryofcambodia.org

# ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ





www.elibraryofcambodia.org

**ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា** សោយរាជ្យបាន១០ព្រះវស្សា៖ ២០ មិថុនា ១៩៦០ - ១៨ មីនា ១៩៧០។ ព្រះមហាក្សត្រិយានីបានទទួលព្រះរាជតំណែងនេះ បន្ទាប់ពីព្រះអគ្គស្វាមីព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត បានសោយព្រះទិវង្គតនាថ្ងៃទី៣ មេសា ឆ្នាំ ១៩៦០។

**ប្រសូត៖** ៩ មេសា ១៩០៤ នៅរាជធានីភ្នំពេញ
**ពិរាល័យ [សោយទិវង្គត]៖** ២៧ មេសា ១៩៧៥ នៅទីក្រុង ប៉េកាំង ប្រទេសចិន ក្នុងព្រះជន្ម៧១វស្សា

**ព្រះបិតា៖** ស៊ីសុវត្ថិ មុនីវង្ស
**ព្រះមាតា៖** ព្រះមហាក្សត្រិយ៍ នរោត្តម កានវិមាន នរល័ក្ខទេវី

ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា មានព្រះរៀមនិងព្រះអនុជបង្កើតចំនួន៣អង្គ និងព្រះជេដ្ឋានិងព្រះអនុជបិតាតែមួយមាតាទីទៃប្រមាណ២០អង្គ។ ព្រះរៀមនិងព្រះអនុជបង្កើតរួមមាន៖

- សម្តេចព្រះរៀម ស៊ីសុវត្ថិ ថាវេត រង្សី នារីវង្ស (៣០ មីនា ១៨៩៩ - ១៩៧៥)
- ព្រះអនុជ សម្តេចក្រុមព្រះស៊ីសុវត្ថិ មុនីរ៉េត (២៥ វិច្ឆិកា ១៩០៩១៩៧៥-)។
- ព្រះអនុជ ព្រះអង្គម្ចាស់ក្រុមហ្លួង ស៊ីសុវត្ថិ មុនីពង្ស (២៥ សីហា ១៩១២-៣១ សីហា ១៩៥៦)។



www.elibraryofcambodia.org

**ព្រះអគ្គស្វាមី៖** សម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ទ្រង់ បានរៀបអភិសេកជាមួយព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត នៅឯប្រាសាទខេមរិន្ទ្រ ព្រះបរមរាជវាំងរាជធានីភ្នំពេញនាឆ្នាំ ១៩២០។ ព្រះករុណាទាំងពីរអង្គដែលបងប្អូនជីដូនមួយនឹងគ្នាមានព្រះរាជបុត្រមួយព្រះអង្គគត់គឺព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ។



ព្រះវររាជបិតា (ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត)
ព្រះវររាជមាតា (ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិកុសុមៈនារីរ័ត្ន សិរីវឌ្ឍនា)
និង ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ



www.elibraryofcambodia.org



**ស៊ីសុវត្ថិ មុនីវង្ស**





**នរោត្តម កានវិមាន នរល័ក្ខទេវី**

ក្រៅពីម្ចាស់ក្សត្រិយ៍ **នរោត្តម កានវិមាន នរល័ក្ខទេវី** ជាមួយនិង បុត្រ៤អង្គ៖ ស៊ីសុវត្ថិ ថាវេតវង្សី នារីវង្ស ស៊ីសុវត្ថិ កុសុមៈ ស៊ីសុវត្ថិ មុនីរ៉េត និង ស៊ីសុវត្ថិ មុនីពង្ស ព្រះបាទ **ស៊ីសុវត្ថិ មុនីវង្ស** មានមហេសី១៥អង្គ/នាក់ និងបុត្រ២៥អង្គផ្សេងទៀត នេះមិនទាន់គិតស្នំផ្សេងៗនៅឡើយទេ។



ស៊ីសុវត្ថិ ថាវេតវង្សី នារីវង្ស



**ស៊ីសុវត្ថិ កុសុមៈ**



**នរោត្តម សុរាម្រិត**



ក្រៅពី ស៊ីសុវត្ថិ កុសុមៈ ស៊ីសុវត្ថិ ផ្ទង់ មធុរ៉េត និង យុន ទេព សោភាគឹមអាន យៀប គឺព្រះបាទ នរោត្តម សុរាម្រិត មានស្នំមួយចំនួនផ្សេងទៀត។



នរោត្តម ស៊ីហនុ



ស៊ីសុវត្ថិ មុនីរ៉េត



ស៊ីសុវត្ថិ មុនីពង្ស



www.elibraryofcambodia.org

## ការសិក្សា

សាលាបឋមសិក្សានរោត្តម (សាលានារី) នៅរាជធានីភ្នំពេញ។

## រាជបល្ល័ង្ក និង រាជកិច្ច

**១៩២៨៖** ព្រះករុណា ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស ជាព្រះបិតា បានប្រទានព្រះយសព្រះអង្គជា "សម្តេចព្រះរាជធីតា កុសុមៈនារីរស្មីក្សត្រី ទ្រង់ល័ក្ម្មីណ៍ អគ្គធីតា រាជវង្សវរ្ម័ន បរមពង្សា ព្រះធិបតីនារីរ័ត្ន សិរីវឌ្ឍនា មហាក្សត្រិយានី"។

**២ ឧសភា ១៩៥១៖** ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជាព្រះបុត្រា បានប្រទានព្រះយសព្រះអង្គឡើងជា "សម្តេចព្រះវររាជិនី កុសុមៈ រាជទេវី"។


ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា

**៥ មីនា ១៩៥៥៖** សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ទ្រង់បានឡើងគ្រងរាជ្យ ស្របពេលជាមួយនឹងព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ជាព្រះអគ្គស្វាមីដែរ បន្ទាប់ពីព្រះរាជបុត្រា នរោត្តម សីហនុ បានដាក់រាជ្យថ្វាយជូន។ ពិធីរាជាភិសេកបានប្រារព្ធធ្វើឡើងនៅឯព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងព្រះបរមរាជវាំង ក្នុងរាជធានីភ្នំពេញនៅថ្ងៃនោះ ដោយបានទទួលព្រះបរមនាមថា "សម្តេច



www.elibraryofcambodia.org

ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា"។

**២០ មិថុនា ១៩៦០៖** នៅពេលព្រះអគ្គស្វាមីសោយព្រះទិវង្គត កាលពីថ្ងៃទី៣មេសា មុននេះ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នាថ្ងៃនោះបានបន្តគ្រងរាជ្យ ដោយឡើងគង់ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក រហូតដល់ថ្ងៃដែលក្មួយបង្កើតរបស់ព្រះអង្គគឺ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ រដ្ឋមន្ត្រីមហាផ្ទៃរួមជាមួយបក្ខពួកធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីព្រះប្រមុខរដ្ឋនាថ្ងៃទី១៨ មីនា ១៩៧០ ហើយផ្លាស់ប្តូររបបរបស់ប្រទេសពី "រាជានិយម" ទៅជា "សាធារណរដ្ឋ"។ សម្តេចព្រះ នរោត្តម សីហនុ បានចោទប្រកាន់ព្រះអង្គម្ចាស់ សិរិមតៈ ថាមានគំនិតគុំកួនយ៉ាងជ្រាលជ្រៅ និងមានបំណងប្រឆាំង ដោយសម្តេចព្រះ នរោត្តម សីហនុ អះអាងថា "ទ្រង់ស្អប់ខ្ញុំតាំងពីកុមារភាព ពីព្រោះទ្រង់យល់ថា ពូរបស់ទ្រង់គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត គួរតែទទួលបានរាជបល្ល័ង្កជំនួសរូបខ្ញុំ។ ទ្រង់ក៏បានបង្ហាញសញ្ញាណដែរថា ទ្រង់ក៏គួរតែត្រូវបានគេជ្រើសតាំងឲ្យឡើងគ្រងរាជ្យតំណែងនេះដែរ"[223]។

[223] *Norodom Sihanouk, My War with the CIA* ( ទំព័រ២៧ )



www.elibraryofcambodia.org



ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (មុខកណ្ដាល) យាងចូលរួមក្នុងព្រះរាជពិធីបុណ្យព្រះបរមសពព្រះបាទ នរោត្តម សុរាម្រិត នាឆ្នាំ១៩៦០។ រូបបណ្ណាល័យជាតិ



www.elibraryofcambodia.org

នៅក្នុងរាជកិច្ចនៃការដឹកនាំប្រទេសជាតិ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ដោយជាស្ត្រីមេម៉ាយផង ហើយក៏មានព្រះជន្មច្រើនដែរនោះ ព្រះអង្គបានពឹងផ្អែកទាំងស្រុងទៅលើព្រះរាជបុត្រា នរោត្តម សីហនុ។ ព្រះមហាក្សត្រិយានីគង់នៅតែព្រះបរមរាជវាំង ហើយរង់ចាំតែទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិតែប៉ុណ្ណោះ។ យូរៗម្តង ព្រះអង្គក៏យាងចេញទៅក្រៅដើម្បីទទួលបដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិនៅឯអាកាសយានដ្ឋានអន្តរជាតិ និងបំពេញព្រះរាជកិច្ចមនុស្សធម៌ដែរ។



*ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា (ស្តាំ) ទទួលស្វាគមន៍លោកជំទាវទី១ Jacqueline Kennedy ភរិយាលោកប្រធានាធិបតីអាមេរិក Kennedy នាខែវិច្ឆិកា ឆ្នាំ១៩៦៧ នៅក្នុងព្រះបរមរាជវាំង។*

*ព្រះមហាក្សត្រិយានី កុសុមៈ (រូបគង់ខាងមុខកណ្តាល) និងព្រះរាជបុត្រា សម្តេចព្រះ នរោត្តម សីហនុ (ស្តាំ) ទស្សនាការសម្តែងរបាំរបស់ក្រុមរបាំព្រះរាជទ្រព្យនៅក្នុងព្រះបរមរាជវាំង នាខែវិច្ឆិកា ឆ្នាំ១៩៦៧ ជាមួយលោកជំទាវទី១អាមេរិក Jacqueline Kennedy។ រូបរបស់ស្ថានទូតអាមេរិក។*



www.elibraryofcambodia.org



ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ (ស្តាំ) ទទួលស្វាគមន៍លោកបណ្ឌិត Zakir Hussain អនុប្រធានាធិបតីឥណ្ឌាក្នុងដំណើរទស្សនកិច្ចជាផ្លូវការនៅកម្ពុជានៅថ្ងៃទី១១- ១៤ តុលា ១៩៦៤។ រូបក្នុងព្រឹត្តិបត្រអនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា (ច្បាប់លេខ៧)



ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ (ទី២ពីស្តាំ) និងព្រះរាជបុត្រាសម្តេច នរោត្តម សីហនុ (ស្តាំ) ទទួលស្វាគមន៍លោកឧត្តមសេនីយ៍ Chales de Gaulle ប្រធានាធិបតីបារាំង និងភរិយានៅឯអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង (បច្ចុប្បន្ន៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) ក្នុងដំណើរទស្សនកិច្ចជាផ្លូវការនៅកម្ពុជានាខែសីហាឆ្នាំ១៩៦៦។ រូបក្នុងព្រឹត្តិបត្រអនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា (ច្បាប់លេខ៧)

www.elibraryofcambodia.org



ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ (ស្ដាំ) ជួបជាមួយ លោក ឧត្តមសេនីយ Chales de Gaulle ប្រធានាធិបតីបារាំង នៅព្រះបរមរាជវាំងខែសីហាឆ្នាំ១៩៦៦។



មហាក្សត្រិយានី ជួបជាមួយលោក Harold Holt នាយករដ្ឋមន្ត្រីអូស្ត្រាលី និងភរិយា នៅព្រះបរមរាជវាំង។ លោក Harold Holt បានមកបំពេញទស្សនកិច្ចនៅកម្ពុជាពីថ្ងៃទី ២៩ មីនា ដល់ដើមខែ មេសា ឆ្នាំ ១៩៦៧។



ព្រះមហាក្សត្រិយានី ជួបជាមួយ លោក ស៊ុហាតូ ប្រធានាធិបតីឥណ្ឌូណេស៊ីនៅព្រះបរមរាជវាំងនាខែ មេសាឆ្នាំ ១៩៦៨។ រូបក្នុងព្រឹត្តិបត្រអនុស្សាវរីយ៍ដោយរូបភាពនៃ កម្ពុជា (ច្បាប់លេខ៧)



www.elibraryofcambodia.org

**៣ វិច្ឆិកា ១៩៧៣៖** បន្ទាប់ពីប្រទេសបានប្រកាសប្តូររបបពី "រាជានិយម" ទៅជា "សាធារណរដ្ឋ" ជាផ្លូវការនៅថ្ងៃទី ៩ តុលា ឆ្នាំ ១៩៧០ អតីតព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ត្រូវបានហាមមិនឲ្យចេញពីព្រះបរមរាជវាំងឡើយ ខណៈដែលព្រះរាជបុត្រា នរោត្តម សីហនុ កំពុងនិរទេសនៅទីក្រុងប៉េកាំង ប្រទេសចិន។ អតីតព្រះមហាក្សត្រិយានី មានព្រះជន្មកាន់តែច្រើន ហើយក៏មានព្រះរោគទៀត។ ដោយខ្លួនជិតស្និទ្ធនឹងអតីតព្រះមហាក្សត្រិយ៍ ស៊ីសុវត្ថិ កុសុមៈ លោកនាយករដ្ឋមន្ត្រី ហង្ស ធុនហាក់[224] នាពេលនោះបានធានាការពារសុវត្ថិភាពព្រះអង្គ។ លោកសេនាប្រមុខ លន់ នល់ ក៏បានអនុញ្ញាតឲ្យអតីតព្រះមហាក្សត្រិយានីយាងទៅប៉េកាំងនៅថ្ងៃទី ៣ ខែ វិច្ឆិកា ដើម្បីព្យាបាលព្រះរោគ ហើយលោក ហង្ស ធុនហាក់ ក៏បានអមដំណើរយាងរបស់ព្រះអង្គទៅប៉េកាំងដែរ។ នៅឆ្នាំនោះ សង្គ្រាមបានផ្ទុះឡើងកាន់តែក្តៅគគុករវាងរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ និងចលនាខ្មែរក្រហមដែលបានសហការជាមួយរដ្ឋាភិបាលបង្រួបបង្រួមជាតិដែលដឹកនាំដោយ សម្តេច សីហនុ។ ពេលជូនអតីតព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈ ដល់ប៉េកាំង ហង្ស ធុនហាក់ នៅទីនោះក៏ជាអ្នកជួយចរចានិងសម្របសម្រួលជាមួយសម្តេច សីហនុ ដែរក្នុងការបញ្ចប់សង្គ្រាម តែការព្យាយាមរបស់គាត់មិនទទួលបានជោគជ័យឡើយ។ នៅពេលនោះដែរ ហង្ស ធុនហាក់ ត្រូវបាន លន់ លន់ សង្ស័យថា គាត់ក៏មានទំនាក់ទំនងខ្លះៗជាមួយចលនាខ្មែរក្រហមដែរតាមរយៈអតីតមេដឹកនាំរបស់គាត់គឺ ហ៊ូ យន់។ ក្រោយពីត្រឡប់មកពីប៉េកាំងវិញ ហង្ស ធុនហាក់ ត្រូវបាន លន់ នល់ "បង្ខំឱ្យលាលែងពីតំណែងពីនាយករដ្ឋមន្ត្រីនៅថ្ងៃទី១៧ មេសា ១៩៧៣ ប៉ុន្តែនៅថ្ងៃទី៦ ឧសភាទើបគាត់លាលែងជាផ្លូវការ។

---

[224] *អានប្រវត្តិ ហង្ស ធុនហាក់ នៅក្នុងសៀវភៅ "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"*



www.elibraryofcambodia.org

**២៧ មេសា ១៩៧៥៖** អតីតព្រះមហាក្សត្រិយានី បានពិរាល័យ (សោយទិវង្គត) នៅឯទីក្រុងប៉េកាំង ប្រទេសចិន ក្នុងព្រះជន្ម៧១ព្រះវស្សា។ ព្រះអដ្ឋិព្រះអង្គត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជាព្រះរាជបុត្របានយាងដង្ហែយកមកបញ្ចុះនៅក្នុងព្រះចេតិយជាមួយព្រះអដ្ឋិព្រះករុណាសម្តេចព្រះ នរោត្តម សុរាម្រិត នៅក្នុងព្រះបរមរាជវាំងនៅខែកញ្ញា ឆ្នាំ១៩៧៦។ ពិធីនេះមានការចូលរួមហែហមដោយមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមដែរដូចជា ខៀវ សំផន និងរដ្ឋមន្ត្រីការពារជាតិ សុន សេន ជាដើម ដោយរួមទាំងសមាជិករាជវង្សានុវង្សមួយចំនួន។



*មុខពីស្តាំ៖ រាជបុត្រា នរោត្តម សីហមុនី និងព្រះអនុជ នរោត្តម នរិន្ទ្រាពង្ស កាន់ព្រះកោដ្ឋដាក់ព្រះអដ្ឋិនៃអតីតព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ដង្ហែយកទៅតម្កល់ក្នុងចេតិយនៅវាំងនាខែកញ្ញា ១៩៧៥។ ខាងក្រោយបន្ទាប់ពីឆ្វេង៖ ព្រះមាតា មុនិនាថ សីហនុ ព្រះបិតា នរោត្តម សីហនុ និងមេខ្មែរក្រហម ខៀវ សំផន សុន សេន និង ហ៊ូ នឹម។ រូបក្នុងសៀវភៅ៖ The Royal Palace of Phnom Penh and Cambodian Royal Life*



www.elibraryofcambodia.org

## គ្រឿងឥស្សរិយយស

**១៩៥៧-១៩៧០៖** ជាព្រះប្រធានកិត្តិយសសមាគមកាកបាទក្រហមកម្ពុជា។

**១៨ មករា ១៩៦៣៖** គ្រឿងឥស្សរិយយសសិតសិង្គនៃប្រទេសឆេកូស្លូវ៉ាគី។

**៤ ឧសភា ១៩៦៨៖** គ្រឿងឥស្សរិយយសសិតសិង្គនៃប្រទេសសូឡូម៉ូនអេត្យូពី និងគ្រឿងឥស្សរិយយស Legion of Honour នៃសាធារណរដ្ឋបារាំង។

**១៨ មេសា ១៩៦៣៖** គ្រឿងឥស្សរិយយសដំរីរាប់លាន និងសិតក្លស់នៃព្រះរាជអាណាចក្រលាវ។

**៩ មេសា ១៩៦៣៖** មេដាយ Temasak ថ្នាក់ទីមួយនៃប្រទេសសិង្គបុរី។

**១៧ មករា ១៩៦៨៖** មេដាយ Grand Star នៃប្រទេសយូហ្គូស្លាវី។

**១ មេសា ១៩៦៨៖** មេដាយ Star នៃសាធារណរដ្ឋឥណ្ឌូនេស៊ីថ្នាក់ទី១ Adipurna៕



www.elibraryofcambodia.org

# មហាក្សត្រ (ចាប់ពីថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣)




**ព្រះបាទ នរោត្តម សីហនុ**

២៤ កញ្ញា ១៩៩៣ - ១៤ តុលា ២០០៤



**សម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

ចាប់ពីថ្ងៃទី ១៤ តុលា ឆ្នាំ២០០៤ មក



www.elibraryofcambodia.org

# ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ

# នរោត្តម សីហមុនី





www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសម័យកាលសកលភាវូបនីយកម្មទំនើប ពោរពេញដោយព័ត៌មានដ៏សម្បូរបែប ដែលយុវជនកម្ពុជាមានភាពកាន់តែក្លាហាន និងចូលរួមយ៉ាងសកម្មក្នុងវិស័យនយោបាយ និងសង្គម ព្រមទាំងហ៊ានបញ្ចេញមតិតាមរយៈមធ្យោបាយចម្រុះពិសេសនៅតាមបណ្ដាញព័ត៌មានសង្គម ដែលមាន Facebook និង YouTube ជាដើម។

**១៤ តុលា ២០០៤៖** សមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក ឬរាជសម្បត្តិបានសម្រេចជ្រើសរើសព្រះអង្គ ហើយកាលពីពេលនោះមានព្រះជន្ម៥១ព្រះវស្សា ឲ្យឡើងគ្រងរាជ្យជំនួសព្រះបិតា នរោត្តម សីហនុ ដែលបានដាក់រាជ្យចូលនិវត្តន៍។

**ប្រសូត៖** ១៤ ឧសភា ឆ្នាំ ១៩៥៣ នៅរាជធានីភ្នំពេញ។

**ព្រះបិតា៖** សម្ដេចព្រះ នរោត្តម សីហនុ

**ព្រះមាតា៖** អ្នកម្នាង អ៊ំ មុនិនាថ ឬ ម៉ូនិកអ៊ីស្ស៊ី ជាកូនស្រីរបស់លោក អ៊ីស្ស៊ី ជនជាតិបារាំងកាត់អ៊ីតាលីនិងលោកស្រី ប៉ុម ពាង[225]។

ព្រះនាមរបស់ព្រះអង្គបានមកពីព្រះនាមព្រះបិតានិងមាតាដាក់បញ្ចូលគ្នា។ បើទោះជាសម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាព្រះជេដ្ឋាមានបិតាតែមួយមាតាទីទៃអាចជាព្រះទាយាទនៃរាជបល្ល័ង្ក ហើយឫកពា

[225] *ឯកសារមួយសរសេរថា "ប៉ោម ពាង"*



www.elibraryofcambodia.org

ខ្លះរបស់រាជបុត្រា សីហមុនី ខុសប្លែកដាច់ពីព្រះបិតាក៏ដោយ ក៏ព្រះបិតានៅតែពេញហឫទ័យចំពោះព្រះរាជបុត្រាអង្គនេះយ៉ាងខ្លាំង។ ព្រះរាជបុត្រា នរោត្តម សីហមុនី មិនដែលជាប់ពាក់ព័ន្ធនឹងនយោបាយ[226]ដូចសម្តេចក្រុមព្រះឡើយ ហើយជាងនេះទៅទៀត ខុសពីព្រះរៀម/ព្រះជេដ្ឋា ព្រះអនុជ និងព្រះបិតា ក៏ដូចជាព្រះអយ្យកោ អយ្យកោទួត និងអយ្យកោលួតរបស់ទ្រង់ ដែលមានព្រះមហេសីនិងស្នំជាច្រើនអង្គ/នាក់នោះ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី មិនទាន់មានព្រះមហេសីជាផ្លូវការនៅឡើយទេរហូតមកដល់បច្ចុប្បន្ន (គិតត្រឹមឆ្នាំសៀវភៅបោះពុម្ពដែលព្រះអង្គមានព្រះជន្ម៦២ព្រះវស្សាទៅហើយនោះ)។



**ព្រះមាតា៖ អ៊ុំ មុនិនាថ**



**ព្រះបិតា៖ នរោត្តម សីហនុ**





**រាជបុត្រា នរោត្តម សីហមុនី** (ឆ្វេង)
និងព្រះអនុជ នរោត្តម នរិន្ទ្រតារាពង្ស[A]

ក្រៅពី អ៊ុំ មុនិនាថ សម្តេចឪ នរោត្តម សីហនុ មានស្នេហាផ្លូវការជាមួយសៃរាជវង្សនិងរាស្ត្រចំនួន៥អង្គ/រូបផ្សេងទៀត ហើយក៏មានបុត្រ១២អង្គទៀតផង។ ក្រៅពីនេះ ព្រះអង្គក៏មានស្នំជាច្រើនទៀតដែរ។

---

[226] កាសែត The Cambodia Daily ភាសាអង់គ្លេសលេខពិសេស (១៤ ឧសភា ២០១២) ទំព័រ៩

[A] ឯកសារខ្លះសរសេរថា "នរិន្ទពង្ស"។ ពាក្យ "នរិន្ទ" មានន័យថា "អ្នកជាម្ចាស់នៃមនុស្ស...."



www.elibraryofcambodia.org

ការមិនយកព្រះមហេសី និងស្នំបែបនេះគឺបានធ្វើឲ្យប្រជារាស្ត្រមើលឃើញថា ព្រះអង្គបានធ្វើបដិវត្តន៍ ឬអាចនិយាយបានថា ព្រះអង្គបានធ្វើកំណែទម្រង់ស្នេហាមួយដ៏ធំ នៅក្នុងចំណោមអតីតព្រះមហាក្សត្រខ្មែរកន្លងមក ដែលមួយអង្គៗមានមហេសីនិងស្នំរាប់សិបអង្គ/នាក់។ អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះអង្គបានកត់សម្គាល់ថា មហាក្សត្រទាំងអស់ពីបុរាណកាលនៃប្រទេសកម្ពុជាគឺមានមហេសីច្រើន សូម្បីតែមហាក្សត្រព្រះបាទ នរោត្តម និងព្រះបាទ ស៊ីសុវត្ថិ ក្នុងរជ្ជកាលទំនើបហើយក្តី ក៏មានស្នំរាប់រយនាក់ដែរ ដោយព្រះអង្គសង្កេតថា "មហាក្សត្រ នរោត្តម សីហមុនី របស់យើងបច្ចុប្បន្នគឺមិនមានទាំងមហេសី និងមិនមានទាំងស្នំ ហើយក៏មិនព្រមផ្សងព្រេងស្វែងរកនារី (feminine adventure) ដែរ"[227]។





*រូបឆ្វេង៖ ព្រះមាតា មុនិនាថ ព្រះរាជបុត្រា សីហមុនី (កណ្តាល) និងព្រះរាជបិតា នរោត្តម សីហនុ។*
*រូបស្តាំ៖ ព្រះរាជបុត្រា នរោត្តម សីហមុនី (មុខ) និងព្រះបិតា នរោត្តម សីហនុ។*

[227] *កាសែត The Cambodia Daily ភាសាអង់គ្លេសលេខពិសេស (១៤ ឧសភា ២០១២) ទំព័រ៩*



www.elibraryofcambodia.org

ព្រះអង្គមានព្រះអនុជបង្កើតមួយអង្គ ព្រះជេដ្ឋានិងព្រះអនុជបិតាតែមួយមាតាទីទៃ១២អង្គ។ ព្រះអនុជបង្កើតរបស់ព្រះអង្គគឺ ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស (១៩៥៤-២០០៣) ដោយត្រូវបានបញ្ជូនឲ្យទៅសិក្សានៅសហភាពសូវៀត (រុស្ស៊ី)។



*ព្រះរាជកុមារ នរោត្តម សីហមុនី (មុខគេ) និងព្រះអនុជ នរោត្តម នរិន្ទ្រតារាពង្ស ជាមួយព្រះមាតា មុនិនាថ និងព្រះបិតា នរោត្តម សីហនុ។*



www.elibraryofcambodia.org





រូបលើ៖ ព្រះរាជកុមារ នរោត្តម សីហមុនី (ឆ្វេង) ព្រះមាតា មុនិនាថ សីហនុ (កណ្តាល) និងព្រះអនុជ នរោត្តម នរិន្ទ្រពង្ស។ រូបក្នុង៖ http://norodomsihanouk.info/photo/album_110/page_1.html

រូបឆ្វេង៖ ព្រះរាជកុមារ នរោត្តម សីហមុនី (ស្តាំ) ព្រះមាតា មុនិនាថ សីហនុ (កណ្តាល) និងព្រះអនុជ នរោត្តម នរិន្ទ្រពង្ស។



www.elibraryofcambodia.org



ព្រះរាជកុមារ នរោត្តម សីហមុនី (មុខឆ្វេង) ព្រះមាតា មុនិនាថ សីហនុ (កណ្តាល) និង ព្រះអនុជ នរោត្តម នរិន្ទ្រពង្ស។ រូបក្នុង http://norodomsihanouk.info/photo/album_110/page_1.html





ព្រះអនុជ នរោត្តម នរិន្ទ្រពង្ស ជាមួយព្រះបិតានិងព្រះមាតា។ រូបក្រោម៖ សម្តេចឪ នរោត្តម សីហនុ ជាមួយព្រះជាយា មុនិនាថ និងរាជបុត្រា សីហមុនី និង នរិន្ទ្រពង្ស ជួបនាយករដ្ឋមន្ត្រីចិន Zhou Enlai និងភរិយា នៅប៉េកាំង។ រូបក្នុង http://norodomsihanouk.info/photo/album_110/page_1.html



www.elibraryofcambodia.org

## ការសិក្សា[228]



**១៩៥៩-១៩៦២៖** ព្រះអង្គសិក្សានៅសាលាបឋមសិក្សានរោត្តម និងវិទ្យាល័យដេកាតរបស់បារាំងនៅក្នុងរាជធានីភ្នំពេញ។

**១៩៦២ - ៦៧៖** ព្រះបិតារបស់ព្រះអង្គបានបញ្ជូនព្រះអង្គទៅទីក្រុងប្រាគ ប្រទេសឆេកូស្លូវ៉ាគី ដែលនៅទីនោះ ទ្រង់បានចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាក្នុងវិទ្យាល័យប្រាគ។



A young King Norodom Sihamoni at his school in Prague receives his dessert after lunch in October 1962.

*ព្រះរាជបុត្រា សីហមុនី ទទួលបង្អែមនៅសាលាឆេកូស្លូវ៉ាគី នាឆ្នាំ១៩៦២។ រូប AFP*

---

[228] http://norodomsihamoni.org/kh/biography



www.elibraryofcambodia.org

**១៩៦៧ - ១៩៧១៖** ទ្រង់បានសិក្សាផ្នែកសិល្បៈ របាំ តូរ្យតន្ត្រី



*ព្រះរាជបុត្រា សីហមុនី រៀននៅឆេកូស្លូវ៉ាគី*

ល្ខោននៅវិទ្យាស្ថានអភិរក្ស ទីក្រុងប្រាគ។

**១៩៧០៖** ព្រះអង្គបាន បញ្ចប់មធ្យមសិក្សាប័ត្រនៅទីក្រុងប្រាគ (និទ្ទេសល្អណាស់)។

**១៩៧១៖** ជ័យលាភីលេខ១ផ្នែករបាំបូរាណវិទ្យាស្ថានអភិរក្ស ទីក្រុងប្រាគ។

**១៩៧១ - ៧៥៖** សិក្សានៅសាកលវិទ្យាល័យ បណ្ឌិតសភាផ្នែកសិល្បៈតន្ត្រី ទីក្រុងប្រាគ។

**១៩៧៥៖** បរិញ្ញាប័ត្រជាន់ខ្ពស់នៃបណ្ឌិតសភាផ្នែកសិល្បៈតន្ត្រី ទីក្រុងប្រាគ។ នៅឆ្នាំនោះដែរ ព្រះអង្គបានព្រះរាជនិពន្ធនិក្ខេបបទស្តីពីទស្សនៈនិងការគ្រប់គ្រងសាលាសិល្បៈនៅកម្ពុជា។

**១៩៧៥ - ៧៦៖** ឧត្តមសិក្សាផ្នែកភាពយន្តនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង)។



www.elibraryofcambodia.org

ក្រៅពីភាសាជាតិ ព្រះអង្គចេះព្រះបន្ទូលភាសាឆេក និងភាសាបារាំងបានយ៉ាងស្ទាត់ ហើយក៏អាចព្រះបន្ទូលភាសាអង់គ្លេស និងរុស្ស៊ីបានល្អផងដែរ។ ព្រះអង្គជាក្សត្រខ្មែរតែមួយអង្គគត់ ដែលចេះព្រះបន្ទូលភាសាឆេក។ បន្ថែមពីលើនេះ ព្រះអង្គក៏ចេះព្រះបន្ទូលភាសាកូរ៉េបានតិចតួចដែរ។ ក្រៅពីចេះរាំរបាំបាលេ ព្រះអង្គក៏បានសម្ដែងក្នុងភាពយន្តដែលជាព្រះរាជនិពន្ធដោយព្រះបិតាសម្ដេច នរោត្តម សីហនុ ដែរ។

## ព្រះទេពកោសល្យ និងការសព្វព្រះទ័យ

សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី បានចំណាយពេលជាច្រើនក្នុងវ័យរាជកុមារភាពនិងយុវជនរបស់ព្រះអង្គនៅឯបរទេស។ ព្រះអង្គចេះរាំរបាំបាលេ ហើយក្រោយមកជាគ្រូបង្រៀនរបាំនេះ។ មុនសោយរាជសម្បត្តិ ព្រះអង្គធ្លាប់បានសម្ដែងទាំងរបាំបាលេ ហើយក៏មិនខុសពីព្រះបិតារបស់ទ្រង់ដែរ គឺព្រះអង្គក៏បានសម្ដែងភាពយន្តដែលជាព្រះរាជនិពន្ធដោយព្រះបិតា។ សម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** សព្វព្រះទ័យហាត់ប្រាណបែបកាយសម្ព័ន្ធ (ការធ្វើចលនាមួយៗ) និងរត់យឺតៗ នៅក្នុងឧទ្យានខាងក្រៅរាជដំណាក់។ ព្រះអង្គចេះកោរព្រះកេសាដោយអង្គឯង គឺទ្រង់មិនចាំបាច់ត្រូវការជាងកាត់សក់ទេ[229]។ តាំងពីកុមារភាព ព្រះអង្គសព្វព្រះទ័យនឹងជីវិតពេលរាត្រីជាជាងពេលថ្ងៃ ហើយកាលពីព្រះអង្គគង់នៅបរទេស ព្រះអង្គសព្វព្រះទ័យយាងទៅក្រៅនៅពេលរាត្រី។ នេះក៏ដោយសារតែព្រះអង្គមិនចូលចិត្តមនុស្សម្នាច្រើននៅក្នុងទីក្រុងដែលមានសំឡេងអ៊ូរអរនិងថ្លង់។ នៅក្នុងកិច្ចសម្ភាសន៍មួយនា

---

[229] *ប្រសាសន៍ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ( ២ មករា ២០១៥)*



www.elibraryofcambodia.org

ថ្ងៃទី៦ មករា ឆ្នាំ ២០១៥ រវាងរូបខ្ញុំ [អ្នកចងក្រងសៀវភៅ] និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ត្រូវជាបងជីដូនមួយព្រះមហាក្សត្រ នរោត្តម សីហមុនី ហើយធ្លាប់គង់នៅជាមួយព្រះអង្គតាំងពីរាជកុមារមកនោះ បានមានបន្ទូលថា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គមិនរើសមុខម្ហូបដូចព្រះបិតារបស់ទ្រង់ទេ តែព្រះអង្គសព្វព្រះទ័យម្ហូបគ្រប់មុខ។ នៅពេលទំនេរពីរាជកិច្ច ព្រះអង្គសព្វព្រះទ័យអានសៀវភៅប្រវត្តិសាស្ត្រ និងស្រាវជ្រាវតាមអ៊ីធឺណិត ដោយស្វែងរក និងទត [ទស្សនា] ភាពយន្តចេញថ្មីៗរបស់អាម៉េរិក បារាំង និងបណ្តាប្រទេសនៅអឺរ៉ុប ហើយព្រះអង្គតាមដានពីបច្ចេកទេសនៃកាថត និងទតលើទេពកោសល្យនៃការសម្តែងរបស់តារានីមួយៗ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ដែលត្រូវជាបងជីដូនមួយសម្តេចព្រះបរមនាថ បានបន្តថា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ក៏សព្វព្រះទ័យស្តាប់ភ្លេងបែបក្លាស៊ិក (Classic) និងចម្រៀងអូប៉េរ៉ា (Opera) ផងដែរ ព្រោះព្រះអង្គមានជំនាញផ្នែកនេះ។



www.elibraryofcambodia.org

ព្រះរាជបុត្រា នរោត្តម សីហមុនី សម្តែងរបាំបាលេឲ្យទស្សនិកជនទស្សនា។
រូបក្រោម៖ ទស្សនិកជនបានមកស្វាគមន៍ព្រះរាជបុត្រា នរោត្តម សីហមុនី ក្រោយពីសម្តែងរបាំបាលេរួចមក។
រូបក្នុងព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្តេចឳ





រូបក្រោម៖ ព្រះរាជបុត្រា នរោត្តម សីហមុនី កំពុងបង្រៀនរបាំដល់កុមារី។ រូបក្នុង៖
http://khmernz.blogspot.com/2009_05_14_archive.html





www.elibraryofcambodia.org






រូបលើ៖ រូបអនុស្សាវរីយ៍របស់សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ពេលព្រះអង្គសម្ដែងរបាំបាលេ។ រូបក្នុង៖
http://www.pinterest.com/pin/396498488050888830/



រូបលើ៖ ឈុតសម្ដែងបែបកំប្លែងរបស់ព្រះរាជបុត្រា នរោត្តម សីហមុនី (រូបក្នុងព្រឹត្តិបត្រ៖ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្ដេចឪ ( ទំព័រ ៤៨)

រូបស្ដាំ៖ ព្រះរាជបុត្រា នរោត្តម សីហមុនី បង្ហាត់របាំ កាលពីមុនព្រះអង្គបានឡើងគ្រងរាជ្យ ដល់នាង អ៊ុក ផល្លា ដែលក្រោយមកអ្នកនាងក៏ក្លាយជាមហេសីសម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ (រូបក្នុងសៀវភៅ៖ ប្រវត្តិសាស្ត្រខ្មែរ ពាក្យកាព្យរបស់ឡៅកន់)



www.elibraryofcambodia.org








*រូបពីរខាងលើ៖ ព្រះរាជបុត្រា នរោត្តម សីហមុនី សម្ដែងរបាំបាលេនៅមុខប្រាសាទតាព្រហ្ម។ រូបស្ដាំ៖ ព្រះអង្គសម្ដែងរបាំបាលេនៅសាលមហោស្រព។*
*រូបក្នុងព្រឹត្តបត្រ អនុស្សាវរីយ៍នៃកម្ពុជាសង្គមរាស្ត្រនិយម (ច្បាប់លេខ៣)*



www.elibraryofcambodia.org




ខ្សែភាពយន្តរឿង "ប្រជាកុមារ" ដែលព្រះសម្តែងដោយព្រះរាជកុមារ នរោត្តម សីហមុនី (ផលិតឆ្នាំ១៩៦៧) ត្រូវបានដាក់បញ្ចាំងជាលើកដំបូងនាថ្ងៃទី ៧ កក្កដា ឆ្នាំ ១៩៦៨ នៅរោងភាពយន្តគីរីរម្យ រាជធានីភ្នំពេញ។ រូបក្នុងព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្តេចឪ

ព្រះរាជបុត្រា សីហមុនី ស្វាគមន៍ទស្សនិកជនមុនទស្សនារឿង"ប្រជាកុមារ" ដែលដាក់បញ្ចាំងជាលើកដំបូងនាថ្ងៃទី ៧ កក្កដា ឆ្នាំ១៩៦៨ នៅរោងភាពយន្តគីរីរម្យ រាជធានីភ្នំពេញ។ រូបក្នុងព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្តេចឪ





www.elibraryofcambodia.org




ឈុតនៅក្នុងរឿង "ប្រជាកុមារ" ឬ "ព្រះប្រជាកុមារ" សម្តែងដោយព្រះរាជបុត្រា នរោត្តម សីហមុនី ដែលឈុតនេះបង្ហាញពីការជួយសងប្រាក់ដោះបំណុលរបស់ព្រះរាជកុមារជូនបុរសអ្នកមានម្នាក់ ជំនួសគ្រួសារកសិករមួយដែលជំពាក់បំណុលបុរសអ្នកមាននោះចំនួន៥.០០០រៀល។ តាមពិត ខ្ចីចំនួន១.០០០រៀល ការប្រាក់២០០រៀលក្នុងរយៈពេលមួយឆ្នាំជាថ្នូរនឹងការឲ្យកូនស្រីនៅបម្រើ តែក្នុងសំបុត្រខ្ចីប្រាក់បែរជាសរសេរថា ៥.០០០ រៀលទៅវិញ ដោយសារតែគ្រួសារកសិករនោះមិនចេះអក្សរ។ សាក្សីជាមេឃុំបានឆ្លើយអេះអុះ ចង់ថា ១.០០០ តែទីបំផុតថា ៥.០០០ រៀល ដែលបង្ហាញពីភាពអយុត្តិធម៌និងអំពើពុករលួយរវាងមេឃុំនឹងបុរសអ្នកមាននោះ។ ភាពយន្តនោះផលិតនៅឆ្នាំ ១៩៦៧ ដែលពេលនោះ ព្រះអង្គមានព្រះជន្មទើបបាន ១៤ ព្រះវស្សា។



www.elibraryofcambodia.org



ឈុតមួយក្នុងរឿង "ប្រជាកុមារ" សម្តែងដោយព្រះរាជកុមារ សីហមុនី។ ឈុតនេះបង្ហាញស្តេចព្រះជន្មក្មេងជាទីស្រឡាញ់របស់ប្រជារាស្ត្របានចាកចេញពីអ្នកភូមិដោយជិះសេះតែអង្គឯងយាងប្រពាតប្រាសាទដែលឡោមព័ទ្ធដោយព្រៃព្រឹក្សា (រូបក្នុងព្រឹត្តិបត្រ CAMBODGE LA CINEMA TOGRAPHIE DE NORODOM SIHANOUK (ANNEES 1965-1969 et ANNEES 1988-1991)។

www.elibraryofcambodia.org










ឈុតមួយក្នុងរឿង "ប្រជាកុមារ" សម្តែងដោយព្រះរាជកុមារ ស៊ីហមុនី។ ឈុតនេះបង្ហាញស្តេចព្រះជន្មក្មេង ជាទីស្រឡាញ់របស់ប្រជារាស្ត្របានចាកចេញពីអ្នកភូមិ ដោយជិះសេះតែអង្គឯងយាងប្រពាតប្រាសាទដែលឡោមព័ទ្ធដោយព្រៃប្រឹក្សា ហើយទ្រង់គិតថានឹងមិនមានបញ្ហាចំពោះទ្រង់ឡើយ។ នៅតាមផ្លូវស្រាប់តែមានអាមាត្យម្នាក់ដែលត្រូវមន្តអាគមបញ្ជាដោយម្តាយមីងរបស់ទ្រង់ឲ្យមកធ្វើឃាតទ្រង់ ប៉ុន្តែរៀបនឹងកាត់ក ក៏ស្រាប់តែមានតាឥសីមកជួយទាន់។ រូបស្តាំ៖ តារាស្រី សាក់ ស៊ីស្បោង សម្តែងជាម្តាយមីងចង់ធ្វើឃាតស្តេចក្មេង ដើម្បីដណ្តើមអំណាច។



www.elibraryofcambodia.org





ព្រះរាជបុត្រា សីហមុនី ត្រូវបានហ៊ុំព័ទ្ធដោយកុមារកុមារី ដើម្បីសូមស្វ័យលេខា [ចុះហត្ថលេខា] ពីទ្រង់ បន្ទាប់ពិធីសម្ពោធរោងមហោស្រពព្រះសីហនុ ក្នុងខេត្តកំពង់ចាមនាថ្ងៃទី ២០ កក្កដា ១៩៦៨។ រោងមហោស្រពអាចដាក់អ្នកទស្សនាបាន ១.១០០នាក់។ រូបក្នុងព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្តេចឪ



www.elibraryofcambodia.org



ឈុតក្នុងរឿង "មាតុភូមិខ្ញុំនាថ្ងៃអស្តង្គត" ផលិតនៅឆ្នាំ១៩៩១ ហើយចេញបញ្ចាំងនៅឆ្នាំ ១៩៩២។ តារាសម្តែងប្រុសជាព្រះរាជបុត្រា នរោត្តម សីហមុនី ជាគ្រូពេទ្យមានឈ្មោះថា សីហា ហើយតារាស្រីឈ្មោះថា នារី។ គ្រូពេទ្យ សីហា ជាជនជាតិខ្មែររស់នៅប្រទេសបារាំងហើយមកស្រុកខ្មែរដោយនិយាយថា ខ្លួនមានចិត្តខ្មាស់គេណាស់ ដោយបានរស់នៅក្នុងទីក្រុងប៉ារីសដ៏សុខស្រួម ខណៈពេលដែលប្រជារាស្ត្រខ្មែរក្រក្សត់។ ដោយទទួលបានប្រាក់ខ្លះពីឪពុកម្តាយដែលផ្ញើមកពីបារាំង សីហា បានស្ម័គ្រចិត្តមិនគិតប្រាក់ខែធ្វើការជួយវះកាត់ព្យាបាលឲ្យពលរដ្ឋ ពិសេសអ្នករងរបួសដោយសារគ្រាប់មីន។ រីឯ នារី វិញ នាងជាកូនកសិករ ហើយបានធ្វើជាគិលានុបដ្ឋាយិកានៅមន្ទីរពេទ្យបង្អែកមួយនៅជនបទ។ នាងមានសមត្ថភាពនិងកក្តីកាព ហើយបានក្លាយជាជំនួយការខាងផ្នែកវះកាត់របស់លោកគ្រូពេទ្យ សីហា។



www.elibraryofcambodia.org




ឈុតក្នុងរឿង "មាតុភូមិខ្ញុំនាថ្ងៃអស្តង្គត" បង្ហាញពីតួស្រីម្នាក់ទៀតជាប្អូនជីដូនមួយលោកគ្រូពេទ្យ សីហា។ ដោយស្រឡាញ់បងជីដូនមួយឯង ក៏ចាប់ឱបបងជីដូនមួយពីក្រោយ ដែលធ្វើឲ្យលោកគ្រូពេទ្យ សីហា ភ្ញាក់ផ្អើលហើយចាប់ដៃចេញដោយនិយាយថា ថ្ងៃក្រោយឈប់ធ្វើបែបនេះទៀត។




ឈុតក្នុងរឿង "មាតុភូមិខ្ញុំនាថ្ងៃអស្តង្គត" បង្ហាញថា លោកគ្រូពេទ្យ សីហា បានសុំនាង នារី ដែលជាជំនួយការរបស់ខ្លួនរៀបការជាមួយ ហើយនារីមិនបានឆ្លើយតបឡើយ តែទឹកមុខនិងកាយវិការបង្ហាញពីការយល់ព្រម ព្រោះនាងក៏លួចស្រលាញ់លោកគ្រូពេទ្យ សីហា ដែរ។ ទីបំផុត អ្នកទាំងពីរក៏ក្លាយជាប្តីប្រពន្ធនឹងគ្នា។



www.elibraryofcambodia.org





ឈុតក្នុងរឿង "មាតុភូមិខ្ញុំនាថ្ងៃអស្ដង្គត" បង្ហាញថា លោកគ្រូពេទ្យ សីហា រៀបការជាមួយ ជំនួយការរបស់ខ្លួនគឺនាង នារី គិលានុបដ្ឋាយិកា។



ឈុតមួយចុងក្រោយក្នុងរឿង "មាតុភូមិខ្ញុំនាថ្ងៃអស្ដង្គត" ដែលគូស្វាមីភរិយាបានបែកគ្នា ព្រោះស្វាមីបានណទៅជួយព្យាបាលក្រុមដោះមីន ហើយទីបំផុតក៏បានបាត់បង់ជីវិត ទុកឲ្យភរិយានៅមេម៉ាយ។



www.elibraryofcambodia.org



*ព្រះមហាក្សត្រ នរោត្តម សីហមុនី និងសម្តេចព្រះរៀម បុប្ផាទេវី ថតរូបអនុស្សាវរីយ៍មួយក្រុមជាមួយព្រះរាជទ្រព្យរបស់ព្រះអង្គក្នុងឱកាសមហោស្រពល្ខោននាថ្ងៃទី៧ កញ្ញា ឆ្នាំ២០០៩។ រូបថតថតចេញពីសារមន្ទីរជាតិនាថ្ងៃទី២៨ មីនា ២០១៥ ដោយ ឆាយ សុផល*

www.elibraryofcambodia.org

## រាជបល្ល័ង្ក និង រាជកិច្ច

ពីដំបូងឡើយ ពេលនៅជាព្រះរាជកុមារនិងជាយុវជន ព្រះអង្គមានហឫទ័យចង់បម្រើជាតិមាតុភូមិតាមរយៈវប្បធម៌និងសិល្បៈ ជាជាងចូលប្រឡូកក្នុងកិច្ចការនយោបាយ។ នេះដោយសារតែព្រះអង្គមាននិស្ស័យ និងទេពកោសល្យខាងផ្នែកសិល្បៈ។ ព្រះអង្គជាតន្ត្រីករ (Musician) ជាអ្នករបាំ (Dancer) និងអ្នកកំប្លែង (Comedian)[230] ផងដែរ។ បន្ទាប់ពីបញ្ចប់ការសិក្សា ព្រះអង្គក៏ចង់ចែករំលែកបទពិសោធន៍លើការងារវប្បធម៌បស្ចឹមប្រទេសជូននិស្សិតខ្មែរនៅសាកលវិទ្យាល័យវិចិត្រសិល្បៈ។ ទោះបីជាយ៉ាងនេះក្តី ព្រះអង្គក៏បានយាងមកលេងប្រទេសនៅពេលវិស្សមកាល ហើយបានយាងចេញទៅក្រៅជាមួយព្រះមាតាបិតាក្នុងការងារមនុស្សធម៌។



*ព្រះរាជកុមារ សីហមុនី យាងចែកអំណោយជាមួយព្រះមាតានៅមន្ទីរពេទ្យខ្មែរ-សូវៀតក្នុងរាជធានីភ្នំពេញនាឆ្នាំ ១៩៦៨។*

**១៩៧៦៖** នៅចុងឆ្នាំនោះ ព្រះអង្គបានយាងត្រឡប់ពីប្រទេសកូរ៉េខាងជើងមកប្រទេសកម្ពុជាវិញ។ ជាអកុសល រដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ប៉ុលពត ខៀវសំផន នួនជា អៀងសារី និងសុនសេន

---

[230] *ព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្ដេចឪ (ទំព័រ ៤៨)*



www.elibraryofcambodia.org

នាពេលនោះ បានសម្រេចប្រឆាំងរាជានិយមដោយចោទថាជាពួកសក្តិភូមិ ហើយបានឃុំព្រះកាយសមាជិករាជវង្សានុវង្ស ដែលរួមមានទាំងព្រះអង្គ និងព្រះមាតាបិតាផងឱ្យស្ថិតនៅក្រោមការឃុំឃាំងក្នុងព្រះរាជវាំង។

**៦ មករា ១៩៧៩៖** នៅរសៀលថ្ងៃនោះគឺមួយថ្ងៃមុនកងទ័ពវៀតណាមវាយចូលកាន់កាប់ទីក្រុងភ្នំពេញ យន្តហោះចិន Boeing 707 បានចុះចតនៅអាកាសយានដ្ឋានពោធិចិនតុង (បច្ចុប្បន្ន៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) ដើម្បីយាងសម្តេច សីហនុ ជាមួយនិងមហេសី មុនិនាថ និងមន្ត្រីស្ថានទូតចិន និងស្ថានទូតផ្សេងៗទៀតទៅប៉េកាំង[231]។ នៅពេលនោះ ព្រះរាជបុត្រា នរោត្តម សីហមុនី ក៏បានយាងទៅជាមួយព្រះមាតានិងបិតាដែរ។ សម្តេចព្រះរាជបិតា នរោត្តម សីហនុ បានឡាយថា ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស ជាបុត្រាមួយអង្គដែលបានធ្វើឲ្យបិតាចុកចាប់ព្រះឱរាជាងគេនៅក្នុងចំណោមបុត្រាបុត្រីទាំង១៤អង្គរបស់ព្រះអង្គ។ ខុសពីព្រះរៀមរបស់ព្រះអង្គដែលបានការពារព្រះបិតារបស់ខ្លួន ទ្រង់ នរិន្ទ្រតារាពង្ស ខណៈដែលក្រុមខ្មែរក្រហមឡើងកាន់អំណាចចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដោយពួកគេបានឃុំឃាំងព្រះបិតា និងព្រះញាតិវង្សមួយចំនួននៅក្នុងព្រះបរមរាជវាំង ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស រួមជាមួយបងប្អូនជីដូនមួយរបស់ទ្រង់គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចិត្រា ជាព្រះអនុជ [ប្អូន] នៃព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ និងជាបុត្រាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេថាវី និងអ្នកម្នាង អ៊ុំ ណាណែតអ៊ីស៊្បី បងស្រីបង្កើតអ្នកម្នាង ម៉ូនិក បានក្លាយជាមនុស្សដ៏ស្និទ្ធស្នាលជាមួយខ្មែរក្រហម និងបានក្លាយជាសត្រូវស្លាប់រស់ជាមួយព្រះបិតាឯង ដោយរួមគ្នាប្រមាថការដឹកនាំរបស់របប

[231] *Brother Enemy* ទំព័រ៣១៦



www.elibraryofcambodia.org

សង្គមរាស្ត្រនិយមថា ជារបបសក្តិភូមិ ព្រមទាំងបានសម្លុតគំរាមកំហែងព្រះញាតិវង្សមួយចំនួន។ ទាំងព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចិត្រា បានលើកតម្កើងការដឹកនាំរបស់ខ្មែរក្រហមថា ត្រឹមត្រូវដែលអាចលុបបំបាត់របបមូលធននិយម ដែលបានជិះជាន់វណ្ណៈកសិករកន្លងមក។ បន្ទាប់ពីវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហមមក ពួកខ្មែរក្រហមបានជម្លៀសសម្តេច សីហនុ និងព្រះញាតិវង្សមួយចំនួនទៅកាន់ប្រទេសចិន។ បើទោះបីជាមិត្តភ័ក្តិព្រះអង្គ លោក ម៉ៅ សេទុង និងលោក ជូ អេនឡាយ បានស្លាប់ទៅហើយក្តី ក៏ក្រុមថ្នាក់ដឹកនាំចិនជំនាន់ក្រោយនៅតែយកចិត្តទុកដាក់និងព្រះអង្គ ជាពិសេសលោកឧបនាយករដ្ឋមន្ត្រីចិន តេង ស៊ាវពីង ដែលក្រោយមកបានក្លាយជាប្រធានាធិបតីកែទម្រង់ចិនដំបូងគេបានកសាងព្រះដំណាក់ដ៏ស្កឹមស្កៃនៅក្នុងទីក្រុងប៉េកាំងថ្វាយព្រះអង្គ និងព្រះញាតិវង្សសម្រាប់គង់នៅ ក៏ប៉ុន្តែសម្តេច សីហនុ បានបដិសេធក្នុងការគង់នៅជាមួយព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស និងព្រះអង្គម្ចាស់ ចិត្រា។ ការបដោសេធនេះ គឺព្រះអង្គហាក់ដូចជាបានដាក់គំនាបដល់ប្រទេសចិនឲ្យជ្រើសរើសរវាងព្រះអង្គ និងព្រះអង្គម្ចាស់ទាំងពីរ។ ដោយជ្រើសរើសយកសម្តេចព្រះ សីហនុ ប្រទេសចិនបានបញ្ជូនព្រះអង្គម្ចាស់ទាំងពីរឲ្យស្នាក់នៅកន្លែងផ្សេង និងក្រោយមក ព្រះអង្គម្ចាស់ទាំងពីរបានយាងទៅរស់នៅប្រទេសបារាំង។ ក្នុងការរស់នៅប្រទេសបារាំង ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស នៅតែបន្តបកអាក្រាត និងរិះគន់ព្រះបិតាឯងយ៉ាងខ្លាំងក្លាដដែល ហើយនៅទីនោះ ព្រះអង្គបានរៀបការជាមួយស្ត្រីម្នាក់ ដោយទទួលបានចំណងដៃនូវព្រះបុត្រីពីរព្រះអង្គ។ បន្ទាប់ពីព្រះបិតាទ្រង់បានគ្រងរាជសម្បត្តិឡើងវិញជាលើកទី២



www.elibraryofcambodia.org

ព្រះអង្គម្ចាស់ នរិន្ទ្រតារាពង្ស ក៏បានយាងមកកាន់រាជវាំងនារាជធានីភ្នំពេញម្តងម្កាលដែរ ហើយព្រះអង្គបានទាក់ទងជាមួយស្ត្រីបម្រើការនៅក្នុងវាំងម្នាក់ ដោយទទួលបានបុត្រាមួយអង្គគឺព្រះអង្គម្ចាស់ នរោត្តម ដារ៉ាទីណូ។ ព្រះអង្គបានសោយទិវង្គតនៅប្រទេសបារាំងក្នុងចន្លោះឆ្នាំ ២០០៣ ដោយជំងឺគាំងបេះដូង ហើយព្រះសពត្រូវបានព្រះរៀម សីហមុនី យាងទៅជង្ហែយកមកកាន់រាជធានីភ្នំពេញ និងបានថ្វាយព្រះភ្លើងដោយព្រះបិតារបស់ទ្រង់។

**១៩៧៩-១៩៨០៖** ព្រះអង្គបានធ្វើជាព្រះលេខាផ្ទាល់របស់ព្រះបិតា នរោត្តម សីហនុ ដែលពេលនោះព្រះអង្គគង់ប្រថាប់នៅប្រទេសចិន។

**១៩៨១៖** ព្រះអង្គបានផ្លាស់ទៅទីក្រុងប៉ារីស ប្រទេសបារាំង។ នៅចន្លោះឆ្នាំ ១៩៨១ - ២០០០ ព្រះអង្គជាសាស្ត្រាចារ្យផ្នែករបាំបុរាណនិងផ្នែកគរុកោសល្យសិល្បៈនៅវិទ្យាស្ថានអភិរក្ស Marius Petipa, Gabriel Faure និង W.A.Mozard ក្នុងទីក្រុងបារីស។

**១៩៨៤-៨៨៖** ព្រះអង្គបានធ្វើជាប្រធានសមាគមរបាំខ្មែរនៅប្រទេសបារាំង និងជាអគ្គនាយក និងជានាយកសិល្បៈនៃក្រុមរបាំបាលេ Deva។ ព្រះអង្គបានគង់នៅក្នុងប្រទេសបារាំងជិត២០ឆ្នាំ ហើយជារឿយៗព្រះអង្គបានយាងបំពេញទស្សនកិច្ចនៅទីក្រុងប្រាគ ជាទីកន្លែងដែលព្រះអង្គធ្លាប់បានចំណាយពេលតាំងពីកុមារភាពនិងយុវវ័យ។

**១៩៨៨ - ១៩៩៣៖** ព្រះអង្គជាអគ្គនាយក និងជានាយកសិល្បៈនៃសារជីវកម្មខេមរភូមិន្ទភាពយន្ត "ខេមរភាពយន្ត"។ ទ្រង់បានបង្កើតស្នា



www.elibraryofcambodia.org

ព្រះហស្តនូវភាពយន្តរបាំបាលេចំនួនពីររឿងគឺរឿង "សុបិន" និងរឿង "ធាតុទាំង៤"។

**១៩៩២ - ៩៣៖** ព្រះអង្គត្រូវបានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ជ្រើសតាំងឲ្យធ្វើជាតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំអង្គការសហប្រជាជាតិ។

**១៩៩៣៖** ព្រះអង្គត្រូវបានតែងតាំងជាប្រតិភូរបស់ប្រទេសកម្ពុជាប្រចាំអង្គការយូណេស្កូ ដែលជាស្ថាប័នលើកស្ទួយវប្បធម៌ របស់អង្គការសហប្រជាជាតិដែលមានមូលដ្ឋាននៅក្នុងទីក្រុងប៉ារីស។ នៅទីនោះ ព្រះអង្គបានដឹងកិច្ចការជាច្រើនទាក់ទិននឹងវប្បធម៌ជាតិ ហើយទ្រង់បានយកព្រះទ័យលើកស្ទួយវិស័យនេះនៅលើឆាកអន្តរជាតិ។ កាលពីមុននេះ ព្រះអង្គធ្លាប់បានបដិសេធការតែងតាំងព្រះអង្គជាឯកអគ្គរាជទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេសបារាំង។ ព្រះអង្គត្រូវបានគេស្គាល់ថា ជាបុគ្គលឆ្នើមសម្រាប់ការងាររបស់ទ្រង់កាលពីទ្រង់ធ្វើជាឯកអគ្គរដ្ឋទូតវប្បធម៌នៅក្នុងទ្វីបអឺរ៉ុប ហើយមុខតំណែងនេះត្រូវបានបន្តរហូតដល់ឆ្នាំ២០០៤។

**១ កុម្ភៈ ១៩៩៤៖** ព្រះអង្គបានទទួលព្រះគោរមងារជា "ស្តេចក្រុមឃុន" ពីព្រះបិតាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ដែលជាព្រះមហាក្សត្រនាពេលនោះ។

**១៧ តុលា ២០០៣៖** ព្រះបិតាព្រះមហាក្សត្រ នរោត្តម សីហនុ បានតែងតាំងព្រះអង្គជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ។

**៣១ សីហា ២០០៤ ៖** ព្រះបិតាព្រះមហាក្សត្រ នរោត្តម សីហនុ បានប្រទានព្រះគោរមងារដល់ព្រះអង្គជា "សម្តេចព្រះបរមនាថ"។ នៅឆ្នាំ



www.elibraryofcambodia.org

២០០៤នេះដែរ ព្រះអង្គបានធ្វើជាសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់នៃបណ្តាប្រទេសនិយាយភាសាបារាំង។

**១៤ តុលា ២០០៤ ៖** នៅថ្ងៃនោះ បន្ទាប់ពីព្រះបាទសម្តេច ព្រះនរោត្តម សីហនុ បានប្រកាសដាក់រាជ្យជាផ្លូវការកាលពីថ្ងៃទី៧តុលាមុននេះ សមាជិកប្រាំបួនអង្គ/រូបនៃក្រុមប្រឹក្សារាជបល្ល័ង្ក ឬរាជសម្បត្តិបានសម្រេចជ្រើសរើសសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដែលកាលពីពេលនោះមានព្រះជន្ម៥១ព្រះវស្សា ឲ្យឡើងគ្រងរាជ្យជំនួសព្រះបិតា។ ពិធីឡើងគ្រងរាជ្យនេះបានធ្វើឡើងនៅថ្ងៃសុក្រ ទី២៩ តុលា ឆ្នាំដដែល ហើយចាប់ពីពេលនោះមក ព្រះអង្គក៏បានក្លាយជាព្រះមហាក្សត្រ ដែលមានបរមងារថា "សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា"។ ព្រះបរមនាមក្នុងរាជ្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី គឺ៖

*"ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរផ្ទៃរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាសកម្ពុជឯករាជវិឌ្ឍបូរណសន្តិសុភមង្គលា សិរីវិបុលា ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី"* ប្រែសេចក្តីថា៖ *"ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី អ្នកបម្រើមាតុភូមិ សាសនា ប្រជាជាតិ និងប្រជារាស្ត្រខ្មែរ ដោយស្វាមីភក្តិ និងភក្តីភាព។ មហាក្សត្រិយ៍ដែលព្រះពុទ្ធ និងព្រះឥន្ទ្រលោកឧបត្ថម្ភ។ អ្នកប្រមូលខេមរជនទាំងអស់។ អ្នកការពារឯករាជ្យ បូរណភាពទឹកដី និងសន្តិភាពរបស់កម្ពុជា ព្រមទាំងសុភមង្គល សេរីភាព និងវិបុលភាពរបស់ប្រជារាស្ត្រខ្មែរ។"*



www.elibraryofcambodia.org





រូបឆ្វេង៖ សម្តេចព្រះសង្ឃរាជទាំងពីគណៈស្រោចទឹកប្រោះព្រំដល់ព្រះមហាក្សត្រថ្មី នរោត្តម សីហមុនី នៅថ្ងៃសុក្រទី២៩ តុលា ២០០៤ ជាថ្ងៃដែលព្រះអង្គឡើងគ្រងរាជសម្បត្តិជាផ្លូវការ។ រូបស្តាំ៖ ព្រះបិតា នរោត្តម សីហនុ និងព្រះមាតា មុនិនាថ ទ្រង់បានស្រោចទឹកប្រោះព្រំដល់ព្រះរាជបុត្រា នរោត្តម សីហមុនី នៅថ្ងៃដែលព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាផ្លូវការ។ រូបថតទាំងពីរសន្លឹកនេះបានតាំងនៅក្នុងអគារពិព័រណ៍ព្រះសីហមុនី ស្ថិតនៅក្នុងព្រះបរមរាជវាំង ដែលខ្ញុំ (ឆាយ សុផល) បានថតចម្លងនៅថ្ងៃទី៥ ធ្នូ ២០១៤។



www.elibraryofcambodia.org





ទិដ្ឋភាពនាថ្ងៃរាជពិធីឡើងគ្រងរាជសម្បត្តិជាផ្លូវការរបស់ព្រះមហាក្សត្រថ្មី នរោត្តម សីហមុនី នាថ្ងៃសុក្រទី២៩ តុលា ២០០៤ (រូបថតតាំងនៅក្នុងអគារ ពិព័រណ៍ព្រះសីហមុនី ស្ថិតនៅក្នុងព្រះបរមរាជវាំង ដែលខ្ញុំ (ឆាយ សុផល) បានថតចម្លងនៅថ្ងៃទី៥ ធ្នូ ២០១៤។



www.elibraryofcambodia.org





ទិដ្ឋភាពនារាត្រីនៃថ្ងៃរាជពិធីឡើងគ្រងរាជសម្បត្តិជាផ្លូវការរបស់ព្រះមហាក្សត្រថ្មី នរោត្តម សីហមុនី នាថ្ងៃសុក្រទី២៩ តុលា ២០០៤។ រូបថតតាំងនៅក្នុងអគារពិព័រណ៍ព្រះសីហមុនី ស្ថិតនៅក្នុងព្រះបរមរាជវាំង ដែលខ្ញុំ (ទាយ សុផល) បានថតចម្លងនៅថ្ងៃទី៥ ធ្នូ ២០១៤។



www.elibraryofcambodia.org

ទិដ្ឋភាពនាថ្ងៃរាជពិធីឡើងគ្រងរាជសម្បត្តិជាផ្លូវការរបស់ព្រះមហាក្សត្រថ្មី នរោត្តម សីហមុនី នាថ្ងៃសុក្រទី២៩ តុលា ២០០៤។ រូបថតតាំងនៅក្នុងអគារពិព័រណ៍ព្រះសីហមុនី ស្ថិតនៅក្នុងព្រះបរមរាជវាំង ដែលខ្ញុំ (ឆាយ សុផល) បានថតចម្លងនៅថ្ងៃទី៥ ធ្នូ ២០១៤។





ទិដ្ឋភាពនាពេលរាត្រីនៃថ្ងៃរាជពិធីឡើងគ្រងរាជសម្បត្តិជាផ្លូវការរបស់ព្រះមហាក្សត្រថ្មី នរោត្តម សីហមុនី នាថ្ងៃសុក្រទី២៩ តុលា ២០០៤។ រូបថតតាំងនៅក្នុងអគារ ពិព័រណ៍ព្រះសីហមុនី ស្ថិតនៅក្នុងព្រះបរមរាជវាំងដែលខ្ញុំ (ឆាយ សុផល) បានថតចម្លងនៅថ្ងៃទី៥ ធ្នូ ២០១៤។ ផ្ទាំងក្រោយពីឆ្វេង៖ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ សម្តេច ជា ស៊ីម ឯកឧត្តម ប៊ិន ឈិន សម្តេច ហ៊ុន សែន សម្តេច នរោត្តម យុវនាថ និងព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស។



www.elibraryofcambodia.org

ព្រះរាជពិធីជាផ្លូវការនេះត្រូវបានព្រះអង្គ ព្រមទាំងព្រះបិតានិងមាតាបានស្នើថា មិនត្រូវធ្វើឲ្យធំដុំនោះទេ ព្រោះថា ប្រទេសគឺកំពុងក្រីក្រ។ ម្យ៉ាងទៀត មកុដ (ម្កុដ) មាសពេជ្រសុទ្ធដែលជានិមិត្តសញ្ញាដ៏ពិសិដ្ឋនៃភ្នំមេរុ និងព្រះខ័ណរាជ (ដាវពិសិដ្ឋរបស់ព្រះរាជា) ដែលត្រូវបានប្រើក្នុងរាជពិធីឡើងសោយរាជសម្បត្តិជាផ្លូវការរបស់ប្រទេសនាសម័យចក្រភពអង្គរ បានបាត់ រួមជាមួយវត្ថុមានតម្លៃដ៏ទៃទៀតជាច្រើន ក្នុងអំឡុងពេលនៃរបប លន់ នល់ នាឆ្នាំ ១៩៧០។ ព្រះរាជពិធីឡើងគ្រងរាជ្យពាក់មកុដនេះក៏មិនត្រូវបានរៀបចំដែរ កាលដែលសម្តេច នរោត្តម សីហនុ បានឡើងសោយរាជ្យជាលើកទី២នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

គួររម្លឹកថា នៅឆ្នាំ១៧៨៣ លោកចៅហ្វា តុឡ្ហៈ បែន (Chaovéa Tolha Bèn) បានសម្រេចថ្វាយព្រះខ័នរាជ្យមហាក្សត្រខ្មែរជូនស្តេចសៀម តែពេលព្រះបាទ អង្គអេង ទ្រង់ឡើងសោយរាជ្យនាឆ្នាំ១៧៩៤ ស្តេចសៀមក៏ប្រគល់ព្រះខ័នរាជ្យមហាក្សត្រខ្មែរមកឲ្យព្រះបាទ អង្គអេង វិញ[232]។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ព្រះខ័នរាជ្យមហាក្សត្រខ្មែរក៏បានបាត់ដោយអាថ៌កំបាំងរហូតមកដល់សព្វថ្ងៃ។

---

[232] *ឯកសារ Preah Khan Reach and The Genealogy of Khmer Kings ( ទំព័រ១០ )*



www.elibraryofcambodia.org



រាជបញ្ញាកណ្ឌ (ទ្រព្យទាំង៥របស់ព្រះរាជា៖ ១. ព្រះមហាស្វេតច្ឆត្រ ២. ព្រះមហាមកុដរាជ្យ ៣. ព្រះខ័នរាជ្យ ៤. ព្រះវាលវីជនី ៥. ព្រះសុព៌ណ៌បាទុកា (ទ្រនាប់ជើង)) ធ្វើពីមាសពេជ្រសុទ្ធដែលជានិមិត្តសញ្ញាដ៏ពិសិដ្ឋ ត្រូវបានប្រើនៅក្នុងរាជពិធីគ្រងរាជសម្បត្តិជាផ្លូវការរបស់ប្រទេសក្នុងសម័យបុរាណចក្រភពអង្គរត្រូវបានបាត់រួមជាមួយវត្ថុដ៏ទៃទៀតជាច្រើនក្នុងអំឡុងពេលនៃរបប លន់ នល់ នា ឆ្នាំ ១៩៧០ ( រូបនៅឆ្នាំ ១៩២០ ក្នុងឯកសារ *Preah Khan Reach and The Genealogy of Khmer Kings* )។



ព្រះខ័នរាជ្យនិងលំពែងជ័យរបស់ព្រះមហាក្សត្រខ្មែរពីសម័យបុរាណនៃចក្រភពអង្គរត្រូវបានបាត់រួមជាមួយវត្ថុដ៏ទៃទៀតជាច្រើនក្នុងអំឡុងពេលនៃរបប លន់ នល់ នាឆ្នាំ ១៩៧០ (រូបនេះនៅឆ្នាំ១៩២០ ក្នុងឯកសារ *Le Palais Du Roi Du Cambodge* )។ បច្ចុប្បន្ន កម្ពុជាបានធ្វើព្រះខ័នរាជ្យនិងលំពែងជ័យថ្មីវិញហើយ។

www.elibraryofcambodia.org



រូបថតព្រះខ័នរាជ្យ (ដាវ) ព្រះមកុដរាជ្យ និងព្រះសុពណ៌បាទុកា (ទ្រនាប់ជើង) ត្រូវបានដាក់តាំងនៅជាន់ខាងក្រោមក្នុងប្រាសាទហោព្រះខ័ននាព្រះបរមរាជវាំង ដោយក្នុងរូបនោះមានសរសេរទាំងភាសាជាតិនិងភាសាអង់គ្លេសថា "ព្រះខ័នរាជ្យ ព្រះមកុដរាជ្យ ព្រះសុពណ៌បាទ (តម្កល់ដាក់តាំងនៅបន្ទប់ខាងលើ)"។ តាមរយៈមគ្គុទេសក៍ទេសចរខ្មែរបានប្រាប់ភ្ញៀវបរទេសថា ព្រះខ័នរាជ្យនេះធ្វើពីមាសសុទ្ធទម្ងន់២គីឡូក្រាម ហើយព្រះមកុដរាជ្យមានដាំពេជ្រចំនួនពីពាន់គ្រាប់។ ទោះបីយ៉ាងនេះក្ដី ទាំងព្រះខ័នរាជ្យ និងព្រះមកុដរាជ្យត្រូវបានសម្ដេចព្រះ នរោត្ដម សីហនុ អះអាងថា បានបាត់ទៅហើយ។ រូបក្រោមគឺប្រាសាទហោព្រះខ័ន។ រូបថតទាំងពីរសន្លឹកនេះ ខ្ញុំ ឆាយ សុផល បានថតនៅក្នុងព្រះបរមរាជវាំងនាថ្ងៃទី ៥ ធ្នូ ២០១៤។



www.elibraryofcambodia.org

សម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានឡើងគ្រងរាជ្យស្ថិតនៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់ប្រទេសជាតិនាឆ្នាំ១៩៩៣។ ព្រះអង្គត្រូវបានតែងតាំងដោយក្រុមប្រឹក្សារាជបល្ល័ង្កដែលមានសមាជិកចំនួន៩អង្គ/នាក់ក្នុងនោះរួមមាន៖ ប្រធានគណសង្ឃទាំងពីរអង្គ ប្រធាន អនុប្រធានទី១និងអនុប្រធានទី២ព្រឹទ្ធសភា ប្រធាន អនុប្រធានទី១និងអនុប្រធានទី២រដ្ឋសភា ហើយនិងនាយករដ្ឋមន្ត្រី។ ទោះបីជាយ៉ាងនេះក្តី ក៏សមាជិកក្រុមប្រឹក្សារាជបល្ល័ង្កដែលមានឥទ្ធពលជាងគេនៅឆ្នាំនោះគឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសម្តេចធ្លាប់បានលើកឡើងថា បើទោះជាលោកមិនមែនជា "ស្តេច" ក៏ដោយ ក៏លោកជាអ្នកជ្រើសរើស "ស្តេច" ឲ្យឡើងគ្រងរាជ្យដែរ។

**២០០៥៖** នៅក្នុងព្រះរាជតំណែងជាព្រះមហាក្សត្រខ្មែរ ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហមុនី ត្រូវបានគេមើលឃើញថា ព្រះអង្គបានទទួលព្រះរាជឱវាទពីព្រះបិតា នរោត្តម សីហនុ និងព្រះមាតា មុនិនាថ ដ៏ផ្ទើម។ ក្រោយពេលដែលព្រះបិតាសោយព្រះទិវង្គតនៅថ្ងៃទី១៥ តុលា ឆ្នាំ ២០១២ ព្រះមាតានៅតែបន្តជួយនិងហែហមព្រះអង្គដដែល។ នៅឆ្នាំ ២០០៥ បន្ទាប់ពីឯកឧត្តម ស៊ុន ឆ័យ តំណាងរាស្ត្រគណបក្សប្រឆាំងបានផ្ញើលិខិតមួយច្បាប់ថ្វាយជូនព្រះមហាក្សត្រ សីហមុនី ដោយស្នើឲ្យព្រះអង្គដើរតួនាទីកាន់តែសកម្មក្នុងរឿងនយោបាយរបស់ប្រទេស ដោយត្រូវផ្តល់ព្រះរាជឱវាទដល់មន្ត្រីដឹកនាំប្រទេស ពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីរឿងការដែលត្រូវធ្វើឲ្យស្ថានភាពនយោបាយកាន់តែល្អប្រសើរនោះ ស្រាប់តែព្រះបិតារបស់ព្រះអង្គគឺសម្តេចព្រះនរោត្តម សីហនុ បែរជាឆ្លើយតបជំនួសព្រះអង្គទៅវិញ។ ចម្លើយនោះ



www.elibraryofcambodia.org

បានបង្ហោះនៅក្នុងគេហទំព័ររបស់សម្តេចឪដែលមានខ្លឹមសារថា "ខ្ញុំសូមឆ្លើយតបទៅនឹងឯកឧត្តមក្នុងនាមកូនប្រុសរបស់ខ្ញុំជាព្រះមហាក្សត្រ។ ខ្ញុំសូមឯកឧត្តមយល់ថា ព្រះមហាក្សត្របានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ព្រះអង្គ ប៉ុន្តែមិនបានទទួលជោគជ័យទេ"[233]។ អ្នកអង្កេតការណ៍បានចែករំលែកគំនិតថា អតីតព្រះមហា ក្សត្រ សីហនុ ដែលចូលនិវត្តន៍ហើយនោះ មានបន្ទូលឥតសំចៃជាងព្រះរាជបុត្រាដែលជាមហាក្សត្រ ប៉ុន្តែយុទ្ធសាស្ត្ររបស់ព្រះមហាក្សត្រ សីហមុនី ចំពោះភាពជារដ្ឋបុរសនោះ គឺមិនគួរត្រូវបានគេបកស្រាយខុសនោះទេ ហើយនៅក្នុងការបែកធ្លាយតាមទូរលេខស្តីពីកិច្ចពិភាក្សាការទូតពីស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំរាជធានីភ្នំពេញ ដោយមន្ត្រីស្ថានទូតបានកត់សម្គាល់ថា "ចាប់ពីពេលនេះតទៅ សីហនុ ទំនងជានឹងធ្វើការងារនៅពីក្រោយឆាក ដើម្បីបង្រៀន សីហមុនី ឲ្យចេះលូកដៃនៅក្នុងរឿងនយោបាយ"[234]។

ព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ពុំសូវមានព្រះរាជបន្ទូលច្រើនទេ ហើយភាគច្រើននៅក្នុងពិធីជាតិធំៗគឺព្រះអង្គតែងតែអានច្រើនជាងមានបន្ទូលផ្ទាល់។ ពេលមានបន្ទូលជាមួយប្រជាពលរដ្ឋ ព្រះអង្គតែងតែញញឹមហើយលើកហត្ថាសំពះជានិច្ច។

តាមធម្មតា ព្រះអង្គគង់នៅរាជវាំងក្នុងរាជធានីភ្នំពេញ ហើយទទួលការចូលបង្គំគាល់ពីមន្ត្រីជាតិនិងអន្តរជាតិ ពិសេសការថ្វាយសារតាំងពីឯកអគ្គរាជទូត និងរដ្ឋទូតនៃបណ្តាប្រទេសជាមិត្តនៅក្នុងពិភព

---

[233] *កាសែត The Cambodia Daily ភាសាអង់គ្លេសលេខពិសេស ( ១៤ ឧសភា ២០១២ ) ទំព័រ៩*

[234] *កាសែត The Cambodia Daily ភាសាអង់គ្លេសលេខពិសេស ( ១៤ ឧសភា ២០១២ ) ទំព័រ៩*



www.elibraryofcambodia.org

លោក។ ព្រះអង្គក៏តែងតែយាងរាជដំណើរចេញទៅតំបន់ជនបទទូទាំងប្រទេសជាញឹកញាប់ ដើម្បីបានជួបជាមួយប្រជារាស្ត្រ និងជូនព្រះរាជអំណោយសប្បុរសធម៌របស់ព្រះអង្គដល់ប្រជារាស្ត្រក្រីក្រ។



www.elibraryofcambodia.org



ព្រះមហាក្សត្រ នរោត្តម សីហមុនី យាងដំណើរចេញទៅតំបន់ជនបទ ដើម្បីជួបជាមួយប្រជារាស្ត្ររបស់ព្រះអង្គនិងជូនព្រះរាជអំណោយសប្បុរសធម៌ដល់ប្រជារាស្ត្រក្រីក្រ
(រូបក្នុងគេហទំព័រ http://www.norodomsihamoni.org/)។







www.elibraryofcambodia.org

**១២ មីនា ២០១០៖** នៅថ្ងៃនោះ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាអក្សរចារឹក និងអក្សរសាស្ត្របារាំង។ ពិធីនេះបានរៀបចំដ៏ឧឡារិកនៅក្នុងបណ្ឌិតសភាអក្សរចារឹក និងអក្សរសាស្ត្រ Academie des Inscrip-tions et Belles Lettres នៅទីក្រុងប៉ារីស។



*ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅក្នុងពិធីនាថ្ងៃទី ១២ មីនា ២០១០ (រូបក្នុងគេហទំព័រ http://www.norodomsihamoni.org/)។*

**១៦ តុលា ២០១២៖** ព្រះមហាក្សត្រ នរោត្តម សហមុនី ស្តេចយាងចេញទៅទីក្រុងបេកាំង ប្រទេសចិន បន្ទាប់ពីព្រះបិតាសម្តេចព្រះនរោត្តម សីហនុ បានសោយព្រះទិវង្គតនៅទីនោះ។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីក៏បានអញ្ជើញទៅទីនោះដែរ ហើយនៅថ្ងៃទី១៧ តុលា ព្រះមហាក្សត្រ នរោត្តម សីហមុនី បានយាងព្រះបរមសពព្រះបិតាមករាជធានីភ្នំពេញវិញ ដើម្បីបានធ្វើព្រះរាជពិធីបុណ្យតាមប្រពៃណីនិងទំនៀមទម្លាប់នៃរាជវង្សខ្មែរ។



www.elibraryofcambodia.org



ព្រះមហាក្សត្រព្រះបរមនាថ នរោត្តម សីហមុនី និងព្រះរាជមាតាទ្រង់ព្រះកន្សែងសោកសង្រេងនៅមុខរាជវាំងក្នុងចំណោមប្រជារាស្ត្រចំពោះការបាត់បង់ព្រះបិតានិងព្រះអគ្គស្វាមី។ រូប AKP



ព្រះមហាក្សត្រព្រះបរមនាថ នរោត្តម សីហមុនី កាន់ព្រះកោដ្ឋដាក់ព្រះអដ្ឋិព្រះរាជបិតា បន្ទាប់ពីរាជពិធីបូជាសព។



www.elibraryofcambodia.org

១៦ មីនា ២០១៣៖ ព្រះមហាក្សត្របានចេញព្រះរាជសារមួយដ៏មានតម្លៃ ដោយទ្រង់បានអំពាវនាវពលរដ្ឋគ្រប់អាយុប្រើសិទ្ធិទៅបោះឆ្នោតនៅថ្ងៃទី២៨ កក្កដា ឆ្នាំ២០១៣ កុំឲ្យបារម្ភចំពោះការគាបសង្កត់ ការគំរាមកំហែង ឬសម្លុតពីជនណាមួយឬបក្សណាមួយឲ្យសោះ។

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ផ្ញើជូនជនរួមជាតិ បងប្អូន កូនក្មួយ ជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ដោយថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាន់តែខិតជិតមកដល់ហើយ ខ្ញុំសូមធ្វើសេចក្តីអំពាវនាវជាឱឡារិក ជូនជនរួមជាតិ បងប្អូន កូនក្មួយ សូមកុំឱ្យមានការព្រួយបារម្ភ ចំពោះការគាបសង្កត់ ការគំរាម កំហែង ឬសម្លុត ពីជនណាមួយ បក្សណាមួយឱ្យសោះ។

ការបោះឆ្នោត នៅថ្ងៃអាទិត្យ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ គឺជាការបោះឆ្នោតសម្ងាត់ ហើយដែលនឹងប្រព្រឹត្ត ធ្វើទៅតាមលទ្ធិប្រជាធិបតេយ្យសេរី។

ហេតុដូច្នេះ ខ្ញុំសូមបងប្អូន កូនក្មួយ មេត្តាប្រើសិទ្ធិរបស់ខ្លួន គឺការបោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗ ដែលមានទំនុកចិត្ត ទៅលើបេក្ខជនណាមួយ បក្សណាមួយបានដោយសេរី។

សូមបងប្អូន កូនក្មួយ ជនរួមជាតិទាំងអស់ ប្រកបនូវព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមេត្តាទទួលនូវសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំ។

នរោត្តម សីហមុនី

ធ្វើនៅ.ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣



www.elibraryofcambodia.org

នៅក្នុងរឿងជម្លោះនៃនយោបាយចុងក្រោយនាពាក់កណ្តាលឆ្នាំ ២០១៣-ពាក់កណ្តាលឆ្នាំ២០១៤ ព្រះមហាក្សត្រ សីហមុនី ក៏បាន បំពេញព្រះរាជតួនាទីដ៏សំខាន់នៅក្នុងការសម្របសម្រួលឲ្យគណបក្ស ប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានស្រុះស្រួលគ្នា បន្ទាប់ពី ជាប់គាំងនយោបាយអស់ពេលជិតមួយឆ្នាំ ដែលការជាប់គាំងនោះបាន បណ្តាលឲ្យមានមនុស្សជាច្រើននាក់បានស្លាប់និងរបួស។

នៅថ្ងៃទី១៥ កញ្ញា ឆ្នាំ២០១៣ មានការប៉ះទង្គិចគ្នាមួយរវាង សមត្ថកិច្ចរបស់រាជរដ្ឋាភិបាលសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និង ក្រុមបាតុករដែលគេជឿថា ជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិរបស់ឯក ឧត្តម សម រង្ស៊ី និង កឹម សុខា បានបណ្តាលឲ្យយុវជនម្នាក់ស្លាប់ដោយ សារគ្រាប់កាំភ្លើង និងជិត២០នាក់ទៀតទាំងកម្លាំងសមត្ថកិច្ចនិងបាតុករ បានរងរបួសធ្ងន់និងស្រាល។ នៅព្រឹកបន្ទាប់ ព្រះមហាក្សត្រ នរោត្តម សីហមុនី បានអំពាវនាវឲ្យបញ្ឈប់ការបង្ករឈាមគ្នា ហើយភាគីទាំងអស់ ត្រូវស្វែងរកដំណោះស្រាយដោយសន្តិវិធីដើម្បីជាតិនិងមាតុភូមិ។ ព្រះ អង្គ និងព្រះមាតានាពេលនោះក៏បានប្រកាសផ្តល់ព្រះរាជអំណោយជា ប្រាក់ដល់អ្នករងរបួសទាំងនោះដែលម្នាក់ៗទទួលបាន១.០០០ដុល្លារ (ព្រះមហាក្សត្រប្រទាន៥០០ដុល្លារ ព្រះមាតា៥០០ដុល្លារ)។



www.elibraryofcambodia.org



ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី នាល្ងាចថ្ងៃទី២៤ ខែកក្កដា ២០១៤ បានអនុញ្ញាតឲ្យថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជាជនកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អនុប្រធានបក្ស និងគណបក្សសង្គ្រោះជាតិ ដឹកនាំដោយឯកឧត្តម សម រង្ស៊ី ប្រធានបក្ស ចូលក្រាបបង្គំគាល់ ដើម្បីទូលថ្វាយអំពីលទ្ធផលនៃកិច្ចព្រមព្រៀងរវាងគណបក្សទាំងពីរ និងដើម្បីរៀបចំថ្ងៃកំណត់ចូលធ្វើសច្ចាប្រណិធានរបស់សមាជិកសមាជិកាជាប់ឆ្នោតតំណាងរាស្ត្រ។ រូប TVK តាមរយៈ AKP









www.elibraryofcambodia.org

ដោយមិនខុសពីព្រះបិតាព្រះអង្គនោះ គឺព្រះអង្គបានយាងទៅទីក្រុងប៉េកាំង ប្រទេសចិន ដើម្បីពិនិត្យនិងព្យាបាលព្រះរោគជាទៀងទាត់ពីគ្រូពេទ្យជំនាញរបស់មហាមិត្តចិនបន្តពីព្រះបិតារបស់ព្រះអង្គរៀងមក។



*ព្រះមហាក្សត្រព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និងសម្តេចម៉ែយាងទៅទីក្រុងប៉េកាំង ប្រទេសចិននាថ្ងៃទី២៥ សីហា ២០១៤ ដើម្បីពិនិត្យនិងព្យាបាលព្រះរោគ (រូប ខឹម សុវណ្ណារ៉ា) រូបក្រោម៖ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី (គង់ជួរមុខទី៥ពីខាងស្តាំ) ជាមួយព្រះមហាក្សត្រ និងប្រមុខផ្សេ នាល្ងាចថ្ងៃទី១២ មិថុនា ឆ្នាំ ២០០៦ ក្នុងឱកាសបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រថៃ ភូមិបុល អាឌុលយ៉ាដេត នៅក្នុងព្រះបរមរាជវាំងថៃនាកជធានីបាងកក។ រូបនេះ ខ្ញុំ ឆាយ សុផល ថត ចម្លងចេញពីរូបថតដែលដាក់តាំងនៅឯអាកាសយានដ្ឋានអន្តរជាតិបាងកក៖ ៥ ធ្នូ ២០១៤*



www.elibraryofcambodia.org



រូបលើ៖ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី (ស្តាំ) យាងជួបព្រះមហាក្សត្រថៃ ភូមិបុល អាឌុលយ៉ាដេត (Bhumibol Adulyadej) និងមហាក្សត្រិយានី ស៊ីរីគីត (Sirikit) នាល្ងាចថ្ងៃទី១២ មិថុនា ឆ្នាំ ២០០៦ ក្នុងឱកាសបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រថៃ ភូមិបុល អាឌុលយ៉ាដេត នៅព្រះបរមរាជវាំងថៃក្នុងរាជធានីបាងកក។ រូប AOP: http://royalista.com/6623/congratulations-to-cambodias-ballet-dancing-king/

រូបក្រោម៖ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី (ឆ្វេង) យាងបំពេញព្រះរាជទស្សនកិច្ចនៅទីក្រុងប្រាគ ប្រទេសឆេក នាថ្ងៃ ១៩ មីនា ២០១០ ( រូបAFP ក្នុង ៖ http://www.globalpost.com/photo/5639653/cambodia-king-sihamoni-2011-04-22



www.elibraryofcambodia.org

១៨ តុលា ២០១៤៖ ព្រះមហាក្សត្រព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និងសម្តេចព្រះវររាជមាតាជាតិខ្មែរ មុនិនាថ សីហនុ នៅថ្ងៃនោះបានសព្វព្រះរាជហឫទ័យផ្តល់កិត្តិយសឲ្យកញ្ញា សិន សៀវម៉ី កីឡាការិនីអាយុ១៩ឆ្នាំនិងម្តាយបានចូលក្រាបថ្វាយបង្គំគាល់នៅក្នុងព្រះបរមរាជវាំង។ សៀវម៉ី ជាកីឡាការិនីតេក្វាន់ដូលើកដំបូងដែលបានទទួលមេដាយមាសនៅក្នុងកីឡាអាស៊ីហ្គេមបន្ទាប់ពី៤០ឆ្នាំកន្លងមក ដែលនាងបាននាំកិត្តិយសដ៏ធំធេងមកឲ្យប្រទេស។ ក្នុងការចូលក្រាបថ្វាយបង្គំគាល់នោះ ព្រះមហាក្សត្របានប្រទានប្រាក់ចំនួន៣.០០០ដុល្លារអាម៉េរិក និងសៀវភៅឯកសារកីឡារបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ហើយសម្តេចព្រះវររាជមាតាជាតិខ្មែរក៏បានប្រទានចំនួន២.០០០ដុល្លារដែរ ដោយសម្តេចម៉ែ មុនិនាថ មានព្រះសវនីយ៍ថា នៅក្នុងរជ្ជកាលរបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះអង្គសព្វព្រះទ័យយកចិត្តទុកដាក់នឹងកីឡាណាស់ ហើយបច្ចុប្បន្ន សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីក៏បានយកចិត្តទុកដាក់បន្តរៀងមក។ សិន សៀវម៉ី បានវាយឈ្នះកីឡាការិនី Fatemeh Rouhini ជនជាតិអ៊ីរ៉ង់ ក្រោយពីផ្តួលកីឡាការិនី Selviana Angelia Jehabut ជនជាតិឥណ្ឌូណេស៊ី ដណ្តើមបានមេដាយមាសជាលើកដំបូងនៅក្នុងការប្រកួតកីឡាអាស៊ីហ្គេមលើកទី១៧ (៣០ កញ្ញា - ៣ តុលា ២០១៤) នៅទីក្រុងអ៊ីនឈាន់ (Incheon) ប្រទេសកូរ៉េខាងត្បូង ដែលកីឡាករកីឡាការិនីកម្ពុជាមិនដែលបានទទួលចាប់ពីរយៈពេល៤០កន្លងមក។ ពេលត្រឡប់មកប្រទេសវិញនាយប់ថ្ងៃទី៥តុលា សម្តេចតេជោ ហ៊ុន សែន បានចាំទទួលស្វាគមន៍នាងនៅឯវិមានសន្តិភាព ហើយហៅនាងថា ជាវីរនារីកម្ពុជា។ ក្នុងជំនួបនោះ សម្តេចតេជោ ហ៊ុន សែន បានផ្តល់រង្វាន់លើកទឹកចិត្តនាងប្រមាណ៤ម៉ឺនដុល្លារអាម៉េរិក។ នៅថ្ងៃប្រឡងបាក់ឌុបនាឆ្នាំសិក្សា២០១៣-



www.elibraryofcambodia.org

២០១៤ កាលពីថ្ងៃទី៤-៥ សីហា ឆ្នាំ ២០១៤ សៀវម៉ី គឺស្ថិតក្នុងចំណោមសិស្សប្រមាណ៧៥% នៃសិស្សសរុប៩៣.៤៥៦នាក់បានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ធ្លាក់ តែសម្តេចតេជោ ហ៊ុន សែន បានសម្រេចឲ្យនាងជាប់ជាស្វ័យប្រវត្តដោយមិនចាំបាច់ប្រឡងជាលើកទី២ ហើយឲ្យអាហារូបករណ៍ដល់នាងបានចូលរៀនមហាវិទ្យាល័យ។



*ព្រះករុណាព្រះបរមនាថ នរោត្តម សីហមុនី (កណ្តាល) ប្រទានវត្ថុអនុស្សាវរីយ៍ជូនកីឡាការិនី សិន សៀវម៉ី នាថ្ងៃទី ១៨ តុលា ២០១៤។ រូបក្រោយ៖ សម្តេចម៉ែ ( រូប AKP)។*





*រូបឆ្វេង៖ សម្តេចម៉ែប្រទានប្រាក់ជូន សៀវម៉ី នៅថ្ងៃទី១៨ តុលា ២០១៤។ រូបស្តាំ: សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រគល់ប្រាក់ជូន សៀវម៉ី នៅថ្ងៃទី៨តុលា នៅវិមានសន្តិភាព (រូប AKP)។*

www.elibraryofcambodia.org

២៩ តុលា ២០១៤៖ ថ្ងៃនេះជាខួបលើកទី១០ឆ្នាំនៃថ្ងៃបានឡើងគ្រងរាជសម្បត្តិរបស់ព្រះអង្គ ហើយពិធីនេះបានធ្វើឡើងយ៉ាងអធិកអធមនៅមុខព្រះរាជវាំង ដោយមានវត្តមានប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ប្រធានគណបក្សប្រឆាំង ប៉ុន្តែមិនមានព្រះរាជវត្តមានសម្តេចម៉ែ និងប្រធានព្រឹទ្ធសភា លោក ជា ស៊ីម ទេ។ អង្គមីទ្ទិញនោះមានការចូលរួមពីមន្ត្រីជាន់ខ្ពស់គណបក្សកាន់អំណាច គណបក្សប្រឆាំង កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត និងប្រជាពលរដ្ឋរាប់ពាន់នាក់បានឈរនៅតាមផែននៅមុខព្រះបរមរាជវាំង។ នៅក្នុងពិធីនោះ ព្រះអង្គបានមានព្រះរាជបន្ទូលថា ការប្រារព្ធខួបនៅពេលនេះ ក្នុងដំណាក់កាលដែលប្រទេសជាតិកំពុងមានស្ថិរភាពនយោបាយ សុខសន្តិភាព ត្រូវបានធានាយ៉ាងពេញលេញ និងស្របពេលដែលរាជរដ្ឋាភិបាលបានបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម។ ព្រះអង្គមានព្រះរាជអំពាវនាវឲ្យពលរដ្ឋគ្រប់មជ្ឈដ្ឋានរួបរួមសាមគ្គីគ្នាជាធ្លុងមួយ រស់ក្រោមដំបូលរដ្ឋធម្មនុញ្ញ ដើម្បីចូលរួមចំណែកអភិវឌ្ឍ និងការពារប្រទេសជាតិគ្រប់វិស័យ។ ព្រះមហាក្សត្របានព្រះរាជបន្ទូលទៀតថា "ឈរលើមូលដ្ឋាននៃមហាសាមគ្គីជាតិឯកភាពជាតិ ក្រោមទង់ដ៏សុខសាន្តនៃព្រះពុទ្ធសាសនា និងក្រោមបារមីព្រះបរមក្សត្រ ដែលជាបុព្វបុរសជាតិ ជាស្ថាបនិកដ៏ល្បីល្បាញនៃការកសាងប្រាង្គប្រាសាទដ៏ល្អប្រណីត ស្ថិតនៅស្ទឹមស្ទែគ្រប់ទិសទីទូទាំងព្រះរាជាណាចក្រកម្ពុជា មាតុភូមិដែលជាកេរមរតកជាតិដ៏មានតម្លៃពុំអាចកាត់ថ្លៃបានរបស់យើងពិតជាពុំអាចមានសត្រូវណាមួយរំលោភឈ្លានពានមកលើបូរណភាពទឹកដីបានឡើយ"[235]។

[235] http://www.akp.gov.kh/kh/?p=98412



www.elibraryofcambodia.org



ព្រះសង្ឃ៥០០អង្គបានសូត្រធម៌បួងសួងថ្វាយព្រះពរនៅមុខព្រះឆាយាល័ក្ខណ៍សម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅមុនមួយថ្ងៃនៃពិធីខួបលើកទី១០ឆ្នាំក្នុងការឡើងគ្រងរាជសម្បត្តិបន្តពីព្រះបិតា (រូប ទុយ ប៊ុនរី/AKP)។



ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី (កណ្តាល) សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី (ស្តាំផុត) និងមន្ត្រីជាន់ខ្ពស់របស់រដ្ឋក្នុងពិធីរំលឹកខួបលើកទី១០ឆ្នាំនៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រនាថ្ងៃទី២៩ តុលា ២០១៤ (រូប AKP)។



www.elibraryofcambodia.org





រូបពីរលើ៖ ទិដ្ឋភាពនៅមុខព្រះបរមរាជវាំងក្នុងពិធីនាព្រឹកថ្ងៃទី២៩ តុលា ២០១៤ (រូប AKP)។




ការបណ្ដែតប្រទីបនិងការបាញ់កាំជ្រួចអបអរពិធីលើកខួបលើកទី១០ឆ្នាំនៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រនាល្ងាចថ្ងៃទី២៩ តុលា ២០១៤ (រូប ប៉េង សុភា)។

www.elibraryofcambodia.org



*ព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រ ព្រះបរមនាថ នរោត្តម សីហមុនី ត្រូវបានដាក់តាំងនៅក្រុងសៀមរាប ដើម្បីអបអរពិធីរំលឹកខួបលើកទី១០ឆ្នាំនៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះអង្គ (រូប ឆាយ សុល)។*

សូមបញ្ជាក់ថា នៅយប់នាថ្ងៃនោះ ស្រាប់តែមានរឿងអកុសលផ្ទែកកំហុសឆ្គងបច្ចេកទេសនៃការបាញ់កាំជ្រួចអបអរពិធីឡើងគ្រងរាជ្យ ១០ឆ្នាំនោះ ដែលបណ្តាលឲ្យយុវជនម្នាក់ស្លាប់ និងមនុស្ស៧នាក់ទៀតរងរបួសធ្ងន់ស្រាលនៅត្រើយម្ខាងជងទន្លេទល់មុខព្រះបរមរាជវាំង។ ជនរងគ្រោះឈ្មោះ ណាគ្រី ដារ៉ូ អាយុ២២ឆ្នាំជានិស្សិតនៃសាកលវិទ្យាល័យស៊ីតិចមានស្រុកកំណើតនៅស្រុកកោះធំ ខេត្តកណ្តាលបានដេកស្លាប់ក្នុងថ្លុកឈាមដោយរយះផ្ទឹងជំនីមួយចំហៀងខ្លួន និងធ្លាយពោះវៀន នៅចម្ងាយប្រមាណ២០០ម៉ែត្រ ពីកន្លែងបាញ់កាំជ្រួច។ លោក ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការពារជាតិបាននិយាយថា "ឧប្បត្តិហេតុ



www.elibraryofcambodia.org

នោះមិនជារឿងធំនោះទេ"[236] ដោយលោកអះអាងថា វាជារឿងដែលមិនបានរំពឹងទុកមុន ហើយក្រសួងនឹងធ្វើឲ្យការបាញ់កាំជ្រួចនេះឲ្យកាន់តែប្រសើរនៅពេលអនាគត។ លោកឧត្តមសេនីយផ្កាយមាស៤ អ៊ិត សារ៉ាត មេបញ្ជាការរងកងយោធពលខេមរភូមិន្ទ ទទួលបន្ទុកនាយកដ្ឋានហ្វឹកហ្វឺននៃក្រសួងការពារជាតិ ហើយនាយកដ្ឋាននេះទទួលរ៉ាប់រងការបាញ់កាំជ្រួចនោះបាននិយាយថា វាមិនមែនជាកំហុសរបស់បុគ្គលិកបាញ់កាំជ្រួចរបស់លោកទេ តែវាជាបញ្ហារបស់កាំជ្រួចដែលផលិតនៅប្រទេសចិន[237]។ លោកក៏បានបន្ទោសប្រជាជនដែលចង់មកឈរមើលការបាញ់កាំជ្រួចជិតពេក។ សម្តេចតេជោ ហ៊ុន សែន នៅព្រឹកបន្ទាប់ បានចាត់មន្ត្រីឲ្យយកថវិកាទៅជូនគ្រួសារសព និងជនរងគ្រោះដទៃទៀតក្នុងនោះអ្នកស្លាប់ និងអ្នករបួសធ្ងន់២នាក់ទទួលបាន២លានរៀល (ប្រមាណ ៥០០ដុល្លារ) ហើយអ្នករងរបួសស្រាល៥នាក់ទៀតទទួលបានម្នាក់ៗចំនួន១លានរៀល (ប្រមាណ២៥០ដុល្លារ)

**៥ វិច្ឆិកា ២០១៤៖** ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានយាងជាព្រះរាជអធិបតីនៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេលបីថ្ងៃ៥-៧ វិច្ឆិកា ជាលើកដំបូង បន្ទាប់ពីរាជពិធីនេះខកខានមិនបានធ្វើចាប់តាំងពីឆ្នាំ២០១១ មក។

---

[236] កាសែត The Cambodia Daily ៣ វិច្ឆិកា ២០១៤ (ទំព័រមុខ)

[237] កាសែត The Cambodia Daily ៣១ តុលា ២០១៤ (ទំព័រមុខ)



www.elibraryofcambodia.org



រូបលើ៖ ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់យាងចូលរួមទតការប្រណាំងទូកក្នុងរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែនារសៀលថ្ងៃទី ៥ វិច្ឆិកា។ រូបក្រោម៖ ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់យាងដុតបំភ្លឺភ្លើងជានិមិត្តរូបនៃការសម្ពោធបណ្តែតប្រទីបនាល្ងាចថ្ងៃទី ៥ វិច្ឆិកា (រូប AKP)។





www.elibraryofcambodia.org



ព្រះមហាក្សត្រសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី (ឆ្វេង៖ រូប AKP) និងទិដ្ឋភាពនៃព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែនារសៀលថ្ងៃទី ៥ វិច្ឆិកា ២០១៤ (រូប ខឹម សុវណ្ណាក៏)។







www.elibraryofcambodia.org

រាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែនាឆ្នាំ២០១៤នោះ បានបញ្ចប់ដោយក្ដីសប្បាយរីករាយជាពន់ពេក បើទោះជាមិនមានមនុស្សច្រើនដូចកាលពីមុនឆ្នាំ ២០១០ ក៏ដោយ។ គួររម្លឹកថា កាលពីយប់ថ្ងៃទី **២២ វិច្ឆិកា ឆ្នាំ ២០១០** ជាថ្ងៃចុងក្រោយនៃរាជពិធីនេះ មានមនុស្ស ៣៥៣ នាក់បានស្លាប់ និង ៣៩៣ នាក់រងរបួស ដោយសារការផ្អើល និងរត់ជាន់គ្នានៅលើស្ពានពេជ្ររបស់មជ្ឈមណ្ឌលកម្សាន្តកោះពេជ្រ ក្នុងរាជធានីភ្នំពេញ។ បន្ទាប់ពីសោកនាដកម្មនោះ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានប្រកាសឲ្យមានការកាន់ទុក្ខរបស់ជាតិទាំងមូល ហើយផ្ដល់ជំនួយជាទឹកប្រាក់ជូនគ្រួសារនៃសព ដែលក្នុងនោះអ្នកស្លាប់ម្នាក់ទទួលបានមួយម៉ឺនដុល្លារ ដែលប្រាក់ទាំងនេះបានមកពីថវិការបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់មជ្ឈមណ្ឌលកម្សាន្តកោះពេជ្រ ដោយរួមទាំងសប្បុរសជនផង។ នៅថ្ងៃទី**១១ សីហា ឆ្នាំ២០១១** សាលារាជធានីភ្នំពេញបានចាប់ផ្ដើមសង់ស្តូបរំឭកវិញ្ញាណក្ខន្ធអ្នកស្លាប់នៅក្បែរស្ពាននោះ។ នៅថ្ងៃទី**១៣ តុលា ឆ្នាំ២០១១** នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានប្រកាសលុបចោលការរៀបចំប្រណាំងទូកនៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេលបីថ្ងៃ ដែលគ្រោងធ្វើនៅថ្ងៃទី៩-១១ វិច្ឆិកា ដោយសារតែទឹកហូរច្រើននៅក្នុងទន្លេ ដែលអាចមានគ្រោះថ្នាក់ដល់អ្នកអុំទូក និងអ្នកទស្សនា។ម្យ៉ាងទៀត រាជរដ្ឋាភិបាលមិនចង់ចំណាយថវិកាលើការប្រណាំងទូកឡើយ ដោយទុកថវិកាសម្រាប់ជួយជនរងគ្រោះដោយទឹកជំនន់ និងស្ដារហេដ្ឋារចនាសម្ព័ន្ធបានខ្លះ។ ប៉ុន្ដែការរៀបចំការកម្សាន្តផ្សេងៗទៀតនៅលើគោកក្នុងពិធីនេះនៅតែប្រព្រឹត្តទៅជាធម្មតាក្នុងរាជធានីភ្នំពេញ។



www.elibraryofcambodia.org

ជាការពិតនៅក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ចាប់តាំងពីព្រះអង្គឡើងគ្រងរាជបល្ល័ង្កជាផ្លូវការនាថ្ងៃសុក្រទី២៩ ខែ តុលា ឆ្នាំ២០០៤ មក ប្រទេសជាតិមានការឯកភាពជាតិនិងសន្តិភាពទាំងស្រុង។ ពិតហើយ បើទោះជាមានជម្លោះផ្នែកនយោបាយខ្លះនៅក្នុងប្រទេស រវាងគណបក្សប្រជាជនកម្ពុជាដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន និងសម្តេច ជា ស៊ីម និងគណបក្សសង្គ្រោះជាតិដឹកនាំដោយឯកឧត្តម សម រង្ស៊ី និងឯកឧត្តម កឹម សុខា ក៏ដោយ ក៏ប្រទេសមិនមានជម្លោះប្រដាប់អាវុធដូចនៅមុនឆ្នាំ២០០០ឡើយ។ នៅក្នុងរជ្ជកាលនៃរាជបល្ល័ង្ករបស់ព្រះអង្គ ដែលមានរាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន ប្រទេសជាតិមានការរីកចម្រើនគួរឲ្យមោទនៈ។ អគារទំនើបខ្ពស់ៗ (Skyscrapers) និងផ្សារទំនើប អេអ៊ន (Aeon) លំដាប់ពិភពលោកបានផុសឡើងនៅក្នុងរាជធានី ហើយហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ធំៗក៏បានស្ថាបនាឡើងដូចជា៖

- ស្ពានអ្នកលឿងឆ្លងកាត់ទន្លេមេគង្គក្រោមដែលមានប្រវែងវែងជាងគេនៅកម្ពុជា (សម្ពោធថ្ងៃទី៦ មេសា ឆ្នាំ ២០១៥)
- ស្ពានជ្រោយចង្វារខ្សែទី២ឆ្លងកាត់ទន្លេសាប (បានដាក់ឲ្យធ្វើចរាចរណ៍ដំបូងនាថ្ងៃទី២១កញ្ញា ឆ្នាំ ២០១៥
- ស្ពានព្រែកផ្ទៅឆ្លងកាត់ទន្លេសាប (សាងសង់ដោយក្រុមហ៊ុនឯកជន សម្ពោធនៅថ្ងៃទី២០ កញ្ញា ឆ្នាំ ២០១០)
- ស្ពានព្រែកក្តាមឆ្លងកាត់ទន្លេសាប (សម្ពោធថ្ងៃទី១០ មេសា ឆ្នាំ ២០១០)



www.elibraryofcambodia.org

- ស្ពានព្រះមុនីវង្សខ្សែទី២ឆ្លងកាត់ទន្លេបាសាក់ (បានដាក់ឲ្យធ្វើចរាចរណ៍ដំបូងនាថ្ងៃទី២៧ ឧសភាឆ្នាំ ២០០៩)
- ស្ពានអាកាសស្ទឹងមានជ័យ (សម្ពោធថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៤)
- ស្ពានអាកាសក្បាលថ្នល់ (សម្ពោធថ្ងៃទី២៤ ឧសភាឆ្នាំ ២០១៣) និងស្ពានអាកាសតិចណូ ព្រមទាំងស្ពានអាកាសមួយចំនួនទៀតនៅក្នុងរាជធានីភ្នំពេញ និងស្ពានជាច្រើនខ្សែទៀតដែលរាជរដ្ឋាភិបាលកំពុងមានគម្រោងសាងសង់ឆ្លងកាត់ទន្លេ។

ទន្ទឹមនឹងនោះ នៅក្នុងរជ្ជកាលរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី រាជរដ្ឋាភិបាលបានខិតខំរហូតទទួលបានជោគជ័យ ដោយប្រាសាទព្រះវិហារខ្មែរ ដែលមានរឿងចម្រូងចម្រាសជាមួយប្រទេសថៃត្រូវបានអង្គការ UNESCO ដាក់បញ្ចូលក្នុងបេតិកភ័ណពិភពលោក។ ជាងនេះទៅទៀត នៅក្នុងអំឡុងពេលនៃពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរនាថ្ងៃទី១៤-១៦ មេសា ឆ្នាំ២០១៥ នៅឯខេត្តសៀមរាប កម្ពុជាទទួលបានកំណត់ត្រាពិភពលោកផ្លូវៗពីស្ថាប័ន The Guinness World Records ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជាកន្លងមក ដោយក្នុងនោះរួមមាននំអន្សមយក្សទម្ងន់៤,៤០តោន ដែលធំជាងគេក្នុងពិភពលោក និងការរាំចង្វាក់ ម៉ាឌីហ្សុន ដែលមានអ្នកចូលរួមដល់ទៅ ២.០១៥នាក់ ពោលគឺមានចំនួនអ្នករាំច្រើនជាងគេនិងរាំត្រូវគ្នាមិនធ្លាប់មានពីមុនមកនៅក្នុងពិភពលោក។ កំណត់ត្រាពិភពលោកទាំងពីរនេះគឺបានទទួលនៅក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៥ ដែលរៀបចំឡើងដោយសហភាពសហព័ន្ធយុវជនកម្ពុជាដឹកនាំដោយ លោក ហ៊ុន



www.elibraryofcambodia.org

ម៉ានី កូនប្រុសពៅរបស់សម្តេចតេជោ ហ៊ុន សែន ហើយពេលនោះ លោក ហ៊ុន ម៉ានី ក៏ជាអ្នកតំណាងរាស្ត្រដែរ។ អ្វីដែលជាមោទនភាពជាតិជាងនេះទៅទៀតនោះគឺព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៥ ដែលបានធ្វើឡើង ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ក្រោមប្រធានបទ "ការចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ" ត្រូវបានចូលរួមពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ព្រមទាំងឯកឧត្តម សម រង្ស៊ី ប្រធានតំណាងសមាជិកភាគតិចនៅរដ្ឋសភា [ប្រធានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា] និងលោកជំទាវ ជូឡុង ស៊ូមូរ៉ា ជាភរិយា។ ការចូលរួមពីថ្នាក់ដឹកនាំកំពូលនៃគណបក្សនយោបាយទាំងពីរ ដែលមានអសនៈនៅរដ្ឋសភានេះបានបង្ហាញថា ប្រទេសកម្ពុជាកំពុងមានសុខសន្តិភាពពេញលេញ មានសាមគ្គីភាពល្អក្នុងមហាគ្រួសារខ្មែរ ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ក្រោមម្លប់ដ៏ត្រជាក់នៃរាជបល្ល័ង្ករបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី។

## គ្រឿងឥស្សរិយយស[238]

- ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេរីវឌ្ឍន៍
- ឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍

---

[238] *http://norodomsihamoni.org/kh/biography*



www.elibraryofcambodia.org

- មន្ត្រីធំនៃកងពលកិត្តិយស (Grand Officier De La Legion D' honneur) នៃសាធារណរដ្ឋបារាំង
- មេដាយប្រាក់នៃក្រុងប៉ារីស (Medaille D'argent De La Ville De Paris) សាធារណរដ្ឋបារាំង

ព្រះមហាក្សត្រ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី គឺជាក្សត្ររក្សាសីលបានយ៉ាងខ្ជាប់ខ្ជួន និងព្រះសណ្តាប់នូវធម្មទេសនាដែលសម្តែងដោយព្រះសង្ឃនៅក្នុងព្រះបរមរាជវាំងយ៉ាងទៀងទាត់នៅរាល់ថ្ងៃឧបោសថផងដែរ។

ចំណុចមួយដែលគួរឲ្យកត់សំគាល់ដែរនោះ គឺលោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ដែលមានមូលដ្ឋានក្នុងប្រទេសបារាំងបានចោទថា រាជរដ្ឋាភិបាលកម្ពុជានៅក្នុងរជ្ជកាលរបស់ព្រះអង្គបានធ្វើឲ្យបាត់បង់កោះត្រល់ជាផ្លូវការ ទៅប្រទេសវៀតណាម។ លោក ប៉េងសែ ដែលជាអ្នករិះគន់មិនសំចៃដល់រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន ពីបញ្ហាព្រំដែននោះ បានប្រកាសថា "បញ្ហាកោះត្រល់នៅតែជាបញ្ហាដែលមិនទាន់ចប់សព្វគ្រប់នោះទេ សូម្បីអតីតព្រះមហាក្សត្រ ព្រះបាទ នរោត្តម សុរាម្រិត និងលោកទេសាភិបាលបារាំង ប្រេវីយេ (Previer) ក៏មិនដែលកាត់សេចក្តីថា កោះខ្មែរដ៏មានតម្លៃមិនអាចកាត់ថ្លៃបានមួយនេះ ជាកម្មសិទ្ធិដាច់មុខរបស់ប្រទេសវៀតណាមនោះដែរ"[239]។ ជាការឆ្លើយតប រាជរដ្ឋាភិបាលរបស់សម្តេចតេ

---

[239] *វិទ្យុអាស៊ីសេរី* *http://www.rfa.org/khmer/indepth/experts_say_kohtral_issue_cannot_be_ended-12092012234436.html*



www.elibraryofcambodia.org

ដោ ហ៊ុន សែន ដែលស្ថិតនៅក្នុងរជ្ជកាលរបស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី តែងតែអះអាងថា អាជ្ញាធរបារាំងបានកាត់កោះនោះទៅឲ្យវៀតណាម ហើយបញ្ហានេះបានចប់សព្វគ្រប់រួចទៅហើយ។ នៅថ្ងៃទី៩ សីហា ឆ្នាំ២០១២ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានប្រកាសនៅក្នុងរដ្ឋសភាថា មូលហេតុដែលនាំឲ្យកោះត្រល់លែងជាកម្មសិទ្ធិរបស់ខ្មែរនោះ គឺដោយសារតែឯកសារព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ដាក់តម្កល់នៅក្នុងអង្គការសហប្រជាជាតិនៅឆ្នាំ១៩៦៤ បានទទួលស្គាល់ខ្សែបន្ទាត់ ប្រេវីយេ ដែលបានកាត់កោះត្រល់ទៅឱ្យប្រទេសវៀតណាម។ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "ខ្មែរបានបាត់កោះត្រល់របស់ខ្លួននៅឆ្នាំ១៩៣៩ ក្រោយពីអគ្គទេសាភិបាលឥណ្ឌូចិនរបស់បារាំង លោក ប្រេវីយេ បានដាក់កោះត្រល់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងក្នុងដែនដីកម្ពុជាក្រោម ឬ កូសាំងស៊ីន ហើយឆ្នាំ១៩៤៩ បារាំងបានប្រគល់ដែនដីកូសាំងស៊ីនដែលជាទឹកដីកម្ពុជាក្រោម ទៅឲ្យព្រះចៅបៅដាយនៃប្រទេសវៀតណាម"។ រឿងបញ្ហាទឹកដីនិងព្រំដែនខ្មែរជាមួយប្រទេសជិតខាងគឺជាបញ្ហាស្មុគស្មាញ ហើយខ្ញុំអ្នកចងក្រងសៀវភៅមិនធ្វើអត្ថាធិប្បាយទេ គឺទុកឱកាសឲ្យអ្នកជំនាញដោះស្រាយ ឯការវិភាគបែបណានោះ វាអាស្រ័យលើពលរដ្ឋម្នាក់ៗ។

សំណួរចុងក្រោយសួរថា ប្រសិនបើព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដាក់រាជ្យ ឬមានបញ្ហាណាមួយដោយចៃដន្យ តើសមាជិករាជវង្សានុវង្សអង្គណាក្នុងចំណោមរាប់ពាន់អង្គដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រសៃ អង្គឌួង នរោត្តម និង ស៊ីសុវត្ថិ អាចជារាជទាយាទបន្ទាប់នៃរាជបល្ល័ង្កខ្មែរ?



www.elibraryofcambodia.org



ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ស្តេចយាងត្រួតពលក្នុងអំឡុងពេលយាងទៅវិមានឯករាជ្យនាថ្ងៃរំលឹកខួបឯករាជ្យជាតិ ៩ វិច្ឆិកា ២០១៤ (រូប ខឹម សុវណ្ណារ៉ា)។



www.elibraryofcambodia.org

# ឯកសារពិគ្រោះ និងទីកន្លែង

**ទីកន្លែង**

១. ខេត្តសមុទ្រប្រាកាន ខេត្តប្រាជីនបុរី និងរាជធានីបាងកក ប្រទេសថៃ
២. រាជធានីបាងកក ប្រទេសថៃ
៣. ទីក្រុងហូជីមិញ ប្រទេសវៀតណាម (អតីតក្រុងព្រៃនគរក្នុងដែនដីកម្ពុជាក្រោម)
៤. ទីក្រុងស៊ីដាហ្គូន ប្រទេសភូមា
៥. ប្រទេសសិង្ហបុរី
៦. ព្រះបរមរាជវាំង
៧. សារមន្ទីរជាតិ
៨. កំពូលភ្នំឧដុង្គក្នុងខេត្តកណ្តាល
៩. ស្រុកសាមគ្គីមានជ័យ និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
១០. ស្រុកកំពង់ត្រាច និងកំពូលភ្នំបូកគោខេត្តកំពត
១១. ប្រាសាទព្រះវិហារ
១២. រាជដំណាក់ខេត្តសៀមរាប
១៣. រាជដំណាក់ក្នុងសាលាខេត្តបាត់ដំបង
១៤. ទីកប់សុក ព្រះបាទនរោត្តម ក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ
១៥. ការិយាល័យអង្គការយូនីស្កូប្រចាំកម្ពុជា
១៦. មជ្ឈមណ្ឌលឯកសារកម្ពុជា
១៧. បណ្ណាល័យជាតិ
១៨. បណ្ណសារដ្ឋានជាតិកម្ពុជា
១៩. បណ្ណាល័យព្រឹទ្ធសភា
២០. បណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា
២១. បណ្ណាល័យ DMC នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
២២. ការិយាល័យក្លឹបអ្នកកាសែតកម្ពុជា
២៣. ទីស្នាក់ការមូលនិធិ Kondrad Adenauer Stiftung នៃប្រទេសអាល្លឺម៉ង់ ប្រចាំរាជធានីភ្នំពេញ
២៤. ក្រសួងព័ត៌មាន។



www.elibraryofcambodia.org

សៀវភៅ


១. "នាយករដ្ឋមន្ត្រីខ្មែរទាំង៣៦រូបជានរណា?"

២. "ហ៊ុន សែន នយោបាយនិងអំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ឆ្នាំ?"

៣. ព្រឹត្តិបត្រ CAMBODGE – THEATERS – CINEMA AUTEMPS DU SANGKUM REASTR NIYUM របស់សម្តេចឪ

៤. ព្រឹត្តិបត្រ "អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា - សង្គមរាស្ត្រនិយម" លេខ៣ លេខ ៤ លេខ៥ និងលេខ ៧

៥. ព្រឹត្តិបត្រ CAMBODGE LA CINEMA TOGRAPHIE DE NORODOM SIHANOUK ( ANNEES 1965-1969 et ANNEES 1988-1991 )

៦. ព្រឹត្តិបត្ររបស់សង្គមរាស្ត្រនិយម "ព្រះរាជពិធីសម្ពោធមណ្ឌលដែលសង់ថ្វាយព្រះបរមរូបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមក្នុងព្រះសុវណ្ណកោដ្ឋ (៨-១១ វិច្ឆិកា ១៩៥៥)

៧. "រាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍នៃកម្ពុជា" របស់សម្តេចឪ

៨. "អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់" ព្រះរាជនិពន្ធដោយ សម្តេចឪ

៩. ឯកសារ "របាំព្រះរាជទ្រព្យ" បោះពុម្ពដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រួមជាមួយការិយាល័យអង្គការ UNESCO ប្រចាំកម្ពុជា (ឆ្នាំ២០០៣)

១០. ព្រឹត្តិបត្រៈ ព្រះរាជពិធីសម្ពោធមណ្ឌលដែលសង់ថ្វាយព្រះបរមរូបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមក្នុងព្រះសុវណ្ណកោដ្ឋ

១១. ពង្សាវតារនៃប្រទេសកម្ពុជា" របស់ក្រសួងសិក្សាធិការឆ្នាំ១៩៥២ រោងពុម្ពព្រះរមរាជវាំង

១២. សារ៉ាម៉ានី (អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ)

១៣. My War with the CIA ព្រះរាជនិពន្ធដោយព្រះបាទ នរោត្តម សីហនុ

១៤. The Royal Palace of Phnom Penh and Cambodian Royal Life

១៥. LE PALAIS DU ROI DU CAMBODGE

១៦. Preah Khan Reach and The Genealogy of Khmer Kings

១៧. Phnom Penh Then and Now ដោយ Michel Igout ( With a Forward by Prince Norodm Sihanouk )




www.elibraryofcambodia.org

១៨. Worrior Prince - Norodom Ranariddh, Son of King Sihanouk of Cambodia
១៩. "ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀមចាប់ពីទសវត្ស ១៦" របស់អ្នកនិពន្ធ សូរ អឿ
២០. "ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា" របស់អ្នកនិពន្ធ ហ្វ្រង់ស្វ័រ ប៉ុងសូដ
២១. "ប្រវត្តិសាស្ត្រខ្មែរ - ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ មុនីវង្ស" របស់អ្នកនិពន្ធ អ្នកស្រី ត្រឹង ងា
២២. "មហាបុរសខ្មែរ - ព្រះរាជពង្សាវតាខ្មែរ" របស់អ្នកនិពន្ធ អេង ហួត
២៣. ប្រវត្តិសាស្ត្រអំពីស្ថាប័ននយោបាយ - រដ្ឋបាលប្រទេសកម្ពុជានិងបុព្វហេតុសង្គ្រាម រៀបរៀងដោយ យិន គឹមវាណ
២៤. ភូមិគិរិដ្ឋាន របស់ក្រសួងអប់រំ យុវជននិងកីឡាឆ្នាំ ២០០៣
២៥. ប្រវត្តិវិទ្យាកម្ពុជាថ្នាក់ទី៩ របស់រដ្ឋកម្ពុជា ឆ្នាំ១៩៨៩
២៦. ប្រវត្តិវិទ្យាថ្នាក់ទី១១ ឆ្នាំ ២០១១
២៧. "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់កម្មវិធីសិក្សាថ្នាក់មូលដ្ឋានឆ្នាំ ២០១២
២៨. "សំនួរនិងចម្លើយ - ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" សម្រាប់ថ្នាក់ឆ្នាំ មូលដ្ឋាន - ការប្រឡងផ្សេងៗជាពិសេសថ្នាក់ទុតិយភូមិ
២៩. ប្រវត្តិសាស្ត្រថៃនិពន្ធដោយលោក David K. Wyatt ប្រែជាភាសាខ្មែរដោយគ្រិស្ថានបោះពុម្ពផ្សាយនគរវត្ត (ទំព័រ១៦១)
៣០. កម្ពុជាក្នុងសង្គ្រាមវៀតណាម ដោយអ្នកនិពន្ធ ឥន សុផល
៣១. WHO'S WHO: The Most Influential People in Cambodia
៣២. Sideshow
៣៣. Shadow Over Angkor
៣៤. The Tragedy of Cambodia History
៣៥. ប្រវត្តិសាស្ត្រកម្ពុជានិងវរជនខ្មែរ
៣៦. ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
៣៧. ខ្មែរលើគម្ពីស្វែងរកព្រះបាទជ័យវរ្ម័នទី២ ដោយ ជៀប គឹមហ៊ាង
៣៨. ឯកសាររបស់ស្ថានទូតអាមេរិក
៣៩. ធម្មនុញ្ញជីវិត (បោះពុម្ពឆ្នាំ២០១០)
៤០. ប្រវត្តិពុទ្ធិកសិក្សា (បោះពុម្ពឆ្នាំ២០០៦)



www.elibraryofcambodia.org

៤១. ឯកសារក្រសួងទេសចរណ៍

៤៣. សៀវភៅ៖ សារៈសំខាន់នៃក្បាច់លម្អរបស់ឧបករណ៍និងសំភារៈប្រើប្រាស់ក្នុងជីវភាពខ្មែរ

៤៤. សៀវភៅ៖ FINALE – The Cremation of Norodom and Norodom Sihanouk, Kings of Cambodia ( ឆ្នាំ២០១២-២០១៣ )by Jim Mizerski https://books.google.com.kh/books?id=9fdOAQAAQBAJ&pg=PA181&lpg= PA181&dq=Where+did+king+norodom+died+in+1904?&source=bl&ots=N_gig1avYx&sig=i8fRGn4XOoXj99r6oAw0StIARR4&hl=en&sa=X&ei=EVDIVLCeJoO68gXr1YGgCA&ved=0CBsQ6AEwADgK#v=onepage&q=Where%20did%20king%20norodom%20died%20in%201904%3F&f=false


## សារព័ត៌មាន


១. The Cambodia Daily

២. ភ្នាក់ងារសារព័ត៌មានកម្ពុជា SPK/AKP

៣. ភ្នាក់ងារសារព័ត៌មានអង់គ្លេស Reuters

៤. ភ្នាក់ងារសារព័ត៌មានបារាំង AFP

៥. ទីភ្នាក់ងារសារព័ត៌មានអាម៉េរិក AP

៦. កាសែតថៃជាភាសាអង់គ្លេស Bangkok Post

៧. កាសែតអាម៉េរិក The New York Times

៨. វិទ្យុសំឡេងសហរដ្ឋអាម៉េរិក VOA

៩. The  SEA Weekly


## គេហទំព័រ


1. គេហទំព័រ បណ្ណសារដ្ឋានជាតិកម្ពុជា៖ http://www.nac.gov.kh/english/index.php?option=com_content&view=frontpage&Itemid=1
2. http://www.norodomsihamoni.org/
3. http://norodomsihanouk.info/
4. Royal Ark ស្តីពីពង្សាវតានៃព្រះចៅក្រុងកម្ពុជាគេហទំព័រ
5. CEN: "http://www.cen.com.kh/local/ជុំវិញ%E2%80%8B ព្រះនាម%E2%80% 8B នៃ%E2%80%8Bព្រះបាទ-"-នរោត្តម%E2% 80%8B"—03524824
6. http://sokheounpang.wordpress.com/2010/07/23/khmer-siam-royal-family-tree/
7. http://freepages.genealogy.rootsweb.ancestry.com/~royalty/cambodia/i205.html




www.elibraryofcambodia.org

8. http://freepages.genealogy.rootsweb.ancestry.com/~royalty/files/pix_cambodia.html
9. http://angkor1431.tripod.com/index/id14.html
10. http://www.topix.com/forum/world/cambodia/T5JM169K6PJ5611N2
http://km.wikipedia.org/wiki/ស៊ីសុវត្ថិ
11. http://en.wikipedia.org/wiki/Si_Votha
12. http://www.highlightthailand.com/main/detail_content/Miniature-Replica-of-Angkor-Wat-in-Wat-Phra-Kaew/226.html
13. http://www.britannica.com/EBchecked/topic/542490/Si-Votha
14. http://nsd.007.free.fr/A/Arch_histo/Regions/Asie/Cambodge/Si_Votha.htm
15. http://webcache.googleusercontent.com/search?q=cache:wuXaDzDkvsUJ:khmerization.blogspot.com/2008/01/biography-of-prince-si-votha-1841-1891.html+&cd=2&hl=en&ct=clnk&gl=kh
16. http://km.wikipedia.org/wiki/ស៊ីសុវត្ថិ_មុនីវង្ស
17. KHMER GEO: http://www.khmer-geo.com/phnompenh/attraction/royal-palace
18. http://www.skyscrapercity.com/showthread.php?t=1166805&page=3
19. http://www.corbisimages.com/stock-photo/rights-managed/U142662P-A/king-sisowath-with-colleagues
20. http://tamabloveyaymab.files.wordpress.com/2011/05/kingsisowath.jpg
21. http://tamabloveyaymab.wordpress.com/2011/05/16/a-legacy-of-a-king/
22. http://khmerbloodkb.blogspot.com/2012/04/blog-post_17.html
23. http://whoincam.wordpress.com/2009/07/16/sisowath-kosamak/
24. http://whoincam.wordpress.com/2009/07/09/norodom-suramarit/
25. http://members.iinet.net.au/~royalty/states/asia/cambodia6.html
26. DAP ផ្សាយនៅគេហទំព័រ http://www.khmerload.com/news/6792
27. http://www.khmer-note.com/archives/31569
28. https://www.youtube.com/watch?v=yaHVVyj6xjk
29. http://webcache.googleusercontent.com/search?q=cache:hlomngQxARAJ:en.wikipedia.org/%20wiki/Norodom_Sihanouk+&cd=1&hl=en&ct=clnk&gl=kh
30. *សមាគមខ្មែរកម្ពុជាក្រោម៖ http://www.khmerkrom.org/news-events/human-rights-monitor/146-27mr-chhean-vam-s-testimony-cochin-china-affair និង សៀវភៅប្រវត្តិសាស្ត្រកម្ពុជានិងអាជនខ្មែរ*



www.elibraryofcambodia.org

31. *http://royalista.com/6623/congratulations-to-cambodias-ballet-dancing-king/*

32. ឯកសារសន្ធិសញ្ញាបារាំងសៀម ២៣ មីនា ១៩០៧៖ *http://webcache.googleusercontent.com/search?q=cache:Of6fMuC5Z3UJ:campropost.org/wp-content/uploads/2011/05/Treaty-of-March-23-1907-Between-France-and-Siam-and-the-Return-of-Battambang-and-Angkor-to-Cambodia-Ed.pdf+&cd=1&hl=en&ct=clnk&gl=kh*

33. *http://www.skyscrapercity.com/showthread.php?t=1491230&page=59*

34. *http://www.thecambodiaherald.com/cambodia/cambodia-braces-for-biggest-royal-funeral-in-half-a-century-2491*

35. *http://www.corbisimages.com/stock-photo/rights-managed/SF38129/king-norodom-suramarit-and-queen-sisowath-kossouan*

36. *http://upload.wikimedia.org/wikipedia/commons/d/d3/Dancers_angkor_wat.jpg*

37. *http://ven.vn/en-us/the-beauty-of-vietnamese-queens_t221c498n18150.aspx*

38. *http://saigoneer.com/saigon-buildings/2607-old-saigon-building-of-the-week-the-former-lycee-chasseloup-laubat*

39. http://www.elibraryofcambodia.org/khmer-leuk-kumpi-sveng-rok-preahbat-jey-voraman-ti-7/

40. http://www.gutenberg.org/files/27404/27404-h/27404-h.htm

41. ឯកសារជាភាសាវៀតណាម៖ *http://hanlecung.wordpress.com/2013/07/03/nhung-cong-chua-co-cong-voi-dai-viet/*

42. https://goingphnomandon.wordpress.com/tag/lee-kuan-yew/

43. http://phoumirak.blogspot.sg/2008/12/lee-kuan-yews-quote-about-cambodia-in.html

## ស៊ុមរូបថតពណ៌មាសនៅទំព័រមុខ (Golden Photo Frames at the front page)

- *The Golden Round Frames for the Kings at the front page are credited to: http://www.dreamstime.com/royalty-free-stock-images-golden-round-frame-image8586439*
- *The Golden Frame for King Norodom Sihamoni at the front page is credited to: http://imgkid.com/antique-ornate-gold-frame.shtml*



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ទៅ យុនសំរ៉ង ខ្ទៅ យ៉ាតណៃ ខ្ទៅសុខផល ខ្ទៅ វិសាល ខ្ទៅ វ៉ាមុន
ខ្ទៅ ភាភដា ខ្ទៅ ចំរើន ខ្ទៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ទៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ ប៉ៅ ភារម្យ

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org